Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# គម្រោងតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិប្រកបដោយនិរន្តរភាព (SLEPC) នៅកម្ពុជា

## ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF)

---

រៀបរៀងឡើងដោយ ៖ ក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទ
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៩

# មាតិកា

ពាក្យកាត់ ..... 4
១.សេចក្តីផ្តើម ..... 5
២.គោលបំណង និងសមាសភាគគម្រោង ..... 5
៣.ក្របខណ្ឌច្បាប់ជាតិ និងគោលនយោបាយធានាសុវត្ថិភាពរបស់ធនាគារពិភពលោក ..... 20
៣.១ ច្បាប់ជាតិ និងលិខិតុបករណ៍ច្បាប់ ..... 20
៣.១.១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ..... 21
៣.១.២ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ..... 22
៣.១.៣ ច្បាប់ស្តីពីព្រៃឈើ (២០០២) ..... 22
៣.១.៤ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ (១៩៩៦) ..... 26
៣.១.៥ ច្បាប់ស្តីពីផ្លូវថ្នល់ (២០០៦) ..... 28
៣.១.៦ អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន (១៩៩១) ..... 32
៣.១.៦ អនុក្រឹត្យពាក់ព័ន្ធផ្សេងទៀត ..... 35
៣.២ គោលនយោបាយធានាសុវត្ថិភាពរបស់ធនាគារពិភពលោក ..... 36
៣.៣ ចំណុចខុសគ្នារវាងបទប្បញ្ញត្តិជាតិស្តីពី EIA និងគោលនយោបាយធានាសុវត្ថិភាពរបស់ធនាគារពិភពលោក 40
៤.ផលប៉ះពាល់ដែលអាចកើតមានឡើង និងការកាត់បន្ថយ ..... 45
៤.១ ផលប៉ះពាល់ដែលអាចកើតឡើងដោយសារសមាសភាគគម្រោង ..... 45
**សមាសភាគទី ១ ៖ ពង្រឹងសមត្ថភាពសម្រាប់ការរៀបចំផែនការតំបន់ទេសភាព និងគ្រប់គ្រងតំបន់ការពារ** ..... 46
**សមាសភាគទី ២ ៖ ពង្រឹងឱកាសសម្រាប់ទេសចរណ៍ធម្មជាតិ និងសង្វាក់តម្លៃអនុផលព្រៃឈើ** ..... 47
**សមាសភាគ ៣ ៖ ការតភ្ជាប់បណ្តាញ និងហេដ្ឋារចនាសម្ព័ន្ធជនបទពាក់ព័ន្ធក្នុងតំបន់មួយចំនួន** ..... 47
៤.២ ផលប៉ះពាល់វិជ្ជមាន ..... 48
៤.២.១ ផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន ..... 49
៤.២.២ ផលប៉ះពាល់ផ្នែកសង្គមដែលអាចកើតឡើង ..... 57
៥. នីតិវិធីសម្រាប់ពិនិត្យបឋម ត្រួតពិនិត្យ និងផ្តល់ការអនុញ្ញាត ..... 58
**៥.១ ការពិនិត្យបឋម និងគំនូសតាងបង្ហាញពីលំហូរ** ..... 59

៥.១.១ លក្ខខណ្ឌទូទៅនៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសង្គម.....61
៥.១.២ ការកំណត់ និងឆ្លើយតបចំពោះបញ្ហានានា.....61
៥.១.៣ ការកំណត់ពីសារៈសំខាន់នៃផលប៉ះពាល់.....62
៥.២ ការកំណត់វិសាលភាព.....62
៥.២.១ វិសាលភាព.....62
៥.២.២ ការពិចារណាអំពីវិសាលភាព.....62
៥.៣ លក្ខខណ្ឌប្រតិបត្តិ.....63
៥.៤ ការវាយតម្លៃលើហេតុប៉ះពាល់បរិស្ថានសង្គម.....63
៥.៥ ផលប៉ះពាល់ និងវិធានការកាត់បន្ថយ.....64
៥.៦ ផែនការគ្រប់គ្រងបរិស្ថាន (EMP).....64
៥.៧ កិច្ចពិគ្រោះយោបល់ជាមួយនឹងសាធារណជន.....66
៥.៨ សេចក្តីសម្រេចចិត្ត.....67
៥.៩ ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈពីគម្រោង ដែលបានទទួលការអនុម័ត.....67
៥.១០ ការពិនិត្យតាមដានគម្រោង.....67
៦. ការរៀបចំការអនុវត្ត.....68
៦.១ ការទទួលខុសត្រូវលើការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម.....68
៦.២ ការរៀបចំរបាយការណ៍.....73
៧. ការកសាងសមត្ថភាព និងការបណ្តុះបណ្តាល.....73
៧.១ ការវាយតម្លៃសមត្ថភាពស្ថាប័ន.....75
៧.២ ការបណ្តុះបណ្តាល.....75
៨. ថវិកាសម្រាប់អនុវត្ត ESMF.....76
៩. យន្តការដោះស្រាយសារទុក្ខ (GRM).....77
៩.១. យន្តការដោះស្រាយជម្លោះ.....77
៩.១.១ យន្តការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ.....77
៩.១.១ យន្តការតុលាការ.....79

១០. ការពិគ្រោះយោបល់ និងការផ្សព្វផ្សាយក្របខ័ណ្ឌគ្រប់គ្រងផ្នែកបរិស្ថាន និងសង្គម .......... 79
១០.១ ការពិគ្រោះយោបល់សាធារណៈ .......... 79
១០.២ ការផ្សព្វផ្សាយក្របខ័ណ្ឌគ្រប់គ្រងផ្នែកបរិស្ថាន និងសង្គម (ESMF) .......... 80
ឯកសារយោង .......... 80
បញ្ជីឧបសម្ព័ន្ធ .......... 81
ឧបសម្ព័ន្ធ ១៖ តារាងត្រួតពិនិត្យការពិនិត្យបឋមផ្នែកសង្គម និងបរិស្ថាន សម្រាប់អនុគម្រោង .......... 81
លក្ខណៈវិនិច្ឆ័យសម្រាប់ពិនិត្យបឋមគម្រោងក្នុងប្រភេទ A .......... 83
**តារាងទី ១. លក្ខណៈវិនិច្ឆ័យសម្រាប់ពិនិត្យបឋមគម្រោងក្នុងប្រភេទ A** .......... 83
លក្ខណៈវិនិច្ឆ័យសម្រាប់ពិនិត្យបឋមគម្រោងក្នុងប្រភេទ C .......... 88
លក្ខណៈវិនិច្ឆ័យសម្រាប់ពិនិត្យបឋមគម្រោងក្នុងប្រភេទ B .......... 89
តារាងត្រួតពិនិត្យផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម .......... 90
ឧបសម្ព័ន្ធ ២៖ ក្រមប្រតិបត្តិបរិស្ថាន (ECOPs) ឬ កិច្ចព្រមព្រៀងការពារបរិស្ថាន .......... 95
ឧបសម្ព័ន្ធ ៣៖ គោលការណ៍ណែនាំផែនការគ្រប់គ្រងបរិស្ថាន សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធទេសភាព និងទេសចរណ៍ .......... 103
ឧបសម្ព័ន្ធ ៤៖ សង្ខេបនៃផលប៉ះពាល់ផ្នែកបរិស្ថាន និងវិធានការកាត់បន្ថយផលប៉ះពាល់ .......... 107
ឧបសម្ព័ន្ធ ៥៖ គំរូក្របខ័ណ្ឌទំនួលខុសត្រូវនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន .......... 109
ឧបសម្ព័ន្ធ ៦៖ បញ្ជីអ្នកពាក់ព័ន្ធក្នុងការពិគ្រោះយោបល់ក្នុង ESMF .......... 131
ឧបសម្ព័ន្ធ ៧. បញ្ជីគម្រោងអវិជ្ជមាន .......... 135

# ពាក្យកាត់

| | |
|---|---|
| CCM-TS | តំបន់ជួរភ្នំក្រវាញកណ្តាល និងទន្លេសាប |
| CMTS | ភ្នំក្រវាញ និងទន្លេសាប |
| CPA | តំបន់ការពារសហគមន៍ |
| CSLEP | គម្រោងតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិប្រកបដោយនិរន្តរភាពនៅកម្ពុជា |
| EA | ទីភ្នាក់ងារអនុវត្តន៍គម្រោង |
| ECOP | ក្រមប្រតិបត្តិបរិស្ថាន |
| EIA | ការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន |
| EMP | ផែនការគ្រប់គ្រងបរិស្ថាន |
| ESMF | ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម |
| IA | ទីភ្នាក់ងារអនុវត្តន៍ |
| IEIA | ការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានបឋម |
| GRM | យន្តការដោះស្រាយបណ្តឹងសាទុក្ខ |
| MoE | ក្រសួងបរិស្ថាន |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| NPASMP | ផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ |
| NTFP | អនុផលព្រៃឈើ |
| POM | សៀវភៅណែនាំប្រតិបត្តិគម្រោង |
| PSC | គណៈកម្មាធិការដឹកនាំគម្រោង |
| SLMP | ផែនការគ្រប់គ្រងតំបន់ទេសភាពប្រកបដោយនិរន្តរភាព |
| SME | សហគ្រាសខ្នាតតូច និងមធ្យម |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RPF | ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ |
| WB | ធនាគារពិភពលោក |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |

## ១.សេចក្តីផ្តើម

នេះជាឯកសារក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) សម្រាប់គម្រោងតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិប្រកបដោយនិរន្តរភាពដែលត្រូវបានស្នើឡើង និងរៀបរៀងឡើងដោយក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីស្នើសុំហិរញ្ញប្បទានពីធនាគារពិភពលោក។

ក្របខណ្ឌនេះមានគោលបំណងធានាថា ការត្រួតពិនិត្យសកម្មភាព CSLEP សម្រាប់ផលប៉ះពាល់អវិជ្ជមានផ្នែកបរិស្ថាន និងសង្គម និងវិធានការកាត់បន្ថយ ត្រូវបានពិចារណាក្នុងការរៀបចំ និងការអនុវត្ត។ អាចនិយាយបានថា ឯកសារនេះធានាមិនឲ្យការវិនិយោគរបស់ CSLEP បង្កើតជា និងបង្កឲ្យមានផលប៉ះពាល់អវិជ្ជមានខ្លាំងលើរបបចិញ្ចឹមជីវិតមូលដ្ឋាន និងបរិស្ថាន និងមានការកំណត់រក បញ្ចៀស ឬយ៉ាងហោចណាស់ កាត់បន្ថយផលប៉ះពាល់ដែលអាចកើតមានឡើង។ អ្វីដែលសំខាន់នោះគឺ ឯកសារនេះរៀបរាប់ពីដំណើរការត្រួតពិនិត្យ និងគោលការណ៍ណែនាំស្តីពីបរិស្ថាន និងសង្គមក្នុងគោលដៅ៖

១. ទប់ស្កាត់ និង/ឬកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតចេញពីសកម្មភាពដែលស្នើឡើងទាំងនេះ

២. ការធានានូវនិរន្តរភាពបរិស្ថានយូរអង្វែងដែលផ្តល់អត្ថប្រយោជន៍ចេញពីសកម្មភាព ដែលស្នើឡើងតាមរយៈការធានាសុវត្ថិភាពធនធានធម្មជាតិដែលពួកគេអាស្រ័យផល និង

៣. ការសម្របសម្រួលប្រកបដោយការផ្តួចផ្តើមជាមុន នូវសកម្មភាពបង្កើនប្រសិទ្ធផលលើការប្រើប្រាស់ និងការគ្រប់គ្រងកាន់តែប្រសើរលើធនធានធម្មជាតិ ដែលធ្វើឲ្យមានការរក្សាស្ថិរភាព និង/ឬការបង្កើនគុណភាពបរិស្ថាន និងសុខុមាលភាពប្រជាជនក្នុងមូលដ្ឋាន។

## ២.គោលបំណង និងសមាសភាគគម្រោង

### គោលបំណងអភិវឌ្ឍន៍ដែលស្នើឡើង

គោលបំណងអភិវឌ្ឍន៍របស់គម្រោងគឺការបង្កើនការគ្រប់គ្រងតំបន់ការពារ និងលើកកម្ពស់ឱកាសទេស ចរណ៍ធម្មជាតិ និងសង្វាក់តម្លៃអនុផលព្រៃឈើក្នុងតំបន់ទេសភាពជួរភ្នំក្រវាញ និងទន្លេសាប។

#### លទ្ធផលសំខាន់ៗ

១. ទំហំតំបន់ការពារស្ថិតក្រោមការគ្រប់គ្រងកាន់តែប្រសើរ (ហិចតា)

២. ចំនួនភ្ញៀវទេសចរណ៍នៅទីតាំងទេសចរណ៍ធម្មជាតិក្នុងសហគមន៍មួយចំនួន

៣. ភាគរយក្រុមសហគមន៍ដែលមានកំណើន ១% ឡើងទៅ ធៀបនឹងសន្ទស្សន៍តម្លៃបន្ថែមធនធានធម្មជាតិ

៤. ភាគរយសហគ្រិនជាស្ត្រីក្នុងសហគមន៍គោលដៅ ដែលមានលទ្ធភាពទទួលបានសេវាអភិវឌ្ឍន៍អាជីវកម្ម និង

៥. ភាគរយសហគមន៍គោលដៅដែលពេញចិត្តនឹងអត្ថប្រយោជន៍របស់គម្រោង។

## ការពណ៌នាគម្រោង

### សមាសភាគទី ១ ៖ ពង្រឹងសមត្ថភាពរៀបចំផែនការ និងគ្រប់គ្រងទេសភាពតំបន់ការពារ (ចំណាយប៉ាន់ស្មានសរុប ៦,៧៩ លានដុល្លា ដែលត្រូវផ្តល់ហិរញ្ញប្បទានទាំងស្រុងដោយឥណទាន IDA)

1. ចាប់តាំងពីតំបន់ព្រៃធំៗត្រូវបានផ្ទេរពីក្រសួងកសិកម្មឲ្យស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថានដែលចូលជាធរមានចាប់ពីខែ មេសា ឆ្នាំ ២០១៦[1] មានវឌ្ឍនភាពជារួមក្នុងការគ្រប់គ្រងតំបន់ការពារ ប៉ុន្តែបញ្ហាប្រឈមនៅតែមាន ពាក់ព័ន្ធនឹងការគ្រប់គ្រងដោយប្រសិទ្ធភាព ៖ ការបែងចែងតំបន់ការពារមិនបានពេញលេញ កង្វះផែនការគ្រប់គ្រងដែលអនុម័តដោយក្រសួងបរិស្ថាន កង្វះសមត្ថភាពរបស់មន្ត្រីក្រសួងបរិស្ថាន និងមន្ត្រីមន្ទីរបរិស្ថានជាពិសេសនៅថ្នាក់មូលដ្ឋានក្នុងការរៀបចំផែនការតំបន់ការពារ និងការពង្រឹងការអនុវត្តច្បាប់ក្នុងតំបន់ការពារ ប្រព័ន្ធមិនគ្រប់គ្រាន់សម្រាប់ការចែករំលែកទិន្នន័យ និងព័ត៌មានដើម្បីគាំទ្រដល់ការពង្រឹងការអនុវត្តច្បាប់ស្តីពីតំបន់ការពារ កង្វះការសម្របសម្រួលដោយប្រសិទ្ធភាពរវាងក្រសួងនានា និងកង្វះប្រព័ន្ធគ្រប់គ្រងប្រាក់ចំណូលសម្រាប់គ្រប់គ្រងប្រាក់ចំណូលរបស់តំបន់ការពារ ដើម្បីផ្តល់ហិរញ្ញប្បទានដែលមានិរន្តរភាពសម្រាប់គាំទ្រដល់ការគ្រប់គ្រងតំបន់ការពារ។ សមាសភាគនឹងនេះដោះស្រាយបញ្ហាទាំងនេះតាមរយៈការវិនិយោគជាយុទ្ធសាស្ត្រលើ ៖ ប្រព័ន្ធព័ត៌មាន និងគាំទ្រការធ្វើសេចក្តីសម្រេចសម្រាប់ការរៀបចំផែនការ និងគ្រប់គ្រងតំបន់ការពារ និងសម្រាប់ការពង្រឹងការអនុវត្តច្បាប់ស្តីពីតំបន់ការពារ ការបង្កើតយុទ្ធសាស្ត្រ ការបណ្តុះបណ្តាល ជំនួយផ្នែកកស្តុការ និងគ្រឿងបរិក្ខារសម្រាប់ពង្រឹងការអនុវត្តច្បាប់ស្តីពីតំបន់ការពារ ការបែងចែកប្រភេទតំបន់ការពារ ការកំណត់ព្រំសីមា និងការបង្កើតផែនការគ្រប់គ្រង និងគំរូគ្រប់គ្រងប្រាក់ចំណូលពីតំបន់ការពារសម្រាប់កម្ពុជា។

### សមាសភាគរង ១.១ ៖ ប្រព័ន្ធព័ត៌មាន និងគាំទ្រការធ្វើសេចក្តីសម្រេច (ISDS)

[1]អនុក្រឹត្យឆ្នាំ ២០១៦ ស្តីពីការផ្ទេរព្រៃការពារ ការអភិរក្សព្រៃឈើ និងតំបន់ព្រៃផលិតកម្ម និង ELCs។

2. គម្រោងនឹងគាំទ្រដល់ការបង្កើត ISDS ដែលជួយកៀរគរ និងវិភាគព័ត៌មានពាក់ព័ន្ធសម្រាប់ការធ្វើសេចក្តីសម្រេចលើការការពារ និងគ្រប់គ្រងតំបន់ការពារ និងការរៀបចំផែនការតំបន់ទេសភាពក្នុង CMTS[2]។ ISDS នឹងត្រូវបានបង្កើតឡើងជាវេទិកាលំហភូមិសាស្ត្រក្នុងកម្មវិធី clould ដែលអាចបញ្ចូលទិន្នន័យ និងព័ត៌មានដែលមានសារៈសំខាន់សម្រាប់ការរៀបចំផែនការ និងគ្រប់គ្រងតំបន់ការពារ ដូចជា ព័ត៌មានស្តីពីជីវៈចម្រុះ ព័ត៌មានលំហស្តីពីការប្រើប្រាស់ដីធ្លី និងរៀបចំជាប្រព័ន្ធនូវព័ត៌មានដែលប្រមូលបានដោយមន្ទីរបរិស្ថាន ឧទ្យានុរក្ស និងសហគមន៍សម្រាប់ ឧ. របាយការណ៍ចុះល្បាត សកម្មភាពល្មើសច្បាប់ និងការសង្កេត) ដែលនឹងគាំទ្រដល់ការរៀបចំផែនការ ការសម្របសម្រួល និងការពង្រឹងតំបន់ការពារកាន់តែប្រសើរឡើង។ ISDS បន្សុីគ្នានឹងយុទ្ធសាស្ត្ររបស់ក្រសួងបរិស្ថានស្តីពីការគ្រប់គ្រងទិន្នន័យ និងព័ត៌មានលំហភូមិសាស្ត្រ ហើយនឹងផ្អែកលើការងារមានស្រាប់ដែលគាំទ្រដោយ UNDP និង WCS ដើម្បីបង្កើតប្រព័ន្ធធ្វើសេចក្តីសម្រេចលើការបែងចែកតំបន់ការពារ[3]។ ដើម្បីគាំទ្រសមាសភាគនេះ ក្រសួងបរិស្ថាននឹងបង្កើតក្រុមការងារអន្តរវិស័យសម្រាប់ **ISDS** នៅថ្ងៃទី...។ គម្រោងនេះនឹងផ្តល់ហិរញ្ញប្បទានដល់ ៖

១. ការគាំទ្រផ្នែកបច្ចេកទេសសម្រាប់ក្រសួងបរិស្ថានដើម្បីបង្កើត និងអនុវត្ត ISDS

២. ផ្នែករឹង និងផ្នែកទន់ចាំបាច់សម្រាប់ការអនុវត្ត ISDS និង

៣. ការបណ្តុះបណ្តាលមន្ត្រីក្រសួងបរិស្ថានក្នុងការប្រើប្រាស់ និងគ្រប់គ្រង ISDS និងអ្នកពាក់ព័ន្ធ (មន្ទីរបរិស្ថាន សហគមន៍ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល) ក្នុងការប្រើប្រាស់ ISDS។

**សមាសភាគរង ១.២ ៖ ការរៀបចំផែនការ ការគ្រប់គ្រង និងការពង្រឹងទេសភាពតំបន់ការពារ**

3. **ការរៀបចំផែនការ និងការគ្រប់គ្រងតំបន់ការពារ។** គម្រោងនេះនឹងគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតតំបន់ការពារ និងផែនការគ្រប់គ្រងតំបន់ការពារ និងតំបន់ការពារសហគមន៍ដោយសហការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន[4]។ NPASMP របស់រដ្ឋាភិបាលមានគោលបំណងយុទ្ធសាស្ត្រមួយស្តីពីការបង្កើតតំបន់ការពារ ដែលគាំទ្រដោយសមាសភាគរងនេះ។ *ដើម្បី*

---

[2] ការគាំទ្រដល់ការធ្វើផែនការតំបន់ទេសភាពលំហក្នុង CMTS មានសារៈសំខាន់ដោយសារតែការបង្កបង្កើនផលស្រូវនៅខេត្តពោធិ៍សាត់ និងបាត់ដំបង និងជលផលក្នុងបឹងទន្លេសាប ពឹងផ្អែកលើសេវាប្រព័ន្ធអេកូឡូស៊ីដែលកំណត់ជាទឹក និងកំទេចកំណា ពីព្រៃឈើក្នុងតំបន់ជួរភ្នំក្រវ៉ាញ។

[3]ក្រសួងបរិស្ថាន ២០១៨ ៖ យុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងព័ត៌មាន និងទិន្នន័យលំហភូមិសាស្ត្របរិស្ថានរបស់ក្រសួងបរិស្ថាន ២០១៨-២០២២។

[4]ច្បាប់ស្តីពីតំបន់ការពារ និងពង្រាងក្រមបរិស្ថានផ្តល់ការណែនាំស្តីពីប្រភេទផែនការដែលអាចបង្កើតផែនការតំបន់ទេសភាពនៅកម្ពុជា ដូចជា ផែនការតំបន់ការពារសហគមន៍ ផែនការតំបន់ព្រៃសហគមន៍ ផែនការគ្រប់គ្រងសកម្មភាពពាណិជ្ជកម្ម និងផែនការអាងទន្លេ។

*គាំទ្រសកម្មភាពក្នុងសមាសភាគរងនេះ ពង្រាង NPASMP នឹងត្រូវសម្រេចបញ្ចប់ និងអនុម័តដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន។*

១. គម្រោងនឹងគាំទ្រដល់ក្រសួងបរិស្ថានក្នុងការពង្រឹងគោលការណ៍ណែនាំស្តីពី ៖ ១) ការបែងចែកតំបន់ការពារ ២) ការបង្កើតផែនការគ្រប់គ្រងតំបន់ការពារសហគមន៍។ ក្នុងបរិការណ៍នេះ ក្រសួងបរិស្ថាននឹងកំណត់រក និងស្នើសុំជំនួយថវិកាបន្ថែមសម្រាប់ការពិនិត្យតាមដានការអនុវត្តផែនការគ្រប់គ្រងតំបន់ការពារ និងតំបន់ការពារសហគមន៍ ក្រោយការបង្កើតផែនការរួចរាល់ (ឆ្នាំ ២០២០)។

២. គម្រោងនឹងអនុវត្តសកម្មភាពផ្សេងៗក្នុងតំបន់ការពារនៅ CMTS ដើម្បីគាំទ្រដល់ការបែងចែកជាតំបន់ ការបង្កើតផែនការគ្រប់គ្រងតំបន់ការពារ ការកំណត់ព្រំសីមា និងការចុះបញ្ជីដីធ្លីតំបន់ការពារដែលបានកំណត់ព្រំសីមារួច (តារាង ២)។ ជាពិសេស ៖

- គម្រោងនឹងគាំទ្រសកម្មភាពក្នុងតំបន់ការពារផ្សេងៗ ដូចជា តំបន់ការពារថ្នាក់ជាតិ ដែនជម្រកសត្វព្រៃ តំបន់ប្រើប្រាស់ចម្រុះ និងច្រកអភិរក្សជីវៈចម្រុះ។ ច្បាប់ស្តីពីតំបន់ការពារកំណត់ការណែនាំស្តីពីប្រភេទសកម្មភាពដែលអាចអនុញ្ញាតទៅបានក្នុងតំបន់ការពារនីមួយៗ និងជះឥទ្ធិពលលើរបៀបបែងចែក និងគ្រប់គ្រងប្រភេទតំបន់តំបន់ការពារផ្សេងៗ[5]។
- សកម្មភាពបែងចែកជាតំបន់នឹងត្រូវធ្វើឡើងនៅគ្រប់តំបន់ការពារទាំងអស់នៅ CMTS លើកលែងតែ BCC ភ្នំក្រវាញ[6]។ ផែនទីបឋមស្តីពីតំបន់នានាត្រូវបានបង្កើតឡើងរួមគ្នាដោយអង្គការសម្ព័ន្ធភាពសត្វព្រៃ និងក្រសួងបរិស្ថាន។ សកម្មភាពនេះនឹងផ្អែកលើផែនការតំបន់បឋម ដោយរួមបញ្ចូល

---

[5]**ឧទ្យានជាតិ ៖** តំបន់ធម្មជាតិលើដី និង/ឬដែនទឹកដែលត្រូវបានបង្កើតឡើងដើម្បីការពារតួនាទីរបស់តំបន់នោះក្នុងប្រព័ន្ធអេកូឡូស៊ី ដើម្បីផ្តល់អត្ថប្រយោជន៍ដល់មនុស្សគ្រប់ជំនាន់ រិតត្បិតការប្រើប្រាស់ដែលអាចបង្កគ្រោះថ្នាក់ ឬបំផ្លាញធនធានជីវៈសាស្រ្ត ធនធានធម្មជាតិ ធនធានវប្បធម៌ និងមុខងារ/តួនាទីរបស់តំបន់នេះធៀបនឹងគោលបំណងជាក់ស្តែង ដើរតួនាទីជាមូលដ្ឋានសម្រាប់ការកំសាន្តសប្បាយ ដំណើរទេសចរណ៍ ការអប់រំ ស្រាវជ្រាវ និងជំនឿ ឲ្យតែសកម្មភាពទាំងនេះមិនគំរាមកំហែងដល់បរិស្ថានធម្មជាតិ និងវប្បធម៌មូលដ្ឋាន។

**ដែនជម្រកសត្វព្រៃ ៖** តំបន់នៅលើដី និង/ឬដែនទឹកដែលតម្រូវឲ្យមានអន្តរាគមន៍យ៉ាងសកម្មលើគោលបំណងគ្រប់គ្រងដើម្បីធានាការរក្សាដែនជម្រក និង/ឬបំពេញលក្ខខណ្ឌចាំបាច់សម្រាប់អំបូររុក្ខជាតិ ឬសត្វ។

**តំបន់ប្រើប្រាស់ចម្រុះ ៖** តំបន់នៅលើដី និង/ឬដែនទឹក ដែលសំបូរដោយធនធានធម្មជាតិដែលមិនទាន់មានការប៉ះពាល់ និងទាមទារនូវសកម្មភាពគ្រប់គ្រងដើម្បីធានាការការពារ និងការថែរក្សាយូរអង្វែងនូវធនធានជីវសាស្រ្ត និងប្រព័ន្ធអេកូឡូស៊ី។ ទន្ទឹមនឹងនេះ តំបន់នេះផ្តល់ផលិតផល និងសេវាធម្មជាតិសម្រាប់ការប្រើប្រាស់ដើម្បីបំពេញតម្រូវការសហគមន៍។

[6] BCCs មិនត្រូវបានបែងចែកជាតំបន់ឡើយ។

ព័ត៌មានលំហជីវៈរូបវន្តបន្ថែមតាមរយៈ ISDS និងការពិគ្រោះយោបល់បន្ថែមជាមួយអ្នកពាក់ព័ន្ធក្នុងតំបន់ការពារ។ អង្គការសម្ព័ន្ធភាពសត្វព្រៃ និងអង្គការអភិរក្សអន្តរជាតិកំពុងធ្វើប្រតិបត្តិការនៅតំបន់ឧទ្យាជាតិភ្នំក្រវាញភាគខាងត្បូង តំបន់ឧទ្យានជាតិភ្នំក្រវាញភាគកណ្តាល និងដែនជម្រកសត្វព្រៃតាតៃ និងបានពិគ្រោះយោបល់ជាមួយសហគមន៍ស្តីពីការបែងចែកជាតំបន់។

- ផែនការគ្រប់គ្រងតំបន់ការពារ នឹងត្រូវបានបង្កើតឡើងសម្រាប់តំបន់ឧទ្យាជាតិភ្នំក្រវាញភាគខាងត្បូង តំបន់ឧទ្យានជាតិភ្នំក្រវាញភាគកណ្តាល ដែនជម្រកសត្វព្រៃភ្នំសំកុស ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដែនជម្រកសត្វព្រៃតាតៃ តំបន់ប្រើប្រាស់ចម្រុះទន្លេសាប និង BCC ភ្នំក្រវាញ។ តំបន់ការពារទាំងនេះត្រូវបានជ្រើសរើសសម្រាប់ការបង្កើតផែនការគ្រប់គ្រង ដោយសារមូលហេតុជាយុទ្ធសាស្ត្រមួយចំនួន ៖ ១) តំបន់ការពារទាំងនេះមានទំហំស្មើនឹង ៨១% នៃតំបន់ការពារនៅ CMTS ហើយការដាក់ឲ្យតំបន់ការពារទាំងនេះស្ថិតក្រោមផែនការអនុម័តដោយក្រសួងបរិស្ថាន គឺជាជំហានបឋមឆ្ពោះទៅរកការគ្រប់គ្រងតំបន់ការពារកាន់តែប្រសើរឡើង ២) ការងាររបស់ដៃគូអភិវឌ្ឍន៍ក្នុងតំបន់ការពារទាំងនេះបានជួយដល់ការត្រៀមខ្លួនសហគមន៍ និងអ្នកពាក់ព័ន្ធក្នុងតំបន់ការពារទាំងនេះសម្រាប់ការរៀបចំផែនការគ្រប់គ្រងតំបន់ការពារ។

**តារាង ២ ៖ សកម្មភាពរៀបចំផែនការតំបន់ទេសភាពដែលគាំទ្រដោយគម្រោង**

| តំបន់ការពារគោលដៅ | សកម្មភាពគាំទ្រដោយគម្រោង | | | |
|---|---|---|---|---|
| | ការបែងចែកជាតំបន់ | ផែនការគ្រប់គ្រងតំបន់ការពារ | ការកំណត់ព្រំសីមា | ការចុះបញ្ជីដីធ្លី |
| តំបន់ភ្នំក្រវាញភាគកណ្តាល | X | X | | |
| តំបន់ភ្នំក្រវាញភាគខាងត្បូង | X | X | | |
| តាតៃ | X | X | X | |
| ភ្នំសំកុស | X | X | X | X |
| ភ្នំឱរ៉ាល់ | X | X | X | X |
| BCC ភ្នំក្រវាញ | | X | | |
| តំបន់ជីវៈដែនទន្លេសាបប្រើប្រាស់ច្រើនយ៉ាង | X | X | | |
| តំបន់ការពារផ្សេងទៀតនៅ CMTS | X | | | |

សម្គាល់ ៖

1. X បង្ហាញពីសកម្មភាពដែលនឹងទទួលបានការគាំទ្រពីគម្រោងសម្រាប់តំបន់ការពារ។

2. ផែនការគ្រប់គ្រង ការកំណត់ព្រំសីមា និងការចុះបញ្ជីដីធ្លីត្រូវបានផ្តោតអាទិភាពលើតំបន់ការពារមួយចំនួនដោយផ្អែកលើការពិភាក្សាជាមួយរដ្ឋាភិបាល និងតួអង្គមិនមែនរដ្ឋាភិបាល ដូចជា អ្នកពាក់ព័ន្ធដែលធ្វើប្រតិបត្តិការនៅ CMTS។

- ការកំណត់ព្រំសីមានឹងត្រូវធ្វើឡើងនៅដែនជម្រកសត្វព្រៃតាតៃ ភ្នំសំកុស និងភ្នំឱរ៉ាល់។ ក្រសួងបរិស្ថានបានផ្តោតអាទិភាពលើតំបន់ការពារទាំងនេះសម្រាប់ការកំណត់ព្រំសីមា ដោយសារតែតំបន់ទាំងនេះជាដែនជម្រកសត្វព្រៃដ៏សំខាន់ និងភាពចាំបាច់ក្នុងការទប់ស្កាត់ការទន្ទ្រានកាន់កាប់ ការបំផ្លិចបំផ្លាញ និងការរំខានដល់ជម្រកសត្វ។
- ការចុះបញ្ជីដីធ្លីព្រំសីមាតំបន់ នឹងត្រូវធ្វើឡើងក្នុងដែនជម្រកសត្វព្រៃសំកុស និងភ្នំឱរ៉ាល់។ ក្រសួងបរិស្ថានបានផ្តោតអាទិភាពការចុះបញ្ជីដីធ្លីសម្រាប់តំបន់ទាំងនេះ ដោយសារតែការគំរាមកំហែងនានាក្នុងទម្រង់ជាការទន្ទ្រានកាន់កាប់ និងការរំខានដល់ដែនជម្រក និងសកម្មភាពបំផ្លិចបំផ្លាញ។

៣. គម្រោងនឹងផ្តល់ហិរញ្ញវត្ថុដល់ដំណើរការបែងចែកជាតំបន់ និងការបង្កើតផែនការគ្រប់គ្រងតំបន់ការពារសហគមន៍អាទិភាពដែលស្ថិតក្នុងតំបន់ការពារគោលដៅ។ យើងបានរៀបចំតារាងដែលមានតំបន់ការពារសហគមន៍ ៣៤ ក្នុងតំបន់ការពារគោលដៅ ហើយតំបន់ការពារសហគមន៍សម្រាប់អន្តរាគមន៍គម្រោង នឹងត្រូវបានកំណត់ឡើងដោយផ្អែកលើការត្រៀមខ្លួនរបស់សហគមន៍។ លក្ខណៈវិនិច្ឆ័យសម្រាប់កការត្រៀមខ្លួនផ្អែកតាមជំហាន ៨ ចំណុចរបស់ក្រសួងបរិស្ថានក្នុងដំណើរការបង្កើតតំបន់ការពារសហគមន៍ ដូចជា ១) តំបន់ការពារសហគមន៍ត្រូវបានបង្កើតឡើងទៅតាមគោលការណ៍ណែនាំរបស់ក្រសួងស្តីពីតំបន់ការពារសហគមន៍[7] ២) តំបន់ការពារសហគមន៍មានគណៈកម្មាធិការគ្រប់គ្រងដែលអនុម័តដោយឃុំ/សង្កាត់ និង ៣) តំបន់ការពារសហគមន៍ផ្តួចផ្តើមការកំណត់ព្រំសីមា និងមានការបង្កើតលក្ខន្តិកៈ។

៤. ការផ្តល់ហិរញ្ញប្បទានគម្រោងផ្តោតលើការបណ្តុះបណ្តាលមន្ត្រីក្រសួងបរិស្ថាន រដ្ឋាភិបាលមូលដ្ឋាន ឧទ្យានុរក្ស និងអ្នកពាក់ព័ន្ធផ្សេងទៀតស្តីពីការបង្កើតតំបន់ការពារ និងការរៀបចំផែនការ និងការសម្របសម្រួល និងពិនិត្យតាមដានការអនុវត្តផែនការទាំងនេះ។

4. **ការពង្រឹងតំបន់ការពារ ៖** គម្រោងនឹងផ្តល់ហិរញ្ញប្បទានជំនួយបច្ចេកទេសដល់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការបង្កើត និងអនុវត្តក្របខណ្ឌពង្រឹងតំបន់ការពារដែលរួមមានដំណើរការ តួនាទី និងការទទួលខុសត្រូវ និងការរៀបចំផ្នែកស្ថាប័នសម្រាប់ការពង្រឹងតំបន់ការពារ។ គម្រោងនឹងបង្កើតយុទ្ធសាស្ត្រពង្រឹងការអនុវត្ត

---

[7] ក្រសួងបរិស្ថាន ២០១៧ ៖ គោលការណ៍ណែនាំស្តីពីនីតិវិធី និងដំណើរការបង្កើតតំបន់ការពារសហគមន៍។

ច្បាប់ជារួម ដែលត្រួសត្រាយ និងសម្របសម្រួលសកម្មភាពក្នុងតំបន់ការពារទាំងអស់ បង្កើតអាទិភាព និងផែនការសកម្មភាព។ ឯកសារជំនួយស្មារតីនឹងត្រូវបានបង្កើតឡើង និងរួមបញ្ចូលការណែនាំសម្រាប់ការចុះល្បាតដោយឧទ្យានុរក្ស ការប្រើប្រាស់អភិក្រម SMART[8] ការប្រមូលទិន្នន័យដែលពាក់ព័ន្ធនឹង ISDS កិច្ចសហការដោយមានការពង្រឹងការអនុវត្តច្បាប់ ដូចជា ប្រព័ន្ធយុត្តិធម៌ ការប្រើប្រាស់ដ្រូន ផ្ទាយរណប និងសញ្ញាផ្តល់រូបភាពពីចម្ងាយ និងទូរគមនាគមន៍ក្នុងការពិនិត្យតាមដានព្រៃឈើ។

5. យុទ្ធសាស្ត្រ និងឯកសារជំនួយស្មារតីនឹងត្រូវបានបង្កើតចេញពីដំណើរការដែលមានការចូលរួមដោយទីភ្នាក់ងាររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដៃគូ ដូចជា អង្គការសម្ព័ន្ធភាពសត្វព្រៃ និងអង្គការអភិរក្សអន្តរជាតិដែលគាំទ្រដល់ការចុះល្បាតរបស់ឧទ្យានុរក្សនៅ CMTS។ សម្ភារបរិក្ខារសម្រាប់ការចុះល្បាត និងពិនិត្យតាមដានព្រៃឈើ និងការស្តារមជ្ឈមណ្ឌលឧទ្យានុរក្សនៅ CMTS នឹងទទួលបានជំនួយពីគម្រោង និងការបណ្តុះបណ្តាលមន្ត្រីក្រសួងបរិស្ថាន រដ្ឋាភិបាលមូលដ្ឋាន សហគមន៍ព្រៃឈើ និងអ្នកពាក់ព័ន្ធផ្សេងទៀតស្តីពីការពិនិត្យតាមដាន និងពង្រឹងព្រៃឈើ និងការគាំទ្រដល់ការសម្របសម្រួលផ្នែកភស្តុភារដោយរដ្ឋាភិបាលខេត្តលើការពង្រឹងការអនុវត្តច្បាប់។ ក្នុងគោលបំណងពង្រឹងតំបន់ការពារ ក្រសួងបរិស្ថាននឹងកំណត់ពីចំនួនឧទ្យានុរក្សបន្ថែមសម្រាប់តំបន់ការពារគោលដៅនីមួយៗ និងជំនួយថវិកាបន្ថែមសម្រាប់ឆ្នាំ ២០២០។

6. **ការគ្រប់គ្រងហិរញ្ញវត្ថុ និងប្រាក់ចំណូលប្រកបដោយនិរន្តរភាព ៖** ការគ្រប់គ្រងតំបន់ការពារប្រឈមនឹងបញ្ហាកង្វះមូលនិធិគ្រប់គ្រាន់សម្រាប់ការរៀបចំផែនការ ការកសាងសមត្ថភាព ការពិនិត្យតាមដាន និងការចូលរួមជាមួយសហគមន៍។ សកម្មភាពជាច្រើនត្រូវបានផ្តល់ហិរញ្ញប្បទានរួមគ្នាដោយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងដៃគូផ្សេងទៀត ដែលមិនមែនជាទស្សនាទានប្រកបដោយនិរន្តរភាពក្នុងរយៈពេលមធ្យម។ ការប្រមូលកម្រៃសេវាពីទេសចរណ៍ធម្មជាតិ នឹងចូលរួមចំណែកដល់និរន្តរភាពហិរញ្ញវត្ថុរបស់តំបន់ការពារគោលដៅ។ បច្ចុប្បន្ន មានការគិតកម្រៃសេវាពីភ្ញៀវទេសចរណ៍ដែលចូលទៅកាន់តំបន់ការពារមួយចំនួន (ឧ. តំបន់ការពារគិរីរម្យ) ប៉ុន្តែមិនទាន់មានគោលនយោបាយ និងគោលការណ៍ណែនាំច្បាស់លាស់ស្តីពីកម្រៃសេវាការប្រមូល និងគ្រប់គ្រងប្រាក់ចំណូល និងការឯកភាពលើការប្រើប្រាស់កម្រៃសេវាពីធនធានទាំងនេះឡើយ។ ការអនុវត្តល្អជាអន្តរជាតិបង្ហាញថា ត្រូវមានការបែងចែកអត្ថប្រយោជន៍សមស្របដើម្បីកំណត់ពីការបែងចែកប្រាក់ចំណូលពីសកម្មភាពទេសចរណ៍។

---

[8]ឧបករណ៍រាយការណ៍ និងពិនិត្យតាមដានលំហ (SMART) ជាកម្រងការអនុវត្តល្អបំផុតសម្រាប់ជួយដល់អ្នកគ្រប់គ្រងតំបន់ការពារ និងសត្វព្រៃឲ្យពិនិត្យតាមដាន វាយតម្លៃ និងគ្រប់គ្រងសកម្មភាពចុះល្បាតដោយប្រសិទ្ធភាព។ SMART កំពុងត្រូវបានប្រើប្រាស់នៅតាមតំបន់ការពារមួយចំនួននៅកម្ពុជា។

7. **ក្រៅពីកម្រៃសេវាទេសចរណ៍ គម្រោងនឹងវិភាគពីឱកាសហិរញ្ញប្បទានជាច្រើនផ្សេងទៀត** (ការទូទាត់សម្រាប់សេវាបរិស្ថាន ៖ PES និងរេដបូក) ហើយនឹងជំរុញការសិក្សាស្តីពីការវាយតម្លៃសេវាប្រព័ន្ធអេកូឡូស៊ីជលសាស្ត្រក្នុងបរិបទនៃគណនេយ្យធម្មជាតិ (WAVES)។ ក្រៅពីនេះ គម្រោងនឹងជំរុញការរៀបចំ និងគាំទ្រមូលនិធិបរិស្ថាន និងសង្គមដែលបង្កើតដោយក្រសួងបរិស្ថាន។

8. គម្រោងនឹងគាំទ្រដល់ការរៀបចំ និងអនុវត្តក្របខណ្ឌគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់តំបន់ការពារនៅ CMTS ជាពិសេស ៖

i. ការវិភាគដើម្បីជួយដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការវាយតម្លៃលើការប្រមូល និងចាត់ចែងកម្រៃសេវា វិភាគគំរូហិរញ្ញវត្ថុផ្សេងៗ រៀនសូត្រពីការអនុវត្តល្អបំផុត និងរៀបចំប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុចម្រុះសម្រាប់មូលនិធិបរិស្ថាន និងសង្គម ដើម្បីទទួលបាន និងគ្រប់គ្រងកម្រៃសេវា និងធនធានមានសក្តានុពលផ្សេងទៀតពីរេដបូក និង PES។

ii. រៀបចំកិច្ចពិភាក្សាពហុភាគីស្តីពីយន្តការហិរញ្ញប្បទាន (ដូចជា PES, រេដបូក និងកម្រៃសេវាទេសចរណ៍)។ ការវាយតម្លៃសេវាប្រព័ន្ធអេកូឡូស៊ីជលសាស្ត្រ និងនៅ CMTS កំពុងធ្វើឡើងក្រោមជំនួយរបស់ WAVES ដើម្បីរៀបចំជំនួយបច្ចេកទេសសម្រាប់ PES។

iii. រៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលជាក់ស្តែងសម្រាប់ការកសាងសមត្ថភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីគ្រប់គ្រងការប្រមូលកម្រៃសេវា និងការបែងចែកអត្ថប្រយោជន៍។

## 2. ពង្រឹងឱកាសទេសចរណ៍ធម្មជាតិ និងសង្វាក់តម្លៃអនុផលព្រៃឈើ (ចំណាយប៉ាន់ស្មានសរុប ១៦,៧៥ លានដុល្លា និងត្រូវផ្តល់ហិរញ្ញប្បទានទាំងស្រុងដោយឥណទាន IDA)។

9. សមាសភាគនេះមានគោលដៅផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគសំខាន់ៗ និងពង្រឹងបរិយាកាសអនុគ្រោះសម្រាប់ការពង្រីកឱកាសទេសចរណ៍ធម្មជាតិ និងសង្វាក់តម្លៃអនុផលព្រៃឈើនៅកម្ពុជា។ ចំណុចផ្តោតសំខាន់ក្នុងសមាសភាគនេះ (និងសមាសភាគទី ៣) គឺការបង្កើន និងពង្រឹងបរិយាកាសអនុគ្រោះសម្រាប់ការចូលរួមរបស់វិស័យឯកជន និងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ (ការតភ្ជាប់ មជ្ឈមណ្ឌលភ្ញៀវទេសចរណ៍។ល។)។ ភាពប្រសើរឡើងផ្នែកអភិបាលកិច្ច ការគ្រប់គ្រង និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងតំបន់គោលដៅ បូករួមនឹងការវិនិយោគលើការតភ្ជាប់ ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ធម្មជាតិ/អនុផលព្រៃឈើ និងតម្លៃបន្ថែមនឹងជួយជំរុញការវិនិយោគដោយវិស័យឯកជន។

### សមាសភាគរង ២.១ ៖ ពង្រឹងឱកាសអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ

10. **ចំណុចស្នូលនៃការបង្កើនសក្តានុពលទេសចរណ៍ធម្មជាតិនៅកម្ពុជា គឺការបង្កើតតំណភ្ជាប់រវាងច្រកទេសចរណ៍សំខាន់ៗ**នៃខេត្តសៀមរាប និងក្រុងភ្នំពេញទៅនឹងមូលដ្ឋានទ្រព្យសម្បត្តិធម្មជាតិនៅ CMTS តាមរយៈគំរូ "ដុំ-កាំ" នៃការអភិវឌ្ឍវិស័យទេសចរណ៍។ ដំបូង គំរូនេះបង្កើនលទ្ធភាពទទួលបាន និងចល័តភាពក្នុង និងជុំវិញទីប្រជុំជន (ដុំ) រួចទើបអភិវឌ្ឍ "កាំ" ពោលគឺទីតាំងទេសចរណ៍ធម្មជាតិដែលផ្សារភ្ជាប់ទៅនឹងដុំ។ អភិក្រមនេះធ្វើឲ្យភ្ញៀវទេសចរណ៍ធ្វើដំណើរទៅមក តាមរបៀបដែលបែងចែកអត្ថប្រយោជន៍សេដ្ឋកិច្ចសង្គម ដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ដល់សហគមន៍នៅជិតតំបន់ទេសចរណ៍ធម្មជាតិ។

11. **"ដុំ" ៤ សម្រាប់ការអភិវឌ្ឍទេសចរណ៍ធម្មជាតិត្រូវបានកំណត់ចេញពីការវិភាគលំហភូមិសាស្ត្រ និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ។** ការវិភាគលំហភូមិសាស្ត្រជួយកំណត់បណ្តុំលំហនៃទីតាំងដែលមានសក្តានុពលសម្រាប់ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ ការអភិវឌ្ឍទេសចរណ៍ធម្មជាតិមានស្រាប់ តំបន់ការពារសហគមន៍ និងក្រុមសហគមន៍។ ដុំ ៤ ត្រូវបានកំណត់រកក្នុងខេត្តកោះកុង សៀមរាប ពោធិ៍សាត់ និងកំពង់ស្ពឺ។ មានការបង្កើតលក្ខណៈវិនិច្ឆ័យបឋមដើម្បីជួយកំណត់រក និងផ្តោតអាទិភាពលើទីតាំងទេសចរណ៍ធម្មជាតិដែលអាចទទួលបានជំនួយហិរញ្ញវត្ថុពីគម្រោងនេះ។ លក្ខណៈវិនិច្ឆ័យរួមមានលទ្ធភាពចេញចូល ភាពទាក់ទាញ ការប្រើប្រាស់/សិទ្ធិកាន់កាប់ដីធ្លី ភាពងាយរងគ្រោះរបស់ទីតាំង លទ្ធភាពទទួលបានសេវា ទីតាំងទេសចរណ៍ធម្មជាតិមានស្រាប់ ស្ថានភាពសេដ្ឋកិច្ចសង្គម តម្រូវការទីផ្សារ ជីវៈចម្រុះ និងនានាភាពនៃការផ្តល់សេវាទេសចរណ៍ធម្មជាតិ។

## ការបង្កើនបរិយាកាសអនុគ្រោះសម្រាប់ទេសចរណ៍ធម្មជាតិ

12. នឹងមានការផ្តល់ជំនួយបច្ចេកទេសដល់ការបង្កើតក្របខណ្ឌកែលម្អ សម្របសម្រួល និងបង្កើតកិច្ចសន្យា/កិច្ចព្រមព្រៀងគ្រប់គ្រងទេសចរណ៍ធម្មជាតិមានស្រាប់ និងការបង្កើតគោលការណ៍ណែនាំថ្នាក់ជាតិ និងអនុវត្តល្អបំផុត ក៏ដូចជាពង្រឹងបរិយាកាសអនុគ្រោះដើម្បីជំរុញភាពលូតលាស់របស់សហគ្រាសខ្នាតតូច និងមធ្យម។ ចំណុចនេះរួមមានការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការរៀបចំទម្រង់ "កិច្ចព្រមព្រៀងគ្រប់គ្រងទេសចរណ៍ធម្មជាតិ" ច្បាស់លាស់ និងស៊ីសង្វាក់គ្នាដើម្បីជួយដល់ការសម្រេចបញ្ចប់ប្រកាសរបស់ក្រសួងបរិស្ថានស្តីពីការអភិវឌ្ឍទេសចរណ៍ធម្មជាតិក្នុងតំបន់ការពារ (នឹងត្រូវអនុម័តដោយលោករដ្ឋមន្ត្រីនៅខែ ធ្នូ ឆ្នាំ ២០១៩) និងការអនុវត្តជាក់ស្តែង។ អ្វីដែលសំខាន់នោះគឺគម្រោងនឹងជួយដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តគោលការណ៍ណែនាំទាំងនេះ (ដូចជា គោលការណ៍ណែនាំស្តីពីការគ្រប់គ្រង ពិនិត្យតាមដាន យន្តការបែងចែកអត្ថប្រយោជន៍។ល។) នៅតាមទីតាំងទេសចរណ៍ធម្មជាតិផ្សេងៗ (ផ្អែកតាមលក្ខណៈវិនិច្ឆ័យស្តង់ដារ) ក្នុងតំបន់ការពារ។

13. គម្រោងនឹងគាំទ្រដល់ការបង្កើតសេវាអភិវឌ្ឍន៍អាជីវកម្ម (BDS) ក្នុងមជ្ឈមណ្ឌលប្រើប្រាស់ចម្រុះ ដែលរួមមានការបណ្តុះបណ្តាល និងការណែនាំបច្ចេកទេសស្តីពីការអភិវឌ្ឍអាជីវកម្មសម្រាប់ទេសចរណ៍ធម្មជាតិ និងសហគ្រាសសង្វាក់តម្លៃអនុផលព្រៃឈើ។ BDS ទាំងនេះនឹងជួយបំពេញចំណុចខ្វះខាតលើជំនាញសហគ្រិន និងការណែនាំអាជីវកម្ម ក៏ដូចជាជំរុញភាពប្រកួតប្រជែងក្នុងចំណោមវិស័យឯកជន និងក្រុមទេសចរណ៍ធម្មជាតិសហគមន៍។ មជ្ឈមណ្ឌលនេះនឹងផ្តល់ការបណ្តុះបណ្តាលស្តីពីតម្រូវការអភិវឌ្ឍន៍អាជីវកម្ម ដូចជា ការកំណត់រកទីផ្សារ និងការធ្វើទីផ្សារ ការអភិវឌ្ឍ និងគ្រប់គ្រងផលិតផល និងជួយដល់វិស័យឯកជន និងក្រុមសហគមន៍រៀបចំផែនការអាជីវកម្មរឹងមាំ។ BDS រួមមានការផ្តល់សេវាដល់សហគ្រិនជាស្ត្រីដើម្បីជំរុញការចូលរួមរបស់ស្ត្រីក្នុងទេសចរណ៍ធម្មជាតិ និងសង្វាក់តម្លៃពាក់ព័ន្ធ។

## ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ធម្មជាតិ

14. សមាសភាគនេះនឹងផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគ ដែលពាក់ព័ន្ធនឹងការបង្កើត/ស្តារហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ធម្មជាតិក្នុងតំបន់ទេសភាពគោលដៅ។ ទេសចរណ៍ធម្មជាតិជាសកម្មភាពដែលផ្អែកលើបរិស្ថានធម្មជាតិ និងត្រូវមានហេដ្ឋារចនាសម្ព័ន្ធគាំទ្រដើម្បីកាត់បន្ថយផលប៉ះពាល់លើមនុស្ស និងបន្សុីគ្នានឹងតំបន់ទេសភាព។ ប្រភេទ និងកម្រិតហេដ្ឋារចនាសម្ព័ន្ធអាស្រ័យលើលក្ខណៈធម្មជាតិ និងវប្បធម៌ និងភាពងាយរងគ្រោះរបស់តំបន់ ព្រមទាំងរបៀបរៀបចំទេសចរណ៍ធម្មជាតិ។ ហេដ្ឋារចនាសម្ព័ន្ធនឹងប្រែប្រួលទៅតាមរបៀបរៀបចំទេសចរណ៍ធម្មជាតិដែលចង់បាន និងសិទ្ធិកាន់កាប់ដីធ្លី។ ក្នុង "ដុំ-កាំ" ទេសចរណ៍ធម្មជាតិនីមួយៗ សកម្មភាពដែលអាចធ្វើឡើងរួមមាន ការបង្កើត ១) ចំណតសមស្រប ហាងអាហារ ការគ្រប់គ្រងសំណល់រឹង ហាង និងកញ្ចុះដែលមានលក់វត្ថុសិប្បកម្មក្នុងសហគមន៍ដែលស្ថិតនៅជិតទីតាំង ២)មជ្ឈមណ្ឌលផ្តល់ព័ត៌មានដល់ភ្ញៀវទេសចរណ៍ ៣) ផ្លូវដើរ ប៉មទស្សនា ក្តារដើរ ផ្ទាំងបង្ហាញព័ត៌មានចាំបាច់នៅតាមទីតាំងទេសចរណ៍ធម្មជាតិ។

15. សម្រាប់ទីតាំងទេសចរណ៍ធម្មជាតិតាមសហគមន៍ (CBET) នឹងមានការផ្តល់ហិរញ្ញប្បទានបន្ថែមដល់ ១) សកម្មភាពស្នាក់នៅតាមសហគមន៍ (ផ្ទះសំណាក់ធម្មជាតិ) ២) ហេដ្ឋារចនាសម្ព័ន្ធសិប្បកម្មដែលអាចលេចឡើង និងបរិក្ខារពាក់ព័ន្ធ និង ៣) ហេដ្ឋារចនាសម្ព័ន្ធសមស្របនឹងបរិស្ថានផ្សេងទៀតនៅជុំវិញទីតាំង។ សហគមន៍/តំបន់ការពារសហគមន៍ អាចប្រើប្រាស់មូលនិធិសម្រាប់សម្ភារៈបរិក្ខារ (ឧ. តង់ វិទ្យុ) និងផលិតផលព័ត៌មាន និងការផ្សាយពាណិជ្ជកម្ម។

16. កិច្ចពិភាក្សាបឋមគូសបញ្ជាក់ពីតំបន់ដុំ-កាំទេសចរណ៍ធម្មជាតិដែលមានសក្តានុពល ២ ៖ មួយនៅខេត្តសៀមរាប និងមួយទៀតនៅជុំវិញខេត្តកោះកុង។ សម្រាប់ខេត្តសៀមរាបដែលដើរតួនាទីជាដុំ "កាំ" នឹងត្រូវ

បានអភិវឌ្ឍ/ពង្រីកបន្ថែមឲ្យគ្រប់ដណ្តប់លើទីតាំងទេសចរណ៍ធម្មជាតិក្បែរខាងជាច្រើន ដោយពង្រីកការផ្តល់សេវាជាច្រើនដែលបង្ហាញពីមូលធនធម្មជាតិ ដូចជា ដែនជម្រកសត្វស្លាបព្រែកទាល់ ទីតាំងជាច្រើននៅក្នុងឧទ្យានជាតិភ្នំគូលែន និងនៅទូទាំង និងជុំវិញទន្លេសាប។ ការវិនិយោគសក្តានុពលរួមមាន ៖

- មជ្ឈមណ្ឌលបកប្រែបណ្តែតទឹក/ក្នុងផ្ទៃបឹង ដោយមានផ្ទាំងបង្ហាញព័ត៌មានពីប្រវត្តិ អេកូឡូស៊ី ជីវៈចម្រុះបឹង សហគមន៍ និងបេតិកភណ្ឌទន្លេសាប
- ការកែលម្អហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ធម្មជាតិក្បែរខាង (កន្លែងស្នាក់នៅ ម្ហូបអាហារ សេវា)
- ការកែលម្អបណ្តាញផ្លូវទឹករបស់បឹងទៅកាន់ភូមិបណ្តែតទឹក ការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធដំណើរកំសាន្តលើផ្ទៃបឹង និង
- ការបង្កើតផ្លូវតភ្ជាប់រវាងខេត្តសៀមរាប និងទន្លេសាបដែលពាក់ព័ន្ធនឹងទេសចរណ៍ធម្មជាតិឯកទេស ដូចជា ការដើរព្រៃ ការប្រមាញ់រូបថត ភ្ញៀវទេសចរណ៍ដែលមានចំណាប់អារម្មណ៍ពិសេស (ទស្សនាសត្វស្លាប សត្វព្រៃ)។

17. សម្រាប់ទេសចរណ៍ធម្មជាតិក្នុងខេត្តកោះកុង (ជុំ) នឹងមានការពង្រីកសេវាជាច្រើនទៅក្នុងតំបន់ជួរភ្នំក្រវាញ ដូចជា ជម្រើសសក្តានុពលសម្រាប់ទេសចរណ៍ធម្មជាតិដែលគ្រប់គ្រងដោយវិស័យឯកជន។ ការតភ្ជាប់បណ្តាញនឹងទាញប្រយោជន៍ពីគម្រោងសាងសង់ព្រលានយន្តហោះអន្តរជាតិឯកជន (តារាសាគរ) ដើម្បីធ្វើពិពិធកម្មតំបន់ទាក់ទាញទេសចណ៍ធម្មជាតិបច្ចុប្បន្ន។ ឧទាហរណ៍ ៖

- មជ្ឈមណ្ឌលអន្តរកម្មដែលបង្ហាញពីជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី សហគមន៍នៅជួរភ្នំក្រវាញ
- ការធ្វើទំនើបកម្ម/កែលម្អទីជម្រក និងផ្លូវលំសម្រាប់ទេសចរណ៍ធម្មជាតិឯកទេស ដូចជា ការដើរព្រៃ ការប្រមាញ់រូបថត និងភ្ញៀវទេសចរណ៍ដែលមានចំណាប់អារម្មណ៍ពិសេស (ទស្សនាសត្វស្លាប សត្វព្រៃ)
- ហេដ្ឋារចនាសម្ព័ន្ធនៅទីតាំងទេសចរណ៍ធម្មជាតិ ដូចជា ចំណត ទឹកស្អាត និងអនាម័យ សិប្បកម្ម និងហាងអាហារ។ល។
- ការដើរទស្សនាក្នុងព្រៃ ប៉ម និងប៉ុស្តិ៍ទស្សនា និង
- ហេដ្ឋារចនាសម្ព័ន្ធសុវត្ថិភាពនៅទីតាំងទឹកជ្រោះ និងច្រាំងចោត/ទីតាំងទស្សនាពីខាងលើ។

## សមាសភាគ ២.២ ៖ ការលើកកម្ពស់សង្វាក់តម្លៃអនុផលព្រៃឈើ

18. ការអភិវឌ្ឍសង្វាក់តម្លៃអនុផលព្រៃឈើ មានសក្តានុពលគាំទ្រដល់ការបង្កើតប្រាក់ចំណូលប្រកបដោយនិរន្តរភាពសម្រាប់សហគមន៍មូលដ្ឋាន ប៉ុន្តែត្រូវមានការអភិវឌ្ឍ និងគ្រប់គ្រងល្អប្រសើរដើម្បីទប់ស្កាត់ការធ្វើអាជីវកម្មហួសកម្រិត និងដើម្បីបង្កើតការងារ និងប្រាក់ចំណូលក្នុងតំបន់គម្រោង។ ឱកាសមានចាប់ពីការទាញយកជ័រឈើ និងផ្តៅ ផ្លែឈើ ក្រវាញ រុក្ខជាតិឱសថ ការកែច្នៃប្រេងបន្លែ រហូតដល់ការគ្រប់គ្រងដោយប្រសិទ្ធភាពនូវឃ្មុំ និងឫស្សី។ ថ្វីបើផលិតផលមួយចំនួនផ្តល់តម្លៃទីផ្សារគួរឲ្យចាប់អារម្មណ៍ ប៉ុន្តែមិនទាន់មានការរៀបចំគោលនយោបាយ ឬការលើកទឹកចិត្តឲ្យបានល្អប្រសើរឡើយ (កម្រៃសេវា ពន្ធនាំចូល ផែនការគ្រប់គ្រង ឬអាជ្ញាប័ណ្ណ)។ គេចាត់ទុកថានេះជាការរិតត្បិតលើអាជីវកម្មផ្លូវការមិនឲ្យចូលរួមក្នុងអនុផលព្រៃឈើទ្រង់ទ្រាយធំ។

19. ក្រោមសមាសភាគទី ១ គម្រោងនឹងគាំទ្រដល់តំបន់ការពារសហគមន៍ និងផែនការគ្រប់គ្រងតំបន់ការពារ (ដូចជា អនុផលព្រៃឈើ និងផែនការស្តារឡើងវិញ) ដែលនឹងជួយតម្រង់ទិសសកម្មភាពសេដ្ឋកិច្ចក្នុងតំបន់សហគមន៍នៅតាមតំបន់ការពារគោលដៅ។ អាទិភាពសម្រាប់អន្តរាគមន៍គម្រោងគឺតំបន់ការពារសហគមន៍ដែលស្ថិតនៅជិតសកម្មភាពទេសចរណ៍ធម្មជាតិ។ គម្រោងនឹងផ្តោតអាទិភាពលើកំណែទម្រង់គោលនយោបាយ បរិយាកាសអនុគ្រោះសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ក៏ដូចជាសហការជាមួយក្រសួងនានាដើម្បីជំរុញបរិយាកាសកាន់តែអនុគ្រោះ និងគ្រប់ជ្រុងជ្រោយសម្រាប់អនុផលព្រៃឈើ ក៏ដូចជាផ្តោតលើសង្វាក់តម្លៃសក្តានុពលមួយចំនួនបន្ថែមទៀតក្នុងពេលអនុវត្តគម្រោង។

20. ការវិភាគបង្ហាញថា សង្វាក់តម្លៃឫស្សី និងក្រវាញនៅ CMTS មានសក្តានុពលសម្រាប់ការអភិវឌ្ឍ និងការពង្រីកបន្ថែម។ សង្វាក់តម្លៃនីមួយៗនឹងទាមទារឲ្យមានយុទ្ធសាស្ត្រផ្សេងៗលើការអភិវឌ្ឍ និងគ្រប់គ្រង។ រដ្ឋាភិបាលកម្ពុជាទទួលបានជំនួយបច្ចេកទេសពីធនាគារពិភពលោក សម្រាប់ការវិភាគស៊ីជម្រៅពីសង្វាក់តម្លៃឫស្សី និងក្រវាញដើម្បីកំណត់រកឱកាសវិនិយោគ ការតភ្ជាប់ទីផ្សារ និងការអភិវឌ្ឍ ការកសាងសមត្ថភាព និងជំនាញអភិវឌ្ឍន៍សហគមន៍សំដៅពង្រឹង និងពង្រីកសង្វាក់តម្លៃឫស្សី និងក្រវាញ។

21. គម្រោងនឹងផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគខ្នាតតូចសម្រាប់សកម្មភាពដែលពាក់ព័ន្ធនឹងការប្រមូលផលដោយនិរន្តរភាព ប្រពលវប្បកម្ម ការកែច្នៃ និងការធ្វើទីផ្សារអនុផលព្រៃឈើក្នុងគោលបំណងពង្រីកឱកាសបរចិញ្ចឹមជីវិតសម្រាប់សហគមន៍មូលដ្ឋានក្នុងតំបន់ការពារសហគមន៍នៅតាមតំបន់ការពារគោលដៅ។ ក្រៅពីនេះ នឹងមានការផ្តល់ការគាំទ្រដល់ការពង្រីកឱកាសដល់វិស័យឯកជនក្នុងការជ្រើសរើសសង្វាក់តម្លៃ និងបង្កើនឱកាសរកប្រាក់ចំណូលសម្រាប់សហគមន៍ដែលចូលរួមក្នុងសង្វាក់តម្លៃ ក៏ដូចជាផ្សារភ្ជាប់នឹងឧស្សាហកម្មទេស

ចរណ៍ធម្មជាតិ។ ប្រភេទការវិនិយោគដែលត្រូវជំរុញ និងគាំទ្រ រួមមាន ការផ្តល់បរិក្ខារកែច្នៃ (ឧ. បរិក្ខារដើរដោយកម្លាំងដៃ) និងការអភិវឌ្ឍ ដូចជា ការស្តារហេដ្ឋារចនាសម្ព័ន្ធឡើងវិញ (ឧ. រោងចក្រកែច្នៃ និងស្តុកទុក) ដើម្បីបំពេញស្តង់ដារអនាម័យ និងសមស្របតាមគោលបំណង និងសម្ភារៈបរិក្ខារវេចខ្ចប់/បិទស្លាកសញ្ញា។

## សមាសភាគ ៣ ៖ បង្កើនលទ្ធភាព និងការតភ្ជាប់បណ្តាញ (ចំណាយប៉ាន់ស្មានសរុប ២៣,៨៦ លានដុល្លា ដែលត្រូវផ្តល់ហិរញ្ញប្បទានទាំងស្រុងដោយឥណទាន IDA)

22. តំបន់ជនបទនៅកម្ពុជាមិនសូវមានផ្លូវថ្នល់គ្រប់គ្រាន់ដែលប្រើប្រាស់បានគ្រប់រដូវកាល មានទំហំធំល្មម និងកាប៉ាស៊ីតេគ្រប់គ្រាន់ទេ និងមិនទាន់អាចបំពេញតម្រូវការកើនឡើងនៃមុខទំនិញ និងមធ្យោបាយធ្វើដំណើរនៅឡើយទេ។ ផ្លូវជនបទជាង ៨០% នៅកម្ពុជាគឺជាផ្លូវក្រាលថ្មបាយក្រៀម ឬគ្រួសក្រហម ដែលបង្កការលំបាកយ៉ាងច្រើននៅរដូវវស្សា ព្រោះផ្លូវខូចខាត និងពិបាកធ្វើដំណើរ បូករួមនឹងចំណាយខ្ពស់លើប្រតិបត្តិការ និងការគ្រប់គ្រង និងការលំបាកនៅរដូវប្រាំងដោយសារធូលីហុយ។

23. ការពង្រីកឱកាសទេសចរណ៍ធម្មជាតិនៅ CMTS ទាមទារឲ្យមានការបង្កើនហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ដើម្បីផ្តល់លទ្ធភាពដល់ការបង្កើនចំនួនភ្ញៀវទេសចរណ៍មកពីច្រកសំខាន់ៗ។ ការកែលម្អទាំងនេះមានគោលបំណងបង្កើនចំនួនភ្ញៀវទេសចរណ៍ប្រកបដោយនិរន្តរភាព និងកាត់បន្ថយការឡើងចុះចំនួនភ្ញៀវតាមរដូវកាលតាមរយៈការផ្តល់លទ្ធភាពចេញចូលគ្រប់រដូវកាល។ ការវិនិយោគជាក់លាក់អាចរួមមាន ការស្តារផ្លូវជនបទ និងហេដ្ឋារចនាសម្ព័ន្ធជនបទពាក់ព័ន្ធផ្សេងទៀតដើម្បីជួយដល់ការអភិវឌ្ឍច្រករបៀងទេសចរណ៍ធម្មជាតិ និងការតភ្ជាប់ជាមួយទីផ្សារសំខាន់ៗ។

24. តាមរយៈការបន្ថែមលទ្ធភាពចូលដល់ទីតាំងចុងក្រោយ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ភ្ញៀវទេសចរណ៍នឹងទទួលបានហេដ្ឋារចនាសម្ព័ន្ធសាធារណៈសំខាន់ៗ ដែលនឹងបង្កើនការពេញចិត្តរបស់ភ្ញៀវទេសចរណ៍។ បូករួមនឹងការដាក់ស្លាកសញ្ញាសម្គាល់ ចំណុចនេះនឹងជួយបង្កើតអារម្មណ៍ដក់ជាប់នឹងទីកន្លែង និងរួមបញ្ចូលទិសដៅទេសចរណ៍សាធារណៈដោយមិនគិតថ្លៃ។ គម្រោងនឹងផ្តល់ហិរញ្ញប្បទានដល់ការធ្វើទំនើបកម្ម និងស្តារផ្លូវជនបទមួយចំនួនឲ្យធន់គ្រប់រដូវកាល និងធន់នឹងអាកាសធាតុ ផ្លាកសញ្ញាតាមផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធអនាម័យខ្នាតតូច។ យើងនឹងប្រើប្រាស់ការរចនាផ្លូវថ្នល់ដែលមានប្រសិទ្ធភាពចំណាយ ហើយការកំណត់រកទីតាំងដែលអាចចេញចូលគ្រប់រដូវកាលពិតជាចាំបាច់សម្រាប់បណ្តាញផ្លូវសំខាន់ៗ ខណៈដែលបណ្តាញផ្លូវដែលមិនសូវសំខាន់នឹងត្រូវចាក់បេតុង (ទោះបីផ្លូវនោះនឹងត្រូវជន់លិចពីរបីសប្តាហ៍/ឆ្នាំ ប៉ុន្តែវានឹងមិនសឹករិចរិលឡើយ)។ ក្រៅពីនេះ មានការស្វែងរកឱកាសប្រើប្រាស់បណ្តាញផ្លូវជនបទដើម្បីពង្រឹងវិធានការគ្រប់គ្រងទឹកជំនន់តាមរយៈការពង្រីកបណ្តាញប្រឡាយបង្ហូរទឹក និងលូបង្ហូរទឹក និងអាចមានការលើកផ្លូវឲ្យខ្ពស់សម្រាប់

ប្រើប្រាស់ជាទំនប់។ ការរចនារឹងមាំផ្នែកវិស្វកម្ម ប្រព័ន្ធបង្ហូរទឹកគ្រប់គ្រាន់ និងអភិក្រមបៃតង នឹងត្រូវបានយកមកប្រើប្រាស់ដើម្បីបង្កើនភាពធន់នៃរចនាសម្ព័ន្ធផ្លូវថ្នល់ក្នុងទីតាំងអាទិភាពទាំងនេះ។

## សមាសភាគទី ៤ ៖ ការគ្រប់គ្រង ការសម្របសម្រួល ការពិនិត្យតាមដាន និងវាយតម្លៃគម្រោង (ចំណាយប៉ាន់ស្មានសរុប ៥,៧៦ លានដុល្លា។ ក្នុងនោះចំណាយ ៣,២៦ លានដុល្លានឹងទទួលបានហិរញ្ញប្បទានពីឥណទាន IDA)

25. ក្រសួងបរិស្ថាននឹងដើរតួនាទីជាទីភ្នាក់ងារអនុវត្តគម្រោងឈានមុខ សម្រាប់ការអនុវត្តសមាសភាគទាំង ៣ និងការគ្រប់គ្រង/សម្របសម្រួលគម្រោងរួម។ ក្រសួងនឹងសហការជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានតួនាទីជាទីភ្នាក់ងារអនុវត្តន៍ទទួលខុសត្រូវលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ជនបទ។ នឹងមានការផ្តល់ការគាំទ្រដល់ការបង្កើតអង្គភាពសម្របសម្រួល និងអនុវត្តគម្រោងដែលដឹកនាំដោយក្រសួងបរិស្ថាន។ គណៈកម្មាធិការដឹកនាំកម្រិតខ្ពស់មួយនឹងត្រូវបានបង្កើតឡើងដើម្បីផ្តល់ការណែនាំស្តីពី និងដោះស្រាយបញ្ហាអន្តរវិស័យដែលលេចឡើង។ ខ្លឹមសារលម្អិតមានបរិយាយក្នុងសៀវភៅណែនាំការអនុវត្តគម្រោង (PIM)។

26. សមាសភាគទី ៤ នឹងគាំទ្រដល់ការគ្រប់គ្រងគម្រោងជារួមតាមរយៈ ១) ការផ្តល់បុគ្គលិកកិច្ចសន្យាចាំបាច់ និងទីប្រឹក្សាក្នុងអង្គភាពសម្របសម្រួល និងអនុវត្តន៍ដើម្បីជួយដល់ក្រសួងបរិស្ថានក្នុងការគ្រប់គ្រងការអនុវត្តគម្រោង ២) ការពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តគម្រោង និង ៣) សេវាប្រឹក្សា និងពិគ្រោះយោបល់ដើម្បីជួយដល់ការអនុវត្តគម្រោង និងការកសាងសមត្ថភាពមន្ត្រីក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀត។

## សមាសភាគទី ៥ ៖ ការឆ្លើយតបនឹងគ្រោះអាសន្នយថាហេតុ (0 លានដុល្លា)

27. គោលបំណងនៃសមាសភាគនេះ គួបផ្សំនឹងការគ្មានការបែងចែកជាបណ្តោះអាសន្ន គឺដើម្បីផ្តល់លទ្ធភាពដល់ការបែងចែកហិរញ្ញប្បទានឡើងវិញដើម្បីផ្តល់ការឆ្លើយតបភ្លាមៗចំពោះវិបត្តិ ឬគ្រោះអាសន្នក្នុងករណីចាំបាច់។ សៀវភៅណែនាំស្តីពីការឆ្លើយតបនឹងគ្រោះអាសន្ន នឹងត្រូវបានរៀបរៀងឡើងសម្រាប់សកម្មភាពដែលស្ថិតក្រោមសមាសភាគនេះ ដោយលម្អិតពី FM លទ្ធកម្ម ការធានាសុវត្ថិភាព និងការអនុវត្តចាំបាច់ផ្សេងទៀត។ ក្នុងករណីដែលមានការបំផុសសមាសភាគនេះ ក្របខណ្ឌលទ្ធផលនឹងត្រូវបានកែសម្រួលតាមរយៈការផ្លាស់ប្តូររចនាសម្ព័ន្ធឡើងវិញជាផ្លូវការ ដើម្បីរួមបញ្ចូលសូចនាករសមស្របដែលពាក់ព័ន្ធនឹងសកម្មភាពឆ្លើយតបនឹងគ្រោះអាសន្ន។

# ការអនុវត្ត

## ការរៀបចំផ្នែកស្ថាប័ន និងការអនុវត្ត

28. **ការរៀបចំផ្នែកស្ថាប័ន ៖** គម្រោងនឹងត្រូវបានអនុវត្តរយៈពេល ៦ ឆ្នាំ។ ការរៀបចំផ្នែកស្ថាប័នសម្រាប់ការអនុវត្ត នឹងអនុវត្តតាមរចនាសម្ព័ន្ធស្ថាប័នរបស់រដ្ឋាភិបាល ដោយមានក្រសួងបរិស្ថានជាទីភ្នាក់ងារអនុវត្តគម្រោង ហើយក្រសួងអភិវឌ្ឍន៍ជនបទជាដៃគូអនុវត្តន៍សម្រាប់ការគាំទ្រហេដ្ឋារចនាសម្ព័ន្ធសាធារណៈពាក់ព័ន្ធក្រោមសមាសភាគទី ៣។ អនុស្សារណៈយោគយល់គ្នាជាមួយនាយកដ្ឋានមួយចំនួនចំណុះឲ្យក្រសួងទាំងពីរដែលទទួលខុសត្រូវលើការអនុវត្តសមាសភាគរង នឹងជានាភាពច្បាស់លាស់លើតួនាទី និងការទទួលខុសត្រូវ (មើលឧបសម្ព័ន្ធ ១, តារាង ៥)។ ទីភ្នាក់ងារអនុវត្តន៍គម្រោង និងដៃគូអនុវត្តន៍នឹងបង្កើតក្រុមអនុវត្តន៍គម្រោងរៀងៗខ្លួន (PITs) ដែលមានអ្នកជំនាញ និងឯកទេសមកពីនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានធានាសុវត្ថិភាពបរិស្ថាន និងសង្គម នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានលទ្ធកម្ម និងនាយកដ្ឋានហិរញ្ញវត្ថុ។ ទិសដៅ និងការណែនាំជាយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រង និងអនុវត្តគម្រោងជាសមត្ថកិច្ចរបស់គណៈកម្មាធិការដឹកនាំគម្រោងកម្រិតខ្ពស់ (PSC) ដែលមានក្រសួងបរិស្ថានជាប្រធាន។ តួនាទី ការទទួលខុសត្រូវ និងនីតិវិធីមានរៀបរាប់លម្អិតក្នុងសៀវភៅណែនាំការអនុវត្តគម្រោង (PIM)។

29. រដ្ឋាភិបាលថ្នាក់ក្រោមជាតិនឹងទទួលបានការគាំទ្រ និងជំរុញការចូលរួមតាមរយៈក្រសួងសាមីថ្នាក់ជាតិពោលគឺក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទ។ មន្ត្រីរបស់មន្ទីរពាក់ព័ន្ធនឹងផ្តល់ការសម្របសម្រួលនៅថ្នាក់ក្រោមជាតិ និងទទួលខុសត្រូវលើសកម្មភាពពិនិត្យតាមដានសំខាន់ៗតាមមូលដ្ឋាន។ ការគាំទ្រលើកិច្ចការបច្ចេកទេសជាសមត្ថកិច្ចរបស់ក្រុមគម្រោងពាក់ព័ន្ធក្នុងក្រសួងទាំងពីរ។ ការវិនិយោគគម្រោងនឹងមិនផ្តោតដោយផ្ទាល់លើស្ថាប័ន ឬអាជ្ញាធរថ្នាក់ក្រោមជាតិណាមួយឡើយ។ ក្នុងករណីដែល និងប្រសិនបើចាំបាច់ស្ថាប័ន និងអាជ្ញាធរទាំងនេះនឹងទទួលបានការគាំទ្រតាមរយៈជំនួយបច្ចេកទេស/ការកសាងសមត្ថភាពដើម្បីសម្រួល និងពង្រឹងការអនុវត្តគម្រោងយ៉ាងរលូន។

30. **ការិយាល័យសម្របសម្រួលគម្រោង (PCO) ៖ ក្រុម**អនុវត្តន៍គម្រោង (PIT) នឹងទទួលខុសត្រូវលើការសម្របសម្រួលការអនុវត្តគម្រោងជារួម ទំនាក់ទំនងខាងក្រៅ ដូចជា ការរាយការណ៍ទៅធនាគារពិភពលោក។ PCO នឹងដឹកនាំដោយអ្នកសម្របសម្រួលម្នាក់មកពីក្រសួងបរិស្ថាន ដោយមានមន្ត្រីជាន់ខ្ពស់មកពីក្រសួងអភិវឌ្ឍន៍ជនបទជាសមាជិកក្រុម។ PCO មានសមាសភាគសមាជិកមកពីអង្គភាពបច្ចេកទេសសំខាន់ៗ

ដែលពាក់ព័ន្ធក្នុងការអនុវត្តគម្រោង ដូចជា មន្ត្រីជាន់ខ្ពស់ដែលទទួលខុសត្រូវលើការគ្រប់គ្រងហិរញ្ញវត្ថុ លទ្ធកម្ម ការពិនិត្យតាមដាន និងវាយតម្លៃ និងទំនាក់ទំនង។ ទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យាអាចបំពេញការខ្វះខាតសមត្ថភាពក្នុងក្រុមនេះបានទៅតាមភាពចាំបាច់។ PCO នឹងស្ថិតក្នុងក្រសួងបរិស្ថាន ប៉ុន្តែនៅពេលដែលគម្រោងត្រូវបានអនុវត្តដោយរចនាសម្ព័ន្ធរដ្ឋាភិបាលមានស្រាប់ (ក្រសួងទាំងពីរ) ដូចជា នាយកដ្ឋានសាមីរបស់ទីភ្នាក់ងារអនុវត្តន៍គម្រោង និងទីភ្នាក់ងារអនុវត្តន៍ ចំនួនបុគ្គលិករបស់ PCO នឹងមានចំនួនកំណត់ ប៉ុន្តែពួកគេមានប្រសិទ្ធភាព និងប្រសិទ្ធផល។ PCO នឹងបំពេញការងារក្រោមការណែនាំផ្ទាល់របស់ប្រធានគម្រោងដែលជ្រើសតាំងដោយក្រសួងបរិស្ថាន។

## ៣.ក្របខណ្ឌច្បាប់ជាតិ និងគោលនយោបាយធានាសុវត្ថិភាពរបស់ធនាគារពិភពលោក

ផ្នែកនេះរៀបរាប់ពីលក្ខខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមនៅកម្ពុជា និងគោលនយោបាយធានាសុវត្ថិភាពរបស់ធនាគារពិភពលោកសម្រាប់គម្រោង និងអនុគម្រោង និងការវិភាគចំណុចខុសគ្នារវាងលក្ខខណ្ឌរបស់រដ្ឋាភិបាល និងលក្ខខណ្ឌគោលនយោបាយរបស់ធនាគារពិភពលោក និងវិធានការលុបបំបាត់ចំណុចខុសគ្នាទាំងនោះ។

### ៣.១ ច្បាប់ជាតិ និងលិខិតុបករណ៍ច្បាប់

ផ្នែកនេះរៀបរាប់ពីច្បាប់ជាតិ ក្រឹត្យ សារាចរណ៍ សេចក្តីសម្រេច និងលិខិតុបករណ៍ច្បាប់ និងស្តង់ដារបច្ចេកទេសពាក់ព័ន្ធនឹងគម្រោង។ អ្វីដែលសំខាន់នោះគឺផ្នែកនេះបរិយាយពីលិខិតុបករណ៍ច្បាប់ស្តីពីសង្គម និងបរិស្ថានតាមវិស័យ (ឧ. ថាមពល ជនបទ សំណង់ សុខភាព...) ដែលពាក់ព័ន្ធនឹងគម្រោងនេះ។

ជារួម ការគ្រប់គ្រងបរិស្ថានស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួងបរិស្ថាន ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៣។ ក្រសួងទទួលខុសត្រូវលើការអនុវត្តច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។ នៅថ្នាក់រដ្ឋធានី និងថ្នាក់ខេត្ត ក្រសួងមានមន្ទីរបរិស្ថានដើរតួនាទីជាស្ថាប័នក្រោមឱវាទ។ មន្ទីរបរិស្ថានទទួលខុសត្រូវលើការពង្រឹងការអនុវត្តច្បាប់ស្តីពីបរិស្ថានក្រោមយុត្តាធិការរបស់ក្រសួងបរិស្ថាន ប៉ុន្តែប្រតិបត្តិការប្រចាំថ្ងៃរបស់មន្ទីរទាំងនេះស្ថិតក្រោមការត្រួតពិនិត្យផ្ទាល់របស់អាជ្ញាធរខេត្ត។

ក្របខណ្ឌច្បាប់តម្រូវឲ្យមានការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានបឋម (IEIA) ឬការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន (EIA) ដោយផ្អែកលើប្រភេទ និងសកម្មភាព និងទីតាំងរបស់គម្រោង (អនុក្រឹត្យស្តីពីការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន ឬដំណើរការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន ៖ មាត្រា ១ និង ២ នៃអនុក្រឹត្យស្តីពីការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានបឋម ឬដំណើរការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន) ដែលត្រូវធ្វើឡើងសម្រាប់គម្រោងឯកជន និងសាធារណៈទាំងអស់ និងត្រូវពិនិត្យឡើងវិញដោយ

ក្រសួងបរិស្ថាន មុនពេលដាក់ជូនរដ្ឋាភិបាលសម្រេច។ រាល់សកម្មភាពដែលស្នើឡើង និងសកម្មភាពមានស្រាប់ត្រូវបំពេញលក្ខខណ្ឌទាំងនេះ។ ប្រកាសស្តីពីការណែនាំទូទៅ លេខ ៣៧៦ ស្តីពីអនុក្រឹត្យស្តីពីដំណើរការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានបឋម/ពេញលេញ ត្រូវបានចុះហត្ថលេខា និងអនុម័តឲ្យចូលជាធរមានដោយក្រសួងបរិស្ថាននៅថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០០៨។ ការណែនាំនេះមានគោលបំណងអនុវត្តការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានបឋម (IEIA) ការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន (EIA) និងផ្តល់ការណែនាំទូទៅ និងតារាងផ្ទៀងផ្ទាត់។ គម្រោងទាំងអស់សុទ្ធតែតម្រូវឲ្យមានការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានបឋម ឬការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានដោយផ្អែកលើប្រភេទ និងសកម្មភាព និងទីតាំងគម្រោង (មាត្រា ១ និង ២ នៃអនុក្រឹត្យស្តីពីការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានបឋម ឬដំណើរការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន)។ ក្រសួងបរិស្ថានទទួលខុសត្រូវលើការពិនិត្យឡើងវិញលើរបាយការណ៍វាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន ពិនិត្យតាមដាន និងត្រួតពិនិត្យបន្ត។

### ៣.១.១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រមចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ និងត្រូវបានធ្វើវិសោធនកម្ម ៧ លើក (លើកទី ១ ៖ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៤, លើកទី ២ ៖ ប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នសរកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩, លើកទី ៣ ៖ ប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នសរកម/០៧០១/១១ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០១, លើកទី ៤ ៖ ប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នសរកម/០៦០៥/០១៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៥, លើកទី ៥ ៖ រដ្ឋធម្មនុញ្ញបំពេញបន្ថែមដែលប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នសរកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤, លើកទី ៦ ៖ ប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នសរកម/០៣០៦/០០៦ ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០០៦, លើកទី ៧ ៖ ប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នសរកម/០២០៨/០០៨ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៨)។

**មាត្រា ៥៨**

ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងទៀតដែលបានកំណត់ថាជារបស់រដ្ឋ។ ការគ្រប់គ្រងការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋនឹងត្រូវកំណត់ក្នុងច្បាប់។

**មាត្រា ៥៩**

រដ្ឋត្រូវរក្សាការពារបរិស្ថាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឲ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រងមានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភោគោគ្គសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល។

**មាត្រា ៦១**

រដ្ឋជំរុញការអភិវឌ្ឍសេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ចាប់ពីតំបន់ដាច់ស្រយាល ដោយយកចិត្តទុកដាក់ទៅលើនយោបាយទឹក ភ្លើង ផ្លូវ និងមធ្យោបាយដឹកជញ្ជូន បច្ចេកទេសទំនើប និងប្រព័ន្ធឥណទាន។

## ៣.១.២ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ត្រូវបានអនុម័តដោយរដ្ឋសភា និងប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នសរកម ១២៩៦/៣៦។ ច្បាប់នេះត្រូវបានអនុម័តនៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦។ ច្បាប់នេះមានគោលដៅ ៖

១. ការពារ លើកកម្ពស់គុណភាពបរិស្ថាន និងសុខភាពពលរដ្ឋដោយធ្វើការទប់ស្កាត់ ការកាត់បន្ថយ និងការត្រួតពិនិត្យការបំពុល

២. វាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន មុននឹងចេញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលចំពោះរាល់គម្រោងដែលបានស្នើឡើង

៣. ធានាឲ្យមានការអភិរក្ស ការអភិវឌ្ឍ ការគ្រប់គ្រង និងការប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា

៤. លើកទឹកចិត្ត និងផ្តល់លទ្ធភាពឲ្យសាធារណជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

៥. បង្ក្រាបអំពើទាំងឡាយណាដែលធ្វើឲ្យប៉ះពាល់ដល់បរិស្ថាន។

ក្រោមច្បាប់នេះ អ្នកអភិវឌ្ឍន៍ ឬម្ចាស់គម្រោង ត្រូវរៀបចំរបាយការណ៍ IEIA ឬ EIA សម្រាប់គម្រោងអភិវឌ្ឍន៍ដែលស្នើឡើង ឬមានស្រាប់។

## ៣.១.៣ ច្បាប់ស្តីពីព្រៃឈើ (២០០២)

ច្បាប់ស្តីពីព្រៃឈើ ត្រូវបានប្រកាសឲ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រមលេខ នសរកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២។

## មាត្រា ១

ច្បាប់នេះកំណត់អំពីក្របខណ្ឌនៃការគ្រប់គ្រង ការប្រមូលផល ការប្រើប្រាស់ ការធ្វើអាជីវកម្ម ការអភិវឌ្ឍ និងការអភិរក្សព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គោលបំណងនៃច្បាប់នេះគឺធានានូវការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវៈចម្រុះ និងមរតកវប្បធម៌។

## មាត្រា ២

ច្បាប់នេះមានវិសាលភាពអនុវត្តលើរាល់ព្រៃឈើទាំងអស់ ទោះជាប្រភេទនៃព្រៃនោះកើតឡើងដោយធម្មជាតិក្តី ឬដោយដាំក្តី។ រដ្ឋធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីនូវផល អនុផលព្រៃឈើរបស់សហគមន៍មូលដ្ឋាន ក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ឬច្បាប់ពាក់ព័ន្ធផ្សេងទៀត។

## មាត្រា ៣

ការគ្រប់គ្រងព្រៃឈើត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការគ្រប់គ្រងព្រៃលិចទឹក ស្ថិតនៅក្រោមច្បាប់មួយដោយឡែក។ រដ្ឋផ្តល់សិទ្ធិគ្រប់គ្រងតំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថាន ក្រោមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ព្រះរាជក្រឹត្យស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ និងលិខិតបទដ្ឋានច្បាប់ផ្សេងទៀត។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិសហការធ្វើសកម្មភាពពង្រឹងការអនុវត្តច្បាប់ ចំពោះរាល់បទល្មើសព្រៃឈើ ដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិក្រោមការសម្របសម្រួលជាមួយក្រសួងបរិស្ថានស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី ១៤ នៃច្បាប់នេះ។ សកម្មភាពនេះនឹងមិនធ្វើឲ្យប៉ះពាល់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឡើយ។

## មាត្រា ៤

ក្នុងការអនុវត្តច្បាប់នេះ រាល់ការសម្រេចរបស់រាជរដ្ឋាភិបាលដែលមានសក្តានុភាពចំពោះផលប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រជាពលរដ្ឋទូទៅ លើជីវភាពសហគមន៍មូលដ្ឋាន និងលើធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការចូលរួមជាសាធារណៈ។ សកម្មភាពចម្បងៗពាក់ព័ន្ធនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើដែលអាចបណ្តាលឲ្យមានផលប៉ះពាល់អាក្រក់ដល់សង្គម និងបរិស្ថាន ចាំបាច់ត្រូវមានការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ដោយផ្អែកតាមក្រមបច្ចេកទេសគ្រប់គ្រងព្រៃឈើកម្ពុជា និងស្របតាមច្បាប់ស្តី

ពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។ ឯកសារនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ត្រូវផ្តល់ជូនសម្រាប់ការចូលរួមផ្តល់មតិជាសាធារណៈបាន។ រាល់ការសម្រេចចុងក្រោយលើរាល់សកម្មភាពចម្បងៗ ពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ រាជរដ្ឋាភិបាលត្រូវពិចារណាលើអនុសាសន៍ចុងក្រោយនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម។ ការសម្រេចចុងក្រោយណាមួយក្រោមមាត្រានេះ រាជរដ្ឋាភិបាលអាចធ្វើការជូនដំណឹងជាសាធារណៈ។

## មាត្រា ៣១

ការឈូសឆាយដីព្រៃក្នុងគោលបំណងស្ថាបនាផ្លូវសាធារណៈ ក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបានហាមឃាត់លើកលែងតែមានការសម្រេចពីរដ្ឋាភិបាលតាមសំណើរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការឈូសឆាយដីព្រៃក្នុងគោលបំណងស្ថាបនាផ្លូវព្រៃក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបានហាមឃាត់លើកលែងតែមានការសម្រេចពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ។ រាល់គម្រោងស្ថាបនាផ្លូវសាធារណៈ ឬផ្លូវព្រៃក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវមានការពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន និងការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ស្របតាមមាត្រា ៤ នៃច្បាប់នេះ។ ការដាក់តាំងដែនដម្រុកថ្មីតាមដងផ្លូវសាធារណៈ ឬផ្លូវព្រៃក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបានហាមឃាត់លើកលែងតែមានការអនុញ្ញាតពីរដ្ឋាភិបាល។

## មាត្រា ៣៥

បន្ថែមលើច្បាប់ដទៃទៀតដែលពាក់ព័ន្ធនឹងការយកថ្ម ដី ខ្សាច់ រ៉ែ និងធនធានធម្មជាតិដទៃទៀតដែលត្រូវអនុវត្តក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវមានការសិក្សាវាយតម្លៃជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល ដោយត្រូវអនុវត្តតាមមាត្រា ៤ នៃច្បាប់នេះ។

ការអនុញ្ញាតនេះត្រូវកម្រិតផងដែរនូវវិធានការការពារ និងស្តារឡើងវិញនៅទីកន្លែងគាស់កកាយយកថ្ម ដី ខ្សាច់ រ៉ែ និងធនធានធម្មជាតិដទៃទៀតដែលអ្នកទទួលសិទ្ធិត្រូវទទួលបន្ទុក ដើម្បីៈ

១. ចៀសវាងបង្ក ឬធ្វើឲ្យធ្ងន់ធ្ងរដល់ការហូរចេញច្រោះ បាក់ដី ឬធ្វើឲ្យខូចខាតដល់ការលូតលាស់របស់រុក្ខជាតិ ឬធ្វើឲ្យខូចខាតដល់ប្រព័ន្ធជលសាស្ត្រ និងគុណភាពទឹក។

២. រៀបចំស្តារទីតាំងនោះឲ្យមានសភាពដូចដើមវិញ ក្រោយពេលបញ្ចប់កិច្ចការគាស់កកាយយកថ្ម ដី ខ្សាច់ រ៉ែ និងធនធានធម្មជាតិដទៃទៀតក្នុងរយៈពេលដែលលិខិតអនុញ្ញាតបានកំណត់។

មាត្រា ៥៤

រាល់ផល អនុផលព្រៃឈើត្រូវវាយតម្លៃដោយមន្ត្រីរដ្ឋបាលព្រៃឈើលើបរិមាណ និងគុណភាពនៅគំនរក្នុងព្រៃគុបប្រចាំឆ្នាំមុនពេលដឹកចេញពីព្រៃ។ គុណភាព និងបរិមាណនៃផល អនុផលព្រៃឈើដែលបានវាយតម្លៃរួច ត្រូវចុះក្នុងកំណត់ហេតុបញ្ជីសៀវភៅ ក ដោយមានការឯកភាពពីប្រធានរដ្ឋបាលព្រៃឈើ។

មាត្រា ៥៥

រាល់ផល អនុផលព្រៃឈើដែលបានចុះក្នុងកំណត់ហេតុបញ្ជីសៀវភៅ ក ត្រូវបង់ប្រាក់ថ្លៃសួយសារ និងបុព្វលាភ។ វិធាននៃការបង់ និងទទួលប្រាក់ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៣.១.៤ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ (១៩៩៦)

ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ត្រូវបានអនុម័ត និងប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី ២៥ ខែមករា ឆ្នាំ ១៩៩៦ ។ មាត្រាមួយចំនួនដែលពាក់ព័ន្ធនឹងរបាយការណ៍នេះ រួមមាន ៖

មាត្រា ១

ច្បាប់នេះមានគោលដៅថែរក្សាការពារបេតិកភណ្ឌវប្បធម៌ជាតិ និងសម្បត្តិវប្បធម៌ទូទៅប្រឆាំងនឹងការបំផ្លិចបំផ្លាញ ការប្រែក្លាយ ការប្តូររូបរាង ការជីករុករក ការផ្ទេរកម្មសិទ្ធិ ការនាំចេញ និងការនាំចូលដោយខុសច្បាប់។

មាត្រា ២

បេតិកភណ្ឌវប្បធម៌ជាតិគឺជាសម្បត្តិវប្បធម៌ដែលត្រូវបានបង្កើតឡើង ឬក៏បានរកឃើញនៅក្នុងទឹកដីនៃមាតុភូមិ។

មាត្រា ៣

ច្បាប់នេះអនុវត្តទៅលើសម្បត្តិវប្បធម៌ជាចលនៈ និងអចលនៈ ទោះជាកម្មសិទ្ធិសាធារណៈក្តី ឬក៏ជាឯកជនក្តី ហើយកិច្ចការពារនេះគឺជាផលប្រយោជន៍សាធារណៈ។ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីច្បាប់នេះ ច្បាប់នេះអនុវត្តទៅលើសម្បត្តិវប្បធម៌ដែលជាចំណែកនៃបេតិកភណ្ឌវប្បធម៌ជាតិតែប៉ុណ្ណោះ។

មាត្រា ៤

តាមន័យនៃច្បាប់នេះ សម្បត្តិវប្បធម៌គឺរាល់ស្នាដៃរបស់មនុស្ស និងរាល់ផលិតផលរបស់ធម្មជាតិ ដែលមានចរិតវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈ ឬសាសនា ដែលឆ្លុះបញ្ចាំងពីដំណាក់កាលនៃការវិវត្តន៍របស់អារ្យធម៌ ឬរបស់ធម្មជាតិ ហើយដែលកិច្ចការពារសម្បត្តិវប្បធម៌ទាំងនោះ បម្រើផលប្រយោជន៍សាធារណៈ។

## មាត្រា ៣៧

នៅពេលកំពុងដំណើរការងារផ្សេងៗ ឬសកម្មភាពផ្សេងៗទៀត ហើយបានជួបប្រទះសម្បត្តិវប្បធម៌ ដូចជា ប្រាសាទបាក់បែក វត្ថុបុរាណ សំណល់ផ្ទះសម្បែងបុរាណ ទីបញ្ចុះសពបុរាណ សិលាចារឹក ឬសម្បត្តិវប្បធម៌ដែលទាក់ទងដល់បុរេប្រវត្តិវិទ្យា បុរាណវិទ្យា ជាតិពន្ធុវិទ្យា បាសាណីភូតវិទ្យា ឬក៏សាខាដទៃទៀតនៃវិទ្យាសាស្ត្រដែលសិក្សាពីអតីតកាល ឬមនុស្សសាស្ត្រ អ្នកដែលបានប្រទះឃើញសម្បត្តិទាំងនេះ និងម្ចាស់អចលនវត្ថុ ត្រូវតែបញ្ឈប់ការងារ ឬសកម្មភាពនោះ រួចរាយការណ៍ជាបន្ទាន់ជូនភ្នាក់ងារនគរបាលក្នុងតំបន់។ ភ្នាក់ងារនគរបាលនោះត្រូវបញ្ជូនរបាយការណ៍នេះយ៉ាងប្រញាប់ជូនទៅអភិបាលខេត្ត ក្រុង។ អភិបាលខេត្ត ក្រុង ត្រូវជូនព័ត៌មាននេះដល់អាជ្ញាធរមានសមត្ថកិច្ចដើម្បីចាត់វិធានការចាំបាច់ដើម្បីធានាសង្គ្រោះសម្បត្តិវប្បធម៌ និងរមណីយដ្ឋានវប្បធម៌នោះ។

## មាត្រា ៣៩

សម្បត្តិវប្បធម៌ជាចលនវត្ថុដែលប្រទះឃើញដោយចៃដន្យ ត្រូវចាត់ទុកជាសម្បត្តិសាធារណៈ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវផ្តល់រង្វាន់លើកទឹកចិត្តដល់អ្នកប្រទះឃើញ ដោយចៃដន្យ ដោយកំណត់តាមការស្រុះស្រួលគ្នា ឬតាមការវាយតម្លៃរបស់អ្នកជំនាញ ក្នុងរយៈពេល ៣ សប្តាហ៍ក្រោយពីបានរកឃើញ។

# ផ្នែកទី ៨ ៖ ការជីករុករកវត្ថុបុរាណ

## មាត្រា ៤០

គ្មានជនណាមួយអាចធ្វើការជីករុករក ឬធ្វើការវាស់ស្ទង់លើដី ឬក្រោមដី ក្នុងគោលបំណងស្រាវជ្រាវរកសម្បត្តិវប្បធម៌ដែលមានប្រយោជន៍ដល់ការសិក្សាខាងបុរេប្រវត្តិវិទ្យា ប្រវត្តិវិទ្យា បុរាណវិទ្យា ជាតិពន្ធុវិទ្យា បាសាណីភូតវិទ្យា ឬសាខានៃវិទ្យាសាស្ត្រផ្សេងៗ ដែលសិក្សាពីអតីតកាល ឬទាក់ទងដល់មនុស្សសាស្ត្រដោយមិនបានទទួលច្បាប់អនុញ្ញាតជាមុនពីសមត្ថកិច្ចឡើយ។

## មាត្រា ៤៦

អាជ្ញាធរមានសមត្ថកិច្ច អាចអនុញ្ញាតឲ្យធ្វើការជីករុករកនៅលើដីជាកម្មសិទ្ធិឯកជន បន្ទាប់ពីបានជូនដំណឹងជាមុនដល់ម្ចាស់កម្មសិទ្ធិ។ អ្នកជីករុករកត្រូវធ្វើបញ្ជីសារពើភណ្ឌទឹកដីដែលនឹងជីករុករកនោះ ហើយលុះត្រាតែបានទទួលការស្រុះស្រួលពីភាគីទាំងអស់ ទើបអាចចាប់ផ្តើមធ្វើការងាររបស់ខ្លួនបាន។ អ្នកជីករុករកបុរាណវត្ថុត្រូវធ្វើការងារនេះក្នុងរយៈពេលពីរឆ្នាំ ហើយនឹងអាចបន្តទៅទៀតបានក្រោយរយៈពេលពីរឆ្នាំនេះ។

## មាត្រា ៤៧

ម្ចាស់កម្មសិទ្ធិ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤៦ មានសិទ្ធិនឹងកាន់កាប់ដីឡើងវិញ និងទទួលបាននូវប្រាក់បំណាច់ចំពោះការខកខានពុំបានស្នាក់អាស្រ័យនៅប្រកបមុខរបរ និងចំពោះការបង់ខាតបង់ ឬខូចខាតផ្សេងៗទៀតដោយថាហេតុ។

## ៣.១.៥ ច្បាប់ស្ដីពីផ្លូវថ្នល់ (២០០៦)

ច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ត្រូវបានប្រកាសឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៤។ មាត្រាមួយចំនួនដែលពាក់ព័ន្ធនឹងរបាយការណ៍នេះរួមមាន ៖

**មាត្រា ១**

ច្បាប់នេះមានគោលបំណងគ្រប់គ្រង អភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងធានាសុវត្ថិភាពចរាចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២**

ច្បាប់នេះមានគោលបំណងដូចតទៅ ៖

១. ការពារទ្រព្យសម្បត្តិសាធារណៈ ការពារ និងលើកកម្ពស់គុណភាពផ្លូវថ្នល់ រក្សាសណ្ដាប់ធ្នាប់ សម្រួលការធ្វើដំណើរ និងការដឹកជញ្ជូនតាមផ្លូវគោក

២. កំណត់គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍សម្រាប់សាងសង់ ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ព្រមទាំងកំណត់វិធាន និងបទប្បញ្ញត្តិបច្ចេកទេស

៣. ជំរុញ និងលើកទឹកចិត្តឲ្យវិស័យឯកជនចូលរួមក្នុងការសាងសង់ ការជួសជុល ការថែទាំ និងការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់

៤. ជំរុញកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មជាតិតំបន់ អនុតំបន់ និងអន្តរជាតិលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់

៥. លើកទឹកចិត្តចំពោះការសិក្សាស្រាវជ្រាវបច្ចេកទេស និងការផ្ទេរបច្ចេកវិទ្យាថ្មីៗ ដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា

៦. អភិវឌ្ឍធនធានមនុស្សក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣**

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាពពាក់ព័ន្ធនឹងវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២៤**

អ្នកប្រើប្រាស់ផ្លូវថ្នល់ និងអ្នកជាក់ពាក់ព័ន្ធនឹងផ្លូវថ្នល់ទាំងអស់ ត្រូវគោរពតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក។ ច្បាប់នេះត្រូវមានអាទិភាព ក្នុងករណីដែលបទប្បញ្ញត្តិនៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោកមិនស្របគ្នានឹងបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា ២៥**

អ្នកប្រើប្រាស់យានយន្តដឹកជញ្ជូនលើផ្លូវថ្នល់ត្រូវអនុវត្តតាមការកំណត់អំពីការផ្ទុកទម្ងន់ ដូចមានចែងក្នុងមាត្រា ២៦ នៃច្បាប់នេះ និងត្រូវចូលត្រួតពិនិត្យថ្លឹងទម្ងន់នៅស្ថានីយថ្លឹងយានយន្តដែលស្ថិតនៅតាមបណ្ដាញផ្លូវថ្នល់នីមួយៗ ព្រមទាំងគោរពតាមបទដ្ឋានបច្ចេកទេស ទំហំផ្លូវកម្រិតកំណត់។

បទដ្ឋានបច្ចេកទេសទំហំកម្រិតកំណត់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ។

**មាត្រា ២៦**

ទម្ងន់ដឹកជញ្ជូនអតិបរមាលើបណ្តាញផ្លូវថ្នល់ មានដូចតទៅ ៖

១.លើផ្លូវល្បឿនលឿន ផ្លូវជាតិ ផ្លូវខេត្ត ផ្លូវរាជធានី ផ្លូវក្រុង ផ្លូវទីប្រជុំជននានាក្នុងខេត្ត និងផ្លូវជនបទ ត្រូវអនុវត្តដូចខាងក្រោម ៖

ក. ការកម្រិតទម្ងន់អតិបរមាសង្កត់លើភ្លៅរថយន្ត រ៉ឺម៉ក ឬសឺមីរ៉ឺម៉កត្រូវកំណត់ត្រឹម ៖

- ៦ (ប្រាំមួយ) តោន សម្រាប់ភ្លៅទោលដែលមានកង់ ២ (ពីរ) ស្ថិតនៅលើផ្នែកចង្កូតរថយន្ត
- ១១ (ដប់មួយ) តោន សម្រាប់ភ្លៅភ្លោះដែលមានកង់ ៤ (បួន) ស្ថិតនៅលើផ្នែកចង្កូតរថយន្ត
- ១០ (ដប់) តោនសម្រាប់ភ្លៅទោលដែលមានកង់ ៤ (បួន)
- ១៩ (ដប់ប្រាំបួន) តោនសម្រាប់ភ្លៅភ្លោះដែលមានកង់ ៨ (ប្រាំបី)
- ២៤ (ម្ភៃបួន) សម្រាប់ភ្លៅបីជិតគ្នាដែលមានកង់ ១២ (ដប់ពីរ)។

ខ. ការកម្រិតទម្ងន់សរុបអនុញ្ញាតអតិបរមារបស់រថយន្តត្រូវកំណត់ត្រឹម ៖

- ១៦ (ដប់ប្រាំមួយ) តោនសម្រាប់រថយន្តដែលមានភ្លៅ ២ (ពីរ) គឺភ្លៅទោលផ្នែកខាងមុខរថយន្តដែលមានកង់ ២ (ពីរ) និងភ្លៅទោលផ្នែកខាងក្រោមរថយន្តដែលមានកង់ ៤ (បួន)
- ២៥ (ម្ភៃប្រាំ) តោន សម្រាប់រថយន្តដែលមានភ្លៅ ៣ (បី) គឺភ្លៅទោលផ្នែកខាងមុខរថយន្តដែលមានកង់ ២ (ពីរ) និងភ្លៅភ្លោះផ្នែកខាងក្រោយរថយន្តដែលមានកង់ ៨ (ប្រាំបី)
- ៣០ (សាមសិប) តោនសម្រាប់រថយន្តដែលមានភ្លៅ ៤ (បួន) គឺភ្លៅភ្លោះផ្នែកខាងមុខរថយន្តដែលមានកង់ ៤ (បួន) និងភ្លៅភ្លោះផ្នែកខាងក្រោយរថយន្តដែលមានកង់ ៨ (ប្រាំបី)។

គ. ការកម្រិតទម្ងន់សរុបអនុញ្ញាតអតិបរមារបស់រថយន្តសណ្តោងរ៉ឺម៉កត្រូវកំណត់ត្រឹម ៖

- ៣៥ (សាមសិបប្រាំ) តោន សម្រាប់រថយន្តសណ្តោងរ៉ឺម៉កដែលមានភ្លៅ ៤ (បួន) គឺភ្លៅទោលផ្នែកខាងមុខរថយន្តដែលមានកង់ ២ (ពីរ) ភ្លៅទោលផ្នែកខាងក្រោយរថយន្តដែលមានកង់ ៤ (បួន) និងភ្លៅទោលផ្នែកខាងក្រោយរ៉ឺម៉កដែលមានកង់ ៥ (ប្រាំ)
- ៤០ (សែសិប) តោនសម្រាប់រថយន្តសណ្តោងរ៉ឺម៉កដែលមានភ្លៅចាប់ពី ៥ (ប្រាំ) ឡើងទៅ។

ឃ. ការកម្រិតទម្ងន់សរុបអនុញ្ញាតអតិបរមារបស់រថយន្តសណ្តោងសឺមីរ៉ឺម៉កត្រូវកំណត់ត្រឹម ៖

- ៣៥ (សាមសិបប្រាំ) តោន សម្រាប់រថយន្តសណ្តោងសឺមីរ៉ឺម៉កដែលមានភ្លៅ ៤ (បួន) គឺភ្លៅទោលផ្នែកខាងមុខរថយន្តដែលមានកង់ ២ (ពីរ) ភ្លៅទោលផ្នែកខាងក្រោយរថយន្តដែលមានកង់ ៤ (បួន) និងភ្លៅភ្លោះផ្នែកខាងក្រោយសឺមីរ៉ឺម៉កដែលមានកង់ ៨ (ប្រាំបី)
- ៤០ (សែសិប) តោនសម្រាប់រថយន្តសណ្តោងសឺមីរ៉ឺម៉កដែលមានភ្លៅ ៥ (ប្រាំ)។

ចំពោះទម្ងន់រថយន្ត និងរថយន្តសណ្តោងរ៉ឺម៉ក ឬសឺមីរ៉ឺម៉ក ដែលគ្មានចែងនៅក្នុងចំណុចខាងលើនេះ ត្រូវសុំលិខិតអនុញ្ញាតពិសេសពីសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់។

២.រាល់ទម្ងន់សង្កត់លើអ័ក្សភ្លៅរថយន្តដូចមានចែងក្នុងចំណុចទី ១ ខាងលើ ត្រូវមានសម្ពាធទៅលើផ្ទៃថ្នល់មិនលើសពី ៥ (ប្រាំ) គក្រ/សម២។

## មាត្រា ២៧

អ្នកប្រើប្រាស់ផ្លូវថ្នល់ក្នុងពេលទៅដល់កំពង់ចម្លង ឬផ្លូវឡើងចំណោតខ្ពស់ ឬផ្លូវតម្រូវឲ្យមានការប្រុងប្រយ័ត្នខ្ពស់ ត្រូវគោរពតាមការបញ្ជារបស់ភ្នាក់ងារកំពង់ចម្លង ឬភ្នាក់ងារសុវត្ថិភាពដែលប្រចាំការនៅតាមគោលដៅ។ បទបញ្ជានៃការប្រើប្រាស់កំពង់ចម្លង និងការប្រើប្រាស់ផ្លូវឡើងចំណោតខ្ពស់ ឬផ្លូវតម្រូវឲ្យមានការប្រុងប្រយ័ត្នខ្ពស់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ។

## មាត្រា ២៨

ការរៀបចំចាត់ចែងសកម្មភាពនានា ដូចជា សកម្មភាពវប្បធម៌ កីឡា ការតាំងពិពណ៌ និងពិធីបុណ្យផ្សេងទៀតនៅលើដងផ្លូវថ្នល់ ត្រូវប្រតិបត្តិតាមការណែនាំដូចខាងក្រោម ៖

១. អ្នករៀបចំត្រូវលើកសំណើសុំប្រើប្រាស់ផ្លូវថ្នល់ ដោយភ្ជាប់ជាមួយនូវគម្រោងការពារសុវត្ថិភាពចរាចរណ៍ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ សកម្មភាពនេះអាចប្រព្រឹត្តទៅបានក្រោយពេលទទួលបានការអនុញ្ញាតពីរដ្ឋបាលថ្នាក់ក្រោមជាតិតាមលំដាប់ថ្នាក់ទៅតាមកម្រិតនៃពិធី និងភាពចាំបាច់។

២. រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្សព្វផ្សាយព័ត៌មានអំពីគម្រោងបិទផ្លូវថ្នល់ឲ្យបានទាន់ពេលវេលា ព្រមទាំងចាត់វិធានការការពារសណ្តាប់ធ្នាប់ និងសុវត្ថិភាពចរាចរណ៍ឲ្យបានត្រឹមត្រូវ។

៣. រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវចូលរួមសហការជាមួយអ្នករៀបចំ ដើម្បីធ្វើការចាត់ចែងកិច្ចការបន្ទាន់ និងធានាសុវត្ថិភាពចរាចរណ៍។

បែបបទ និងនីតិវិធីនៃការប្រើប្រាស់ផ្លូវថ្នល់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឬប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ។

## មាត្រា ២៩

ការប្រើប្រាស់ផ្លូវថ្នល់ និងសកម្មភាពផ្សេងៗពាក់ព័ន្ធនឹងផ្លូវថ្នល់តាមដងផ្លូវនៅក្នុងរាជធានី ក្រុង និងទីប្រជុំជន ត្រូវអនុវត្តដូចតទៅ ៖

ក. ចិញ្ចើមផ្លូវ និងផ្លូវថ្មើរជើងត្រូវប្រើប្រាស់សម្រាប់តែគោលបំណងក្នុងការធ្វើចរាចរណ៍ដោយថ្មើរជើង។

ខ. ចិញ្ចើមផ្លូវ និងផ្លូវថ្មើរជើងអាចយកទៅប្រើប្រាស់សម្រាប់គោលបំណងផ្សេងទៀតបានសមស្របតាមបញ្ញត្តិនៃមាត្រា ២៨ នៃច្បាប់នេះ។

គ. មិនត្រូវអនុវត្តសកម្មភាពដូចខាងក្រោម ៖

- ចតរថយន្ត ឬយានជំនិះមិនត្រឹមត្រូវតាមដងផ្លូវ ចិញ្ចើមផ្លូវ និងផ្លូវសម្រាប់ថ្មើរជើងខុសពីទីតាំងកំណត់
- សាងសង់របារកាត់ទទឹង ឬទួលបន្ថយល្បឿន ឬវត្ថុប្រហាក់ប្រហែលពីលើផ្លូវថ្នល់ដោយគ្មានការអនុញ្ញាត
- ធ្វើសកម្មភាពផ្សេងទៀតផ្ទុយពីច្បាប់នេះ។

**មាត្រា ៤៨**

ទណ្ឌកម្មក្នុងបទល្មើសនៃច្បាប់នេះរួមមាន ការព្រមានជាលាយលក្ខណ៍អក្សរ ការដកហូត ឬការព្យួរវិញ្ញាបនបត្រ អាជ្ញាបណ្ណ ការពិន័យអន្តរការណ៍ ទោសពិន័យជាប្រាក់ និងទោសដាក់ពន្ធនាគារ។

**មាត្រា ៦២**

ជនណាដែលមានគោរពតាមការបញ្ជារបស់ភ្នាក់ងារសុវត្ថិភាព ដែលប្រចាំការតាមគោលដៅ ដូចមានចែងក្នុងមាត្រា ២៧ នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) រៀល។

### ៣.១.៦ អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន (១៩៩១)

យោងតាមសេវាផ្តល់ប្រឹក្សា និងវិភាគរបស់ធនាគារពិភពលោក ឆ្នាំ ២០១៨ (P164300) អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន (EIA) (១៩៩៩) និងគោលការណ៍ណែនាំគាំទ្រដែលបានបង្កើតឡើងនៅឆ្នាំ ២០០៥, ២០០៩ និង ២០១៧ មានបទប្បញ្ញត្តិលម្អិតស្តីពីលក្ខខណ្ឌ ដំណើរការ និងតួនាទី និងការទទួលខុសត្រូវផ្នែកស្ថាប័នលើការវាយតម្លៃបរិស្ថាន និងសង្គម[9]។ កម្ពុជាមានអនុក្រឹត្យ EIA ចាប់តាំងពីឆ្នាំ ១៩៩៩ មក។ អនុក្រឹត្យនេះតម្រូវឲ្យមានការធ្វើ EIA លើ "រាល់គម្រោង ឬសកម្មភាពរបស់ឯកជន ឬសាធាណៈ" ហើយត្រូវបានពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថានមុនដាក់ជូនរាជរដ្ឋាភិបាលសម្រេច "លើក

---

[9]អនុក្រឹត្យ EIA (១៩៩៩) ពង្រីក និងបញ្ជាក់បន្ថែមពីបទប្បញ្ញត្តិក្នុងច្បាប់ស្តីពីការវិនិយោគឆ្នាំ ១៩៩៤ ដែលតម្រូវឲ្យមានការអនុម័តដោយគណៈរដ្ឋមន្ត្រីលើគម្រោងវិនិយោគដែលអាចបង្ក "ផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន"។ បទប្បញ្ញត្តិស្រដៀងគ្នាស្តីពីការរៀបចំ ពិនិត្យឡើងវិញ និងដាក់ EIAs ទៅរដ្ឋាភិបាល ត្រូវបានរួមបញ្ចូលក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ មុនឆ្នាំ ១៩៩៦ ៖ "ត្រូវធ្វើ EIA លើរាល់គម្រោង ឬសកម្មភាពរបស់ឯកជន ឬសាធាណៈ ហើយត្រូវបានពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថានមុនដាក់ជូនរាជរដ្ឋាភិបាលសម្រេច"។

លែងតែគម្រោងដែលមានលក្ខណៈពិសេស និងចាំបាច់បន្ទាន់ដែលសម្រេចដោយរាជរដ្ឋាភិបាល"។ សំខាន់បំផុត អនុក្រឹត្យនេះរៀបរាប់លម្អិតពីការទទួលខុសត្រូវផ្នែកស្ថាប័នរបស់ក្រសួងបរិស្ថាន និងមន្ទីរបរិស្ថាន នីតិវិធីសម្រាប់ការពិនិត្យឡើងវិញ និងអនុម័តគម្រោង និងការដាក់ពិន័យទូទៅសម្រាប់ការមិនអនុលោមតាម។ អនុក្រឹត្យនេះជំរុញការចូលរួមជាសាធារណៈ និងអំពាវនាវឲ្យម្ចាស់គម្រោងបង្កើតផែនការគ្រប់គ្រងបរិស្ថាន (EMP)។ ម្ចាស់គម្រោងអាចអនុលោមតាមច្បាប់នេះដោយបញ្ចប់ EIA បឋម ឬ EIA ពេញលេញ ដោយមាត្រា ៨ បញ្ជាក់ថា មានតែគម្រោងដែល "បង្កផលប៉ះពាល់ធ្ងន់ធ្ងរ" ប៉ុណ្ណោះដែលទាមទារឲ្យមានការធ្វើ EIA ពេញលេញ។

អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន ចុះខែ សីហា ឆ្នាំ ១៩៩៩។ មាត្រាសំខាន់ៗមានដូចតទៅ។

អនុក្រឹត្យនេះមានគោលបំណង ៖

- កំណត់ការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន លើរាល់គម្រោង និងសកម្មភាពឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថានមុនដាក់ជូនរដ្ឋាភិបាលសម្រេច
- កំណត់ប្រភេទ និងទំហំគម្រោងសកម្មភាពដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន ទាំងសាធារណៈដែលត្រូវវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន
- បំផុសឲ្យមានការចូលរួមពីសាធារណៈជន ក្នុងកិច្ចដំណើរការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណាក្នុងកិច្ចដំណើរការអនុម័តគម្រោង។

**គោលការណ៍ណែនាំទូទៅសម្រាប់ការរៀបចំរបាយការណ៍ EIA បឋម និងពេញលេញ (២០០៩) មានតារាងសម្រាប់ការវាយតម្លៃហេតុផលប៉ះពាល់តិចតួច មធ្យម និងធ្ងន់ធ្ងរ ប៉ុន្តែមិនមាននិយមន័យ ឬលក្ខណៈវិនិច្ឆ័យសម្រាប់ការកំណត់កម្រិតហេតុផលប៉ះពាល់ទាំងនេះឡើយ[10]។** គោលការណ៍ណែនាំឆ្នាំ ២០០៩ បានបញ្ជាក់ពីដំណើរការពិនិត្យឡើងវិញលើគម្រោង និងការអនុម័ត។ ក្រៅពីការកំណត់រយៈពេល ៣០ ថ្ងៃ និងការគូសផែនទីដំហានដែលតម្រូវដោយស្ថាប័នទទួលខុសត្រូវ (រូប ១) គោលការណ៍ណែនាំរៀបរាប់ពីខ្លឹមសារ

[10]តារាងក្នុងឧបសម្ព័ន្ធ ២ នៃគោលការណ៍ណែនាំ EIA (២០០៩) គ្របដណ្តប់លើធនធានបរិស្ថានធម្មជាតិរូបវន្ត និងជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គមក្នុងដំណាក់កាល ៣ (មុនប្រតិបត្តិការ ក្នុងពេលប្រតិបត្តិការ និងនៅពេលបញ្ចប់ប្រតិបត្តិការ)។

ដាក់លាក់ក្នុងរបាយការណ៍ EIA ដូចជា តារាងផ្ទៀងផ្ទាត់ស្តីពីហេតុផលប៉ះពាល់បរិស្ថាន[11] និងសេដ្ឋកិច្ចសង្គម[12] ដែលត្រូវវិភាគ និងជំពូកស្តីពីការចូលរួមជាសាធារណៈ[13]។

[11]ព្រៃឈើ (តំបន់ ពូជសត្វ ការធ្វើចំណាត់ថ្នាក់) សត្វ (កម្រ និងជិតផុតពូជ បំលាស់ទី) ជីវៈចម្រុះ ដែនជម្រក ដីសើម ដី ធនធានរ៉ែ ជាតុអាកាស (សីតុណ្ហភាព កម្ពស់ទឹកភ្លៀង ល្បឿន និងទិសខ្យល់ សម្ពាធខ្យល់ សំណើម) គុណភាពខ្យល់ សំឡេងរំខាន និងរំញ័រ ជលសាស្រ្ត (គុណភាព និងបរិមាណទឹកលើដី និងក្រោមដី ចរន្ត និងលំហូរទឹក)។

[12]ការប្រើប្រាស់ដីធ្លី ការប្រើប្រាស់ទឹក ការប្រើប្រាស់ថាមពល ការអប់រំ សុខភាពសាធារណៈ បេតិកភណ្ឌវប្បធម៌ (អគារប្រវត្តិសាស្រ្ត ប្រាសាទបុរាណ វត្តអារាម ទំនៀមទំលាប់/ប្រពៃណី ជាតិពន្ធុ ជនជាតិដើមភាគតិច។ល។) ស្ថានភាពសេដ្ឋកិច្ច (ការងារ និងប្រាក់ចំណូលបឋម និងបន្ទាប់បន្សំ) ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ប្រជាសាស្រ្ត និងលំនៅដ្ឋាន តំបន់ទេសចរណ៍។

[13]ក្នុងជំពូកនេះ ម្ចាស់គម្រោងត្រូវពណ៌នាពីការពិគ្រោះយោបល់សាធារណៈស្តីពី ១) ការផ្សព្វផ្សាយដល់អាជ្ញាធរ និងសហគមន៍មូលដ្ឋានអំពីគម្រោងអភិវឌ្ឍន៍ ២) សេចក្តីអត្ថាធិប្បាយរបស់ក្រសួង/ស្ថាប័ន/មន្ទីរពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ៣) សេចក្តីអត្ថាធិប្បាយរបស់អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ និង ៤) ការពិគ្រោះយោបល់ជាមួយប្រជាជនមូលដ្ឋាន។

រូប ១ ៖ ដំណើរការពិនិត្យឡើងវិញលើ EIA និងការអនុម័ត ជំហាន និងស្ថាប័នទទួលខុសត្រូវ




ប្រភព ៖ គោលការណ៍ណែនាំទូទៅស្តីពី EIA សម្រាប់ការរៀបចំរបាយការណ៍ EIA បឋម និងពេញលេញ (២០០៩)

យោងតាមការពិនិត្យឡើងវិញដោយ សំ ចន្ទី មកពីវិទ្យាស្ថាន AIT Thailand (២០១៥) អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន និង**គោលការណ៍ណែនាំទូទៅស្តីពីការរៀបចំរបាយការណ៍ EIA បឋម និងពេញលេញ (២០០៩)** គ្រាន់តែលើកឡើងពីតម្រូវការទីប្រឹក្សា ប៉ុន្តែមិនបានកំណត់លក្ខណៈនីតិបុគ្គលដែលមានគុណវុឌ្ឍិសម្រាប់ការផ្តល់សេវាវាយតម្លៃប្រកបដោយវិជ្ជាជីវៈ ដល់អតិថិជនឡើយ។ បទប្បញ្ញត្តិក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីបរិស្ថានថ្មី ស្នើឲ្យក្រុមហ៊ុនមានស្រាប់ដាក់ពាក្យសុំអាជ្ញាបណ្ណថ្មី ដែលមានសុពលភាពរយៈពេល ៥ ឆ្នាំ។

## ៣.១.៦ អនុក្រឹត្យពាក់ព័ន្ធផ្សេងទៀត

- អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក

  អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹកត្រូវបានអនុម័តនៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៩៩៩។ អនុក្រឹត្យនេះមានគោលដៅកំណត់ការត្រួតពិនិត្យការបំពុលទឹកដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ សំដៅធានាបានការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចម្រុះ (មាត្រា ១)។

  - អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយដែលបង្កឲ្យមានការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ (មាត្រា ២)។ អនុក្រឹត្យនេះចែងពីប្រភេទប្រភពបំពុល ស្តង់ដារបញ្ចេញសំណល់ ស្តង់ដារគុណភាពទឹកក្នុងតំបន់ផ្សេង ទៀត។

សម្រាប់គម្រោងនេះ ស្តង់ដារគុណភាពទឹកមួយចំនួនសម្រាប់តំបន់ទឹកសាធារណៈត្រូវយកមកអនុវត្ត។

- អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង
  - អនុក្រឹត្យលេខ ៣៦ អនរក.បក ស្តីពីការគ្រប់គ្រងសំណល់រឹង ត្រូវបានអនុម័តនៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩។ អនុក្រឹត្យនេះមានគោលដៅកំណត់ការគ្រប់គ្រងសំណល់រឹងប្រកបដោយលក្ខណៈបច្ចេកទេសសមស្រប និងប្រកបដោយសុវត្ថិភាព សំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវៈចម្រុះ។
  - អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចេញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់។
- អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង
  - អនុក្រឹត្យលេខ ៤២ អនរក.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង ត្រូវបានអនុម័តនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០។ អនុក្រឹត្យនេះមានគោលបំណងការពារគុណភាពបរិស្ថាន និងសុខភាពមនុស្សពីការបំពុលខ្យល់ និងការបំពុលដោយសំឡេងតាមរយៈសកម្មភាពពិនិត្យតាមដាន ដោះស្រាយ និងកាត់បន្ថយ។ អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុលចល័ត និងអចល័តទាំងឡាយដែលបង្កឲ្យមានការបំពុលខ្យល់ និងការរំខានដោយសំឡេងនៅក្នុងបរិយាកាស។

## ៣.២ គោលនយោបាយធានាសុវត្ថិភាពរបស់ធនាគារពិភពលោក

*គម្រោងនេះបំផុសគោលនយោបាយធានាសុវត្ថិភាពដូចខាងក្រោម ៖*

*ការវាយតម្លៃបរិស្ថាន (OP/BP 4.01) ត្រូវបានបំផុស* ចេញពីគោលការណ៍ណែនាំបណ្តោះអាសន្នរបស់ធនាគារពិភពលោកស្តីពីការធានាសុវត្ថិភាពសម្រាប់ជំនួយបច្ចេកទេស (២០១៦) និងផលប៉ះពាល់តាមទីតាំងអាចបង្វែរត្រលប់បាន និងផ្អែកតាមមូលដ្ឋាន ដោយសារសកម្មភាពទេសចរណ៍ធម្មជាតិខ្នាតតូច។ ដូច្នេះគម្រោងនេះត្រូវបានកំណត់ជាប្រភេទ ខ ថ្វីបើទីតាំងគម្រោងមិនទាន់ត្រូវបានកំណត់ជាមុនក្តី។ ដោយសារតែគម្រោងស្ថិតក្នុងប្រភេទ ខ អនុគម្រោងប្រភេទ ក ប្រហែលជាមិនមានឡើយ និងគ្មានលក្ខណៈសម្បត្តិដើម្បីទទួលបានហិរញ្ញប្បទានគម្រោងឡើយ លុះត្រាតែគម្រោងត្រូវបានរៀបចំរចនាសម្ព័ន្ធឡើងវិញជាប្រភេទ ក។

*ដែនជម្រកធម្មជាតិ (OP/BP 4.04)* ត្រូវបានបំផុសព្រោះគម្រោងនឹងពាក់ព័ន្ធនឹងសកម្មភាពក្នុងច្រកតំបន់គម្រោង ២។ ដោយសារតែទេសចរណ៍ធម្មជាតិក្នុងតំបន់គម្រោងទាំង ២ នេះត្រូវមានការការពារ គួរមាន

ការធានាថា វាមិនបង្កការគំរាមកំហែងកាន់តែខ្លាំងលើការរៀបចំផែនការទេសភាព និងសកម្មភាពទេសចរណ៍ធម្មជាតិ។ ការអនុលោមតាមគោលនយោបាយនេះនឹងធានាបានថា ការអភិវឌ្ឍទេសចរណ៍ធម្មជាតិអនុលោមតាមគោលបំណងនៃការការពារដែនជម្រកធម្មជាតិ។

***ព្រៃឈើ (OP/BP 4.36)*** ត្រូវបានបំផុស ព្រោះគម្រោងនឹងវិនិយោគលើសកម្មភាពជំនួយបច្ចេកទេសសម្រាប់តំបន់ទេសភាព និងការគ្រប់គ្រងធនធានព្រៃឈើ និងការរៀបចំផែនការអាជីវកម្មទេសចរណ៍ធម្មជាតិក្នុងតំបន់ការពារ។ គម្រោងនឹងមិនបង្ក ឬសម្រួលការធ្វើឲ្យបាត់បង់ ឬការបំផ្លិចបំផ្លាញព្រៃឈើឡើយ។ ESMS គម្រោង ត្រូវបានរៀបចំឡើងដើម្បីចាត់វិធានការសមស្របលើការការពារគម្របព្រៃឈើនៅសេសសល់ តាមរយៈការរិតត្បិតអន្តរាគមន៍លើដីធ្លីដែលស្ថិតក្រោមការប្រើប្រាស់ដីធ្លី និងទ្រព្យសម្បត្តិធម្មជាតិ និងទប់ស្កាត់ការទន្ទ្រានកាន់កាប់ក្នុងតំបន់ព្រៃជិតខាង និងតំបន់ការពារសហគមន៍។ ការអនុលោមតាមគោលនយោបាយនេះនឹងធានាថា ការបង្កើតផែនការអាជីវកម្មសម្រាប់ទេសចរណ៍ធម្មជាតិអនុលោមតាមគោលបំណងគោលនយោបាយព្រៃឈើ។

***ធនធានវប្បធម៌រូបវន្ត (OP/BP 4.11)*** ត្រូវបានបំផុសជាវិធានការ "ប្រុងប្រយ័ត្ន" ។ ការវាយតម្លៃបឋមមិនទាន់គ្របដណ្តប់លើសារៈសំខាន់ផ្នែកបុរាណវត្ថុវិទ្យា ឬវប្បធម៌ក្នុងតំបន់ទេសភាពដែលបានជ្រើសរើសឡើយ។ នីតិវិធីស្វែងរកឱកាស (chance-find) ក្រោមក្រមប្រតិបត្តិបរិស្ថាន (ECOP) ឬកិច្ចព្រមព្រៀងការពារបរិស្ថានរបស់ក្រសួងបរិស្ថាន ត្រូវបានដាក់បញ្ចូលក្នុង ESMF។

គម្រោងនឹងអនុវត្តផងដែរនូវគោលការណ៍ណែនាំស្តីពីបរិស្ថាន សុខភាព និងសុវត្ថិភាពរបស់ក្រុមធនាគារពិភពលោក (គោលការណ៍ណែនាំ EHS)[14]។ គោលការណ៍ណែនាំនេះជាការសំអាងផ្នែកបច្ចេកទេសដែលបង្ហាញពីឧទាហរណ៍ជាក់លាក់ ឬទូទៅនៃការអនុវត្តល្អផ្នែកឧស្សាហកម្មជាអន្តរជាតិ។ គោលការណ៍ណែនាំផ្តល់ព័ត៌មានស្តីពីកម្រិតអនុវត្តន៍ការងារ និងវិធានការដែលអាចទទួលយកបានសម្រាប់ធនាគារពិភពលោក និងត្រូវបានចាត់ទុកថាត្រូវសម្រេចឲ្យបានក្នុងតំបន់តាំងដែនជម្រកថ្មីដោយមានចំណាយសមស្រប និងប្រើប្រាស់បច្ចេកវិទ្យាមានស្រាប់។ ដំណើរការវាយតម្លៃបរិស្ថានអាចផ្តល់អនុសាសន៍ស្តីពីព្រំដែនកំណត់ ឬវិធានការផ្សេងទៀត (អាចខ្ពស់ ឬទាបជាង) ហើយប្រសិនបើអាចទទួលយកបានសម្រាប់ធនាគារពិភពលោក អនុសាសន៍ទាំងនេះនឹងក្លាយជាលក្ខខណ្ឌសម្រាប់គម្រោង ឬសម្រាប់ទីតាំងជាក់លាក់។

***ការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត (OP/BP 4.12) និងជនជាតិដើមភាគតិច (OP/BP 4.10)*** ត្រូវបានអនុវត្ត ហើយទីភ្នាក់ងារអនុវត្តន៍មានក្របខណ្ឌធានាសុវត្ថិភាពសង្គមដោយឡែក ៖ ក្របខណ្ឌរៀបចំផែន

---

[14] *សូមមើលគោលការណ៍ណែនាំ EHS ៖ www.ifc.org/ifcext/enviro.nsf/Content/EnvironmentalGuidelines*

ការជនជាតិដើមភាគតិច (IPPF) ក្របខណ្ឌរៀបចំផែនការតាំងទីលំនៅថ្មី (RPF) និងក្របខណ្ឌដំណើរការ (PF)។ ការរៀបរាប់សង្ខេបស្តីពីក្របខណ្ឌទាំងនេះមានបង្ហាញក្នុងប្រអប់ខាងក្រោម។

*ក្របខណ្ឌរៀបចំផែនការជនជាតិដើមភាគតិច (IPPF) ៖* គោលនយោបាយស្តីពីជនជាតិដើមភាគតិច (OP/BP 4.10) ត្រូវបានរៀបរៀងឡើងដើម្បីធានាថាដំណើរការអភិវឌ្ឍគោរពពេញលេញនូវសេចក្តីថ្លៃថ្នូ សិទ្ធិមនុស្ស សេដ្ឋកិច្ច និងវប្បធម៌របស់ជនជាតិភាគតិច។ នៅពេលដែលការត្រួតពិនិត្យបឋមរបស់ធនាគារពិភពលោកបង្ហាញថា ក្រុមជាតិពន្ធុងាយនឹងមានវត្តមាន ឬមានទំនាក់ទំនងជាសមូហភាពទៅនឹងតំបន់គម្រោង ប៉ុន្តែវត្តមាន ឬទំនាក់ទំនងទាំងនោះមិនអាចគ្រប់គ្រងបានរហូតទាល់តែមានការកំណត់កម្មវិធី ឬអនុគម្រោង អ្នកខ្ចីត្រូវរៀបចំ IPPF មុនការវាយតម្លៃ។ IPPF ត្រូវបានរៀបរៀងឡើងដើម្បីរៀបរាប់ពីគោលនយោបាយរបស់ធនាគារពិភពលោក និងក្របខណ្ឌនិយ័តកម្មនៅកម្ពុជា។ ឯកសារនេះផ្តល់ព័ត៌មានទូទៅស្តីពីជនជាតិដើមភាគតិចនៅកម្ពុជា ជាពិសេសក្នុងខេត្តប្រតិបត្តិគម្រោង។ ជំហានចាំបាច់ក្នុងការពិគ្រោះយោបល់ជនជាតិដើមភាគតិច រៀបចំការវាយតម្លៃសង្គម និងធានានូវការព្រមព្រៀងដោយសេរី ជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ (FPIC) របស់ជនជាតិដើមភាគតិចក្នុងការរៀបចំ អនុវត្ត និងពិនិត្យតាមដានគម្រោង មានរៀបរាប់លម្អិតក្នុង IPPF។

*ក្របខណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅថ្មី (RPF)៖* គោលនយោបាយស្តីពីការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត (OP/BP 4.12) មានគោលបំណងទប់ស្កាត់ការលំបាករយៈពេលវែង ការធ្លាក់ចូលក្នុងភាពក្រីក្រ និងផលប៉ះពាល់អវិជ្ជមានលើរបបចិញ្ចឹមជីវិតរបស់សហគមន៍រងផលប៉ះពាល់ដោយសារការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត។ នៅពេលគម្រោងតម្រូវឲ្យមានលទ្ធកម្មដីធ្លី ឬការផ្លាស់ប្តូរលទ្ធភាពទទួលបានធនធានដោយសារគម្រោង ត្រូវអនុវត្តគោលនយោបាយនេះ។ គោលនយោបាយរបស់ធនាគារពិភពលោកតម្រូវឲ្យមានក្របខណ្ឌគោលនយោបាយដើម្បីដោះស្រាយផលប៉ះពាល់/ការតាំងទីលំនៅថ្មី នៅពេលគេមិនដឹងពីព័ត៌មានជាក់លាក់នៅដំណាក់កាលវាយតម្លៃគម្រោង និងនៅពេលដែលអ្នកខ្ចីត្រូវដាក់ក្របខណ្ឌនេះមុនការវាយតម្លៃ ដោយអនុលោមតាមគោលនយោបាយនេះ។ RPF ត្រូវបានតាក់តែងឡើងក្នុងគោលបំណងបញ្ជាក់ពីគោលការណ៍តាំងទីលំនៅថ្មី ការរៀបចំផ្នែកស្ថាប័ន និងលក្ខណៈវិនិច្ឆ័យដែលត្រូវអនុវត្តលើអនុគម្រោងដែលអាចធ្វើឲ្យមានលទ្ធកម្មដីធ្លីដោយមិនស្ម័គ្រចិត្ត និងផ្តល់ការណែនាំចាំបាច់លើការរៀបចំផែនការសកម្មភាពតាំងទីលំនៅថ្មី (RAPs) ទៅតាមភាពចាំបាច់។

*ក្របខណ្ឌដំណើរការ ៖* គោលនយោបាយស្តីពីការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត (OP/BP 4.12) លើកឡើងផងដែរពីការរឹតត្បិតដោយមិនស្ម័គ្រចិត្តលើលទ្ធភាពចេញចូលតំបន់ឧទ្យានដែលកំណត់ដោយច្បាប់ ឬតំបន់ការពារ។ នៅពេលគ្មានព័ត៌មានជាក់លាក់ស្តីពីផលប៉ះពាល់នៅដំណាក់កាលវាយតម្លៃ ចាំបាច់ត្រូវមានក្របខណ្ឌដំណើរការ (PF) សម្រាប់ការបង្កើតដំណើរការដែលមានការចូលរួមក្នុងការបង្កើត និងអនុវត្តការរឹតត្បិតលើការប្រើប្រាស់ធនធាន។ PF ត្រូវបានរៀបចំឡើងដើម្បីរៀបរាប់ពីដំណើរការដែលមានការចូលរួមដែលសហគមន៍ និងអាជ្ញាធរគម្រោង ឬទីភ្នាក់ងារ/អង្គការពាក់ព័ន្ធផ្សេងទៀត នឹងផ្តល់អនុសាសន៍រួមស្តីពីការរឹតត្បិតលើការប្រើប្រាស់ធនធាន និងសម្រេចចាត់វិធានការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានធំៗដោយសារការរឹតត្បិតទាំងនេះ។ ផែនការស្តារ និងកាត់បន្ថយគឺជាផ្នែកមួយនៃក្របខណ្ឌនេះ។

## ៣.៣ ចំណុចខុសគ្នារវាងបទប្បញ្ញត្តិជាតិស្ដីពី EIA និងគោលនយោបាយធានាសុវត្ថិភាពរបស់ធនាគារពិភពលោក

ផ្នែករងនេះផ្ដោតលើចំណុចខុសគ្នារវាងប្រព័ន្ធធានាសុវត្ថិភាពថ្នាក់ជាតិ និងការធានាសុវត្ថិភាពពាក់ព័ន្ធរបស់ ធនាគារពិភពលោក។ មានភាពខុសគ្នាយ៉ាងច្រើនរវាងប្រព័ន្ធទាំងពីរនេះ ហើយចាំបាច់ត្រូវមានវិធានការលុប បំបាត់ចំណុចខ្វះខាតមួយចំនួនដែលត្រូវដាក់បញ្ចូលក្នុង ESMF។ គោលនយោបាយធានាសុវត្ថិភាពរបស់ធនាគារពិភពលោក និងក្របខណ្ឌច្បាប់កម្ពុជាស្ដីពីការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានមានលក្ខណៈបន្សុីគ្នាលើគោលការណ៍ និងគោលបំណង ៖

- ប្រព័ន្ធទាំងពីរនេះសុទ្ធតែតម្រូវឲ្យមានការត្រួតពិនិត្យការវិនិយោគលើអនុគម្រោង ដើម្បីកំណត់កម្រិតនៃការវាយតម្លៃសង្គម និងបរិស្ថានចាំបាច់ (ឧ. EMP, IEE ឬ EIA)។
- ប្រព័ន្ធទាំងពីរនេះសុទ្ធតែតម្រូវឲ្យមាន ESIA លម្អិតសម្រាប់គម្រោងដែលបង្កផលប៉ះពាល់កាន់តែខ្លាំង (ប្រភេទ ក) ការសិក្សា EIA ដែលមិនសូវលម្អិតសម្រាប់គម្រោងដែលមិនសូវបង្កផលប៉ះពាល់ (ប្រភេទ ខ) និងគ្មានការសិក្សា ESIA សម្រាប់គម្រោងដែលគ្មាន ឬមានផលប៉ះពាល់អវិជ្ជមានតិចតួចលើបរិស្ថាន (ប្រភេទ គ)
- ក្នុងដំណើរការ ESIA សមាសភាគបរិស្ថាន (ឧ. ការប្រែប្រួលអាកាសធាតុ សេវាប្រព័ន្ធអេកូឡូស៊ី និងទស្សនាទានគ្មានការបាត់បង់សរុប) និងសមាសភាគសង្គម (ឧ. ការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត បេតិកភណ្ឌវប្បធម៌ និងក្រុមងាយរងគ្រោះ) សុទ្ធតែត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធទាំងពីរនេះ។
- ប្រព័ន្ធទាំងពីរនេះសុទ្ធតែមានអភិក្រមឋានានុក្រមកាត់បន្ថយ។
- ធនាគារពិភពលោកតម្រូវឲ្យមានការពិគ្រោះយោបល់អ្នកពាក់ព័ន្ធ ក្នុងដំណាក់កាលរៀបចំផែនការអនុវត្ត និងប្រតិបត្តិការគម្រោងដែលសមមូលនឹងលក្ខខណ្ឌកាត់បន្ថយ។

ក្រៅពី ESIA ក្របខណ្ឌច្បាប់ថ្នាក់ជាតិកំណត់ពីអភិក្រមឆ្ពោះទៅរកការធ្វើសវនកម្មបរិស្ថាន និងអធិការកិច្ច។

ចំណុចខុសគ្នាសំខាន់ៗ ៖

- ទោះបីជាក្រសួងបរិស្ថាន និងធនាគារពិភពលោកតម្រូវឲ្យមាន ESMP សម្រាប់គម្រោងប្រភេទ ខ ក្ដី ក៏ធនាគារពិភពលោកទាមទារឲ្យមានការរៀបចំឯកសារដាច់ដោយឡែកមួយដែលលម្អិតជាងនេះ។
- ក្របខណ្ឌច្បាប់ជាតិមិនបានដាក់បញ្ចូលលិខិតុបករណ៍មួយចំនួនដែលត្រូវបានពិចារណាក្នុង OP 4.01 ដូចជា ការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន និងសង្គមជាយុទ្ធសាស្ត្រ (SESA), ESMF ឬក្របខណ្ឌដំណើរការ (PF) ឡើយ។

- ក្រោមច្បាប់ជាតិ គ្មានការកំណត់ជាក់លាក់ស្តីពីវិធីសាស្ត្រចម្រុះលើការគ្រប់គ្រងសត្វចង្រៃ ឬផលិតកម្មកសិកម្មសរីរាង្គនោះទេ។

ខាងក្រោមនេះជាឧទាហរណ៍ ស្តីពីការវិភាគចំណុចខុសគ្នារវាងអនុក្រឹត្យស្តីពីការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានរបស់រាជរដ្ឋាភិបាលកម្ពុជា និងគោលនយោបាយ O.P.4.01 របស់ធនាគារពិភពលោក។

**តារាងទី ១ ៖ ការវាយតម្លៃចំណុចខុសគ្នារវាងច្បាប់/លិខិតុបករណ៍ច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា និងគោលនយោបាយវាយតម្លៃបរិស្ថាន OP 4.01 របស់ធនាគារពិភពលោក**

| ប្រធានបទ | OP 4.01 | រាជរដ្ឋាភិបាលកម្ពុជា | ចំណុចខុសគ្នា/វិធានការរបស់គម្រោង |
|---|---|---|---|
| **១.ដំណើរការវាយតម្លៃបរិស្ថាន** | | | |
| ១.១ ការវាយតម្លៃបរិស្ថានពិចារណាពីផ្នែកធម្មជាតិ និងផ្នែកសង្គមទូទៅ ដោយផ្តោតលើកាតព្វកិច្ចក្នុងសន្ធិសញ្ញា និងកិច្ចព្រមព្រៀងថ្នាក់ជាតិ និងអន្តរជាតិ។ | ការវាយតម្លៃភាពគ្រប់ជ្រុងជ្រោយនៃក្របខណ្ឌច្បាប់ពាក់ព័ន្ធ និងស្ថាប័ន និងកិច្ចព្រមព្រៀងបរិស្ថានអន្តរជាតិមានស្រាប់ និងការបញ្ជាក់ថាកិច្ចព្រមព្រៀងទាំងនេះបង្ហាញថារដ្ឋាភិបាលដែលធ្វើកិច្ចសហប្រតិបត្តិការជាមួយធនាគារពិភពលោក នឹងមិនផ្តល់ហិរញ្ញប្បទានដល់សកម្មភាពគម្រោងដែលផ្ទុយនឹងកាតព្វកិច្ចអន្តរជាតិទាំងនេះឡើយ។ | ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ៖<br>▪ មាត្រា ៦ – ការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន ត្រូវអនុវត្តលើរាល់គម្រោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថាន មុនដាក់ជូនរាជរដ្ឋាភិបាលសម្រេច។<br>អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន (១៩៩៩) ៖<br>▪ មាត្រា ១ – កំណត់ការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានលើរាល់គម្រោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថាន មុនពេលដាក់ជូនរដ្ឋាភិបាលសម្រេច។<br>▪ មាត្រា ៦ – ម្ចាស់គម្រោងត្រូវធ្វើរបាយការណ៍វាយតម្លៃហេតុផលប៉ះពាល់បរិស្ថានដំបូងចំពោះគម្រោង | នីតិវិធីគោលនយោបាយ OP 4.01 នឹងត្រូវបានអនុវត្តដើម្បីធានាថា អនុគម្រោងអនុលោមតាមកាតព្វកិច្ចក្នុងសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងដោយមិនគិតអំពីថាតើចាំបាច់ ឬមិនចាំបាច់ត្រូវមានការវាយតម្លៃបរិស្ថានក្រោមលិខិតុបករណ៍ច្បាប់ជាតិ។ |

| តារាងទី ១ ៖ ការវាយតម្លៃចំណុចខុសគ្នារវាងច្បាប់/លិខិតុបករណ៍ច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា និងគោលនយោបាយវាយតម្លៃបរិស្ថាន OP 4.01 របស់ធនាគារពិភពលោក | | | |
|---|---|---|---|
| **ប្រធានបទ** | **OP 4.01** | **រាជរដ្ឋាភិបាលកម្ពុជា** | **ចំណុចខុសគ្នា/វិធានការរបស់គម្រោង** |
| | | ដែលតម្រូវឲ្យមានការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។ | |
| ១.២ ការវាយតម្លៃជម្រើសគម្រោងផ្សេងទៀត | ការបញ្ជាក់ពីការវាយតម្លៃជម្រើសដែលអាចមានសម្រាប់ការវិនិយោគ ជម្រើសផ្នែកបច្ចេកទេស និងទីតាំង និងជម្រើស "មិនចាត់វិធានការ" ផលប៉ះពាល់ដែលអាចកើតមានឡើង សមិទ្ធិលទ្ធភាពកាត់បន្ថយមូលធន និងចំណាយចរន្ត ដោយសារផលប៉ះពាល់ទាំងនេះ ភាពសមស្របនៃជម្រើសទាំងនេះក្រោមលក្ខខណ្ឌដើមគ្រា លក្ខខណ្ឌផ្នែកស្ថាប័ន ការបណ្ដុះបណ្ដាល និងការពិនិត្យតាមដានដែលពាក់ព័ន្ធនឹងជម្រើសទាំងនេះ។ | មិនត្រូវបានរួមបញ្ចូល | នីតិវិធីគោលនយោបាយ OP 4.01 នឹងត្រូវបានអនុវត្តដើម្បីធានាថា ការវាយតម្លៃផលប៉ះពាល់ដែលអាចកើតមានឡើងរបស់គម្រោងបានពិនិត្យឡើងវិញលើជម្រើសនានា ដូចជា ជម្រើស "មិនចាត់វិធានការ"។ |
| ១.៣ ការរក្សាទីប្រឹក្សាគម្រោង | អ្នកខ្ចីគួរបង្កើតគណៈកម្មាធិការប្រឹក្សាគម្រោងដែលរួមមានអ្នកឯកទេសបរិស្ថានឯករាជ្យដែលទទួលស្គាល់ជាអន្តរជាតិ ដើម្បីផ្ដល់ការណែនាំស្ដីពីផ្នែកគម្រោងទាំងអស់ដែលពាក់ព័ន្ធនឹងការវាយតម្លៃបរិស្ថាន។ | មិនត្រូវបានរួមបញ្ចូល | នីតិវិធីគោលនយោបាយ OP 4.01 នឹងត្រូវបានអនុវត្តដើម្បីផ្ដល់ការណែនាំប្រសិនបើត្រូវមានការណែនាំដល់អ្នកខ្ចីដើម្បីជួលអ្នកឯកទេសបរិស្ថានឯករាជ្យដែលទទួលស្គាល់ជាអន្តរជាតិ ឲ្យផ្ដល់ការណែនាំស្ដីពីការពិនិត្យឡើងវិញលើគម្រោង។ |

| តារាងទី ១ ៖ ការវាយតម្លៃចំណុចខុសគ្នារវាងច្បាប់/លិខិតុបករណ៍ច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា និងគោលនយោបាយវាយតម្លៃបរិស្ថាន OP 4.01 របស់ធនាគារពិភពលោក | | | |
|---|---|---|---|
| ប្រធានបទ | OP 4.01 | រាជរដ្ឋាភិបាលកម្ពុជា | ចំណុចខុសគ្នា/វិធានការរបស់គម្រោង |
| **២.ការពិគ្រោះយោបល់សាធារណៈ និងការផ្សព្វផ្សាយព័ត៌មាន** | | | |
| ២.១ ដំណើរការវាយតម្លៃបរិស្ថានត្រូវរួមបញ្ចូលក្នុងការពិគ្រោះយោបល់សាធារណៈនិងការផ្សព្វផ្សាយព័ត៌មាន។ | ប្រសិនបើសមស្រប ធនាគារពិភពលោកអាចតម្រូវឲ្យមានការពិគ្រោះយោបល់សាធារណៈ និងការផ្សព្វផ្សាយព័ត៌មាន។ អ្នកខ្ចីត្រូវពិគ្រោះយោបល់ជាមួយក្រុមដែលរងផលប៉ះពាល់ដោយសារគម្រោង និងអង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន។ | ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ៖<br>▪ មាត្រា ១ – ច្បាប់នេះមានគោលដៅ ៖<br>○ លើកទឹកចិត្ត និងផ្តល់លទ្ធភាពឲ្យសាធារណៈជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។<br>▪ មាត្រា ១៦ – ក្រសួងបរិស្ថានត្រូវផ្តល់ជូនតាមសំណូមពររបស់សាធារណជន នូវព័ត៌មានស្តីពីសកម្មភាពរបស់ខ្លួន និងត្រូវលើកទឹកចិត្ត ឲ្យមានការចូលរួមពីសាធារណជន ក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។<br>អនុក្រឹត្យលេខ ៧២ អនរក.បក ស្តីពីដំណើរការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន (១៩៩៩) ៖<br>▪ មាត្រា ១ – បំផុសឲ្យមានការចូលរួមពីសាធារណៈជន ក្នុងកិច្ចដំណើរការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណា ក្នុងកិច្ចដំណើរការអនុម័តគម្រោង។ | នីតិវិធីគោលនយោបាយ OP 4.01 ត្រូវបានយកមកអនុវត្តដើម្បីផ្តល់ការណែនាំស្តីពីការពិគ្រោះយោបល់សាធារណៈ និងការផ្សព្វផ្សាយព័ត៌មានដើម្បីផ្តល់ព័ត៌មានដល់ក្រុមដែលរងផលប៉ះពាល់ដោយសារគម្រោង និងអង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន។ |
| **៣.ការពិនិត្យតាមដាន និងវាយតម្លៃ** | | | |

| តារាងទី ១ ៖ ការវាយតម្លៃចំណុចខុសគ្នារវាងច្បាប់/លិខិតុបករណ៍ច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា និងគោលនយោបាយវាយតម្លៃបរិស្ថាន OP 4.01 របស់ធនាគារពិភពលោក | | | |
|---|---|---|---|
| **ប្រធានបទ** | **OP 4.01** | **រាជរដ្ឋាភិបាលកម្ពុជា** | **ចំណុចខុសគ្នា/វិធានការរបស់គម្រោង** |
| ៣.១ លក្ខខណ្ឌពិនិត្យតាមដានផ្ទៃក្នុង និងខាងក្រៅ | ក្នុងពេលអនុវត្តគម្រោង អ្នកខ្ចីត្រូវរៀបចំរបាយការណ៍អនុលោមតាមវិធានការដែលបានព្រមព្រៀងជាមួយធនាគារពិភពលោកដោយផ្អែកលើលទ្ធផលរកឃើញ និងលទ្ធផលពីការវាយតម្លៃបរិស្ថាន និងការអនុវត្ត EMP។ | អនុក្រឹត្យលេខ ៧២ អនរក.បក ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន (១៩៩៩) ៖<br>▪ មាត្រា ៣ – ក្រសួងបរិស្ថានត្រូវតាមដាន ឃ្លាំមើល និងចាត់វិធានការឲ្យម្ចាស់គម្រោងប្រតិបត្តិតាមផែនការគ្រប់គ្រងបរិស្ថានក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គម្រោង ដូចមានចែងក្នុងរបាយការណ៍វាយតម្លៃហេតុផលប៉ះពាល់បរិស្ថានដែលបានអនុម័តរួច។ | នីតិវិធីគោលនយោបាយ OP 4.01 នឹងត្រូវបានអនុវត្ត។ ការិយាល័យសម្របសម្រួលគម្រោង (PCO) សហការជាមួយអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់/គណៈកម្មាធិការដោះស្រាយផលប៉ះពាល់អន្តរក្រសួង ដើម្បីធ្វើការពិនិត្យតាមដានផ្ទៃក្នុងលើដំណើរការដោះស្រាយទំនាស់ និងការអនុលោមតាមលក្ខខណ្ឌនៃការរាយការណ៍សម្រាប់ការអនុវត្ត ESMMP។ ការពិនិត្យតាមដានត្រូវរួមបញ្ចូលរបាយការណ៍វឌ្ឍនភាព ស្ថានភាពនៃការអនុវត្តផែនការ ការដោះស្រាយផលប៉ះពាល់/ការតាំងទីលំនៅថ្មី ព័ត៌មានស្តីពីទីតាំង និងចំនួនអ្នករងផលប៉ះពាល់ ទំហំនៃការទូទាត់សំណង និងជំនួយដែលផ្តល់ដល់គ្រួសារដែលរងផលប៉ះពាល់ដោយសារគម្រោង។ របាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យតាមដានត្រូវរៀបចំឡើងដោយក្រសួងអភិវឌ្ឍន៍ជនបទ និងដាក់ជូនគណៈកម្មាធិការដោះស្រាយផលប៉ះពាល់អន្តរក្រសួង និងធនាគារ |

| តារាងទី ១ ៖ ការវាយតម្លៃចំណុចខុសគ្នារវាងច្បាប់/លិខិតុបករណ៍ច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា និងគោលនយោបាយវាយតម្លៃបរិស្ថាន OP 4.01 របស់ធនាគារពិភពលោក | | | |
|---|---|---|---|
| ប្រធានបទ | OP 4.01 | រាជរដ្ឋាភិបាលកម្ពុជា | ចំណុចខុសគ្នា/វិធានការ របស់គម្រោង |
| | | | ពិភពលោករៀងរាល់ត្រីមាស។ |

## ៤.ផលប៉ះពាល់ដែលអាចកើតមានឡើង និងការកាត់បន្ថយ

សម្រាប់គម្រោងដែលគ្មានអនុគម្រោងក្នុងពេលរៀបចំគម្រោង គេនៅតែមានវិធីមួយចំនួនក្នុងការកំណត់ផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានដែលអាចកើតមានឡើង និងវិធានការកាត់បន្ថយសម្រាប់ការរៀបចំ ESMF។

ក្រៅពីនេះ គោលការណ៍ណែនាំ EHS របស់ក្រុមធនាគារពិភពលោក ដែលមានកម្រិតអនុវត្តន៍ការងារ និងវិធានការដែលគេចាត់ទុកថាអាចសម្រេចបានក្នុងហេដ្ឋារចនាសម្ព័ន្ធថ្មីដោយប្រើប្រាស់បច្ចេកវិទ្យាមានស្រាប់ក្នុងតម្លៃសមរម្យ អាចជាមូលដ្ឋានផ្នែកបច្ចេកទេសសម្រាប់ការកំណត់រកផលប៉ះពាល់គម្រោង និងវិធានការកាត់បន្ថយ។ ម្យ៉ាងវិញទៀត គេហទំព័រស្តីពីការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាននៅកម្ពុជាផ្តល់បទប្បញ្ញត្តិ និងការណែនាំទូទៅស្តីពី EIA សម្រាប់ព្យាករណ៍ពីផលប៉ះពាល់ និងវិធានការកាត់បន្ថយក្នុងការវិនិយោគគម្រោងផ្សេងៗ។ ចាំបាច់ត្រូវកំណត់រកផលប៉ះពាល់ដែលកើតមានឡើងក្នុងដំណាក់កាលគម្រោងនានា។ ការអនុវត្តល្អគឺការបង្កើតតារាងផលប៉ះពាល់មុនដំណាក់កាលសាងសង់ ក្នុងពេលសាងសង់ ប្រតិបត្តិការ និងរុះរើ។ ផលប៉ះពាល់គួររួមមានជីវៈរូបវន្ត សុខភាព យេនឌ័រ ការតាំងទីលំនៅថ្មី ជាតិពន្ធុ ធនធានវប្បធម៌ សក្តានុពលនៃផលប៉ះពាល់ជាបន្តបន្ទាប់។

## ៤.១ ផលប៉ះពាល់ដែលអាចកើតឡើងដោយសារសមាសភាគគម្រោង

ផ្នែករងនេះរៀបរាប់ពីផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានដែលអាចកើតមានឡើង។ តាមធម្មតា ការរៀបចំគម្រោងត្រូវបានចាត់ទុកជាគម្រោងដែលរួមបញ្ចូលតំបន់ទេសភាពទន្លេសាប និងជួរភ្នំក្រវាញ ដែលជាមូលដ្ឋានសម្រាប់ការរៀបចំផែនការវាយតម្លៃបរិស្ថាន និងសង្គមក្នុងតំបន់។ ក្រោយដំណាក់កាលទស្សនាទាន ការរៀបចំគម្រោងចេះតែបន្តទៅមុខ និងលែងពាក់ព័ន្ធនឹងការវិនិយោគជលផល ឬកសិកម្មក្នុងតំបន់ទន្លេសាបទៀតហើយ។ យើងបានដកចេញសមាសភាគជលផល ហើយគម្រោងលែងគាំទ្រការវិនិយោគលើតំបន់ទេសភាពពាក់ព័ន្ធតទៅទៀតហើយ។ ដូច្នេះ យើងមិនបានរៀបចំការវាយតម្លៃបរិស្ថាន និងសង្គមថ្នាក់តំបន់ឡើយ។

## សមាសភាគទី ១ ៖ ពង្រឹងសមត្ថភាពសម្រាប់ការរៀបចំផែនការតំបន់ទេសភាព និងគ្រប់គ្រងតំបន់ការពារ

| | |
|---|---|
| សមាសភាគរង ១.១ ៖ ប្រព័ន្ធព័ត៌មាន និងគាំទ្រការធ្វើសេចក្តីសម្រេច (ISDS)<br><br>សមាសភាគរង ១.២ ៖ ការរៀបចំផែនការ ការគ្រប់គ្រង និងការពង្រឹងតំបន់ទេសភាព | ផលប៉ះពាល់វិជ្ជមានលើគោលនយោបាយស្តីពីដែនជម្រកធម្មជាតិ និងព្រៃឈើតាមរយៈជំនួយបច្ចេកទេស ដែលនឹងត្រូវបានពិនិត្យឡើងវិញសម្រាប់ផលវិបាកផ្នែកបរិស្ថាន និងសង្គមដែលអាចកើតឡើង ហានិភ័យ និងផលប៉ះពាល់ និងត្រូវអនុលោមតាមគោលនយោបាយរបស់ធនាគារពិភពលោក ជាពិសេស "គោលការណ៍ណែនាំបណ្តោះអាសន្ន ស្តីពីការអនុវត្តគោលនយោបាយធានាសុវត្ថិភាពលើជំនួយបច្ចេកទេស ក្នុងគម្រោងទទួលបានហិរញ្ញប្បទានពីធនាគារពិភពលោក និង Trust Funds" ដែលរៀបចំឡើងដោយធនាគារពិភពលោក (២០១៤)"។<br>ក្នុងករណីនេះ ក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទនឹងរួមបញ្ចូលការធានាសុវត្ថិភាពបរិស្ថាន និងសង្គមក្នុងលក្ខខណ្ឌជំនួយបច្ចេកទេស ការពិគ្រោះយោបល់ និងរបាយការណ៍វឌ្ឍនភាព។ ការធានាសុវត្ថិភាពបរិស្ថាន និងសង្គមនឹងត្រូវបានដាក់បញ្ចូលក្នុងការរៀបចំផែនការទេសភាព និងការស្តារឡើងវិញ ដូចជា សកម្មភាពគាំទ្រការគ្រប់គ្រងតំបន់ការពារ ដែលគួរទទួលបានព័ត៌មានពីការវាយតម្លៃជីវៈចម្រុះ/ដែនជម្រកធម្មជាតិ ការប្រើប្រាស់ NRM ដោយសហគមន៍មូលដ្ឋាន ការទាមទារដាប្រពៃណី និងហានិភ័យ និងផលប៉ះពាល់ដែលអាចកើតឡើងចំពោះសហគមន៍។ ក្រៅពីនេះ បញ្ហាធានាសុវត្ថិភាពបរិស្ថាន និងសង្គមនឹងត្រូវបានដោះស្រាយក្នុងសកម្មភាពរៀបចំផែនការតំបន់ទេសភាពរបស់គម្រោង ដូចជា សកម្មភាពគាំទ្រការគ្រប់គ្រងតំបន់ការពារ ដែលគួរទទួលបានព័ត៌មានពីការវាយតម្លៃជីវៈចម្រុះ/ជម្រកធម្មជាតិ ការប្រើប្រាស់ NRM ដោយសហគមន៍មូលដ្ឋាន ការទាមទារដាប្រពៃណី និងហានិភ័យ និងផលប៉ះពាល់ដែលអាចកើតឡើងចំពោះសហគមន៍ (គោលការណ៍ណែនាំសម្រាប់ឯកសារនេះត្រូវបានរៀបចំឡើងក្រោម BPAMP ដោយមានជំនួយពីធនាគារពិភពលោក)។ |

## សមាសភាគទី ២ ៖ ពង្រឹងឱកាសសម្រាប់ទេសចរណ៍ធម្មជាតិ និងសង្វាក់តម្លៃអនុផលព្រៃឈើ

| សមាសភាគរង | ផលប៉ះពាល់ដែលអាចកើតមានឡើង |
|---|---|
| សមាសភាគរង ២.១ ៖ ពង្រឹងឱកាសសម្រាប់ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ<br>សមាសភាគរង ២.២ ៖ ការជំរុញសង្វាក់តម្លៃអនុផលព្រៃឈើ | ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ធម្មជាតិថ្មី និងការកែច្នៃអនុផលព្រៃឈើអាចបង្កជាផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងសង្គម ប៉ុន្តែគេរំពឹងថា ផលប៉ះពាល់ទាំងនោះមានកម្រិតតិចតួច-មធ្យម អាចបង្វែរវិញបាន និងអាចកាត់បន្ថយបានតាមរយៈការគ្រប់គ្រងគម្រោង ដូចជា ECOP និង/ឬ EMP ក្នុង ESMF។ បញ្ហាជានាសុវត្ថិភាពបរិស្ថាន និងសង្គម នឹងត្រូវបានដោះស្រាយក្នុងសកម្មភាពរៀបចំផែនការតំបន់ទេសភាពរបស់គម្រោង ដូចជាសកម្មភាពគាំទ្រការគ្រប់គ្រងតំបន់ការពារ ដែលគួរទទួលបានព័ត៌មានពីការវាយតម្លៃជីវៈចម្រុះ/ជម្រកធម្មជាតិ ការប្រើប្រាស់ NRM ដោយសហគមន៍មូលដ្ឋាន ការទាមទារជាប្រពៃណី និងហានិភ័យ និងផលប៉ះពាល់ដែលអាចកើតឡើងចំពោះសហគមន៍។ |

## សមាសភាគ ៣ ៖ ការតភ្ជាប់បណ្តាញ និងហេដ្ឋារចនាសម្ព័ន្ធជនបទពាក់ព័ន្ធក្នុងតំបន់មួយចំនួន

ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធជនបទ និងអនាម័យខ្នាតតូច នឹងបង្កផលប៉ះពាល់ផ្ទាល់ និងប្រយោលលើបរិស្ថានជុំវិញ។ ផលប៉ះពាល់ផ្ទាល់កើតចេញពីការសាងសង់ផ្លូវថ្នល់លើជម្រកធម្មជាតិ ឬពូជសត្វដែលត្រូវអភិរក្ស។ ផលប៉ះពាល់ប្រយោលកើតចេញពីសកម្មភាពរបស់មនុស្ស ដែលជំរុញដោយការសាងសង់ផ្លូវថ្នល់ ឬការកែលម្អ មិនមែនដោយសារការងារសាងសង់ផ្លូវថ្នល់ផ្ទាល់ឡើយ។ ហានិភ័យបរិស្ថានដោយប្រយោលដែលពាក់ព័ន្ធនឹងភាពរស់ដែលងាយរងផលប៉ះពាល់ ដូចជា ការកែលម្អផ្លូវ អាចបង្កឲ្យមានការបាត់បង់ និងហិនហោចជម្រកធម្មជាតិ ហើយបណ្តាញផ្លូវអាចពាក់ព័ន្ធនឹងការបរបាញ់ខុសច្បាប់ដោយកម្មករសំណង់ ឬការទន្ទ្រានយកដីដោយខុសច្បាប់ដោយមនុស្សពីខាងក្រៅ។ ក្នុងករណីភាគច្រើន ផលប៉ះពាល់ដោយប្រយោលនៃការងារសាងសង់ផ្លូវថ្នល់លើជីវៈចម្រុះ កាន់តែធ្ងន់ធ្ងរ និងកាន់តែលំបាកគ្រប់គ្រងជាងផលប៉ះពាល់ផ្ទាល់។

ក្រសួងអភិវឌ្ឍន៍ជនបទនឹងសហការជាមួយក្រសួងបរិស្ថាន និងអាជ្ញាធរមូលដ្ឋានដើម្បីចងកាតព្វកិច្ចក្រុមហ៊ុនម៉ៅការឲ្យធានាថា កម្មករមិនធ្វើសកម្មភាពបរបាញ់ខុសច្បាប់។ ក្រសួងអភិវឌ្ឍន៍ជនបទត្រូវព្រមព្រៀង

ជាមួយក្រសួងបរិស្ថាន និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធលើការប្តេជ្ញាចិត្ត និងវិធានការកាត់បន្ថយដើម្បីគ្រប់គ្រងហានិភ័យ និងការទន្ទ្រានយកដីធ្លីខុសច្បាប់ដោយសារការតភ្ជាប់បណ្តាញផ្លូវ។ ៤. ការវិនិយោគផ្លូវថ្នល់ត្រូវអាចធ្វើទៅបាន នៅក្រោយការពង្រឹងការអនុវត្តច្បាប់ និងការពង្រឹងសមត្ថភាពគ្រប់គ្រងតំបន់ទេសភាព និងតំបន់ការពារ។

ផលប៉ះពាល់ផ្ទាល់ក្នុងពេលសាងសង់ត្រូវបានវាយតម្លៃថាមានកម្រិតតិចតួច ប្រែប្រួលតាមបរិបទមូលដ្ឋាន អាចគ្រប់គ្រងបាន និងអាចបង្វែរវិញបាន និងអាចបញ្ចៀស ឬកាត់បន្ថយតាមរយៈការរៀបចំ និងការអនុវត្តវិធានការកាត់បន្ថយបានសមស្រប។ វិធានផ្នែកបរិស្ថានសម្រាប់ក្រុមហ៊ុនម៉ៅការ ដូចជា ការពិន័យប្រកបដោយតម្លាភាពលើការមិនអនុលោមតាម ត្រូវដាក់បញ្ចូលក្នុងឯកសារដេញថ្លៃ និងកិច្ចសន្យា។ យន្តការពង្រឹងការអនុវត្តច្បាប់គួរត្រូវបានវាយតម្លៃក្នុងរបាយការណ៍ EMP/IEE/EIA និងការគ្រប់គ្រងប្រតិបត្តិការ។

## ៤.២ ផលប៉ះពាល់វិជ្ជមាន

គេរំពឹងថា គម្រោងនឹងបង្កផលប៉ះពាល់វិជ្ជមានយ៉ាងច្រើនដល់បរិស្ថានតាមរយៈការលើកឡើងពីគោលបំណងអាទិភាពនៃតំបន់ទេសភាព ព្រៃឈើ និងការស្តារទេសចរណ៍ធម្មជាតិ។ គម្រោងនេះបន្សុីគ្នាទាំងស្រុងទៅនឹងគោលនយោបាយស្តីពីដែនជម្រកធម្មជាតិ និងព្រៃឈើរបស់ធនាគារពិភពលោក។ គេរំពឹងថា ផលប៉ះពាល់អវិជ្ជមានផ្នែកបរិស្ថាន និងសង្គមដែលអាចកើតមានឡើង ផ្អែកតាមទីតាំង អាចបង្វែរឡើងវិញ និងអាចកាត់បន្ថយបានតាមរយៈការគ្រប់គ្រងអនុគម្រោង។ យើងមិនទាន់កំណត់ទីតាំងគម្រោងឡើយ ប៉ុន្តែផលប៉ះពាល់អវិជ្ជមានលើបរិស្ថានដែលអាចកើតចេញពីអនុគម្រោងទូទៅរួមមាន ៖

- ការបំពុលកាន់តែខ្លាំង ឬការហិនហោចធនធានដី និងទឹកដោយសារការពង្រីកកសិកម្មប្រពលវប្បកម្ម បសុសត្វ វារីវប្បកម្ម និង/ឬព្រៃផលិតកម្ម ដូចជា ដោយសារការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងជី។
- ផលប៉ះពាល់ដែលពាក់ព័ន្ធនឹងការងារសាងសង់ខ្នាតតូច
- ការបង្កើនកាន់តែខ្លាំងដោយសារការបោះចោលសម្ភារសំណង់មិនបានសមស្រប និង/ឬសារធាតុគ្រោះថ្នាក់
- លទ្ធកម្មដីធ្លីខ្នាតតូចដែលអាចកើតមានឡើង ការបំផ្លិចបំផ្លាញរចនាសម្ព័ន្ធឯកជន និងផលប៉ះពាល់លើដំណាំ និងដើមឈើ
- ការរិតត្បិតលើសហគមន៍ និងជនជាតិដើមភាគតិចក្នុងការទាញយកអនុផលព្រៃឈើ ធនធានធម្មជាតិ និងប្រភពរបរចិញ្ចឹមជីវិត
- ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសហគមន៍ និងសកម្មភាពគម្រោងផ្សេងទៀតអាចបង្កផលប៉ះពាល់

លើបេតិកភណ្ឌវប្បធម៌រូបវន្ត ឬអរូបីយ។

### ៤.២.១ ផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន

ការងារសាងសង់ផ្លូវថ្នល់ជនបទ និងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ធម្មជាតិខ្នាតតូចនឹងបង្កផលប៉ះពាល់ផ្ទាល់លើបរិស្ថានជុំវិញ។ គេរំពឹងថា ផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងសង្គមកើតឡើងតាមទីតាំង អាចបង្វែរវិញបាន និងអាចកាត់បន្ថយតាមរយៈការគ្រប់គ្រងអនុគម្រោង។ ប៉ុន្តែនៅពេលពិចារណាពីទំហំ ទីតាំង និងប្រភេទ គម្រោងអាចបង្កផលប៉ះពាល់បរិស្ថានជាច្រើននៅដំណាក់កាលសាងសង់ និងប្រតិបត្តិការ។ ផ្នែកនេះរៀបរាប់ពីផលប៉ះពាល់/ហានិភ័យអវិជ្ជមានជាច្រើនដែលអាចកើតមានឡើង ការពន្យល់សង្ខេបពីបញ្ហាទាំងនោះ និងសកម្មភាពទូទៅដែលបង្កផលប៉ះពាល់បរិស្ថាន ផលប៉ះពាល់សង្គម និងផលប៉ះពាល់ជាក់ស្តែង។

**ផលប៉ះពាល់អវិជ្ជមានលើបរិស្ថានដោយសារសេវាហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ធម្មជាតិ**

| | ផលប៉ះពាល់/ហានិភ័យដែលអាចកើតមានឡើង | ការពណ៌នាពីបញ្ហា/ហានិភ័យ | សកម្មភាពទូទៅដែលអាចបង្កផលប៉ះពាល់ ឬហានិភ័យ |
|---|---|---|---|
| | | ដំណាក់កាលសាងសង់ | |
| ១ | ការបំផ្លាញ ឬការបាត់បង់គម្របដំណាំ និងព្រៃឈើ ដូចជា ការរំខានដល់ទេសភាពធម្មជាតិ និងដែនជម្រកធម្មជាតិ | គម្របដំណាំ/ព្រៃឈើនៅការដ្ឋាន (ផ្លូវថ្នល់ ប្រព័ន្ធបង្ហូរទឹក។ល។) ឬទីតាំងផ្សេងទៀតដែលត្រូវប្រើប្រាស់ដោយគម្រោង អាចត្រូវបានលុបបំបាត់ ឬរំខានក្នុងដំណាក់កាលសាងសង់។ ផលប៉ះពាល់នេះអាចបញ្ចៀស ឬកាត់បន្ថយបាន។ | • ការសម្អាតការដ្ឋា ជំរំ។ល។<br>• ការទាញយក និង/ឬស្តុកទុកវត្ថុធាតុសាងសង់ |
| ២ | ការបាត់បង់ ឬហិនហោចធនធានអេកូឡូស៊ី/ធម្មជាតិដ៏មានតម្លៃ | • ប្រសិនបើមានការបូមយកដីខ្សាច់ គ្រួស និងថ្មបាតទន្លេ វាអាចធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់លំហូរទឹក។ ទន្លេអាចហូរច្រោះនៅជុំវិញកំពង់ដ និងទម្រស្អាន និងបង្កគ្រោះថ្នាក់ដល់ស្ថិរភាពហេដ្ឋារចនាសម្ព័ន្ធទាំងនេះ។ ទន្លេអាចបង្កភាពសឹករិចរឹលលើផ្នែកផ្សេងទៀតនៃ | • ការសម្អាតទីតាំង<br>• ការសាងសង់<br>• ការទាញយកធនធានធម្មជាតិសម្រាប់ធ្វើជាវត្ថុធាតុសាងសង់នៅទីតាំង |

| | ផលប៉ះពាល់/ហានិភ័យដែលអាចកើតមានឡើង | ការពណ៌នាពីបញ្ហា/ហានិភ័យ | សកម្មភាពទូទៅដែលអាចបង្កផលប៉ះពាល់ ឬហានិភ័យ |
|---|---|---|---|
| | | បាតទន្លេ និងច្រាំង និងបង្កបញ្ហាធ្ងន់ធ្ងរនៅទីកន្លែងផ្សេងទៀត។<br>• ទីតាំងមួយចំនួនអាចមានសារៈសំខាន់បំផុតចំពោះសហគមន៍មូលដ្ឋាន (វប្បធម៌ សាសនា ប្រវត្តិសាស្ត្រ បុរាណវត្ថុ)។<br>• ប្រសិនបើការងារសាងសង់ធ្វើឡើងនៅក្នុង ឬនៅជិតទីតាំងងាយរងផលប៉ះពាល់ផ្នែកសង្គម-វប្បធម៌ អាចមានការគំរាមកំហែង/ការខូចខាតអចិន្ត្រៃយ៍ដល់ទីតាំងទាំងនោះ។<br>• ការចេញចូលទីតាំងដែលគ្មានការរំខានអាចធ្វើឲ្យមានការបំផ្លាញ (ចាប់ពីការប្រមូល/ដករុក្ខជាតិ ការចាប់សត្វព្រៃ ការបរបាញ់ ការបង្កាត់ភ្លើង សំរាម។ល។) គម្របដំណាំ ដែលជាជម្រករបស់សត្វព្រៃ ឬបង្កហានិភ័យភ្លើងព្រៃ។ | សំខាន់ៗ ជាពិសេស ការបូមយកគ្រួសពីបាតទន្លេ។ល។ |
| ៣ | ការប៉ះពាល់ដល់តំបន់ទេសភាពមានស្រាប់ | • ផលប៉ះពាល់នេះអាចកើតឡើងនៅពេលគម្របដំណាំ/ដីស្រទាប់លើត្រូវបានយកចេញ ឬក៏មានការបង្កើតរចនាសម្ព័ន្ធបង្កើតឡើងដោយមនុស្សក្នុងមជ្ឈដ្ឋានធម្មជាតិដែលមានការរំខានតិចតួចបំផុត ឬនៅពេលដែលរចនាសម្ព័ន្ធថ្មីបិទបាំងតំបន់ទេសភាពស្រស់ស្អាតក្នុងទីតាំង។ | • ការសម្អាតទីតាំង<br>• ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្មីក្នុងតំបន់ដែលមានទេសភាពស្រស់ស្អាត/មានតម្លៃ។ |
| ៤ | លទ្ធកម្មដីធ្លីបរាជ័យ | • ប្រហែលជាត្រូវមានលទ្ធកម្មដីធ្លីមួយផ្នែកតូចតាមរយៈការបរិច្ចាគ ឬការទូទាត់សំណង | • វត្តមានក្រុមហ៊ុនម៉ៅការនៅការដ្ឋាន |

| | ផលប៉ះពាល់/ហានិភ័យដែលអាចកើតមានឡើង | ការពណ៌នាពីបញ្ហា/ហានិភ័យ | សកម្មភាពទូទៅដែលអាចបង្កផលប៉ះពាល់ ឬហានិភ័យ |
|---|---|---|---|
| | | សម្រាប់ការងារកសិកម្ម បសុសត្វ និងផលផល និងហេដ្ឋារចនាសម្ព័ន្ធផលិតភាពខ្នាតតូច ( ឧ. បរិក្ខារកែច្នៃក្រោយការប្រមូលផល កន្លែងរក្សាទុក និងរោងបសុបក្សី។ល។) | • ការចាប់ផ្តើមសាងសង់ ឬសកម្មភាពបន្តជាប់។ |
| ៥ | ធនធានវប្បធម៌រូបវន្តក្នុងទីតាំងអនុគម្រោង | • ក្នុងដំណាក់កាលរៀបចំផែនការ ឬសាងសង់របស់អនុគម្រោង មានការកំណត់រកធនធានវប្បធម៌ រូបវន្ត និងសាសនា។ | • ការសម្អាតទីតាំងសំណង់ ជំរំ។ល។<br>• ការប្រើប្រាស់ និង/ឬស្តុកទុកសម្ភារ/វត្ថុធាតុសាងសង់។ |
| ៦ | សំណល់រឹង | • ការដឹកលុងធ្វើឲ្យមានសំណល់។<br>• សំណល់កើតចេញពីវត្ថុធាតុដើមទុកចោល ដូចជា ឈើមូល/កញ្ចក់/លោហៈធាតុ សម្ភារវេចខ្ចប់ ឬដោយកម្មករ ដូចជា ប្រដាប់ដាក់អាហារថ្ងៃត្រង់ សំណល់អាហារ។ល។ | • ការដឹកលុង<br>• ការសាងសង់<br>• សកម្មភាពប្រចាំថ្ងៃរបស់កម្មករ |
| ៧ | ទឹកកខ្វក់ | • ទឹកកខ្វក់ចេញពីសកម្មភាពលាងសម្អាត និងបង្គន់អនាម័យរបស់កម្មករ។<br>• សំណល់ដែលគ្មានការគ្រប់គ្រងអាចធ្វើឲ្យបំពុលបរិស្ថាន ការរំខាន និងបញ្ហាសុខភាពដល់កម្មករ និងសាធារណជន។ | • ការដឹកលុង<br>• ការប្រើប្រាស់វត្ថុធាតុ/សម្ភារសំណង់<br>• សកម្មភាពប្រចាំថ្ងៃរបស់កម្មករនៅការដ្ឋាន |
| ៨ | សារធាតុគីមី សំណល់គ្រោះថ្នាក់ | • ប្រេង ថ្នាំពណ៌ ប្រេងឥន្ទនៈ អាគុយដែលមិនប្រើប្រាស់ និងវត្ថុធាតុដើមដែលមានសារធាតុ asbestos សុទ្ធតែបង្កការបំពុល។<br>• សំណល់រឹងមួយចំនួនអាចបំពុលដោយប្រេង | • ការសម្អាតទីតាំង<br>• ការជួសជុលយានយន្ត<br>• ការលាបថ្នាំ |

| | ផលប៉ះពាល់/ហានិភ័យដែលអាចកើតមានឡើង | ការពណ៌នាពីបញ្ហា/ហានិភ័យ | សកម្មភាពទូទៅដែលអាចបង្កផលប៉ះពាល់ ឬហានិភ័យ |
|---|---|---|---|
| | | ឬថ្នាំពណ៌ដែលអាចធ្វើឲ្យពុល ឬបង្កហានិភ័យសុខភាពសាធារណៈ។ | • អគារសំណង់ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត |
| ៩ | ធូលី ការបំពុលខ្យល់ | • ការប្រឈមនឹងធូលី និងផ្សែងហុយច្រើនអាចប៉ះពាល់ដល់សុខភាព ប្រព័ន្ធដកដង្ហើម និងភ្នែក។ | • ការសម្អាតទីតាំង<br>• ការជីកលុង<br>• ការដំណើរការគ្រឿងម៉ាស៊ីន<br>• ការលើកដាក់វត្ថុធាតុ/សម្ភារសំណង់ |
| ១០ | សំឡេងរំខាន និងរំញ័រ | • សំឡេងរំខានធ្វើឲ្យថ្លង់ និងអាចបង្កភាពតានតឹង ឬអាការៈឈឺក្បាល។<br>• រំញ័រអាចធ្វើឲ្យមានស្នាមប្រេះ/ការខូចខាតរចនាសម្ព័ន្ធមានស្រាប់។ | • ការគរដាំពំនូក<br>• ការបង្ហាប់ដី<br>• ការលើកដាក់វត្ថុធាតុ/សម្ភារសំណង់ |
| ១១ | ហានិភ័យសំណឹកកាន់តែខ្លាំង/កំណកក់ល្បាប់/កំទេចកំណ | • ទីជម្រាលលែងមានស្ថិរភាពនៅពេលមានការរំខានផ្ទៃដី។ ទឹកអាចហូរលឿនជាងមុន និងអាចបង្កសំណឹកដីលើជម្រាលដែលគ្មានគម្របដំណាំ។<br>• ដូច្នេះ មានហានិភ័យខ្ពស់នៃសំណឹកដី និងការបាក់ដី ប្រសិនបើអគារស្ថិតលើជម្រាលភ្នំ ឬក៏សកម្មភាពសាងសង់ប៉ះពាល់ដល់ទីជម្រាល។<br>• ដីគម្របលើដែលរងសំណឹកនឹងហូរចុះទៅជម្រាលខាងក្រោមដែលបង្កជាកករល្អក់ និងកំទេចកំណ/ភក់ល្បាប់នៅបាតទន្លេ។ | • ការសម្អាតទីតាំង<br>• ការជីកលុងធ្វើឲ្យដីបាត់បង់គម្របដំណាំនៅក្នុងពេល និងក្រោយពេលសាងសង់<br>• ការងារសាងសង់ដែលធ្វើឡើងនៅលើទីជម្រាល និង/ឬចំណោត |

| | ផលប៉ះពាល់/ហានិភ័យដែលអាចកើតមានឡើង | ការពណ៌នាពីបញ្ហា/ហានិភ័យ | សកម្មភាពទូទៅដែលអាចបង្កផលប៉ះពាល់ ឬ ហានិភ័យ |
|---|---|---|---|
| ១២ | ការថយចុះគុណភាពទឹក | • សំណល់ និងទឹកកខ្វក់ វត្ថុធាតុសាងសង់អាចលេចជ្រាប ឬបោះចោលក្នុងប្រភពទឹកនៅជិតការដ្ឋាន ឬខ្សែទឹកខាងក្រោមនៃការដ្ឋាន។<br>• ការធ្លាក់ចុះគុណភាពទឹកក្នុងខ្សែទឹក និងទន្លេ ប្រសិនបើមានការហូរច្រោះដីពីទីជម្រាល ដោយសារតែសំណឹក/ការបាក់ដី នៅពេលមានការលើកដីក្នុងការដ្ឋាន។<br>• សកម្មភាពប្រើប្រាស់ទឹកដោយខ្វះការប្រុងប្រយ័ត្នរបស់កម្មករ ដូចជា ការលាងជម្រះឧបករណ៍ដោយផ្ទាល់ក្នុងប្រភពទឹក។<br>• ប្រេង ឥន្ធនៈ ឬសារធាតុរាវផ្សេងទៀតដែលត្រូវបានប្រើប្រាស់ក្នុងពេលសាងសង់ ដូចជាការជួសជុលគ្រឿងម៉ាស៊ីននៅនឹងទីតាំង អាចលេចជ្រាប ឬហៀរកំពប់ចូលក្នុងដី ហើយទឹកភ្លៀងអាចបង្ហូរសារធាតុបំពុលទៅក្នុងប្រភពទឹកក្បែរការដ្ឋាន។ | • ការសង់ស្ពានលើខ្សែទឹក បាតទន្លេ<br>• ការបង្ហូរកាកសំណល់ពីសកម្មភាពសាងសង់ និងទឹកកខ្វក់<br>• ការលាងសម្អាត និងជួសជុលឧបករណ៍ និងគ្រឿងម៉ាស៊ីន |
| ១៣ | ប៉ះពាល់ដល់ទីតាំងវប្បធម៌ ដូចជា ព្រះវិហារ ទីតាំងប្រវត្តិសាស្ត្រ ទីបញ្ចុះសព ។ល។ | • ទីតាំងវប្បធម៌អាចរងផលប៉ះពាល់ដោយសារធូលី សំឡេងរំខានពីការលើកដាក់/បោះចោលវត្ថុធាតុដើម/សំណល់។<br>• អាចមានវត្ថុបុរាណលេចឡើងក្នុងពេលជីកកាយ ឬលើកដីក្នុងការដ្ឋាន។ | • សកម្មភាពដែលបង្កជាធូលី និងសំឡេងរំខាន<br>• ការលើកដាក់សម្ភារ/វត្ថុធាតុសំណង់ និងសំណល់ |

| | | | |
|---|---|---|---|
| ១៤ | ការរំខានសកម្មភាពសង្គមរបស់សហគមន៍មូលដ្ឋាន ៖<br>ចរាចរណ៍/ការធ្វើដំណើរ/ការផ្គត់ផ្គង់ទឹកធារាសាស្ត្រ កសិកម្ម កិច្ចប្រជុំសហគមន៍ ។ល។<br>កម្មករក្រៅសហគមន៍/អ្នកចំណូលស្រុក | • ប្រសិនបើការងារសាងសង់ធ្វើឡើងនៅក្នុង ឬជិតផ្លូវថ្នល់ ឬប្រព័ន្ធបង្ហូរទឹក សកម្មភាពសាងសង់អាចរំខាន ឬរាំងស្ទះចរាចរណ៍លើផ្លូវទាំងនោះ។<br>• ការដឹកលុងអាចធ្វើឲ្យបាត់បង់គម្របដំណាំ ឬប៉ះពាល់ដល់ផ្ទៃដី។<br>• ការដឹកលុងអាចរំខានដល់ប្រតិបត្តិការ និងសេវាដែលផ្តល់ដោយហេដ្ឋារចនាសម្ព័ន្ធមានស្រាប់ក្នុងមូលដ្ឋាន ដូចជា ការផ្គត់ផ្គង់ទឹក ការបង្ហូរទឹក បណ្តាញថាមពល។ល។ ប្រសិនបើបំពង់/បណ្តាញរត់កាត់ទីតាំងជីកលុង។<br>• គំនរសម្ភារ/វត្ថុធាតុដែលបានជីកកកាយ។<br>• ប្រសិនបើសកម្មភាពសាងសង់ធ្វើឡើងនៅជិតទីតាំងកសិកម្ម អាចមានការរំខានដល់លទ្ធភាពប្រើប្រាស់ដីកសិកម្ម។ វត្ថុធាតុសំណល់ និងទឹកកខ្វក់ពីការដ្ឋានអាចជ្រៀតចូលក្នុងកសិដ្ឋានដែលធ្វើឲ្យផលិតភាពធ្លាក់ចុះ និងបង្កទំនាស់ក្នុងសង្គម។<br>• ប្រសិនបើការដ្ឋានស្ថិតនៅជិតមជ្ឈមណ្ឌលសហគមន៍ ការលើកដាក់វត្ថុធាតុ/សម្ភារ ឬសំឡេងរំខានពីការកាត់ ខួង និងផ្សារ អាចរាំងស្ទះលទ្ធភាពចេញចូលមជ្ឈមណ្ឌលសហគមន៍ ឬរំខានដល់កិច្ចប្រជុំសាធារណៈ។ | • ការសម្អាតទីតាំង<br>• ការជីកលុង<br>• ប្រតិបត្តិការគ្រឿងម៉ាស៊ីន<br>• ការទប់ទន្លេ/ចរន្តទឹក/ប្រឡាយធារាសាស្ត្រមានស្រាប់ជាបណ្តោះអាសន្នដើម្បីធ្វើការងារសាងសង់<br>• ការបិទផ្លូវជាបណ្តោះអាសន្នដើម្បីធ្វើការតភ្ជាប់នឹងបណ្តាញផ្លូវថ្មី |
| ១៥ | សុខភាព និងអនាម័យក្នុងសហគមន៍មូលដ្ឋាន | • ទឹកនឹងក្នុងការដ្ឋានក្លាយជាជម្រកមូសដែលជាភ្នាក់ងារបង្កជំងឺតាមទឹក។<br>• សំណល់បន្សល់ដោយកម្មករដែលស្នាក់ | • ការជីកលុងធ្វើឲ្យមានរណ្តៅ ឬជម្រៅ |

| | | | |
|---|---|---|---|
| | | នៅការដ្ឋាន អាចទាក់ទាញសត្វចង្រៃ និងសត្វល្អិត។<br>• ទឹកកខ្វក់អាចបង្កការរំខាន និងហានិភ័យសុខភាពដល់មនុស្ស។ | |
| ១៦ | ហានិភ័យសុវត្ថិភាពក្នុងសហគមន៍ | • សកម្មភាពពាក់ព័ន្ធនឹងការសាងសង់អាចបង្កហានិភ័យសុវត្ថិភាពដល់សហគមន៍មូលដ្ឋាន ជាពិសេសកុមារប្រសិនបើពួកគេចេញចូលរណ្ដៅ ឬមានវត្តមាននៅការដ្ឋានក្នុងពេលដឹកជញ្ជូន/លើកដាក់សម្ភារ/វត្ថុធាតុ។ | • ការដឹកជញ្ជូនសម្ភារៈ/សំណល់<br>• ការលើកដាក់សម្ភារៈ<br>• រណ្ដៅជ្រៅ<br>• ប្រតិបត្តិការគ្រឿងម៉ាស៊ីន |
| ១៧ | សុខភាព និងសុវត្ថិភាពកម្មករ | • រណ្ដៅដែលគ្មានការការពារក្នុងការដ្ឋាន ការប្រឈមនឹងចរាចរណ៍តាមផ្លូវ ខ្សែភ្លើងដែលបំពាក់មិនបានសមស្រប ការធ្វើប្រតិបត្តិការ និងរៀបចំចាត់ចែងរោងចក្រសាងសង់ គ្រឿងម៉ាស៊ីន និងឧបករណ៍នានា អាចបង្កហានិភ័យសុវត្ថិភាពដល់កម្មករ។ | • សកម្មភាពសាងសង់ទូទៅ ការប្រើប្រាស់ឧបករណ៍ និងដំណើរការរោងចក្រ |
| **• ដំណាក់កាលប្រតិបត្តិការ** | | | |
| ១ | ការបំពុលទឹក/ដី | • ការលេចជ្រាប ឬការបង្ហូរសំណល់ និងទឹកកខ្វក់ដែលបង្ហូរចេញពីការដ្ឋាន។ | • សកម្មភាពប្រើប្រាស់ទឹកនៅបរិវេណអគារ/ជម្រក |
| ២ | ការបំពុលទឹក/ដី | • ការបង្ហូរទឹកកខ្វក់ដែលមិនបានធ្វើប្រព្រឹត្តកម្មបំពុលប្រភពទឹក។<br>• ការបោះចោលសំណល់មិនបានសមរម្យ<br>• ការលេចធ្លាយចេញពីអាងទឹកសំអុយអាចបំពុលទឹកលើផ្ទៃដី ជាពិសេសប្រសិនបើមានការដាក់បំពង់បូមកណ្ដាលវាល។<br>• ការលេចជ្រាបនូវសារធាតុដែលបានធ្វើ | • ហេដ្ឋារចនាសម្ព័ន្ធអនាម័យ |

| | | | |
|---|---|---|---|
| | | ប្រព្រឹត្តកម្មខ្លះៗចេញពីអាងទឹកសំអុយ អាចបំពុលទឹកលើផ្ទៃដីក្នុងអណ្តូងជីក សូម្បីតែក្រោយរយៈពេលជាច្រើនឆ្នាំ។<br>• ទឹកពុលលើផ្ទៃដីដែលលេចជ្រាបពីអាងទឹកសំអុយអាចជ្រាបចូលក្នុងទឹកលើដី។ | |
| ៣ | ផលប៉ះពាល់ជាក់ស្តែង | • ប្រសិនបើហេដ្ឋារចនាសម្ព័ន្ធលេចឡើងក្នុងទីសារធារណៈ និងប៉ះពាល់ដល់តម្លៃទេសភាពជុំវិញ<br>• សំណល់រឹង | • ហេដ្ឋារចនាសម្ព័ន្ធអនាម័យ/បង្ហូរទឹក<br>• សំណល់រឹង |
| ៤. | ការរំខាន ក្លិន កង្វះអនាម័យ ហានិភ័យសុខភាពសាធារណៈ | • អាងទឹកសំអុយជះក្លិនមិនល្អ និងអាចរំខានដល់សាធារណជន (ហិតក្លិន/មើលឃើញ)។<br>• សំណល់រឹង<br>• ការលេចជ្រាបពីអាងទឹកសំអុយត្រូវបានធ្វើប្រព្រឹត្តកម្មខ្លះៗតែប៉ុណ្ណោះ និងអាចបង្កជំងឺឆ្លង។<br>• កង្វះប្រព័ន្ធបង្ហូរទឹកសមស្របនៅជុំវិញប្រភពទឹករូប៊ីណេសាធារណៈ បង្កជាភក់នៅជុំវិញទឹករូប៊ីណេ ឬក្នុងទីធ្លា។ ទឹកនឹង ក្លាយជាជម្រកមូស និងបង្កការលំបាកដល់អ្នកប្រើប្រាស់ទឹក។<br>• ក្បាលរូប៊ីណេចំហ ឬគ្មានគម្របត្រឹមត្រូវអាចបង្ហូរទឹកចេញយ៉ាងច្រើន និងធ្វើឲ្យបាត់បង់ទឹកសម្រាប់ប្រើប្រាស់។ | • អនាម័យ<br>• សំណល់រឹង |
| ៦. | កង្វះអនាម័យ ហានិភ័យសុខភាពសាធារណៈ | • ភក់ល្បាប់/កំទេចកំណានៅប្រភពទឹករូប៊ីណេសាធារណៈ ធ្វើឲ្យបាត់បង់អនាម័យ និង/ឬបង្កើតជាជម្រកមូស។<br>• សំណល់រឹង | • ការផ្គត់ផ្គង់ទឹក<br>• សំណល់រឹង |

| | | | |
|---|---|---|---|
| ៧. | ប៉ះពាល់ដល់តម្រូវការទឹកនៅខ្សែទឹកខាងក្រោម | • នៅពេលលំហូរទឹកត្រូវបានស្តុកទុកខ្លះនៅខ្សែទឹកខាងលើ ដោយអ្នកប្រើប្រាស់ទឹកមួយក្រុម ក្រុមអ្នកប្រើប្រាស់ផ្សេងទៀតអាចមិនសូវមានលទ្ធភាពប្រើប្រាស់ទឹកដែលខ្លួនត្រូវការ។ បញ្ហានេះអាចបង្កទំនាស់ក្នុងសង្គមរវាងក្រុមសហគមន៍ផ្សេងៗ។ | • ការផ្គត់ផ្គង់ទឹក |
| ៨ | បាតុភូតអាកាសធាតុមិនល្អ/គ្រោះមហន្តរាយធម្មជាតិ ដូចជា ខ្យល់ព្យុះ។ | • បាតុភូតអាកាសធាតុមិន/គ្រោះមហន្តរាយធម្មជាតិអាចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធដែលផ្តល់ដោយគម្រោង ឬរំខានដល់សេវាដែលផ្តល់ដោយហេដ្ឋារចនាសម្ព័ន្ធទាំងនេះ។<br>• ក្នុងករណីមួយចំនួន បាតុភូតអាកាសធាតុមិនល្អ ដូចជា ព្យុះសីក្លូន អាចមិនបង្កការខូចខាតផ្ទាល់ដល់ហេដ្ឋារចនាសម្ព័ន្ធ ប៉ុន្តែបំផ្លាញវត្ថុនៅទីតាំងជុំវិញ ហើយវត្ថុទាំងនេះអាចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ ដែលផ្តល់ដោយគម្រោង ដូចជា ដើមឈើរលំលើស៊ីទែនទឹក។ | • ជំនន់ទឹកភ្លៀង<br>• ការបំផ្លាញទីតាំងភូមិសាស្ត្រ |

### ៤.២.២ ផលប៉ះពាល់ផ្នែកសង្គមដែលអាចកើតឡើង

**ជាតិពន្ធុនៅកម្ពុជា**

ផ្អែកលើការអង្កេតប្រជាជនចុងក្រោយ (ក្រសួងផែនការ ឆ្នាំ ២០១៣) កម្ពុជាមានជាតិពន្ធុ ២៤ ក្រុម។ តំបន់ដែលមានជនជាតិដើមភាគតិចរស់នៅច្រើនបំផុតស្ថិតនៅភាគខាងជើង និងភាគឦសាននៃប្រទេសកម្ពុជា ដូចជា ខេត្តក្រចេះ (ស្ទៀង ក្រោល មិល ព្នង កួយ ថ្មូន) មណ្ឌលគិរី (ព្នង ស្ទៀង ក្រោល រ្វង រដែ) រតនគិរី (ទំពួន ចារ៉ាយ គ្រឹង ព្រៅ លុន កាវេត កាចក់) ស្ទឹងត្រែង (កួយ ព្នង កាវ៉េត គ្រឹង ខិ លុន ព្រៅ) ព្រះវិហារ (កួយ) និងកំពង់ធំ (កួយ) និងតំបន់ប្រជុំភ្នំនៅខេត្តកោះកុង (ព័រ) ពោធិ៍សាត់ (ព័រ) កំពង់ស្ពឺ (សួយ) និងព្រះសីហនុ (ស្អូច)។ តំបន់ទាំងនេះស្ថិតនៅតាមបណ្តោយព្រំដែនប្រទេសវៀតណាម ឡាវ និងថៃ។ ផ្ទុយទៅវិញ តំបន់ភាគកណ្តាល និងដងទន្លេមេគង្គសំបូរដោយជនជាតិខ្មែរ។ កង្វះការសិក្សាពីប្រជាជន

បានបង្កការលំបាកដល់ការកំណត់ចំនួនក្រុមជាតិពន្ធុនៅកម្ពុជា។ ក្រសួងអភិវឌ្ឍន៍ជនបទលើកឡើងថាជនជាតិដើមភាគតិចអាចរស់នៅក្នុងសហគមន៍របស់ខ្លួនលាយឡំនឹងសហគមន៍ជនជាតិខ្មែរ ឬបានធ្វើសមាហរណកម្មពេញលេញក្នុងសហគមន៍ខ្មែរ ប៉ុន្តែនៅតែរក្សាលក្ខណៈមួយចំនួនរបស់ខ្លួន និងភាសារបស់ខ្លួនក្នុងករណីខ្លះ។ ការងារចុះតាមខេត្តដែលមានសក្តានុពលបញ្ជាក់ថា អ្នកដែលកំណត់អត្តសញ្ញាណដោយខ្លួនឯងថាជាជនជាតិដើមភាគតិច លើកឡើងថា ពួកគេអាចទំនាក់ទំនងដោយប្រើប្រាស់ភាសាខ្មែរ និងភាសាដើមរបស់ខ្លួន។ ជនជាតិដើមភាគច្រើននិយាយថា ពួកគេបានរស់នៅក្នុងសហគមន៍ជនជាតិខ្មែរជាងមួយជំនាន់មកហើយ។

ដូចការរកឃើញក្នុងជំរឿនប្រជាជន រដ្ឋាភិបាលកម្ពុជាលើកឡើងថាមានក្រុមជាតិពន្ធុ ២៦៤.៦០០ នាក់ កំពុងរស់នៅក្នុងប្រទេសកម្ពុជា ឬប្រហែល ៤% នៃចំនួនប្រជាជនសរុប។ ជនជាតិចាម ឬខ្មែរអ៊ីស្លាម គឺជាក្រុមជាតិពន្ធុធំជាងគេទីពីរបន្ទាប់ពីជនជាតិខ្មែរ។ សហគមន៍ជនជាតិចិនដែលមានប្រហែល ៣៤.៥០០ នាក់ គឺជាក្រុមជាតិពន្ធុធំជាងគេទីបី ចំណែកលំដាប់ទីបួនគឺជនជាតិព្នងរស់នៅតំបន់ខ្ពង់រាប។ សហគមន៍ជនជាតិវៀតណាមត្រូវបានកំណត់ជាក្រុមជាតិពន្ធុធំជាងគេទី ៧។ រហូតដល់ឆ្នាំ ១៩៩២ ទើបជនជាតិចិន និងវៀតណាមត្រូវបានកំណត់ជាក្រុមជាតិពន្ធកម្ពុជា ទន្ទឹមគ្នានឹងជនជាតិដើមភាគតិច និងជនជាតិចាម។

លើកលែងតែក្រុងភ្នំពេញ រាល់ខេត្តដែលអាចស្ថិតក្រោមវិសាលភាពគម្រោងសុទ្ធតែជាតំបន់ដែលក្រសួងអភិវឌ្ឍន៍ជនបទកត់សម្គាល់ពីវត្តមានគ្រួសារជនជាតិភាគតិច ដែលរស់នៅក្នុង ឬក្បែរសហគមន៍ដោយឡែក ឬដីកសិកម្មក្នុងសហគមន៍ជនជាតិខ្មែរ។ ដូច្នេះ សកម្មភាពអនុគម្រោងមួយចំនួនអាចនឹងរួមបញ្ចូលគ្រួសារជនជាតិដើមភាគតិចមួយចំនួនក្នុងពេលអនុវត្តគម្រោង។ ប៉ុន្តែដោយសារតែលក្ខណៈអន្តរាគមន៍គម្រោងដែលស្នើឡើង និងគំរូរបចិញ្ចឹមជីវិតរបស់ជនជាតិភាគតិចក្នុងខេត្តគោលដៅរបស់គម្រោង គេយល់ថាហានិភ័យសង្គមដែលអាចកើតឡើងពាក់ព័ន្ធនឹងពួកគេមានទំហំតូច និងពាក់ព័ន្ធតែនឹងភាពចាំបាច់ក្នុងការពិគ្រោះយោបល់ស្តីពីការងារស៊ីវិល និងកែសម្រួល និងបកប្រែឯកសារបណ្តុះបណ្តាលស្តីពីបញ្ហានានា ដូចជា ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត ព័ត៌មានពាក់ព័ន្ធនឹងកសិកម្ម និងសកម្មភាពបង្កើនការយល់ដឹងផ្សេងទៀត។

## ៥. នីតិវិធីសម្រាប់ពិនិត្យបឋម ត្រួតពិនិត្យ និងផ្តល់ការអនុញ្ញាត

ដើម្បីធានាឱ្យមានការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ការការពារបរិស្ថាន និងជីវចម្រុះ ត្រូវមានការពិនិត្យបឋមលើផលប៉ះពាល់បរិស្ថាន និងសង្គមឱ្យបានច្បាស់លាស់ ការសិក្សាវាយតម្លៃ និងការរៀបចំឧបករណ៍ធានាសុវត្ថិភាពបរិស្ថាន និងសង្គម (ដូចជា ECOP, EMP, IEE ឬ EIA) ក្នុងអនុគម្រោង នៃគម្រោង ដែលត្រូវបានលើកស្នើឡើងក្នុងសមាសភាគទី ១ និងទី ២ និងដែលអាចបង្កឱ្យមានផលប៉ះពាល់បរិស្ថាន និងសង្គមធ្ងន់ធ្ងរ ។

ផ្នែកនេះ អាចបែងចែកជាផ្នែកតូចៗ ដូចខាងក្រោម៖ i) ការពិនិត្យលើការធានាសុវត្ថិភាព និងការកំណត់វិសាលភាពនៃការវាយតម្លៃលើផលប៉ះពាល់, ii) ការរៀបចំវិធានការកាត់បន្ថយ និងកិច្ចពិគ្រោះយោបល់ជាមួយនឹងសាធារណជន, iii) ការពិនិត្យ ការឯកភាព និងការបង្ហាញពីឧបករណ៍ធានាសុវត្ថិភាពរបស់អនុគម្រោង, និង iv) ការអនុវត្ត ការតាមដាន ការត្រួតពិនិត្យ និងការរាយការណ៍។

## ៥.១ ការពិនិត្យបឋម និងគំនូសតាងបង្ហាញពីលំហូរ

ដំណើរការពិនិត្យបឋម ដូចជា ឧបសម្ព័ន្ធទី ១៖ ទម្រង់ពិនិត្យបឋមលើបរិស្ថាន និងសង្គម និងឧបសម្ព័ន្ធទី ៧ បញ្ជីអវិជ្ជមានដែលមានបញ្ចូលអនុគម្រោង ឬសកម្មភាពវិនិយោគ ដែលត្រូវបានហាមឃាត់មិនឱ្យទទួលបានហិរញ្ញប្បទានពីធនាគារពិភពលោក។ ការពិនិត្យបឋមមានគោលបំណង៖ (i) កំណត់ពីគោលនយោបាយស្តីពីការធានាសុវត្ថិភាពរបស់ធនាគារពិភពលោកដែលត្រូវយកមកអនុវត្ត, (ii) បែងចែកប្រភេទអនុគម្រោងជាប្រភេទ B ឬ C, និង (iii) ធ្វើការកំណត់ថាតើចាំបាច់ត្រូវមានការរៀបចំ ប្រភេទឧបករណ៍ធានាសុវត្ថិភាពសម្រាប់អនុគម្រោងដែរឬទេ។ ឧទាហរណ៍៖

- អនុគម្រោងដែលឋិតក្រោមប្រភេទ C ឬអនុគម្រោង (ដូចជា តម្លើងស្លាកសញ្ញាទេសចរណ៍) ដែលមានផលប៉ះពាល់បរិស្ថានតិចតួច ឬក្នុងកម្រិតទាប ត្រូវមាន ECOP និង/ឬ កិច្ចសន្យាការពារបរិស្ថាន (សូមមើលឧបសម្ព័ន្ធទី ២)។ ទីភ្នាក់ងារអនុវត្តន៍ មិនចាំបាច់រៀបចំរបាយការណ៍ IEE ឬរបាយការណ៍ EIA ប្រសិនបើអនុគម្រោងនេះត្រូវរៀបចំជា ECOP ឬកិច្ចសន្យាការពារបរិស្ថាន ព្រោះថាចំណុចនេះពុំត្រូវបានចែកក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យ EIA ឡើយ។
- អនុគម្រោងដែលឋិតក្នុងប្រភេទ B (ឧទាហរណ៍ ការកែលម្អផ្លូវថ្នល់) អនុគម្រោងដែលមានហានិភ័យបរិស្ថាន ពីមធ្យម រហូតដល់បង្គួរ នាយកដ្ឋាន EIA របស់ក្រសួងបរិស្ថាន តម្រូវឱ្យម្ចាស់គម្រោងរៀបចំ TOR (ក្នុងឧបសម្ព័ន្ធទី ៥) ដើម្បីធ្វើការវាយតម្លៃពីប្រភេទនៃឧបករណ៍ធានាសុវត្ថិភាព ដូចជា EMP ឬ IEE/EIA។
- អនុគម្រោងដែលឋិតក្រោមប្រភេទ A ដែលមានហានិភ័យបរិស្ថានខ្ពស់ ត្រូវមានរបាយការណ៍ EIA។ ក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទ គួរធ្វើការពិភាក្សាជាបន្ទាន់ពីករណីនេះ ជាមួយនឹងធនាគារពិភពលោក ព្រោះថាគេមិនរំពឹងថា នឹងមានអនុគម្រោងដែលឋិតក្នុងប្រភេទ "A" នោះឡើយ ហើយប្រភេទអនុគម្រោងទាំងនេះ ក៏ពុំអាចទទួលបានហិរញ្ញប្បទានពីគម្រោងដែរ លុះត្រាតែគម្រោងនេះត្រូវបានកែសម្រួលឡើងវិញ ជាគម្រោងប្រភេទ A។

## គំនូសតាងលំហូរ ដែលបង្ហើញពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសង្គម



## ៥.១.១ លក្ខខណ្ឌទូទៅនៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសង្គម

ជាទូទៅ ការពិនិត្យបឋម ត្រូវសម្រេច ដោយនាយកដ្ឋាន EIA របស់ក្រសួងបរិស្ថាន យោងតាមច្បាប់ជាតិ និងដោយធនាគារពិភពលោក យោងតាមគោលនយោបាយស្តីពីការធានាសុវត្ថិភាពរបស់ធនាគារ។ ដើម្បីវិភាគលើផលប៉ះពាល់បរិស្ថានក្នុង IEE ឬ EIA ចាំបាច់ត្រូវធ្វើការវិភាគ ដោយផ្តោតលើបីចំណុច៖ (១). ប្រភេទនៃផលប៉ះពាល់ (២). ការព្យាករណ៍ពីកម្រិតធ្ងន់ធ្ងរ និងវិសាលភាពនៃផលប៉ះពាល់ដែលអាចកើតមានឡើង និង (៣) ធ្វើការកំណត់ពីផលប៉ះពាល់។

ម្ចាស់គម្រោង ត្រូវដាក់ TOR ទៅកាន់នាយកដ្ឋាន EIA របស់ក្រសួងបរិស្ថាន និងរៀបចំកិច្ចពិគ្រោះយោបល់ ដើម្បីកំណត់ពីប្រភេទអនុគម្រោងដែលត្រូវមាន EMP ឬ IEE ឬ EIA។

## ៥.១.២ ការកំណត់ និងឆ្លើយតបចំពោះបញ្ហានានា

ក្រសួងខ្លួនឯង ត្រូវទទួលខុសត្រូវកំណត់ពីរាល់បញ្ហាពាក់ព័ន្ធទាំងអស់ ដែលអាចលើកឡើងដោយអ្នកជំនាញរបស់ក្រសួង អ្នកធ្វើការសម្រេចចិត្ត អ្នកជំនាញវិជ្ជាជីវៈ សាធារណជន ឬម្ចាស់គម្រោង និងត្រូវបញ្ចូលបញ្ហាទាំងនេះទៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសង្គម។ ក្រសួងទទួលបន្ទុក ត្រូវពិនិត្យ និងធ្វើការពិចារណាលើបញ្ហាទាំងនេះ ក្នុងដំណាក់កាលពិគ្រោះយោបល់ និងដំណាក់កាលក្រោយៗទៀត បើទោះបីជាក្រសួងដទៃទៀត ម្ចាស់គម្រោង ឬសាធារណជន ពុំបានលើកឡើងពីការព្រួយបារម្ភទាំងនេះ ក្នុងដំណាក់កាលកំណត់វិសាលភាពក៏ដោយ។ ចាំបាច់ត្រូវមានការកំណត់លើសំណើនេះដោយប្រុងប្រយ័ត្ន ដើម្បីជ្រើសរើសគ្រប់បញ្ហាទាំងអស់។

ជាទូទៅ នឹងមានការផ្តល់យោបល់ផ្សេងៗគ្នា ពាក់ព័ន្ធនឹងគម្រោងដែលត្រូវបានស្នើឡើង។ យោបល់មួយចំនួន អាចមានសារៈសំខាន់គ្រប់គ្រាន់ ដើម្បីឱ្យគេអាចយកមកធ្វើការពិចារណា និងចងក្រងទុកជាឯកសារសឱ្យបានត្រឹមត្រូវ។ បញ្ហាសំខាន់ៗដែលត្រូវធ្វើការពិចារណា មានដូចជា៖

- សកម្មភាពគម្រោងដែលបង្កឱ្យមានផលប៉ះពាល់
- ផលប៉ះពាល់មកលើធនធានបរិស្ថានដែលមានស្រាប់
- ផលប៉ះពាល់សង្គម
- ទីតាំងសកម្មភាពជាក់លាក់ និងទីតាំងផលប៉ះពាល់ជាក់លាក់
- ពេលដែលសកម្មភាព និងផលប៉ះពាល់កើតមានឡើង
- ទំនាក់ទំនងហេតុ និងផលដែលសកម្មភាពបង្កឱ្យមានផលប៉ះពាល់ដោយផ្ទាល់ ផលប៉ះ

ពាល់ប្រយោល ឬបណ្តុំផលប៉ះពាល់។

### ៥.១.៣ ការកំណត់ពីសារៈសំខាន់នៃផលប៉ះពាល់

ក្រសួងបរិស្ថាន ត្រូវធ្វើការកំណត់ពីវិសាលភាពនៃផលប៉ះពាល់របស់គម្រោង ដែលត្រូវបានលើកស្នើឡើង។ ការកំណត់នេះ គឺជាមូលដ្ឋានសម្រាប់ឱ្យនាយកដ្ឋាន EIA របស់ក្រសួងបរិស្ថាន ធ្វើការរៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានសង្គមបឋម ឬពេញលេញ និងគោលនយោបាយធានាសុវត្ថិភាពរបស់ធនាគារពិភពលោក។ នាយកដ្ឋាន EIA របស់ក្រសួងបរិស្ថាន ត្រូវធ្វើការពិចារណាលើបញ្ជីត្រួតពិនិត្យ បញ្ជីតារាងម៉ាទ្រីក និងតារាងអូវើឡេ (Overlay) (ឧបសម្ព័ន្ធទី៣៖ តារាងសង្ខេប ដែលបង្ហាញពីវិសាលភាពនៃវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន)។

## ៥.២ ការកំណត់វិសាលភាព

ការកំណត់វិសាលភាពនេះ គឺជាដំណាក់កាលដំបូងដែលត្រូវធ្វើឡើងក្នុង EIA បន្ទាប់ពីបានបញ្ចប់ការពិនិត្យបឋមលើអនុគម្រោង។ វាគឺជាដំណាក់កាលដើម្បីធ្វើការកំណត់ពីទំហំ IEIA ឬ EIA និងទិន្នន័យដែលចាំបាច់ត្រូវប្រមូល និងវិភាគពីផលប៉ះពាល់ដែលគម្រោងមានលើបរិស្ថាន សង្គម ដែលការសិក្សាបែបនេះ ទាមទារឱ្យមានការរៀបចំនូវលក្ខខណ្ឌប្រតិបត្តិ សម្រាប់រៀបចំរបាយការណ៍ហេតុប៉ះពាល់បរិស្ថាន សង្គម។

### ៥.២.១ វិសាលភាព

ត្រូវមានការកំណត់វិសាលភាព ដើម្បីត្រូវលើកឡើង ក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន សង្គម។ សកម្មភាពគម្រោងដែលត្រូវបានលើកស្នើនីមួយៗ គោលបំណងនៃការកំណត់វិសាលភាពមានដូចជា៖

- ការជំរុញឱ្យមានការចូលរួមពីសាធារណជន ដែលរងផលប៉ះពាល់
- ការកំណត់ពីបញ្ហាដែលនឹងកើតមានឡើង តំបន់/ព្រំប្រទល់
- ការកំណត់លើធនធានបរិស្ថានដែលមានស្រាប់ និងឯកសារដែលពាក់ព័ន្ធដទៃទៀត
- កំណត់ពីជម្រើសដែលអាចមាន។

### ៥.២.២ ការពិចារណាអំពីវិសាលភាព

ដើម្បីកំណត់ពីវិសាលភាព ម្ចាស់គម្រោងត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុច ដូចតទៅ៖

- ផ្តល់ឱកាសឱ្យមានការចូលរួមពីតំណាងស្ថាប័នរដ្ឋាភិបាល

អាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធ សហគមន៍ដែលរងផលប៉ះពាល់ ជនជាតិដើមភាគតិច អង្គការមិនមែនរដ្ឋាភិបាល និងក្រុមដែលពាក់ព័ន្ធដទៃទៀត

- ភូមិ សហគមន៍ដែលអាចរងផលប៉ះពាល់
- កំណត់ពីបញ្ហាដែលពាក់ព័ន្ធនឹងសកម្មភាពគម្រោង ដែលត្រូវបានលើកស្នើឡើង ដែលអាចបង្កឱ្យមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ និងធ្វើការវិភាគបញ្ហាទាំងនេះឱ្យបានស៊ីជម្រៅ ក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានសង្គម
- សម្រាប់បញ្ហាដែលគេមិនរំពឹងថា បង្កឱ្យមានផលប៉ះពាល់គួរឱ្យកត់សម្គាល់លើគុណភាពបរិស្ថាន និងសង្គម របាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សង្គម គួររៀបរាប់ត្រឹមតែមូលហេតុដែលនាំឱ្យមានផលប៉ះពាល់ទាំងនេះដោយសង្ខេបតែប៉ុណ្ណោះ
- កំណត់ពីជម្រើសដែលអាចមាន ដើម្បីយកមកធ្វើការពិចារណា។

## ៥.៣ លក្ខខណ្ឌប្រតិបត្តិ

លក្ខខណ្ឌប្រតិបត្តិ គឺជាការពិពណ៌នាពីគ្រប់ការងារទាំងអស់ដែលត្រូវធ្វើ នៅពេលធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមបឋម ឬពេញលេញ ស្របតាមវិសាលភាពនៃការសិក្សានេះ ដើម្បីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (ឧបសម្ព័ន្ធទី ៥៖ លក្ខខណ្ឌប្រតិបត្តិគំរូសម្រាប់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍)។

លក្ខខណ្ឌប្រតិបត្តិនេះ ត្រូវរៀបរាប់ពីវិសាលភាពនៃរបាយការណ៍វាយតម្លៃលហេតុប៉ះពាល់ លើបរិស្ថាន សង្គម និងត្រូវប្រើប្រាស់ជាផែនទីបង្ហាញផ្លូវដ៏សំខាន់ សម្រាប់ក្រសួងបរិស្ថាន អ្នករៀបចំរបាយការណ៍ និងអ្នកពិនិត្យលើរបាយការណ៍។

ទម្រង់នៃលក្ខខណ្ឌប្រតិបត្តិ ត្រូវយកគំរូតាមប្រកាសស្តីពីលក្ខខណ្ឌប្រតិបត្តិរបស់ក្រសួងបរិស្ថាន។

## ៥.៤ ការវាយតម្លៃលើហេតុប៉ះពាល់បរិស្ថានសង្គម

នៅក្នុងដំណាក់កាលនីមួយៗនៃប្រតិបត្តិការរបស់គម្រោងអភិវឌ្ឍន៍ នឹងមានផលប៉ះពាល់មកលើធនធានរូបវន្ត ធនធានជីវសាស្ត្រ និងធនធានសង្គមសេដ្ឋកិច្ចជាមិនខាន។ ដូច្នេះ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សង្គម ត្រូវធ្វើការពិចារណាពីគ្រប់សកម្មភាពពាក់ព័ន្ធនឹងគម្រោងទាំងអស់ ដូចជាបច្ចេកវិទ្យាជាក់លាក់ជាដើម ក្នុងសេចក្តីពិពណ៌នាសម្រាប់គម្រោងដែលត្រូវបានលើកស្នើឡើង។ ចាំបាច់

ត្រូវមានការរៀបចំរបាយការណ៍ឱ្យបានល្អ ដើម្បីរៀបរាប់ពីផលប៉ះពាល់ បង្កឡើងដោយសកម្មភាពរបស់គម្រោង។

## ៥.៥ ផលប៉ះពាល់ និងវិធានការកាត់បន្ថយ

ផលប៉ះពាល់ដោយផ្ទាល់ និងប្រយោល ត្រូវបានវាយតម្លៃក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន សង្គម។

- ផលប៉ះពាល់ផ្ទាល់៖ គឺផលប៉ះពាល់ដែលកើតមានឡើងនៅពេលតែមួយ និងកន្លែងតែមួយ ដូចគ្នានឹងសកម្មភាពរបស់គម្រោងដែលត្រូវបានលើកស្នើឡើង។
- ផលប៉ះពាល់ប្រយោល៖ គឺជាផលប៉ះពាល់ដែលកើតមានឡើងនៅក្រោយមកទៀត ឬនៅឆ្ងាយពីសកម្មភាពគម្រោង ដែលត្រូវបានលើកស្នើឡើង។
- បណ្តុំផលប៉ះពាល់៖ គឺជាផលប៉ះពាល់ដែលអាចមានទំហំតូចសម្រាប់គម្រោងណាមួយ ប៉ុន្តែនៅពេលដែលមានការពិនិត្យបញ្ចូលគ្នាលើគម្រោង ដែលអនុវត្តកាលពីអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ផលប៉ះពាល់អាចមានទំហំគួរឱ្យកត់សម្គាល់។ ជាទូទៅមានការវិភាគលើផលប៉ះពាល់ផ្ទាល់ និងប្រយោលរួមគ្នា។ ការវិភាគលើបណ្តុំផលប៉ះពាល់គួរធ្វើឡើងសម្រាប់គ្រប់ធនធានទាំងអស់ ដែលត្រូវបានលើកឡើងថាជាបញ្ហា និងអាចបញ្ចូលគ្នា ដើម្បីកំណត់ជាផលប៉ះពាល់គម្រោងដែលត្រូវបានលើកស្នើឡើង។ ដំណើរការកំណត់វិសាលភាពបឋម នឹងជួយធ្វើការកំណត់រកធនធាន ដែលរងផលប៉ះពាល់ជាបណ្តុំពីសកម្មភាពគម្រោងដែលត្រូវបានលើកស្នើឡើង។
- ផលប៉ះពាល់អវិជ្ជមាន៖ គឺជាផលប៉ះពាល់ដែលបង្កឡើងដោយវត្តមានរបស់គម្រោងដែលអាចបង្កផលប៉ះពាល់ជាអវិជ្ជមានដល់ធនធានសេដ្ឋកិច្ច និងសង្គម។

## ៥.៦ ផែនការគ្រប់គ្រងបរិស្ថាន (EMP)

នៅក្នុងផ្នែកនេះ ម្ចាស់គម្រោងត្រូវមានមូលនិធិគ្រប់គ្រាន់សម្រាប់ការពារបរិស្ថាន និងត្រូវបង្កើតជំនាញដែលមានសមត្ថភាពមួយក្រុម ឧបករណ៍សមស្រប វិធីសាស្ត្រ និងធ្វើការវិភាគ ដើម្បីពិនិត្យតាមដានគុណភាពបរិស្ថាន ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួងពាក់ព័ន្ធ ក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ដែលគម្រោងបង្កលើបរិស្ថាន ធនធាន

ធម្មជាតិ និងធនធានសង្គមសេដ្ឋកិច្ច។ ផែនការគ្រប់គ្រងបរិស្ថាន ផ្តោតលើសមាសភាគសំខាន់ៗ ដូចខាងក្រោម៖

- ការពិពណ៌នាដោយសង្ខេបពីផលប៉ះពាល់អវិជ្ជមានធំៗ និងវិធានការកាត់បន្ថយផលប៉ះពាល់ទាំងនេះ

កម្មវិធីបណ្តុះបណ្តាល

- កម្មវិធីពិនិត្យតាមដានបរិស្ថាន ក្នុងអំឡុងដំណាក់កាលសាងសង់ ដំណាក់កាលប្រតិបត្តិការ និងដំណាក់កាលបញ្ចប់គម្រោង
- ផែនការថវិកាសម្រាប់អនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថាន
- ផែនការសម្រាប់មូលនិធិបរិស្ថាន និងសង្គម។

ផែនការគ្រប់គ្រងបរិស្ថាន (EMP)៖ EMP របស់គម្រោងមួយ ត្រូវបញ្ចូលវិធានការកាត់បន្ថយផលប៉ះពាល់ វិធានការពិនិត្យតាមដាន និងវិធានការស្ថាប័ន ដែលត្រូវអនុវត្តក្នុងអំឡុងពេលអនុវត្តន៍ និងប្រតិបត្តិការគម្រោង ដើម្បីលុបបំបាត់ផលប៉ះពាល់អវិជ្ជមានមកលើបរិស្ថាន និងសង្គម កាត់កងផលប៉ះពាល់ទាំងនេះ ឬកាត់បន្ថយផលប៉ះពាល់ទាំងឱ្យនៅត្រឹមកម្រិត ដែលអាចទទួលយកបាន។ ផែនការនេះក៏មានបញ្ចូលសកម្មភាពដែលចាំបាច់ សម្រាប់អនុវត្តវិធានការទាំងនេះផងដែរ។ EMP គឺជាសមាសភាគសំខាន់ៗនៃរបាយការណ៍របស់ EA សម្រាប់គម្រោងប្រភេទ A[15]។ ដោយឡែកសម្រាប់គម្រោងប្រភេទ B ជាច្រើន EA អាចរៀបចំតែផែនការគ្រប់គ្រងតែប៉ុណ្ណោះ។ ដើម្បីរៀបចំផែនការគ្រប់គ្រង អ្នកខ្ចីកម្ចី និងក្រុមរចនាគម្រោងរបស់ EA (ក) ត្រូវធ្វើការកំណត់ពីការឆ្លើយតបចំពោះផលប៉ះពាល់អវិជ្ជមាន ដែលអាចកើតមានឡើង, (ខ) កំណត់ពីលក្ខខណ្ឌ ដើម្បីជានាយ៉ាងណាឱ្យការឆ្លើយតបទាំងនេះ ធ្វើឡើងប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា, និង (គ) រៀបរាប់ពីមធ្យោបាយ ដើម្បីបំពេញទៅតាមលក្ខខណ្ឌតម្រូវទាំងនេះ។

ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន (EMP) និងកិច្ចពិគ្រោះយោបល់ជាមួយសាធារណជន៖ EMP រៀបរាប់ពីគោលការណ៍ និងសកម្មភាពជាមូលដ្ឋាន ដើម្បីធ្វើឡើងដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានឡើង។ EMP ត្រូវលើកឡើងដោយសង្ខេបពីសេចក្តីពិពណ៌នាអំពីអនុគម្រោង

[15] គម្រោងបិតក្រោមគោលការណ៍ណែនាំស្តីពី EIA របស់ក្រសួងបរិស្ថាន អាចមានន័យថាជាអនុគម្រោង ដែលបិតក្រោម ESMF ឬ OP ៤.០១ របស់ធនាគារពិភពលោក។

សាវតារសង្គម និងបរិស្ថាននៃតំបន់អនុគម្រោង និងផែនទីដែលបង្ហាញពីទីតាំងរបស់អនុគម្រោង និងសកម្មភាពតាមទីតាំងជាក់លាក់ និង/ឬ ដំណើរការទៅតាមការសមស្រប, ផលប៉ះពាល់ដែលអាចកើតមានឡើង និងវិធានការកាត់បន្ថយផលប៉ះពាល់ដែលត្រូវបានលើកស្នើឡើង និងការរៀបចំថវិកាសម្រាប់អនុវត្ត និងពិនិត្យតាមដាន។ មាតិកាទូទៅនៃ EMP មានបង្ហាញជូនក្នុងឧបសម្ព័ន្ធទី គ នៃ OP 4.01 និងត្រូវបានបញ្ចូលក្នុងឧបសម្ព័ន្ធទី ៣។ កិច្ចពិគ្រោះយោបល់ជាមួយនឹងសាធារណជន ត្រូវធ្វើឡើងជាផ្នែកមួយនៃការរៀបចំ EMP។ សម្រាប់អនុគម្រោងនីមួយៗ ត្រូវធ្វើការកំណត់ឱ្យបានច្បាស់លាស់ពីសកម្មភាពដែលត្រូវធ្វើដើម្បីវាយតម្លៃ និងកាត់បន្ថយហានិភ័យពាក់ព័ន្ធ ក៏ដូចជា ផលប៉ះពាល់ដែលអាចកើតមានឡើង ក្នុងអំឡុងពេលសម្អាតទីតាំង និងក្នុងអំឡុងការសាងសង់ និងកាត់បន្ថយហានិភ័យ ក្នុងអំឡុងពេលប្រតិបត្តិការ។ យ៉ាងហោចណាស់ EMP ត្រូវបញ្ចូល ECOP ដែលមានលក្ខណៈស្តង់ដារ (ឧបសម្ព័ន្ធទី ២) និងវិធានការកាត់បន្ថយតាមទីតាំងជាក់លាក់ រួមនឹងកម្មវិធីពិនិត្យតាមដានបរិស្ថានផងដែរ។ គោលការណ៍ណែនាំស្តីពីរៀបចំ និងឧទាហរណ៍គំរូអំពី EMP មានបង្ហាញជូនក្នុងឧបសម្ព័ន្ធទី ៣។

## ៥.៧ កិច្ចពិគ្រោះយោបល់ជាមួយនឹងសាធារណជន

គោលបំណងនៃការចូលរួមរបស់សាធារណជនក្នុងដំណើរការចូលរួមរបស់សាធារណជន គឺដើម្បីផ្តល់ឱ្យអ្នករងផលប៉ះពាល់ដោយសារគម្រោង និងតួអង្គពាក់ព័ន្ធដទៃទៀត មានឱកាសទទួលបានព័ត៌មាន និងចូលរួមពិគ្រោះយោបល់អំពីគម្រោង ឬសកម្មភាពនានាដើម្បីផ្តល់យោបល់លើគម្រោង ឬសកម្មភាពទាំងនេះ និងផ្តល់លទ្ធភាពឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាព និងអត្ថន័យក្នុងគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសង្គម។

ការចូលរួមរបស់សាធារណជន អាចធ្វើឡើងនៅកម្រិតផ្សេងៗគ្នានៃការចូលរួម និងការប្រាស្រ័យទាក់ទង។ ការចូលរួមជាសាធារណៈបែបនេះ ត្រូវបានហៅថាជាកម្រិតនៃការចូលរួមរបស់សាធារណជន។ ការចូលរួមបែបនេះចាប់ផ្តើមនៅកម្រិតសាមញ្ញបំផុត គឺការជូនដំណឹង (ការផ្តល់ព័ត៌មាន) ដល់អ្នករងផលប៉ះពាល់ដោយសារគម្រោង និងដល់តួអង្គពាក់ព័ន្ធនានា។ កម្រិតពីរបន្ទាប់មកទៀត ដូចជា "ការពិគ្រោះយោបល់" និង "ការចូលរួមដោយផ្ទាល់" គឺសំដៅលើការចូលរួមរបស់អ្នករងផលប៉ះពាល់ដោយសារគម្រោង និងតួអង្គពាក់ព័ន្ធ។ ការចូលរួមរបស់សាធារណជន អាចកើតឡើងច្រើនទម្រង់ ប៉ុន្តែវាជាផ្នែកមួយនៃការផ្តល់មតិត្រលប់ជាមុន ទៅម្ចាស់គម្រោង។ កម្រិតខ្ពស់បំផុតនៃការចូលរួមរបស់សាធារណជន គឺការសហការ។ សម្រាប់ការចូលរួមរបស់សាធារណជននៅទាំងពីកម្រិតនេះ និងជនដែល

រងផលប៉ះពាល់ដោយសារគម្រោង នឹងត្រូវចូលរួមដោយផ្ទាល់ក្នុងកម្រិតខ្ពស់ជាមួយនឹងគម្រោង ក្នុងដំណើរការនេះ ពោលគឺពួកគេនឹងក្លាយទៅជាដៃគូ និងមានកម្រិតស្មើគ្នានឹងម្ចាស់គម្រោងដែរ។

## ៥.៨ សេចក្តីសម្រេចចិត្ត

នាយកដ្ឋាន EIA របស់ក្រសួងបរិស្ថាន ត្រូវពិនិត្យ និងអនុម័តលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានសង្ខេបបឋម ឬពេញលេញស្របតាមនីតិវិធី និងដំណើរការនៃការពិនិត្យ និងផ្តល់យោបល់។

## ៥.៩ ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈពីគម្រោង ដែលបានទទួលការអនុម័ត

ត្រូវមានការធានាថា របាយការណ៍នឹងអាចចូលមើលបានដោយសាធារណជនទូទៅ និងត្រូវមានការផ្សព្វផ្សាយព័ត៌មានដល់សាធារណជនទូទៅ តាមរយៈមធ្យោបាយ និងប្រព័ន្ធផ្សព្វផ្សាយសមស្រប ដូចជា គេហទំព័ររបស់ក្រសួងបរិស្ថាន និងដាក់តាំងជាឯកសារនៅសាលាក្រុង/ខេត្ត និងមន្ទីរបរិស្ថាន និង/ឬសាលាឃុំ/សង្កាត់។

## ៥.១០ ការពិនិត្យតាមដានគម្រោង

ចំពោះការគ្រប់គ្រងគម្រោង ម្ចាស់គម្រោងត្រូវគោរពទៅតាមលក្ខខណ្ឌពិនិត្យតាមដាន ដែលត្រូវបានកំណត់ដោយស្ថាប័ននិយតកម្ម ហើយម្ចាស់គម្រោងត្រូវដាក់របាយការណ៍ពិនិត្យតាមដានបរិស្ថាន ឱ្យបានទាន់ពេលវេលាទៅកាន់ស្ថាប័នធ្វើនិយតកម្ម និងត្រូវសហការជាមួយនឹងមន្ត្រីជំនាញ ពាក់ព័ន្ធមកពីក្រសួងពាក់ព័ន្ធក្នុងការពិនិត្យតាមដានការអនុវត្តការគ្រប់គ្រងបរិស្ថាននេះ។ ដំណើរការតាមដានការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ត្រូវធ្វើឡើងស្របតាម៖

- ការទទួលខុសត្រូវរបស់ក្រសួង ក្នុងការអនុវត្តតាមកិច្ចព្រមព្រៀងស្តីពីការការពារបរិស្ថាន
- បណ្តឹងតវ៉ារបស់សហគមន៍

គុណតម្លៃនៃការពិនិត្យតាមដាន គឺការកំណត់រកឃើញបញ្ហាដែលអាចកើតមានឡើងទាន់ពេលវេលា។ ឧទាហរណ៍ វិធីដែលល្អបំផុតដើម្បីកាត់បន្ថយផលប៉ះពាល់លើគុណភាពទឹក គឺត្រូវធ្វើការកំណត់ឱ្យបានទាន់ពេលវេលានៅកម្រិតក្នុងសំណាកគំរូ និងវិធានការកាត់បន្ថយផលប៉ះពាល់នេះ មុនពេលកំហុសកើតមានឡើង បើធៀបនឹងស្តង់ដារអនុវត្តន៍។ ផែនការពិនិត្យតាមដាន គួរផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងវិធានការកាត់បន្ថយផលប៉ះពាល់ជាក់លាក់ ដូច្នេះ ប្រសិនបើការពិនិត្យតាមដានបង្ហាញថា ពិតជាមានបញ្ហាមែននោះ (ឧទាហរណ៍ ប្រសិនបើគុណភាពទឹកឋិតក្រោមស្តង់ដារ) វិធានការកាត់បន្ថយផលប៉ះពាល់ជាក់លាក់ នឹងត្រូវអនុវត្តដោយម្ចាស់គម្រោង/ប្រតិបត្តិករ ម្ចាស់គម្រោងត្រូវមានមូលនិធិគ្រប់

គ្រាន់សម្រាប់អនុវត្តន៍ផែនការពិនិត្យតាមដាន និងផែនការកាត់បន្ថយហានិភ័យបញ្ហា ដែលកើតមានឡើង។

# ៦. ការរៀបចំការអនុវត្ត

## ៦.១ ការទទួលខុសត្រូវលើការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម

ទីភ្នាក់ងារអនុវត្តន៍ទាំងពីរ៖ ក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទ សុទ្ធតែមានបទពិសោធន៍ជាមួយនឹងគម្រោង ដែលទទួលបានមូលនិធិគាំទ្រពីធនាគារពិភពលោកកន្លងមក ដូចជាគម្រោង Kh-DRM និងគម្រោង Kh-CASDP (កំពុងអនុវត្ត) និងគម្រោង BPMAP (បានបញ្ចប់) ប៉ុន្តែមន្ត្រីបង្គោលទទួលបន្ទុកការងារធានាសុវត្ថិភាពបរិស្ថាន និងសង្គម គឺជាមនុស្សថ្មីសម្រាប់គោលនយោបាយស្តីពីការធានាសុវត្ថិភាពរបស់ធនាគារ។ លើសពីនេះ គម្រោង BPAMP ដែលអនុវត្តដោយក្រសួងបរិស្ថាន គឺជាគម្រោងមួយផ្សេងខុសពីគម្រោងដែលលើកស្នើឡើងនេះ និងពាក់ព័ន្ធតែជាមួយនឹងតំបន់ការពារតែមួយ ហើយក៏មានការផ្តល់ធាតុចូលយ៉ាងច្រើនពីទីប្រឹក្សាអន្តរជាតិ ហើយគេមិនប្រាកដទេថាបទពិសោធន៍ បែបនេះមានភាពពាក់ព័ន្ធខ្លាំងជាមួយនឹងគម្រោង ដែលលើកស្នើឡើងនេះ បើគិតពីការធានាសុវត្ថិភាពបរិស្ថាននោះ។ ដោយសារតែការកំណត់ទីតាំងគម្រោង នឹងត្រូវធ្វើឡើងក្នុងអំឡុងពេលអនុវត្ត ក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទ បានរៀបចំនូវក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) ដើម្បីធានាយ៉ាងណាឱ្យសកម្មភាព ឬអនុគម្រោងនីមួយៗនៃគម្រោង CSLEP ត្រូវបានពិនិត្យបឋម និងវាយតម្លៃកំណត់ពីភាពអនុលោមទៅតាមគោលនយោបាយស្តីពីការធានាសុវត្ថិភាពរបស់រដ្ឋាភិបាល និងធនាគារក្នុងអំឡុងពេលអនុវត្តន៍។ ESMF ត្រូវបានរៀបចំឡើង ដើម្បីធានាយ៉ាងណាមិនឱ្យអនុគម្រោង CSLEP បង្កើត ឬនាំឱ្យមានផលប៉ះពាល់អវិជ្ជមានលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងបរិស្ថាន និងមានការកំណត់ពីផលប៉ះពាល់ដែលអាចកើតមានឡើង បញ្ចៀសផលប៉ះពាល់ទាំងនេះ ឬយ៉ាងហោចណាស់កាត់បន្ថយផលប៉ះពាល់ឱ្យនៅកម្រិតអប្បបរមា។ ESMF មានបញ្ចូលគោលការណ៍ណែនាំស្តីពីការពិនិត្យបឋមលបរិស្ថាន និងសង្គម និងការវាយតម្លៃលើហេតុប៉ះពាល់ ក្នុងគោលបំណង៖

(ក) បង្ការ និង/ឬ កាត់បន្ថយផលប៉ះពាល់លើបរិស្ថាន និងសង្គម ដែលអាចកើតចេញពីសកម្មភាពដែលត្រូវបានលើកស្នើឡើង

(ខ) ធានាថាអត្ថប្រយោជន៍ដែលបានពីសកម្មភាពដែលត្រូវបានលើកស្នើឡើង និងអាចធានាបាននូវបរិស្ថានក្នុងរយៈពេលវែង តាមរយៈការធានាសុវត្ថិភាពមូលដ្ឋានធនធានធម្មជាតិ ដែលសកម្មភាពទាំងនេះពឹងអាស្រ័យលើ និង

(គ) ផ្ដួចផ្ដើមសម្របសម្រួលការអនុវត្តសកម្មភាព ដែលគេរំពឹងថានឹងបង្កើនប្រសិទ្ធភាពការប្រើប្រាស់ និងការកែលម្អការគ្រប់គ្រងធនធានធម្មជាតិ ដែលនាំឱ្យមានការធានាបាននូវស្ថិរភាព និង/ឬការបង្កើនគុណភាពបរិស្ថាន និងសុខុមាលភាពមនុស្សក្នុងមូលដ្ឋាន។

ការអនុវត្ត EMP, IEE ឬ EIA ត្រូវគោរពទៅតាមប្រព័ន្ធគ្រប់គ្រង និងអនុវត្តន៍គម្រោងរបស់រដ្ឋាភិបាល ដែលឋិតនៅក្រោមការដឹកនាំរបស់ក្រសួងបរិស្ថាន។ ECOP សម្រាប់អនុគម្រោងដែលបង្កផលប៉ះពាល់តិចតួច (ដូចជា ការតម្លើងស្លាកសញ្ញាជាដើម) គឺជាលក្ខខណ្ឌតម្រូវដោយធនាគារពិភពលោក មិនមែនដោយក្រសួងបរិស្ថាននោះឡើយ។ ក្រសួងបរិស្ថានទទួលខុសត្រូវដឹកនាំដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដោយនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានធ្វើជាសេនាធិការសម្រាប់ការងារនេះ។

ក្រសួងបរិស្ថាន គឺជាទីភ្នាក់ងារអនុវត្តន៍គម្រោង សហការជាមួយនឹងក្រសួងទេសចរណ៍ ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងរៀបចំដែនដី នគរូបនីយ-កម្ម និងសំណង់, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងរ៉ែ និងថាមពល, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, និងស្ថាប័នពាក់ព័ន្ធសម្រាប់គម្រោងដែលពាក់ព័ន្ធនានា។ នៅថ្នាក់ជាតិ ក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទ ទទួលខុសត្រូវលើការអនុវត្តការគ្រប់គ្រងប្រសិទ្ធភាព និងការសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងជាមួយនឹងវិនិយោគិន ឬម្ចាស់គម្រោង។ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) របស់ក្រសួងបរិស្ថាន ទទួលខុសត្រូវលើការពិនិត្យ និងអនុម័តលើ TOR និងការអនុវត្ត EMP, IEE និង EIA នៅកម្រិតអនុគម្រោង។

នាយកដ្ឋាន EIA ដែលឋិតក្រោមក្របខ័ណ្ឌនៃក្រសួងបរិស្ថាន និងដែលត្រូវបានបង្កើតឡើង ចាប់តាំងពីឆ្នាំ ១៩៩៤ មក គឺជាស្ថាប័នទទួលខុសត្រូវលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ទោះជាយ៉ាងនេះក្ដី ប្រកាសស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននេះ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តកាលពីពេលថ្មីៗនេះ ក្នុងខេត្ត ធ្នូ ឆ្នាំ ២០០៥ តែប៉ុណ្ណោះ។

រាល់ដំណើរការរៀបចំ វាយតម្លៃ ពិនិត្យ និងអនុម័តលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានសង្គម ត្រូវគោរពតាមនីតិវិធី ច្បាប់ និងលិខិតុបករណ៍គតិយុត្តដែលមានស្រាប់របស់ជាតិ។

## ការទទួលខុសត្រូវស្ថាប័ន ESMF

| សហគមន៍/ទីភ្នាក់ងារ | ការទទួលខុសត្រូវ |
|---|---|
| | |
| ទីភ្នាក់ងារអនុវត្តន៍៖ ក្រសួងបរិស្ថាន និង ក្រសួងអភិវឌ្ឍន៍ជនបទ | ក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទ ទទួលខុសត្រូវលើការគ្រប់គ្រងក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម។ អនុគម្រោងនីមួយៗ ត្រូវរៀបចំរបាយការណ៍ពិនិត្យបឋមលើសង្គម និងបរិស្ថាន ដើម្បីបញ្ជាក់ថាតើចាំបាច់ត្រូវរៀបចំ ECOP (ឬ កិច្ចព្រមព្រៀងស្តីពីការការពារបរិស្ថាន) ឬ EMP ឬ IEE/EIA។ ECOP (សម្រាប់ធនាគារពិភពលោក និងកិច្ចសន្យាស្តីពីការការពារបរិស្ថានសម្រាប់ក្រសួងបរិស្ថាន) គឺចាំបាច់សម្រាប់ករណីដែលមានហានិភ័យបរិស្ថានតិចតួច ឬក្នុងកម្រិតទាប នៅកម្រិតអនុគម្រោង។ EMP ឬ IEE/EIA គឺចាំបាច់សម្រាប់ហានិភ័យបរិស្ថានមធ្យម ឬខ្ពស់នៅកម្រិតអនុគម្រោង។<br>ក្រសួងបរិស្ថាន និងក្រសួង ឬស្ថាប័នពាក់ព័ន្ធ ទទួលខុសត្រូវលើការពិនិត្យតាមដានការអនុវត្តគម្រោង ក៏ដូចជា ភាពអនុលោមទៅតាមការការពារបរិស្ថានរបស់គម្រោង។ ក្រសួងបរិស្ថាន និងក្រសួង ឬស្ថាប័នពាក់ព័ន្ធ ជាអ្នកទទួលខុសត្រូវចុងក្រោយលើការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម។ ក្រសួងបរិស្ថាន និងក្រសួង ឬស្ថាប័នពាក់ព័ន្ធ ត្រូវ ១) សហការឱ្យបានជិតស្និទ្ធជាមួយនឹងអាជ្ញាធរមូលដ្ឋាន ដើម្បីជំរុញឱ្យមានការចូលរួមពីសហគមន៍ ក្នុងអំឡុងពេលរៀបចំឱ្យអនុវត្តគម្រោង ២) ពិនិត្យតាមដាន និងគ្រប់គ្រងការអនុវត្តក្របខ័ណ្ឌវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ៣) ធានាថា ប្រព័ន្ធវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវបានរៀបចំ និងបំពេញមុខងារយ៉ាងត្រឹមត្រូវ និង ៤) រៀបចំរបាយការណ៍ស្តីពីការពិនិត្យតាមដានផែនការគ្រប់គ្រងបរិស្ថានដែលដាក់ជូនធនាគារពិភពលោក។ |

| | |
|---|---|
| | ដើម្បីអនុវត្តគម្រោង ESMF ឱ្យមានប្រសិទ្ធភាព ក្រសួងបរិស្ថានបានយល់ព្រមតែងតាំងជនបង្គោលថ្មី ទទួលខុសត្រូវការជានាសុវត្ថិភាពបរិស្ថាន មុនពេលអនុវត្តគម្រោង។ |
| មន្ត្រីមង្គោលទទួលបន្ទុកការជានាសុវត្ថិភាពបរិស្ថានរបស់ក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទ និងនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន | តួនាទីរបស់មន្ត្រីបង្គោលទទួលបន្ទុកជានាសុវត្ថិភាពបរិស្ថាន ដែលតែងតាំងដោយក្រសួងបរិស្ថាន គឺត្រូវសម្របសម្រួលជាមួយនឹងនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់ក្រសួងបរិស្ថាន និងផ្ញើឯកសារអនុគម្រោង (ដូចជា TORs និង EMP/IEE/EIA) ទៅកាន់នាយកដ្ឋាន EIA របស់ក្រសួងបរិស្ថាន។ |
| នាយកដ្ឋាន EIA របស់ក្រសួងបរិស្ថាន | នាយកដ្ឋាន EIA ទទួលខុសត្រូវពិនិត្យតាមដានការអនុវត្តសកម្មភាពគម្រោង។ នាយកដ្ឋាន EIA ទទួលខុសត្រូវលើ i) កពិនិត្យបឋមលើអនុគម្រោងនានា ធៀបនឹងលក្ខណៈវិនិច្ឆ័យ កំណត់ពីភាពសមស្រប ដើម្បីកំណត់ពីផលប៉ះពាល់លើបរិស្ថាន និងសង្គម គោលនយោបាយដែលត្រូវយកមកអនុវត្ត និងឧបករណ៍ដែលត្រូវរៀបចំ; ii) ពិនិត្យឡើងវិញលើ EIAs/EPCs និង EMPs របស់អនុគម្រោង ដែលរៀបចំដោយទីប្រឹក្សា ដើម្បីជានាយ៉ាងណាឱ្យឯកសារទាំងនេះមានគុណភាព។<br>នាយកដ្ឋាន EIA របស់ក្រសួងបរិស្ថាន មានតួនាទីពិនិត្យឡើងវិញ អនុម័ត និងពិនិត្យតាមដានឯកសារជានាសុវត្ថិភាពបរិស្ថាន ដែលទីភ្នាក់ងារអនុវត្ត (ពោលគឺក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទ) ផ្ញើមក។ |
| ចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សាដែលធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន | តាមរយៈការសម្របសម្រួលជាមួយនឹងមន្ត្រីបង្គោលទទួលបន្ទុកការជានាសុវត្ថិភាពបរិស្ថាន ម្ចាស់គម្រោងត្រូវជួលក្រុមហ៊ុន EIA ក្នុងស្រុក ដែលត្រូវបានចុះបញ្ជីឱ្យរៀបចំ TORs សម្រាប់រៀបចំ EMP ឬ IEE ឬ EIA នៅកម្រិតអនុគម្រោង។ ក្រុមហ៊ុននេះត្រូវជួយម្ចាស់គម្រោងក្នុងការរៀបចំ EMP ឬ IEE ឬ EIA ដោយត្រូវធ្វើការពិគ្រោះយោបល់ជាមួយនឹងធនាគារពិភពលោក មុនពេលដាក់ជូននាយកដ្ឋាន EIA របស់ក្រសួងបរិស្ថាន ពិនិត្យ និងអនុម័ត។ |

| | |
|---|---|
| អ្នកទទួលការ | - ផ្អែកតាម EMP និងព័ត៌មានយថាប្រភេទ/លក្ខខណ្ឌតម្រូវផ្នែកបរិស្ថាន ដែលបានទទួលការអនុម័តក្នុងឯកសារដេញថ្លៃ និងឯកសារកិច្ចសន្យា អ្នកទទួលការទទួលខុសត្រូវរៀបចំ EMP សម្រាប់ទីតាំងដែលមានការសាងសង់នីមួយៗ ផ្ញើផែនការទៅឱ្យម្ចាស់អនុគម្រោង/ទីភ្នាក់ងារអនុវត្ត និង CSC ដើម្បីពិនិត្យ និងអនុម័ត មុនពេលចាប់ផ្ដើមការងារសាងសង់។ លើសពីនេះ អ្នកទទួលការត្រូវទទួលបានការអនុញ្ញាតទាំងអស់សម្រាប់ការងារសាងសង់ (ដូចជា ការគ្រប់គ្រង និងការបង្វែទិសចរាចរ ការកកាយដី សុវត្ថិភាពកម្មករ។ល។ មុនពេលចាប់ផ្ដើមការងារសាងសង់) ទៅតាមលិខិតបទដ្ឋានគតិយុត្ត ដែលកំពុងចូលជាធរមាន។<br>- អ្នកទទួលការ ត្រូវតែងតាំងបុគ្គលដែលមានសមត្ថភាពម្នាក់ឱ្យធ្វើជា *មន្ត្រីទទួលបន្ទុកសុវត្ថិភាព និងបរិស្ថាន* នៅនឹងទីតាំងរបស់ខ្លួន ដែលមន្ត្រីរូបនេះជាអ្នកទទួលខុសត្រូវពិនិត្យតាមដានភាពអនុលោមរបស់អ្នកទទួលការ ទៅតាមលក្ខខណ្ឌតម្រូវក្នុង EMP និងព័ត៌មានយថាប្រភេទអំពីបរិស្ថាន។<br>- ចាត់វិធានការកាត់បន្ថយរាល់ផលប៉ះពាល់អវិជ្ជមាន ដែលអាចកើតមានឡើងទាំងអស់ ស្របតាមគោលដៅ ដែលរៀបរាប់ក្នុង EMP។<br>- ទំនាក់ទំនងឱ្យបានសកម្មជាមួយនឹងប្រជាពលរដ្ឋនៅមូលដ្ឋាន និងចាត់វិធានការដើម្បីបង្ការមិនឱ្យមានការរំខានក្នុងអំឡុងពេលសាសង់។<br>- ធានាយ៉ាងណាឱ្យបុគ្គលិក និងកម្មករយល់ពីនីតិវិធី និងពីកិច្ចការដែលពួកគេត្រូវធ្វើនៅក្នុងប្រព័ន្ធគ្រប់គ្រងបរិស្ថាន។<br>- រាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធអំពីការលំបាកនានា និងដំណោះស្រាយចំពោះបញ្ហាទាំងនោះ។<br>រាយការណ៍ជូនអាជ្ញាធរមូលដ្ឋាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ ប្រសិនបើមានគ្រោះថ្នាក់កើតមានឡើងពាក់ព័ន្ធនឹងបរិស្ថាន និងធ្វើការសម្របសម្រួលជាមួយនឹងទីភ្នាក់ងារ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីដោះស្រាយបញ្ហាទាំងនេះ។ |

| | |
|---|---|
| សហគមន៍មូលដ្ឋាន | - សហគមន៍មានសិទ្ធិ និងទទួលខុសត្រូវពិនិត្យតាមដានជាប្រចាំលើសមិទ្ធកម្មបរិស្ថាន ក្នុងអំឡុងពេលសាងសង់ ដើម្បីធានាយ៉ាងណាឱ្យមានការការពារឱ្យបានគ្រប់គ្រាន់ដល់សិទ្ធិ និងសុវត្ថិភាពរបស់ពួកគេ និងហើយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធនានា/ម្ចាស់អនុគម្រោង និងអ្នកទទួលការត្រូវអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់ប្រកបដោយប្រសិទ្ធភាព។ នៅក្នុងករណីដែលមានបញ្ហាមិនបានរំពឹងទុកកើតមានឡើង ពួកគេត្រូវរាយការណ៍ទៅកាន់ CSC/ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ/ម្ចាស់អនុគម្រោង។ |
| រដ្ឋបាលថ្នាក់ក្រោមជាតិៈ ថ្នាក់ខេត្ត ស្រុក និងឃុំ | - សម្របសម្រួលជាមួយអ្នកទទួលការ និងទីភ្នាក់ងារអនុវត្តនៅថ្នាក់ជាតិ ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីវិធានការកាត់បន្ថយហានិភ័យ និងសម្របសម្រួលឆ្លើយតបចំពោះបណ្តឹងតវ៉ារបស់សហគមន៍មូលដ្ឋាន ពាក់ព័ន្ធនឹងការអនុវត្ត EMP។ |

## ៦.២ ការរៀបចំរបាយការណ៍

ការរៀបចំរបាយការណ៍ស្តីពីការអនុវត្ត ESMF មិនមែនធ្វើឡើងដាច់ដោយឡែកនោះឡើយ ព្រោះថាសមិទ្ធកម្មនៃការធានាសុវត្ថិភាព នឹងត្រូវបញ្ចូលទៅក្នុងរបាយការណ៍វឌ្ឍនភាព។ ផ្នែកនានានៃគម្រោងត្រូវរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគម្រោងមួយដងក្នុងមួយឆ្នាំ។

## ៧. ការកសាងសមត្ថភាព និងការបណ្តុះបណ្តាល

ពិន្ទុដែលដាក់ឱ្យហានិភ័យបរិស្ថាន និងសង្គមរបស់គម្រោងនេះ នៅដំណាក់កាលនេះ គឺកម្រិតបង្គួរ ព្រោះថាទាំងក្រសួងបរិស្ថាន ទាំងក្រសួងអភិវឌ្ឍន៍ជនបទ សុទ្ធតែត្រូវការការគាំទ្រយ៉ាងច្រើនក្នុងអំឡុងពេលអនុវត្តគម្រោង។ ក្រសួងអភិវឌ្ឍន៍ជនបទបានអនុវត្តគម្រោង ដែលទទួលបានថវិកាពីធនាគារពិភពលោក នៅខាងក្រៅតំបន់ការពារ។ ប្រសិនបើមិនពង្រឹងការអនុវត្តឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលានោះទេ ផ្លូវដែលត្រូវបានកែលម្អ ដែលអាចភ្ជាប់ទំនាក់ទំនងពីតំបន់មួយទៅតំបន់មួយទៀត អាចជួយសម្រួលដល់ការអនុវត្តសកម្មភាពខុសច្បាប់ ដូចជា ការទន្ទ្រានយកដីខុសច្បាប់ជាដើម។ ក្រសួងបរិស្ថានធ្លាប់អនុវត្តគម្រោង BPAM ក្រោមជំនួយរបស់ធនាគារពិភពលោក ប៉ុន្តែគម្រោងបានអនុវត្តកាលពីមួយទសវត្សរ៍មុន ដោយក្រុមគ្រប់គ្រងគម្រោងផ្សេងមួយទៀត។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសកម្ពុជាមាន

ហានិភ័យបរិស្ថានខ្ពស់ ព្រោះថាប្រទេសនេះជាប្រទេសដែលងាយរងគ្រោះ ដោយសារការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ និងការរេចរឹលធនធានធម្មជាតិ ដើម្បីកាត់បន្ថយហានិភ័យដែលអាចកើតមានឡើង ក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទ បានរៀបចំ ESMF នេះឡើង ដើម្បីបញ្ចៀសកាត់បន្ថយឱ្យបានជាអតិបរមា និងសម្រាលហានិភ័យផលប៉ះពាល់បណ្តោះអាសន្នតាមទីតាំងជាក់លាក់ ដែលអាចកើតឡើងចំពោះបរិស្ថាន និងប្រជាពលរដ្ឋ។ គេអាចគ្រប់គ្រងហានិភ័យបរិស្ថានអវិជ្ជមាន តាមរយៈការដាក់ឱ្យអនុវត្តនូវឧបករណ៍ធានាសុវត្ថិភាពបរិស្ថានរបស់គម្រោង (ឧទាហរណ៍ ESMF សម្រាប់គម្រោង; ESMP/IEE សម្រាប់អនុគម្រោងជាដើម) និងបម្រុងទុកថវិកាសម្រាប់ធានាសុវត្ថិភាព ដើម្បីជួលឱ្យទីប្រឹក្សាផ្តល់ការបណ្តុះបណ្តាលផ្ទាល់ និងបន្តកសាងសមត្ថភាពដល់មន្ត្រីបង្គោលទទួលបន្ទុកការធានាសុវត្ថិភាពបរិស្ថានរបស់ក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទ។

ដើម្បីធានាយ៉ាងណាឱ្យមានការអនុវត្ត ESMF ប្រកបដោយប្រសិទ្ធភាព គួរមានការវាយតម្លៃលើសមត្ថភាពរបស់ក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការគ្រប់គ្រងផលប៉ះពាល់ និងហានិភ័យបរិស្ថាន និងសង្គម និងក្នុងការអនុវត្តតាមច្បាប់ជាតិ និងលក្ខខណ្ឌតម្រូវរបស់ធនាគារពិភពលោក។ នៅក្នុងករណីនេះ ត្រូវមានការវាយតម្លៃលើតម្រូវការនៃការបណ្តុះបណ្តាល (TNA) ដោយទីប្រឹក្សាទទួលបន្ទុកការធានាសុវត្ថិភាពក្នុងអំឡុងពេលនៃការអនុវត្តគម្រោង។ TNA ត្រូវធ្វើលើអ្នកចូលរួមទាំងអស់ ដែលទទួលខុសត្រូវលើការអនុវត្ត ESMF។ ចាំបាច់ត្រូវមានការបែងចែកនូវតម្រូវក្នុងការផ្តល់ការបណ្តុះបណ្តាល ដូចជា ការបង្កើនការយល់ដឹង ការអប់រំផ្សព្វផ្សាយអំពីបញ្ហា និងការរៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេសលម្អិតជាដើម៖

- ការបង្កើនការយល់ដឹងដល់អ្នកចូលរួម ដែលចាំបាច់ត្រូវដឹងពីសារៈសំខាន់ ឬភាពពាក់ព័ន្ធនៃបញ្ហាបរិស្ថាន និងសង្គម
- ការផ្សព្វផ្សាយអំពីបញ្ហាទាំងនេះដល់អ្នកចូលរួម ដែលចាំបាច់ត្រូវដឹងពីបញ្ហាក្នុងកម្រិតមួយឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យពួកគេអាចលើសំណើដាក់លាក់សុំជំនួយបច្ចេកទេស និង
- ការបណ្តុះបណ្តាលបច្ចេកទេសលម្អិតដល់អ្នកចូលរួម ដែលចាំបាច់ត្រូវធ្វើការវិភាគលើផលប៉ះពាល់បរិស្ថាន និងសង្គម ដែលអាចកើតមានឡើង កំណត់ពីវិធីសាស្ត្រ និងវិធានការកាត់បន្ថយផលប៉ះពាល់ទាំងនេះ និងត្រៀមរៀបចំ ក៏ដូចជា គ្រប់គ្រងការអនុវត្តផែនការគ្រប់គ្រង។

ដើម្បីធានាយ៉ាងណាឱ្យសមត្ថភាពរៀបចំផែនការ និងអនុវត្តវិធានការធានាសុវត្ថិភាព គម្រោងនេះបានវិភាជន៍ថវិកាគ្រប់គ្រាន់ (ក្នុងជំពូកទី ៨) សម្រាប់ការបណ្តុះបណ្តាល ការកសាងសមត្ថភាព និងការផ្តល់ជំនួយបច្ចេកទេស ជាពិសេស ក្នុងឆ្នាំដំបូងៗ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ មិនត្រឹមតែផ្តល់ប្រយោជន៍ដល់គម្រោងរបស់ធនាគារពិភពលោកប៉ុណ្ណោះទេ ថែមទាំងជួយកសាងសមត្ថភាពអនុវត្តគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ដទៃទៀត ដែលទទួលបានថវិកាពីក្នុងស្រុក និងពីអ្នកផ្តល់ជំនួយដទៃទៀតផងដែរ។

## ៧.១ ការវាយតម្លៃសមត្ថភាពស្ថាប័ន

ការវាយតម្លៃលើសមត្ថភាពដែលមានស្រាប់របស់ស្ថាប័ន ក្នុងការអនុវត្ត ESMF ត្រូវបានលើកមកបង្ហាញក្នុងផ្នែកនេះ។ ផ្នែកនេះផ្តោតលើចំណុចសំខាន់ៗ ដូចខាងក្រោម៖

- រចនាសម្ព័ន្ធនៃស្ថាប័នជាតិ និងអាជ្ញាធរនៅគ្រប់កម្រិតដែលពាក់ព័ន្ធក្នុងការឆ្លើយតបចំពោះបញ្ហានៃការគ្រប់គ្រងបរិស្ថាន និងសង្គម ដែលមានភាពពាក់ព័ន្ធជាមួយនឹងគម្រោង និងអនុគម្រោង;
- ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ ពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន និងសង្គម ដូចជា លិខិតបទដ្ឋានសម្រាប់ផ្តល់លើការអនុញ្ញាត និងអាជ្ញាប័ណ្ណជាដើម;
- ចំនួន និងគុណវុឌ្ឍិរបស់បុគ្គលិក (មន្ត្រីរាជការ អង្គការសហគមន៍ ទីប្រឹក្សាខាងក្រៅ) ដើម្បីបំពេញការទទួលខុសត្រូវពាក់ព័ន្ធនឹង ESMF;
- ធនធានថវិកា សម្រាប់គាំទ្រដល់បុគ្គលិកក្នុងការបំពេញការងាររបស់ពួកគេ។

## ៧.២ ការបណ្តុះបណ្តាល

ESMF លើកឡើងថា អាចមានការវាយតម្លៃលើតម្រូវការបណ្តុះបណ្តាល ដែលជាផ្នែកមួយនៃការរៀបចំគម្រោង។ ការវាយតម្លៃលើតម្រូវការបណ្តុះបណ្តាលត្រូវពិចារណាពីតម្រូវការបណ្តុះបណ្តាលរបស់អ្នកចូលរួមទាំងអស់ ដែលទទួលខុសត្រូវលើការអនុវត្ត ESMF។ ការវាយតម្លៃដំណាក់កាលបណ្តុះបណ្តាលនេះនឹងកំណត់ពីតម្រូវការបណ្តុះបណ្តាលផ្សេងៗគ្នារបស់ពួកគេ ដូចជា ការបង្កើនការយល់ដឹង ការផ្សព្វផ្សាយអំពីបញ្ហា និងការបណ្តុះបណ្តាលបច្ចេកទេសលម្អិតជាដើម៖

- ការបង្កើនការយល់ដឹងដល់អ្នកចូលរួម ដែលត្រូវដឹងពីសារៈសំខាន់ ឬភាពពាក់ព័ន្ធនៃបញ្ហាបរិស្ថាន និងសង្គម

- ការផ្សព្វផ្សាយពីបញ្ហាទាំងអស់ដល់អ្នកចូលរួម ដែលចាំបាច់ត្រូវដឹងឲ្យបានគ្រប់គ្រាន់ពីបញ្ហាទាំងនេះ ដើម្បីអាចលើកឡើងនូវដំណោះស្រាយបច្ចេកទេសជាក់លាក់ ដើម្បីឆ្លើយតបចំពោះបញ្ហាទាំងនេះ
- ការបណ្តុះបណ្តាលបច្ចេកទេសលម្អិតដល់អ្នកចូលរួម ដែលចង់ដឹងពីរបៀបវិភាគលើផលប៉ះពាល់បរិស្ថាន និងសង្គមអវិជ្ជមាន ដែលអាចកើតមានឡើង និងដែលចង់ដាក់ចេញនូវវិធានការកាត់បន្ថយផលប៉ះពាល់ និងរៀបចំផែនការគ្រប់គ្រងបរិស្ថាន
- ក្រសួងបរិស្ថានត្រូវរៀបចំផែនការបណ្តុះបណ្តាល ផ្អែកតាមលទ្ធផលនៃការវាយតម្លៃលើសមត្ថភាពស្ថាប័ន តាមរយៈការកំណត់ពីប្រធានបទ របៀបវារៈ ធនធាន (ទីកន្លែង អ្នកបណ្តុះបណ្តាល និងឧបករណ៍បណ្តុះបណ្តាល សម្ភារៈ។ល។) ទៅតាមប្រភេទនៃការបណ្តុះបណ្តាល។

## ៨. ថវិកាសម្រាប់អនុវត្ត ESMF

ផ្នែកនៃ ESMF នេះបង្ហាញពីថវិកាប៉ាន់ប្រមាណដែលចាំបាច់ សម្រាប់ការអនុវត្តគម្រោង។ សម្រាប់ដំណើរការនេះ ក្រសួងបរិស្ថាន បានគ្រោងថវិកាសម្រាប់អនុវត្តសកម្មភាពសំខាន់ៗ ដូចខាងក្រោម៖

- សកម្មភាពអភិវឌ្ឍន៍ស្ថាប័ន;
- ការបណ្តុះបណ្តាល និងការពង្រឹងសមត្ថភាពស្ថាប័ន ទីប្រឹក្សា អាជ្ញាធរមូលដ្ឋាន ដែលចូលរួមពាក់ព័ន្ធក្នុងគម្រោង;
- ការជួលក្រុមហ៊ុនផ្តល់ប្រឹក្សា ដើម្បីធ្វើការវាយតម្លៃ និងរៀបចំរបាយការណ៍ហេតុប៉ះពាល់បរិស្ថាន និងសង្គម;
- ចំណាយលើប្រតិបត្តិការ ការសម្របសម្រួល និងការគ្រប់គ្រងគម្រោង;
- ការតាមដាន និងការវាយតម្លៃ;
- ការរៀបចំរបាយការណ៍

គម្រោងនេះបានវិភាជថវិកា ១.០០០.០០០ ដុល្លារ សម្រាប់ការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម៖ ការអនុវត្ត ការតាមដាន និងការរៀបចំរបាយការណ៍ស្តីពីភាពអនុលោមទៅតាមការធានាសុវត្ថិភាពផ្នែកបរិស្ថាន និងសង្គមរបស់គម្រោង។ ថវិកានេះគ្របដណ្តប់លើចំណាយសម្រាប់ជួលក្រុមហ៊ុន

EIA ដែលបានចុះបញ្ជី និងដែលមានសមត្ថភាព ការចុះតាមមូលដ្ឋាន ការបណ្តុះបណ្តាលបុគ្គលិក ឧបករណ៍បរិក្ខា និងគោលបំណងពាក់ព័ន្ធដទៃទៀត។ ផែនការថវិកាលម្អិតសម្រាប់អនុវត្តក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម មានបង្ហាញជូនខាងក្រោម។

### ផែនការថវិកាសម្រាប់ការអនុវត្តគម្រោង

| ល.រ | ពិពណ៌នា | ដុល្លារ |
|---|---|---|
| 1 | ចំណាយលើប្រតិបត្តិការ និងការគ្រប់គ្រងគម្រោង | 200,000 |
| 2 | ចំណាយលើឧបករណ៍ សម្ភារ និងបរិក្ខាសម្រាប់អនុវត្តគម្រោង | 100,000 |
| 3 | ចំណាយលើការពង្រឹងសមត្ថភាព ការរៀបចំកិច្ចប្រជុំ សិក្ខាសាលា វេទិកា និងវគ្គបណ្តុះបណ្តាល | 100,000 |
| 4 | ចំណាយលើការជួលទីប្រឹក្សា និងក្រុមហ៊ុន EIA ដែលបានចុះបញ្ជី សម្រាប់ធ្វើការរៀបចំរបាយការណ៍ IEE ឬ EIA និងផែនការគ្រប់គ្រងបរិស្ថាននៅកម្រិតអនុគម្រោង | 500,000 |
| 5 | ចំណាយផ្សេងៗ (១០%) | 100,000 |
| **សរុប** | | 1,000,000 |

## ៩. យន្តការដោះស្រាយសារទុក្ខ (GRM)

### ៩.១. យន្តការដោះស្រាយជម្លោះ

គ្រប់ប្រភេទនៃជម្លោះគឺកើតមានឡើងកំឡុងពេលរៀបចំរបាយការណ៍ប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គមរបស់អនុគម្រោង នៃសមាសភាគទាំងពីរ។ ភាគីជម្លោះអាចជ្រើសរើសយកប្រព័ន្ធតុលាការ ឬយកយន្តការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ ដូចខាងក្រោម។

#### ៩.១.១ យន្តការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ

ក. នីតិវិធីដោះស្រាយរវាងភាគីជម្លោះ

- កំណត់វិសាលភាពនៃការសម្រុះសម្រួល (ឧទាហរណ៍៖ តើកម្រិតណាដែលអាចសម្រុះ

សម្រួលបាន និងកម្រិតណាដែលមិនអាចសម្រុះសម្រួលបាន )

- បង្កើតជម្រើសនៃការសម្រុះសម្រួល ដូចជា៖
  - ការបង់ជំងឺចិត្ត ដោយផ្អែកលើការយោគយល់គ្នា និងការព្រមព្រៀងគ្នា
  - ជួសជុលការខូចខាត ( ស្តារឲ្យត្រឡប់ទៅរកសភាពដើមវិញ )
  - ធ្វើកិច្ចសន្យារវាងភាគីជម្លោះ
- អ្នកសម្រេចចិត្ត
  - អ្នកដែលរងផលប៉ះពាល់/មនុស្សចាស់/មេក្រុម និង/ឬ តំណាងសហគមន៍ ដែលទទួលបានសិទ្ធិតំណាងពីសមាជិក
  - ប្រធានក្រុមហ៊ុន/តំណាងក្រុមហ៊ុនដែលទទួលបានការអនុញ្ញាត

ខ. នីតិវិធីដំណោះស្រាយជម្លោះនៅថ្នាក់ក្រោមជាតិ

- អាជ្ញាធរឃុំ/សង្កាត់
  - ភាគីជម្លោះត្រូវដាក់ពាក្យបណ្តឹងជាលាយលក្ខអក្សរទៅអាជ្ញាធរឃុំ/សង្កាត់
  - ករណីដែលភាគីមិនពេញចិត្តនឹងការសម្រេចចិត្តរបស់អាជ្ញាធរឃុំ/សង្កាត់ ភាគីត្រូវដាក់ពាក្យបណ្តឹងទៅអាជ្ញាធរក្រុង/ស្រុក/ខណ្ឌ។
- អាជ្ញាធររាជធានី ឬ អាជ្ញាធរខេត្ត
  - ភាគីជម្លោះត្រូវដាក់ពាក្យបណ្តឹងជាលាយលក្ខអក្សរទៅអាជ្ញាធររាជធានី/ខេត្ត។
  - ករណីដែលភាគីមិនពេញចិត្តនឹងការសម្រេចចិត្តរបស់អាជ្ញាធររាជធានី/ខេត្ត ភាគីត្រូវដាក់ពាក្យបណ្តឹងទៅរដ្ឋបាលថ្នាក់ជាតិ។

គ. នីតិវិធីដោះស្រាយជម្លោះនៅថ្នាក់ជាតិ

  - ភាគីជម្លោះត្រូវដាក់ពាក្យបណ្តឹងជាលាយលក្ខអក្សរទៅស្ថាប័ន ឬ ក្រសួងដែលទទួលខុសត្រូវ។
  - ករណីដែលភាគីមិនពេញចិត្តនឹងការសម្រេចចិត្តរបស់ស្ថាប័ន ឬ ក្រសួងដែលទទួលខុសត្រូវ ភាគីត្រូវដាក់ពាក្យបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ច។

### ៩.១.១ យន្តការតុលាការ

ភាគីជម្លោះត្រូវដាក់ពាក្យបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ច ដោយអនុលោមទៅតាម នីតិវិធី និងប្បញ្ញត្តិដែលមាននៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។ ក្របខ័ណ្ឌគ្រប់គ្រងផ្នែកបរិស្ថាន និងសង្គម (ESMF)។

## ១០. ការពិគ្រោះយោបល់ និងការផ្សព្វផ្សាយក្របខ័ណ្ឌគ្រប់គ្រងផ្នែកបរិស្ថាន និងសង្គម

### ១០.១ ការពិគ្រោះយោបល់សាធារណៈ

ដំណើរការពិគ្រោះយោបល់ជាសាធារណៈ និងដំណើរការផ្សព្វផ្សាយជាសាធារណៈ កំឡុងពេលនៃដំណាក់កាលរៀបចំរបាយការណ៍ប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម គឺមានបង្ហាញលម្អិតនៅក្នុងផ្នែក ៥.៧ និង ៥.៩ នៃឯកសារនេះ។ ការពិគ្រោះយោបល់កំឡុងពេលរៀបចំក្របខ័ណ្ឌគ្រប់គ្រងផ្នែកបរិស្ថាន និងសង្គម។ ក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំការពិគ្រោះយោបល់ជាសាធារណៈមួយ ដែលផ្តោតលើសេចក្តីព្រាងក្របខ័ណ្ឌគ្រប់គ្រងផ្នែកបរិស្ថាន និងសង្គម នៅសណ្ឋាគារហ៊ីម៉ាវ៉ារី កាលពីថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៨។ បញ្ជីអ្នកចូលរួមមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ ៦។ យោបល់សំខាន់ៗទទួលបានពីការពិគ្រោះយោបល់ មានដូចជា ត្រូវលើកទឹកចិត្តឲ្យម្ចាស់គម្រោងបន្ត (sub-owners) បន្តធ្វើការពិគ្រោះយោបល់ជាសាធារណៈ ដូចជា ការពិចារណាអំពីយេនឌ័រ និងការសម្រិតសម្រាំងប្រភេទហានិភ័យផ្នែកបរិស្ថាន (A, B, និង C) សម្រាប់គម្រោង និងអនុគម្រោង។ យោបល់ទាំងនេះត្រូវបានឆ្លើយតបនៅក្នុងជំពូក ៥។ នៅក្នុងគោលការណ៍ណែនាំទូទៅសម្រាប់ EIA របស់ក្រសួងបរិស្ថាន មិនមានប្បញ្ញត្តិជាក់លាក់ពាក់ព័ន្ធនឹងភាគរយនៃការចូលរួមផ្នែកយេនឌ័រឡើយ។ ការពិគ្រោះយោបល់ជាសាធារណៈនឹងត្រូវធ្វើឡើងកំឡុងពេលរៀបចំតាក់តែង និងអនុវត្តអនុគម្រោងនីមួយៗ។ ការពិគ្រោះយោបល់សាជាធារណៈ គឺជាតម្រូវការពិសេសរបស់គោលនយោបាយគាំពារផ្នែកបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក និងគោលនយោបាយរបស់រដ្ឋាភិបាល តាមរយៈអនុក្រឹត្យលេខ ៧២ អនក្រ/បក ស្តីពីដំណើរការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម (EIA)។ ការពិគ្រោះយោបល់ ត្រូវគ្រប់ដណ្តប់លើច្បាប់ និងបទបញ្ញត្តិរបស់ប្រទេស ដែលពាក់ព័ន្ធទៅនឹងដំណើរការផ្សព្វផ្សាយ និងពិគ្រោះយោបល់ និងត្រូវបានប្រើសម្រាប់ផ្តល់ព័ត៌មានដល់អ្នកពាក់ព័ន្ធ និងឲ្យពួកគេចូលរួមក្នុងដំណើរការផ្នែកបរិស្ថាន និងសង្គម។

.

## ១០.២ ការផ្សព្វផ្សាយក្របខ័ណ្ឌគ្រប់គ្រងផ្នែកបរិស្ថាន និងសង្គម (ESMF)

ការផ្សព្វផ្សាយក្របខ័ណ្ឌគ្រប់គ្រងផ្នែកបរិស្ថាន និងសង្គម។ ក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទបានផ្សព្វផ្សាយ ESMF នៅលើគេហទំព័ររបស់ខ្លួនកាលពីខែធ្នូ ឆ្នាំ ២០១៨។ ESMF ដែលមានបច្ចុប្បន្នភាពចុងក្រោយដែលមានដាក់បញ្ចូលយោបល់ទទួលបានពីការពិគ្រោះយោបល់ គឺត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័ររបស់ក្រសួងបិរស្ថាន៖ www.moe-govt.kh និង គណនីហ្វេសប៊ុកផ្លូវការរបស់ក្រសួង៖ www.facebook.com/314699302002531/posts/1304089593063492 កាលពីថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៩។

### ឯកសារយោង


MoE (1996): ច្បាប់ ស្តីពី ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

MoE (2008): ច្បាប់ ស្តីពី តំបន់ការពារ

MoE (1999): អនុក្រឹត្យស្តីពីដំណើរការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន

MoE (1999): អនុក្រឹត្យស្តីពីការគ្រប់គ្រងការបំពុលទឹក

MoE (1999): អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង

MoE (2000): អនុក្រឹត្យស្តីពីការគ្រប់គ្រងការបំពុលបរិយាកាស និងសំឡេងរំខាន

MoE (2009): គោលការណ៍ណែនាំ ស្តីពី ការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន៖ *អនុក្រឹត្យស្តីពីការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន (១៩៩៩)*

MoE (2018): ប្រកាស ស្តីពី ក្របខ័ណ្ឌទំនួលខុសត្រូវ (ToR) នៃដំណើរការ IEE និង EIA សម្រាប់ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍។

World Bank (2018): *កម្ពុជា៖ គម្រោងទេសចរណ៍ធម្មជាតិ និងការអភិវឌ្ឍទេសភាពប្រកបដោយចីរភាព (P165344)*

World Bank (2018): *ឯកសារព័ត៌មានគម្រោង/តារាងទិន្នន័យរួមផ្នែកគាំពារ (PID/ISDS)*

## បញ្ជីឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១៖ តារាងត្រួតពិនិត្យការពិនិត្យបឋមផ្នែកសង្គម និងបរិស្ថាន សម្រាប់អនុគម្រោង

| |
|---|
| *តារាងត្រួតពិនិត្យការសម្រិតសម្រាំងអនុគម្រោងនេះ គឺសម្រាប់ម្ចាស់អនុគម្រោង/ភ្នាក់ងារអនុវត្តន៍យកទៅប្រើ ដើម្បីកំណត់ប្រភេទសមស្របនៃឯកសារគាំពារ ដែលនឹងតម្រូវដោយធនាគារពិភពលោក សម្រាប់អនុគម្រោង ដោយអនុលោមទៅតាម ESMF។* |

ឈ្មោះគម្រោង

ឈ្មោះអនុគម្រោង៖

ទីតាំងអនុគម្រោង៖ *(ដូចជា តំបន់ ស្រុក ។ល។)*

ប្រភេទសកម្មភាព៖ *(ដូចជា ការសាងសង់ថ្មី ការជួសជុល ការថែទាំតាមពេលកំណត់)*

ម្ចាស់អនុគម្រោង និងអាសយដ្ឋាន៖

ប្រភេទបរិស្ថាន នៃគម្រោងមេ៖ (ដូចជា A ឬ B)

### ១. ការពិនិត្យបឋមបរិស្ថានផ្នែកបច្ចេកទេស

1. ការពិនិត្យបឋមបរិស្ថានផ្នែកបច្ចេកទេសលើសំណើអនុគម្រោងនីមួយៗ គឺត្រូវបានធ្វើឡើង ដើម្បីកំណត់វិសាលភាពសមស្រប និងប្រភេទនៃការប៉ាន់ប្រមាណផ្នែកបរិស្ថាន (EA)។ លទ្ធផលនៃការពិនិត្យបឋមនេះ គឺត្រូវបានប្រើដើម្បីកំណត់ចំណាត់ថ្នាក់អនុគម្រោង ក្នុងប្រភេទមួយនៃប្រភេទទាំងបី អាស្រ័យលើប្រភេទ ទីតាំង ភាពងាយរងគ្រោះ វិសាលភាព លក្ខណៈ និងអនុភាពនៃផលប៉ះពាល់ផ្នែកបរិស្ថានជាសក្តានុពលរបស់អនុគម្រោង (OP ៤.០១ នៃកថាខ័ណ្ឌទី ៨)។

(a) ប្រភេទ A៖ សំណើអនុគម្រោង[16] ត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ A បើសិនជាវាទំនងនឹងមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរផ្នែកបរិស្ថាន ដែលមានភាពងាយរងគ្រោះ ភាពផ្សេងៗគ្នា ឬ ដែលមិនធ្លាប់កើតមាន

[16] sub-project can be equiventlyrefered to project under MOE’s EIA general guidelines.

ពីមុនមក។ ផលប៉ះពាល់ទាំងនេះ អាចមាននៅលើតំបន់មួយ ដែលធំជាងទីតាំង ឬ បរិក្ខារនៃការងារដែលត្រូវធ្វើទៅទៀត។

(b) ប្រភេទ B៖ សំណើអនុគម្រោង ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ B លុះត្រាតែផលប៉ះពាល់អវិជ្ជមានផ្នែកបរិស្ថានជាសក្តានុពលមកលើប្រជាជន តំបន់សំខាន់ៗផ្នែកបរិស្ថាន ដូចជា តំបន់ដីសើម ព្រៃឈើ ដីមានស្មៅ និងដីដែនជម្រកធម្មជាតិផ្សេងៗទៀត មានភាពអវិជ្ជមានតិចជាងគម្រោងក្នុងប្រភេទA។ ផលប៉ះពាល់ទាំងនេះ គឺមានស្ថានភាពជាក់លាក់ទៅតាមតំបន់នីមួយៗ ដូចជា វាមានតិច បើសិនផលប៉ះពាល់ណាមួយមិនអាចកែប្រែបាន និងក្នុងករណីភាគច្រើន វិធានការណ៍កាត់បន្ថយអាចត្រូវបានរៀបចំឡើងរួចរាល់ជាងគម្រោងក្នុងប្រភេទ A។

(c) ប្រភេទ C៖ សំណើគម្រោងដែលត្រូវបានចាត់ក្នុងប្រភេទ C បើសិនជាវាទំនងនឹងមានផលប៉ះពាល់អវិជ្ជមានតិចតួច ឬ គ្មានសោះមកលើបរិស្ថាន។ លើសពីការពិនិត្យបឋម គម្រោងក្នុងប្រភេទ C មិនចាំបាច់ធ្វើការប៉ាន់ប្រមាណផ្នែកបរិស្ថានទេ។

**កំណត់សម្គាល់៖**

- *លក្ខណៈវិនិច្ឆ័យសម្រាប់ពិនិត្យបឋមគម្រោងក្នុងប្រភេទ A គឺត្រូវបានអនុវត្តសម្រាប់គោលបំណងបង្ការទុកជាមុន។ ចំឡើយរំពឹងទុក ភាគច្រើន គឺ "ទេ" សម្រាប់សំណួរទាំងអស់។*
- *ដោយសារគម្រោងមេ ត្រូវបានចាត់ជាគម្រោងក្នុងប្រភេទ B (មិនមែនប្រភេទ A) ដូច្នេះ អនុគម្រោងទាំងឡាយត្រូវបានសន្មត់ថា ជាប្រភេទ B ឬ C ។*

### លក្ខណៈវិនិច្ឆ័យសម្រាប់ពិនិត្យបឋមគម្រោងក្នុងប្រភេទ A

សំណួរសម្រាប់ពិនិត្យបឋមមួយចំនួនខាងក្រោមនេះ គឺត្រូវបានបង្កើតឡើងសម្រាប់កំណត់ថាតើអនុគម្រោងមានសក្តានុពលអាចធ្វើឲ្យមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរ (ដូចអនុគម្រោងក្នុងប្រភេទ A) ដែរឬទេ។ *ចំលើយរំពឹងទុក គឺ "ទេ" សម្រាប់សំណួរទាំងអស់។*

| តារាងទី ១. លក្ខណៈវិនិច្ឆ័យសម្រាប់ពិនិត្យបឋមគម្រោងក្នុងប្រភេទ A | | | |
|---|---|---|---|
| **សំណួរពិនិត្យបឋម** | បាទ ចាស | ទេ | **កំណត់សម្គាល់** |
| **១. តើអនុគម្រោងមានសក្តានុពលអាចនឹងធ្វើឲ្យមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់ដែនជម្រក ធម្មជាតិ ឬដែនជម្រកធម្មជាតិសំខាន់ៗ ដែរឬទេ?** | | | |
| បណ្តាលឲ្យមានការបាត់បង់ ឬ ការធ្លាក់ចុះនៃដែនជម្រកធម្មជាតិដែលងាយរងគ្រោះ ត្រូវបានកំណត់និយមន័យថាៈ ដី និងតំបន់ទឹកដែល (i) សហគមន៍ជីវសាស្ត្រនៃប្រព័ន្ធអេកូឡូស៊ីត្រូវបានបង្កើតឡើងមួយភាគធំដោយព្រៃធម្មជាតិ និងប្រភេទសត្វផ្សេងៗ និង (ii) សកម្មភាពរបស់មនុស្សមិនបានកែប្រែ ជាពិសេសនូវមុខងារអេកូឡូស៊ីសំខាន់ៗក្នុងតំបន់ឡើយ។ ដែនជម្រកធម្មជាតិសំខាន់ៗ អាចមាននៅក្នុងតំបន់ព្រៃដែលសើម ស្ងួត និងមានអ័ព្ទក្នុងតំបន់ត្រូពិកព្រៃនៅភាគខាងជើងដែលមានអាកាសធាតុបង្គួរ ដីប្រភេទព្រៃល្បាស់ក្នុងតំបន់មេឌីទែរ៉ាណេ ដីដែលស្ងួតសោះកក្រោះ ឬពាក់កណ្តាលស្ងួតសោះកក្រោះ ដីវាលភក់ល្បាប់ព្រៃកោងកាង ដីវាលភក់តាមឆ្នេរ និងដីសើមផ្សេងៗទៀត ប្រាំងទន្លេ ប្រាំងសមុទ្រដែលមានស្មៅផ្កាថ្មសមុទ្រ បឹងនិងទន្លេទឹកសាប បរិស្ថានលើភ្នំ និងជើងភ្នំ រួមមាន វាលស្មៅ និង paramos; និង វាលស្មៅក្នុងតំបន់ត្រូពិក និងដែលមានអាកាសធាតុ | | | បញ្ជាក់ទីតាំង និងប្រភេទដែនជម្រកធម្មជាតិ និងប្រភេទនៃផលប៉ះពាល់ដែលអាចកើតឡើង ដូចជា ការបាត់បង់ដែនជម្រក និងទំហំនៃការខូចខាត ការបាត់បង់សេវាកម្មប្រព័ន្ធអេកូឡូស៊ី ផលប៉ះពាល់លើគុណភាពនៃដែនជម្រក។ សូមបញ្ជាក់ថា ហេតុអ្វីបានជាផលប៉ះពាល់ទាំងនេះ ធ្ងន់ធ្ងរ ឬមិនធ្ងន់ធ្ងរ។<br>កត់សម្គាល់ថា ធនាគារពិភពលោកមិនគាំទ្រគម្រោងណាដែលពាក់ព័ន្ធ នឹងការកែប្រែធ្ងន់ធ្ងរលើដែនជម្រកធម្មជាតិ លើកលែងតែគ្មានជម្រើស ផ្សេងទៀតដែលអាចធ្វើទៅបាន សម្រាប់គម្រោង និងទីតាំងរបស់វា ហើយការវិភាគស៊ីជម្រៅបង្ហាញថា ផលប្រយោជន៍រួមរបស់គម្រោង គឺមានតម្លៃលើសលុបនៃការខូចខាតផ្នែកបរិស្ថាន។ |

| | | | |
|---|---|---|---|
| បង្ករ។ | | | |
| បណ្តាលឲ្យមានការបាត់បង់ ឬ ការធ្លាក់ចុះនៃដែនជម្រកធម្មជាតិសំខាន់ៗ ដូចជា ដែនជម្រកធម្មជាតិដែលត្រូវបានការពារដោយស្របច្បាប់ មានសំណើការពារជាផ្លូវការ ឬ ដែលមិនត្រូវបានការពារ ប៉ុន្តែត្រូវបានគេដឹងឮថាមានតម្លៃខ្ពស់ផ្នែកអភិរក្ស។ ដែនជម្រកសំខាន់ៗ រួមមាន តំបន់ការពារបច្ចុប្បន្ន និងតំបន់ដែលរដ្ឋាភិបាលដាក់សំណើជាផ្លូវការថាជាតំបន់ការពារ (ដូចជា អាងដែលឆ្លើយតបទៅតាមលក្ខណៈវិនិច្ឆ័យរបស់អង្គការសហព័ន្ធអភិរក្សពិភពលោកអន្តរជាតិ IUCN) តំបន់ដែលត្រូវបានទទួលស្គាល់ដំបូងដោយសហគមន៍ ថាជាតំបន់ការពារបែបប្រពៃណី (ដូចជាព្រៃពិសិដ្ឋ) និងទីតាំងដែលជួយថែរក្សាស្ថានភាពសំខាន់ៗសម្រាប់ភាពរស់នៅបាននៃតំបន់ការពារទាំងនេះ។ ទីតាំងទាំងនេះអាចរួមមាន តំបន់ដែលត្រូវបានស្គាល់ថាមានលក្ខណៈសមស្របខ្ពស់សម្រាប់ការអភិរក្សជីវចម្រុះ និងតំបន់ដែលសំខាន់សម្រាប់រុក្ខជាតិ និងសត្វមក្រ ងាយរងគ្រោះ ពនេចរ និងដែលជិតផុតពូជ។ | | | កត់សម្គាល់ថា ធនាគារពិភពលោកមិនអាចផ្តល់មូលនិធិដល់គម្រោងទាំងឡាយណាដែលធ្វើឲ្យមានការផ្លាស់ប្តូរធ្ងន់ធ្ងរ ឬការចុះអន់ថយនៃដែនជម្រកធម្មជាតិសំខាន់ៗ។<br>បញ្ជាក់ទីតាំង និងប្រភេទនៃដែនជម្រកធម្មជាតិសំខាន់ៗ និងបញ្ជាក់ថាហេតុអ្វីពួកវាធ្ងន់ធ្ងរឬមិនធ្ងន់ធ្ងរ។ |
| **២. តើអនុគម្រោងមានសក្តានុពលនឹងបណ្តាលឲ្យមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់ធនធាន វប្បធម៌ជារូបវន្តដែរឬទេ ?** | | | |
| បណ្តាលឲ្យមានការបាត់បង់ ឬ ការធ្លាក់ចុះនៃធនធានវប្បធម៌ជារូបវន្ត ត្រូវបានកំណត់និយមន័យថាជា វត្ថុ ទីតាំង រចនាសម្ព័ន្ធ ក្រុមនៃរចនាសម្ព័ន្ធ ដែលអាចផ្លាស់ទីបាន ឬមិនអាចផ្លាស់ទីបាន និងលក្ខណៈ ព្រមទាំងទេសភាពធម្មជាតិដែលមានសារៈសំខាន់ផ្នែកបុរាណវិទ្យា បុរាណលេខសាស្ត្រ ប្រវត្តិសាស្ត្រ ស្ថាបត្យកម្ម | | | ពិព៌ណនាទីតាំង និងប្រភេទនៃធនធានធម្មជាតិ និងប្រភេទនៃផលប៉ះពាល់ដែលអាចកើតឡើង។ បញ្ជាក់ពីកម្រិតការពារ (នៅមូលដ្ឋាន ថ្នាក់ខេត្ត ថ្នាក់ជាតិ ឬ អន្តរជាតិ)។ តើមានទីតាំងណាខ្លះក្នុងចំណោមទីតាំងទាំងនេះ ត្រូវបានគេចាត់ |

| | | | |
|---|---|---|---|
| សាសនា សិល្បវិជ្ជា ឬតម្លៃផ្សេងៗទៀតផ្នែកវប្បធម៌។ ពួកគេអាចមាននៅទីប្រជុំជន ឬជនបទ នៅលើ ឬ ក្រោមដី ឬ ក្រោមទឹក។ ផលប្រយោជន៍ផ្នែកវប្បធម៌របស់វា គឺអាចមាននៅថ្នាក់មូលដ្ឋាន ថ្នាក់ ខេត្ត ឬ ថ្នាក់ជាតិ ឬ ក្នុងចំណោមសហគមន៍អន្តរជាតិ។ | | | ទុកថាសំខាន់ ដើម្បីរក្សាស្ថានភាពដើមរបស់វា មានន័យថា ធនធានទាំងនេះ មិនត្រូវបានយកចេញពីទីតាំងដើមរបស់វាទេ ? <br>បញ្ជាក់ថា ហេតុអ្វីពួកវាធ្ងន់ធ្ងរឬមិនធ្ងន់ធ្ងរ។ |
| អាចនឹងបណ្តាលឲ្យមានការបំពារបំពានលើច្បាប់របស់ជាតិ ឬ កាតព្វកិច្ចជាតិក្រោមកិច្ចព្រមព្រៀង និង សន្ធិសញ្ញាអន្តរជាតិនានា រួមមាន អនុសញ្ញាបេតិកភ័ណ្ឌពិភពលោករបស់អង្គការយូណេស្កូ ឬ អាចមានផលប៉ះពាល់ដល់ទីតាំង ដែលមានការទទួលស្គាល់ពីសារៈប្រយោជន៍ផ្នែកទេសចរណ៍ និង វិទ្យាសាស្ត្រ។ | | | ពិព៌ណនាអំពីផលប៉ះពាល់ទាំងឡាយណា ដែលអាចបំពានទៅលើបទបញ្ញត្តិជាតិ ឬអន្តរជាតិ ពាក់ព័ន្ធនឹងធនធានវប្បធម៌។ បើសិនជាវាមិនត្រូវបានគេចាត់ទុកថាធ្ងន់ធ្ងរ សូមពន្យល់ពីមូលហេតុ។ |
| **៣. តើអនុគម្រោងមានសក្តានុពលនឹងបណ្តាលឲ្យមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់ដី និងធនធានធម្មជាតិពាក់ព័ន្ធនឹងដី ដែលជនជាតិដើមភាគតិចអាស្រ័យផលដែរឬទេ ?** | | | |
| អាចបណ្តាលឲ្យមានផលប៉ះពាល់ទៅលើដី ឬ ដែនដី ដែលមានកម្មសិទ្ធិជាប្រពៃណី ឬ ដែលត្រូវបានអាស្រ័យផល ឬកាន់កាប់បែបប្រពៃណី និងដែលលទ្ធភាពទទួលបានធនធានធម្មជាតិមានសារៈសំខាន់ណាស់សម្រាប់ចីរភាពផ្នែកវប្បធម៌ និងជីវភាពរស់នៅរបស់ប្រជាជនជនជាតិភាគតិច។ អាចមានផលប៉ះពាល់ជាសក្តានុពលលើតម្លៃវប្បធម៌ និងជំនឿទៅលើដី និងធនធានទាំងនោះ ឬមានផលប៉ះពាល់លើការគ្រប់គ្រងធនធានធម្មជាតិ និងចីរភាពយូរអង្វែងនៃធនធានដែលរងគ្រោះ។ | | | ពិព៌ណនាអំពីប្រភេទ និងវិសាលភាពនៃផលប៉ះពាល់ និងភាពធ្ងន់ធ្ងរនៃការប្តូរទិសដៅទៅរកធនធានរបស់ជនជាតិភាគតិចដែលរងគ្រោះទៅវិញ។ <br>កត់សម្គាល់ថា ផែនការអភិវឌ្ឍជនជាតិដើមភាគតិច គឺជាតម្រូវការមួយ ស្របតាម OP 4.10 របស់ធនាគារពិភពលោក។ |
| **៤. តើអនុគម្រោងមានសក្តានុពលនឹងបណ្តាលឲ្យមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់ប្រជាពលរដ្ឋ ពាក់ព័ន្ធ** | | | |

| | | | |
|---|---|---|---|
| **នឹងការបាត់បង់ទីលំនៅជារូបវន្តដែរឬទេ ?** | | | |
| បណ្តាលឲ្យមានការបាត់បង់ទីលំនៅក្នុងចំណោមប្រជាពលរដ្ឋ ដែលអាស្រ័យលើដី ឬ ការប្រើប្រាស់ជាក់លាក់នៃធនធាន ដែលពិបាកនឹងជំនួសបាន ឬ ស្តារឡើងវិញ ? បើមិនអញ្ចឹងទេ វានឹងបណ្តាលឲ្យមានបញ្ហាលំបាកៗ សម្រាប់អនុគម្រោង ក្នុងការស្តារជីវភាពរស់នៅរបស់ប្រជាជន ? | | | បញ្ជាក់អំពីចំនួននៃខ្នងផ្ទះដែលរងគ្រោះ និងធនធានដែលអាចនឹងពិបាកជំនួសសម្រាប់ការស្តារជីវភាពរស់នៅឡើងវិញ។ កត់សម្គាល់ថា ផែនការសកម្មភាពផ្លាស់ទីលំនៅ ចាំបាច់នឹងត្រូវបានរៀបចំ ស្រប តាម OP 4.12 របស់ធនាគារពិភពលោក។ |
| **៥. តើអនុគម្រោងមានសក្តានុពលនឹងបណ្តាលឲ្យមានផលប៉ះពាល់ដែលមិនអាចកែប្រែបាន ឬផលប៉ះពាល់ដែលងាយស្រួលក្នុងការកាត់បន្ថយដែរឬទេ ?** | | | |
| បណ្តាលឲ្យមានការបាត់បង់តំបន់កកើតឡើងវិញនៃធនធានក្នុងទឹក ផលប៉ះពាល់លើគុណភាពនៃអាងស្តុកទឹកដែលប្រើ សម្រាប់ផ្គត់ផ្គង់ទឹកដល់មណ្ឌលសំខាន់ៗដែលមានពលរដ្ឋរស់នៅ។ | | | ផ្តល់ឈ្មោះហេដ្ឋារចនាសម្ព័ន្ធទឹក ដែលរងគ្រោះ និងពិព៌ណនាអំពីសភាពធ្ងន់ធ្ងរនៃផលប៉ះពាល់។ |
| បណ្តាលឲ្យមានផលប៉ះពាល់ផ្សេងៗ ដូចជា កំឡុងពេលនៃផលប៉ះពាល់គឺមានលក្ខណៈអចិន្ត្រៃយ៍បន្តិច មានផលប៉ះពាល់ដល់តំបន់ភូមិសាស្ត្រកាន់តែធំ ឬ ផលប៉ះពាល់កាន់តែមានភាពធ្ងន់ធ្ងរ។ | | | ពិព៌ណនាអំពីផលប៉ះពាល់ទាំងឡាយណាដែលត្រូវបានចាត់ទុកថានឹងមានជាអចិន្ត្រៃយ៍ ដែលប៉ះពាល់ដល់ភូមិសាស្ត្រយ៉ាងធំ (កំណត់ឲ្យច្បាស់) និងមានផលប៉ះពាល់កម្រិតធ្ងន់ធ្ងរ។ |
| **៦. តើអនុគម្រោងមានសក្តានុពលនឹងបណ្តាលឲ្យមានភាពចម្រុះដ៏ធំធេងនៃផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដែរឬទេ ?** | | | |
| ទីតាំងច្រើនក្នុងទីតាំងផ្សេងៗគ្នាអាចមានផលប៉ះពាល់គ្នាទៅវិញទៅមក និងដែលអាចបណ្តាលឲ្យការបាត់បង់ដែនជម្រកដ៏ធំធេង ធនធាន ដី ឬ ការធ្លាក់ចុះគុណភាពនៃធនធានទាំងនេះ។ | | | កំណត់ និងពិព៌ណនាតំបន់ទាំងអស់ដែលរងគ្រោះ។ |
| ផលប៉ះពាល់អវិជ្ជមានធំៗជាសក្តានុពល អាចនឹងមាន | | | កំណត់ |

| | | | |
|---|---|---|---|
| ហួសពីទីតាំង ឬ បរិក្ខាសម្រាប់កិច្ចការ ជារូបវន្តរបស់អនុគម្រោង ទៅទៀត។ | | | និងពិព៌ណនាប្រភេទនៃផលប៉ះពាល់ដែលមានហួសពីទីតាំង ឬ បរិក្ខានៃកិច្ចការរូបវន្ត។ |
| ផលប៉ះពាល់ឆ្លងព្រំដែន (ជាជាងការប្តូរទិសដៅទៅជាសកម្មភាពផ្លូវទឹកដែលកំពុងមាន)។ | | | ពិព៌ណនាអំពីកម្រិតធ្ងន់ធ្ងរនៃផលប៉ះពាល់ឆ្លងព្រំដែន។ |
| តម្រូវការឲ្យមានផ្លូវធ្វើដំណើរថ្មី ផ្លូវវាងក្នុងដី ប្រឡាយរបៀងបញ្ជូនថាមពល បំពង់នាំប្រេង ឬតំបន់សម្រាប់ចោលសំណល់ ក្នុងតំបន់ដែលមិនសូវអភិវឌ្ឍន៍ក្នុងពេលបច្ចុប្បន្ន។ | | | ពិព៌ណនាពីសកម្មភាពទាំងឡាយដែលថ្មីនិងដែលចាំបាច់សម្រាប់ឲ្យឲ្យសកម្មភាពសំខាន់ៗមានដំណើរការ។ |
| ការរំខានដល់ទំនោរនៃដំណើរពនេចររបស់សត្វព្រៃហ្វូងសត្វ ឬអ្នកចិញ្ចឹមសត្វ អ្នករសាត់អណ្តែត ឬអ្នកពាក់កណ្តាលរសាត់អណ្តែត។ | | | ពិព៌ណនាអំពីកម្រិតធ្ងន់ធ្ងរនៃផលប៉ះពាល់ដែលមានមកលើប្រជាជននិងសត្វ។ |
| **៧. តើអនុគម្រោងអាចនឹងមានជម្លោះ និងទំនងជាអាចទាក់ទាញការចាប់អារម្មណ៍ពីអង្គការមិនមែន រដ្ឋាភិបាល ឬសង្គមស៊ីវិលជាតិ ឬ អន្តរជាតិដែរឬទេ?** | | | |
| ត្រូវបានចាត់ទុកថាមានហានិភ័យ ឬ ទំនងជានឹងមានចំណុចខ្វែងគំនិតគ្នាច្រើន។ | | | ពិព៌ណនាអំពីហានិភ័យដែលត្រូវបានយល់ឃើញនិងទិដ្ឋភាពជម្លោះ ។ |
| ទំនងជានឹងបណ្តាលឲ្យមានការតវ៉ា ឬប្រជាជនចង់បាតុកម្ម ឬ ទប់ស្កាត់មិនឲ្យមានការសាងសង់។ | | | ពិព៌ណនាអំពីមូលហេតុដែលអនុគម្រោងណាមួយមិនត្រូវបានស្វាគមន៍។ |

2. បើមានចំលើយថា បាទ/ចាស សម្រាប់សំណួរណាមួយក្នុងចំណោមសំណួរពិនិត្យបឋមខាងលើ អនុគម្រោងនោះអាចនឹងត្រូវបានចាត់ចូលទៅក្នុងអនុគម្រោងប្រភេទA។ បើដូច្នេះ ក្រសួងបរិស្ថាន និង/ឬ ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវធ្វើការពិភាក្សាជាបន្ទាន់លើលទ្ធផលនៃការពិនិត្យបឋមនេះជាមួយធនាគារពិភពលោក ដោយសារអនុគម្រោងទាំងឡាយដែលស្ថិតក្នុងប្រភេទ A គឺនឹងមិនទទួលបាន និងមិនគួរមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សម្រាប់ទទួលបានហិរញ្ញប្បទានឡើយ។

3. មានភាពខុសគ្នារវាងតម្រូវការរបស់ធនាគារពិភពលោក និងរដ្ឋាភិបាល ក្នុងការកំណត់គម្រោងក្នុងប្រភេទ A ទាក់ទងទៅនឹងក្របខ័ណ្ឌទទួលខុសត្រូវ (TOR) នៃ EIA/EMP ការពិគ្រោះយោបល់ មាតិកា និងរចនាសម្ព័ន្ធនៃរបាយការណ៍ EIA។ ចាំបាច់ត្រូវមាន EIAs ២ ដាច់ដោយឡែកពីគ្នា ដើម្បីបំពេញចិត្តធនាគារពិភពលោក និងរដ្ឋាភិបាល។

### លក្ខណៈវិនិច្ឆ័យសម្រាប់ពិនិត្យបឋមគម្រោងក្នុងប្រភេទ C

4. សំណួរពិនិត្យបឋមមួយចំនួនខាងក្រោម គឺដើម្បីកំណត់ថាតើអនុគម្រោងណាមួយមានសក្ដានុពលធ្វើឲ្យមានផលប៉ះពាល់អវិជ្ជមានតិចតួច ឬគ្មាន (ដូចជាអនុគម្រោងក្នុងប្រភេទ C)។

**តារាង ២. លក្ខណៈវិនិច្ឆ័យពិនិត្យបឋមអនុគម្រោងប្រភេទ B ឬ C**

| **សំណួរពិនិត្យបឋម** | បាទ ចាស | ទេ | **កំណត់សម្គាល់/ការពន្យល់អំពីមូលហេតុ** |
|---|---|---|---|
| 1. សកម្មភាពរបស់អនុគម្រោងមានកំណត់ត្រឹមតែការបណ្តុះបណ្តាល ជំនួយបច្ចេកទេស និងការកសាងសមត្ថភាព។ | | | ពិព៌ណនាអំពីសកម្មភាព |
| 2. ការបណ្តុះបណ្តាល ជំនួយបច្ចេកទេស និងការកសាងសមត្ថភាព មិនទាមទារឲ្យមានការប្រើប្រាស់សារធាតុគីមី ភ្នាក់ងារជីវសាស្ត្រ និងថ្នាំសម្លាប់សត្វល្អិត។ | | | គាំទ្រការថ្លែងនេះ |
| 3. មិនមានហេដ្ឋារចនាសម្ព័ន្ធដែលត្រូវបំផ្លាញ ឬសាងសង់។ | | | គាំទ្រការថ្លែងនេះ |

| | | | |
|---|---|---|---|
| 4. គ្មានអន្តរាគមន៍ដែលអាចប៉ះពាល់ដល់ដី ទឹក ខ្យល់ រុក្ខជាតិ ឬ មនុស្ស។ | | | គាំទ្រការថ្លែងនេះ |
| 5. បើសិនជាការស្រាវជ្រាវបែបវិទ្យាសាស្ត្រកំពុងតែត្រូវបានធ្វើ ការស្រាវជ្រាវនោះមិនត្រូវបណ្តាលឲ្យមានសំណល់ដែលមានជាតិពុល ឬ គ្រោះថ្នាក់ ហើយការស្រាវជ្រាវនោះមិនត្រូវពាក់ព័ន្ធនឹងការបង្កើតឌីអិនអេ ឬ ការស្រាវជ្រាវណាមួយដែលអាច បណ្តាលឲ្យមានភ្នាក់ងារបង្កគ្រោះថ្នាក់ នៅពេលដែលបញ្ចេញវាពីកន្លែងទុកដាក់ ឬ បន្ទប់ពិសោធន៍។ | | | បើសិនជា បាទ/ចាស សូមពិភាក្សាជាមួយអ្នកជំនាញការរបស់ធនាគារពិភពលោក។ |

### លក្ខណៈវិនិច្ឆ័យសម្រាប់ពិនិត្យបឋមគម្រោងក្នុងប្រភេទ B

5. បន្ទាប់ពីបានពិនិត្យបឋមគម្រោងប្រភេទ A និង C រួចហើយ និងបន្ទាប់ពីបានបញ្ចប់ការសន្និដ្ឋានថា អនុគម្រោងមិនស្ថិតក្នុងប្រភេទ A និង ប្រភេទ C មានន័យថា អនុគម្រោងនោះ គួរតែស្ថិតនៅក្នុងប្រភេទ B។

6. អនុគម្រោងជាច្រើនដែលត្រូវស្នើឡើង នឹងស្ថិតនៅក្នុងប្រភេទ B។ ពួកគេអាចមានប្រភេទនៃផលប៉ះពាល់ប្រហាក់ប្រហែលគ្នា ទៅនឹងអនុគម្រោងក្នុងប្រភេទ A ដែរ ប៉ុន្តែ ផលប៉ះពាល់របស់វាគឺមិនអាចកែប្រែបានទេ ហើយមិនសូវរាលដាល មិនសូវធ្ងន់ធ្ងរ មិនសូវអវិជ្ជមាន អាចងាយស្រួលកាត់បន្ថយ មិនទំនងថានឹងមានជម្លោះ និងដែលមិនធ្លាប់មានពីមុនមក។

7. ប្រភេទ B ក៏តម្រូវឲ្យធ្វើ EIA ឬ ឧបករណ៍ប៉ាន់ប្រមាណបរិស្ថានផ្សេងៗទៀត ស្របតាម OP 4.01 របស់ធនាគារពិភពលោក។ PCO នឹងអនុវត្តលក្ខណៈវិនិច្ឆ័យនៃបទបញ្ញត្តិជាតិ ដើម្បីកំណត់ថាតើ ត្រូវរៀបចំធ្វើ EIA ឬ EPC ស្របទៅតាមច្បាប់ ស្តីពី ការការពារបរិស្ថាន និងក្រឹត្យ និងសារាចរណែនាំ ពាក់ព័ន្ធ។ ក្នុងករណីភាគច្រើន តម្រូវឲ្យមានភាពស៊ីសង្វាក់គ្នារវាង EMP និងគោលនយោបាយរបស់ធនាគារពិភពលោក។ សម្រាប់ករណីផ្សេង អាចអនុវត្ត EMP សាមញ្ញ ឬ ECOP គឺគ្រប់គ្រាន់ហើយ។

8. បញ្ហាដែលអាចត្រូវបានឆ្លើយតបនៅក្នុងឯកសារគាំពារប្រភេទ B គឺខុសៗគ្នា ហើយអាស្រ័យលើប្រភេទនៃអនុគម្រោង ទីតាំងរបស់វា និងការប្រើប្រាស់ដីធ្លីជុំវិញនោះ ប្រភេទនៃការសាងសង់ និងនិតិវិធីប្រតិបត្តិ ដែលនឹងត្រូវប្រើ។

តារាងត្រួតពិនិត្យផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម

| តារាងទី ៣. ផលប៉ះពាល់ជាសក្តានុពលផ្នែកបរិស្ថាន និងសង្គម ដែលត្រូវដោះស្រាយ | | | | | | | |
|---|---|---|---|---|---|---|---|
| | **តើអនុគម្រោងបានបញ្ជាក់ពីភាពចាំបាច់នៃផលប៉ះពាល់ផ្នែកបរិស្ថាន ទាំងនេះដែរឬទេ?** | ទេ | ទាប | មធ្យម | ខ្ពស់ | អត់ដឹង | *កំណត់សម្គាល់* |
| 1. | ការទន្ទ្រានកាន់កាប់តំបន់ប្រវត្តិសាស្ត្រ/វប្បធម៌ | | | | | | |
| 2. | ការទន្ទ្រានកាន់កាប់ប្រព័ន្ធអេកូឡូស៊ី (ដូចជា តំបន់ដែនជម្រកធម្មជាតិដែលងាយរងគ្រោះ ឬ តំបន់ការពារ តំបន់អភិរក្សធម្មជាតិ ។ល។) | | | | | | *ពិពណ៌នា និងប៉ាន់ប្រមាណដោយសង្ខេបពីកម្រិតនៃផលប៉ះពាល់* |
| 3. | ការធ្វើឲ្យខូចទ្រង់ទ្រាយដើមនៃទេសភាពធម្មជាតិ និងបង្កើនសំណល់។ | | | | | | |
| 4. | ការយកចេញគម្របសួនបន្លែ ឬ ការកាប់ឈើកំឡុងពេលសំអាតដីសម្រាប់ការសាងសង់ | | | | | | |
| 5. | កែប្រែគុណភាពនៃផ្ទៃខាងលើទឹក ឬលំហូរទឹក (ដូចជា ការបង្កើននូវសភាពល្អក់នៃទឹក ដោយសារទឹកហូរចេញសំណល់ទឹកចេញពីជំរុំ ការបាក់ដី និងសំណល់ពីការសាងសង់) ឬ | | | | | | *បញ្ជាក់ពីរបៀប និងពេលដែលវាកើតឡើង* |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | រយៈពេលវែង។ | | | | | | |
| 6. | ការកើនឡើងកម្រិតធូលី ឬ ការបន្ថែមសមាសធាតុកខ្វក់ចូលទៅក្នុងខ្យល់ កំឡុងពេលសាងសង់។ | | | | | | *បញ្ជាក់ពីរបៀប និងពេលដែលវាកើតឡើង* |
| 7. | ការកើនឡើងនូវសំឡេងនិង/ឬរំញ័រ | | | | | | *បញ្ជាក់ពីរបៀប និងពេលដែលវាកើតឡើង* |
| 8. | ការផ្លាស់ទីលំនៅ? បើមែន មានប៉ុន្មានខ្នងផ្ទះ? | | | | | | |
| 9. | ប្រើប្រាស់ទីតាំងផ្លាស់ប្តូរទីលំនៅ ដែលស្របទៅតាមបរិស្ថាន និង/ឬ វប្បធម៌។ | | | | | | *ពិព៌ណនាដោយសង្ខេប អំពីផលប៉ះពាល់ជាសក្តានុពល* |
| 10. | ហានិភ័យនៃការសាយភាយមេរោគពីកម្មករសំណង់ទៅប្រជាជន នៅមូលដ្ឋាន (និងបញ្ច្រាស់មកវិញ)? | | | | | | *កត់ត្រាពីចំនួនកម្មករ ដែលបានជួលសម្រាប់ការងារសាងសង់របស់អនុគម្រោង នៅក្នុងឃុំ/ស្រុក និងប្រភេទនៃមេរោគ ដែលពួកគេអាចនាំចូលទៅសហគមន៍ ឬអាចចម្លងពីសហគមន៍* |
| 11. | ជម្លោះជាសក្តានុពលរវាងកម្មករសំណង់ និងប្រជាជននៅមូលដ្ឋាន (និងបញ្ច្រាស់មកវិញ)? | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 12. | ការប្រើប្រាស់សមាសធាតុគីមីផ្ទុះ និង ដែលមានគ្រោះថ្នាក់។ | | | | | | |
| 13. | ការប្រើប្រាស់ទីតាំងដែលធ្លាប់មានគ្រោះថ្នាក់កើតឡើងកាលពីអតីតកាល ដោយសារគ្រាប់មីនក្នុងដី ឬ សម្ភារៈផ្ទុះផ្សេងៗ ដែលបន្សល់ទុកពីសង្គ្រាម | | | | | | |
| 14. | ការសាងសង់ដែលអាចបណ្តាលឲ្យមានការរំខានដល់ការដឹកជញ្ជូន ចរាចរណ៍តាមផ្លូវ ឬ ការដឹកជញ្ជូន តាមផ្លូវទឹក? | | | | | | |
| 15. | ការសាងសង់ដែលអាចបណ្តាលឲ្យមានការខូចខាតទៅដល់ផ្លូវថ្នល់ ស្ពាន ឬ ហេដ្ឋារចនាសម្ព័ន្ធជនបទផ្សេងៗទៀតដែលមានស្រាប់ក្នុងមូលដ្ឋាន។ | | | | | | |
| 16. | ការជីកយកដីកំឡុងពេលការសាងសង់របស់អនុគម្រោង ដែលអាចបណ្តាលឲ្យមានការបាក់ដី។ | | | | | | |
| 17. | តម្រូវការឲ្យបើកផ្លូវថ្មី បណ្តោះអសន្ន ឬ អចិន្ត្រៃយ៍។ | | | | | | *ប៉ាន់ប្រមាណចំនួន និងរយៈពេលនៃផ្លូវបណ្តោះអាសន្ន ឬ អចិន្ត្រៃយ៍ និង ទីតាំងនៃផ្លូវទាំងនោះ។* |
| 18. | ការបំបែក ឬការចែកជាផ្នែកនៃដែនជម្រករបស់រុក្ខជាតិ និងសត្វ? | | | | | | *ពិព៌ណនាអំពីរបៀប* |
| 19. | ផលប៉ះពាល់រយៈពេលវែងលើគុណភាព | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ខ្យល់ | | | | | | |
| 20. | ហានិភ័យគ្រោះថ្នាក់សម្រាប់កម្មករ និង សហគមន៍ កំឡុងពេលនៃដំណាក់កាលសាងសង់។ | | | | | | |
| 21. | ការប្រើប្រាស់សម្ភារៈដែលមានជាតិពុល និងគ្រោះថ្នាក់ និងការបង្កើតសំណល់ដែលមានគ្រោះថ្នាក់។ | | | | | | |
| 22. | ហានិភ័យចំពោះសុវត្ថិភាព និងសុខភាពរបស់មនុស្ស | | | | | | *ពិព័ណនាអំពីរបៀប* |
| **តើអនុគម្រោងបានបញ្ជាក់ពីភាពចាំបាច់នៃការទទួលបានដី ឬ កំហិតនៃការប្រើប្រាស់ធនធានទាំងនេះដែរឬទេ ?** | | | | | | | |
| 23. | ការកាន់កាប់ដី (បណ្ដោះអាសន្ន ឬ អចិន្ត្រៃយ៍) (ដីឯកជន ឬ ដី សាធារណៈ) សម្រាប់ការអភិវឌ្ឍ។ | | | | | | *ចុះបញ្ជីតំបន់ដីសម្រាប់ការកាន់កាប់បណ្ដោះអាសន្ន ឬ អចិន្ត្រៃយ៍ ប្រភេទដី រយៈពេល និង គោលបំណងនៃការកាន់កាប់ដី។* |
| 24. | ប្រើប្រាស់ដីដែលកំពុងមានកម្មសិទ្ធិ ឬ ដែលត្រូវបានប្រើប្រាស់ជាទៀងទាត់ សម្រាប់គោលបំណងផលិតកម្ម (ដូចជា សួនដំណាំ ធ្វើកសិកម្ម ដាំស្មៅ ទីតាំងនេសាទ និងដាំឈើ) | | | | | | |
| 25. . | ការបាត់បង់ទីលំនៅរបស់បុគ្គល គ្រួសារ ឬ អាជីវកម្ម | | | | | | |
| 26. | ការបាត់បង់ទិន្នផលកសិកម្ម | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ដើមឈើហូបផ្លែ ឬហេដ្ឋារចនាសម្ព័ន្ធ ផ្ទះសំបែង ជាបណ្តោះអាសន្ន ឬ អាចិន្ត្រៃយ៍ | | | | | | |
| 27. | ការដាក់កំហិតមិនឱ្យប្រជាជន ប្រើប្រាស់ឧទ្យាន និងតំបន់ការពារ ដែលត្រូវបានកំណត់ដោយច្បាប់។ | | | | | | |
| *បើសិនចំលើយសម្រាប់សំណួរទី ២៣ ដល់ ២៧ គឺ "បាទ/ចាស" សូមពិគ្រោះយោបល់ជាមួយ ESMF ហើយទំនង ជាចាំបាច់ក្នុងការរៀបចំផែនការផ្លាស់ទីលំនៅ (RP)។* | | | | | | | |
| **តើអនុគម្រោងបានបញ្ជាក់ពីភាពចាំបាច់នៃឥទ្ធិពលដែលអាចមានមកលើប្រជាជន ជនជាតិដើមភាគតិចដែរឬទេ?** | | | | | | | |
| 28. | ក្រុមជនជាតិដើមភាគតិច គឺរស់នៅក្នុង ព្រំដែនរបស់អនុគម្រោង ឬនៅជិត អនុគម្រោង | | | | | | |
| 29. | សមាជិកនៃក្រុមជនជាតិដើមភាគតិច ក្នុងតំបន់ដែលអាចទទួលបាន ប្រយោជន៍ ឬ ទទួលរងនូវការខូចខាត ដោយសារគម្រោង | | | | | | |
| *បើសិនចំលើយសម្រាប់សំណួរទី ២៨ ឬ ២៩ ថា " បាទ/ចាស" សូមពិគ្រោះយោបល់ជាមួយ ESMF ហើយ ការរៀបចំផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (EMDP) គឺទំនងជាចាំបាច់។* | | | | | | | |

**9.** ក្រសួងបរិស្ថាន ឬ ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវបញ្ជូនរបាយការណ៍ពិនិត្យបឋមនេះ ទៅធនាគារពិភពលោក ដើម្បីពិនិត្យ ពាក់ព័ន្ធទៅនឹងការឲ្យចំណាត់ថ្នាក់អនុគម្រោង។

## ឧបសម្ព័ន្ធ ២៖ ក្រមប្រតិបត្តិបរិស្ថាន (ECOPs) ឬ កិច្ចព្រមព្រៀងការពារបរិស្ថាន

### ផ្នែកទី ១. គោលដៅ

ក្រមប្រតិបត្តិបរិស្ថាននេះ (ECOP) ឬ កិច្ចព្រមព្រៀងការពារបរិស្ថាន គឺត្រូវបានអនុវត្ត ដើម្បីគ្រប់គ្រងផលប៉ះពាល់ផ្នែកបរិស្ថានកម្រិតទាប ដែលបណ្តាលមកពីការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ដូចជា ការស្តារឡើងវិញបរិក្ខាអនាម័យ និងទេសចរណ៍ធម្មជាតិ។ ECOPs នឹងត្រូវអនុវត្ត ដើម្បីគ្រប់គ្រងអនុគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច។ ECOP គឺជាផ្នែកមួយដែលត្រូវតែមាន នៅក្នុងកិច្ចសន្យាសាងសង់ ឬ ឯកសារដេញថ្លៃ ដើម្បីឲ្យអ្នកទទួលការអនុវត្តទៅតាមកតិកាសញ្ញា បរិស្ថាន។ ក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទនឹងទទួលខុសត្រូវក្នុងការពិនិត្យតាមដានអនុលោមភាពទៅនឹងECOP និងរៀបចំរបាយការណ៍ ដែលតម្រូវ។

| បញ្ហា/ហានិភ័យ | វិធានការកាត់បន្ថយ |
|---|---|
| **១). ការធ្វើឲ្យមានធូលី / ភាពកខ្វក់នៃខ្យល់** | • អ្នកទទួលការត្រូវអនុវត្តវិធានការគ្រប់គ្រងធូលី ដើម្បីធានាថា មានការកាត់បន្ថយធូលី និងមិនត្រូវធ្វើឲ្យប្រជាជនក្នុងសហគមន៍មានភាពសោះហ្មងដោយសារតែ បញ្ហានេះ និងដើម្បីរក្សាសុវត្ថិភាពបរិយាកាសការងារ ដូចជា៖<br>- ស្រោចទឹកផ្លូវដែលហុយ និងទីតាំងសំណង់<br>- គ្របសម្ភារៈក្នុងស្តុក<br>- សម្ភារៈដែលបានដាក់លើឡានត្រូវគ្រប និងធានាសុវត្ថិភាព កំឡុងពេល ដឹកជញ្ជូន ដើម្បីបញ្ចៀសភាពរាយប៉ាយនៃគំនរដី ខ្សាច់ សម្ភារៈ ឬ ធូលី<br>- គំនរដី និងសម្ភារៈ គួរតែត្រូវបានការពារ កុំឲ្យប៉ើងតាមខ្យល់។ |
| **២). សំឡេង និងរំញ័រ** | • រថយន្តទាំងអស់ត្រូវតែមាន " វិញ្ញាប័ណ្ណប័ត្របញ្ជាក់ពីភាពត្រឹមត្រូវ ដែលចេញដោយផ្នែកអធិការកិច្ចគុណភាព សុវត្ថិភាព បច្ចេកទេស និងការការពារផ្នែកបរិស្ថាន "ស្របតាមសេចក្តីសម្រេចលេខ 35/2005/QD-BGTVT ដើម្បីជៀសវាងការបញ្ចេញសំឡេងខ្លាំងពីម៉ាស៊ីនឡានដែលមិនសូវថែទាំបានល្អ។ |
| **៣). ការបំពុលទឹក** | • ត្រូវតែផ្តល់បង្គន់អនាម័យដែលអាចចល័តបាន ឬ ដែលសាងសង់ហើយ សម្រាប់កម្មករសំណង់នៅតាមការដ្ឋានប្រើប្រាស់។ សំណល់ទឹកពីបង្គន់ ចង្ក្រានបាយ បន្ទប់ងូតទឹក អាងទឹក ។ល។ គួរតែបង្ហូរចូលទៅក្នុងអាងស្តុកទុកមួយ ដែលត្រូវយកចេញពីការដ្ឋាន ឬ បញ្ចូលទៅក្នុងប្រព័ន្ធលូរបស់ក្រុង។ មិនគួរមានការបង្ហូរ សំណល់ទឹកទាំងនេះដោយផ្ទាល់ទៅក្នុង |

| បញ្ហា/ហានិភ័យ | វិធានការកាត់បន្ថយ |
|---|---|
| | ដែនទឹកទេ។<br>• សំណល់ទឹកដែលលើសពីកម្រិតអនុញ្ញាតដោយស្តង់ដា/បទបញ្ញតិ បច្ចេកទេសជាតិពាក់ព័ន្ធ ត្រូវតែបានប្រមូលទុកក្នុងអាងស្តុកទុក និងត្រូវប្រមូលចេញពីការដ្ឋាន ដោយអ្នកប្រមូលសំណល់ដែលមានអាជ្ញាប័ណ្ណ។<br>• នៅពេលបញ្ចប់ការងារសាងសង់ ត្រូវគ្របធុងដាក់ទុក និងអាងស្តុកទឹកសំអុយ និងបិទវាឲ្យបានជិត។ |
| **៤). លូបង្ហូរចេញ និងការវេងកករនៅបាតលូ** | • អ្នកទទួលការត្រូវអនុវត្តតាមការរៀបចំប្លង់ប្រព័ន្ធលូលំអិត ដែលមានបញ្ចូលក្នុងផែនការសាងសង់ ដើម្បីធានាថា ប្រព័ន្ធលូតែងតែត្រូវបានថែទាំ និងសម្អាតរាល់ភក់ និងអ្វីៗផ្សេងទៀតដែលរារាំងដល់ការហូរ។<br>• ទីតាំងផ្សេងៗក្នុងការដ្ឋានដែលមិនប៉ះពាល់ដោយសកម្មភាពសំណង់ គួរតែថែរក្សា ឲ្យនៅសភាពដើម។ |
| **៥). សំណល់រឹង** | • នៅគ្រប់កន្លែងការងារ អ្នកទទួលការត្រូវផ្តល់ធុងដាក់សំរាម ធុង និងកន្លែងបោះ សំរាមចោល។<br>• សំណល់រឹងអាចត្រូវបានរក្សាទុកនៅការដ្ឋាន ក្នុងកន្លែងមួយដែលមានការកំណត់ច្បាស់លាស់ ដោយទីប្រឹក្សាត្រួតពិនិត្យការសាងសង់ និងអាជ្ញាធរមូលដ្ឋាន ដែលពាក់ព័ន្ធនៅមុនពេលប្រមូល និងបោះចោល។<br>• ធុងផ្ទុកសំណល់ត្រូវតែបិតឲ្យជិតដោយគម្របដែលធននឹងអកាសធាតុ និងដែលការពារកុំឲ្យអ្នករើសអេតចាយបើកបាន។<br>• កុំដុត និងមិនត្រូវកប់ ឬ ទម្លាក់សំណល់រឹងនៅក្នុងការដ្ឋានសំណង់ឡើយ។<br>• ប្រើប្រាស់សម្ភារៈឡើងវិញ ដូចជា បន្ទះក្តាឈើសម្រាប់កិច្ចការលេណដ្ឋាន ដែក សម្ភារៈដែលអាចបត់ចុះបត់ឡើងបាន សម្ភារៈវេចខ្ចប់ ។ល។ គួរតែត្រូវបានប្រមូល និងបំបែកចេញពីប្រភពសំណល់ផ្សេងទៀត ក្នុងគោលបំណងប្រើប្រាស់ឡើងវិញ ប្រើសម្រាប់ចាក់បំពេញដី ឬសម្រាប់លក់ចេញ។<br>• បើមិនត្រូវបានយកចេញពីការដ្ឋានទេ សំណល់រឹង ឬកំទេចកំទីសំណង់ នឹងត្រូវបោះចោលនៅតាមទីតាំងដែលកំណត់និងអនុញ្ញាតដោយទីប្រឹក្សាត្រួតពិនិត្យការសាងសង់ និងដែលមានបញ្ចូលក្នុងផែនការគ្រប់គ្រងសំណល់រឹង។ |

| បញ្ហា/ហានិភ័យ | វិធានការកាត់បន្ថយ |
|---|---|
| | គ្មានស្ថានភាពណាមួយដែលអ្នកទទួលការអាចបោះចោលសម្ភារៈណាមួយក្នុងតំបន់ដែលងាយរងគ្រោះផ្នែកបរិស្ថាន ដូចជា ដែនជម្រកធម្មជាតិ ឬផ្លូវទឹកឡើយ។ |
| **៦). សំណល់គីមី ឬ សំណល់ដែលមានគ្រោះថ្នាក់** | • ប្រេង និងខ្លាញ់ដែលបានប្រើហើយត្រូវយកចេញពីការដ្ឋាន និងលក់ទៅឲ្យក្រុមហ៊ុនណាដែលទទួលបានសិទ្ធិកែច្នៃប្រេងឡើងវិញ។<br>• ប្រេង ប្រេងរំអិល សម្ភារៈសម្អាតផ្សេងៗ។ល។ ដែលបានប្រើសល់ពីការថែទាំរថយន្ត និងគ្រឿងម៉ាស៊ីន នឹងត្រូវបានប្រមូលដាក់ក្នុងធុងស្តុកទុក នឹងយកចេញពី ការដ្ឋាន ដោយក្រុមហ៊ុនណាដែលទទួលបានសិទ្ធិកែច្នៃប្រេងឡើងវិញ ដើម្បីយក ទៅបោះចោលនៅកន្លែងបោះចោលសំណល់ដែលមានគ្រោះថ្នាក់ ដែលទទួលបានការអនុញ្ញាតត្រឹមត្រូវ។<br>• កៅស៊ូចាក់ថ្នល់ដែលសល់ពីការប្រើ ឬ ដែលត្រូវបានបដិសេធមិនប្រើ ឬផលិតផល ផ្សេងៗទៀតដែលដូចគ្នានឹងកាកប្រេង គួរតែបញ្ជូនទៅរោងចក្រផលិតរបស់អ្នកផ្គត់ផ្គង់វិញ។<br>• ទុកដាក់សមាសធាតុគីមីឲ្យមានសុវត្ថិភាព ដូចជា ដាក់ក្រោមដំបូល ក្នុងរបង និងដាក់ផ្លាកសម្គាល់ឲ្យបានត្រឹមត្រូវ។ |
| **៧). ការរំខានលើគម្របរុក្ខជាតិ និងធនធានអេកូឡូស៊ី** | • តំបន់ដែលត្រូវសម្អាត គួរតែមានទំហំតូច តាមដែលអាចធ្វើទៅបាន។<br>• អ្នកទទួលការត្រូវយកដីស្រទាប់ខាងលើចេញពីតំបន់ការងារ ដោយសារវាអាចនឹងរងផលប៉ះពាល់ដោយសកម្មភាពជួសជុល រួមមាន សកម្មភាពជាបណ្តោះអាសន្ន ដូចជា ការរៀបចំឃ្លាំង និងការដាក់សម្ភារៈក្នុងឃ្លាំង ។ល។ ស្រទាប់ដីផ្នែកខាងលើដែលបានយកចេញទាំងនោះ គួរតែត្រូវបានរក្សាទុកនៅកន្លែងមួយដែលទីប្រឹក្សាត្រួតពិនិត្យការសាងសង់បានយល់ព្រម សម្រាប់យកទៅប្រើប្រាស់ក្នុងការដាំដុះបន្លែឡើងវិញ និងគួរតែមានការការពារឲ្យបានត្រឹមត្រូវ។<br>• ការប្រើប្រាស់សមាសធាតុគីមី ដើម្បីសម្អាតសួនដំណាំមិនត្រូវបានអនុញ្ញាតទេ។<br>• ហាមឃាត់ការកាប់ដើមឈើ លើកលែងតែមានការអនុញ្ញាតច្បាស់លាស់ ដែលមាននៅក្នុងផែនការសម្អាតសួនដំណាំ។<br>• ពេលចាំបាច់ ត្រូវដាក់របង ដើម្បីការពារដើមឈើដែលត្រូវរក្សាទុក ឲ្យមានប្រសិទ្ធិភាព មុនពេលចាប់ផ្តើមការងារណាមួយនៅក្នុងការដ្ឋាន។<br>• អ្នកទទួលការត្រូវធានាថាមិនមានការបរបាញ់សត្វ កីឡាបាញ់ចានហោះ ការបំពុល ពពួកសត្វទាំងឡាយ។ |

| បញ្ហា/ហានិភ័យ | វិធានការកាត់បន្ថយ |
|---|---|
| **៨). ការគ្រប់គ្រងចរាចរណ៍** | • មុនពេលសាងសង់ ពិគ្រោះយោបល់ជាមួយរដ្ឋាភិបាលមូលដ្ឋាន សហគមន៍មូលដ្ឋាន និង ប៉ូលីសចរាចរណ៍។<br>• ការធ្វើដំណើរតាមរថយន្តមានការកើនឡើងយ៉ាងច្រើន ដូច្នេះ ត្រូវតែមានលើកវាឡើងនៅក្នុងផែនការសាងសង់ ដែលត្រូវបានអនុម័តកន្លងមក។ ការបើកបរតាមផ្លូវ ជាពិសេស សម្រាប់រថយន្តធុនធ្ងន់ ចាំបាច់ត្រូវពិចារណាអំពីកន្លែងដែលងាយរងគ្រោះ ដូចជា សាលារៀន មន្ទីរពេទ្យ និងផ្សារ។<br>• ការដំឡើងភ្លើងបំភ្លឺសម្រាប់ពេលយប់ត្រូវតែធ្វើ បើសិនជាចាំបាច់ ដើម្បីធានាសុវត្ថិភាពក្នុងការធ្វើដំណើរនៅក្នុងការដ្ឋាន។<br>• ដាក់ស្លាកសញ្ញាសម្គាល់ជុំវិញការដ្ឋានសាងសង់ ដើម្បីជួយសម្រួលចរាចរណ៍ បង្ហាញទិសដៅសម្រាប់ការបំពេញការងារ និងផ្តល់ជាយោបល់សម្រាប់សុវត្ថិភាព ធ្វើដំណើរ និងការព្រមានឲ្យដឹងជាមុន។<br>• អនុវត្តវិធានការគ្រប់គ្រងសុវត្ថិភាពចរាចរណ៍ រួមមាន ដាក់ស្លាកសញ្ញាតាមផ្លូវ/ទន្លេ/ព្រែក និង ផ្តល់ការប្រមានឲ្យដឹងជាមុនសម្រាប់ស្ថានភាពគ្រោះថ្នាក់ផ្សេងៗ។<br>• ជៀសវាងការដឹកជញ្ជូនសម្ភារៈសំណង់ កំឡុងពេលមានការមមាញឹកតាមផ្លូវ<br>• ស្លាកសញ្ញាគួរតែត្រូវបានដាក់ឲ្យបានសមស្រប ទាំងនៅតាមផ្លូវទឹក និងផ្លូវគោក បើចាំបាច់។ |
| **៩). ការរំខានដល់ការផ្តល់សេវាកម្ម** | • ផ្តល់ព័ត៌មានដល់គ្រួសាររងគ្រោះអំពីកាលវិភាគការងារ និងការខកខានផ្គត់ផ្គង់ទឹក/ភ្លើង យ៉ាងហោចណាស់ឲ្យបាន ២ ថ្ងៃមុន។<br>• ការខូចខាតណាមួយលើខ្សែបណ្តាញនៃប្រព័ន្ធប្រើប្រាស់បច្ចុប្បន្ន នឹងត្រូវរាយការ ទៅ អាជ្ញាធរ និងត្រូវជួសជុលឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ |
| **១០). ការស្តារឡើងវិញនូវតំបន់ដែលរងគ្រោះ** | • តំបន់ដែលបានសម្អាត ដូចជា កន្លែងចាក់សំរាម ការដ្ឋាន ជម្រករបស់កម្មករ កន្លែងស្តុកសម្ភារៈ កន្លែងការងារ និងកន្លែងផ្សេងៗទៀតដែលប្រើប្រាស់ជា បណ្តោះអាសន្នកំឡុងពេលការងារសាងសង់ នឹងត្រូវស្តារឡើងវិញ ដោយការកែលម្អទេសភាព ដាក់ប្រព័ន្ធលូគ្រប់គ្រាន់ និងរៀបចំសួនដំណាំឡើងវិញ។<br>• ដើមឈើនឹងត្រូវដាំនៅលើដីទំនេរ និងនៅតាមទីជម្រាល ដើម្បីការពារ ឬ កាត់បន្ថយការបាក់ដី និងថែរក្សាស្ថេរភាពទីជម្រាល។<br>• ដីដែលប្រឡាក់ទៅដោយសារធាតុគីមី ឬ សារធាតុគ្រោះថ្នាក់ នឹងត្រូវបានយកចេញ និងដឹក |

| បញ្ហា/ហានិភ័យ | វិធានការកាត់បន្ថយ |
|---|---|
| | ទៅកប់នៅទីកន្លែងចោលសំណល់យ៉ាងត្រឹមត្រូវ។ |
| **១១). សុវត្ថិភាពកម្មករ និងសុវត្ថិភាពសាធារណៈ** | • បណ្តុះបណ្តាលកម្មករអំពីបទបញ្ញត្តិសុវត្ថិភាពការងារ និងផ្តល់សំលៀកបំពាក់ធានាសុវត្ថិភាពដល់កម្មករ ស្របទៅតាមច្បាប់ជាតិដែលសមស្រប។<br>• ធ្វើរបង របាំង ផ្តល់ការប្រមានពីគ្រោះថ្នាក់/កំហិតការចូលទៅកាន់ទីតាំងគ្រោះថ្នាក់ ជុំវិញការដ្ឋាន សម្រាប់សាធារណៈជន។<br>• អ្នកទទួលការត្រូវផ្តល់វិធានការសុវត្ថិភាព ដូចជា ការធ្វើរបង របាំង សញ្ញាប្រមាន គ្រោះថ្នាក់ ប្រព័ន្ធបំភ្លឺដើម្បីការពារកុំឲ្យមានគ្រោះថ្នាក់ចរាចរណ៍ និងហានិភ័យផ្សេងៗទៀត សម្រាប់មនុស្ស និងកន្លែងដែលងាយរងគ្រោះផ្សេងៗទៀត។<br>• បើសិនជាការប៉ាន់ប្រមាណកន្លងមកបានបញ្ជាក់ថាអាចមានគ្រឿងផ្ទុះ (UXO) គឺបុគ្គលិកដែលមានសមត្ថភាពត្រូវចាំបាច់ធ្វើការសម្អាត ដូចដែលមានចែងនៅក្នុងផែនការលម្អិតដែលអនុម័តដោយវិស្វករសំណង់។ |
| **១២). ការប្រាស្រ័យទាក់ទងជាមួយសហគមន៍មូលដ្ឋាន** | • អ្នកទទួលការត្រូវសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាន (អ្នកដឹកនាំឃុំ អ្នកដឹកនាំភូមិ) ដើម្បីព្រមព្រៀងលើកាលវិភាគសកម្មភាពសំណង់នៅទីកន្លែងដែលងាយរងគ្រោះ ឬនៅក្បែរ និងពេលវេលាពិសេសណាមួយ (ដូចជា ថ្ងៃបុណ្យសាសនា)។<br>• ផ្សព្វផ្សាយព័ត៌មានគម្រោងដល់ភាគីរងគ្រោះ (ឧទាហរណ៍ អាជ្ញាធរមូលដ្ឋាន សហគ្រាស និងខ្ទង់ផ្ទះរងគ្រោះ ។ល។) តាមរយៈការប្រជុំនៅសហគមន៍ មុនពេល សកម្មភាពសាងសង់ចាប់ផ្តើម។<br>• ផ្តល់ព័ត៌មានអំពីអ្នកដែលត្រូវប្រាស្រ័យទាក់ទងជាមួយសហគមន៍ ដែលភាគីពាក់ព័ន្ធអាចទទួលព័ត៌មាន អំពីសកម្មភាពនៅការដ្ឋាន ស្ថានភាពរបស់គម្រោង និងលទ្ធផលនៃការអនុវត្តគម្រោង។<br>• ផ្តល់ព័ត៌មានដល់ប្រជាជនមូលដ្ឋានអំពីកាលវិភាគការងារ និងការសាងសង់ ការខកខានផ្គត់ផ្គង់សេវាកម្មជាក់លាក់ ផ្លូវវាង និងផ្លូវរថយន្តក្រុងបណ្តោះអាសន្ន ការបំផ្ទុះ និងការកំទេចចោលណាមួយ ទៅតាមស្ថានភាពសមស្រប។<br>• ក្តារព័ត៌មាននឹងត្រូវបានដំឡើងនៅគ្រប់ការដ្ឋានសាងសង់ សម្រាប់ផ្តល់ព័ត៌មានអំពីគម្រោង និងព័ត៌មានពាក់ព័ន្ធរបស់អ្នកចាត់ការការដ្ឋាន បុគ្គលិកផ្នែកបរិស្ថាន បុគ្គលិកសុខភាពនិងសុវត្ថិភាព លេខទូរស័ព្ទ និងព័ត៌មានផ្សេងៗទៀត និងដែលជនរងគ្រោះអាចបញ្ចេញយោបល់ |

| បញ្ហា/ហានិភ័យ | វិធានការកាត់បន្ថយ |
|---|---|
| | អំពីការព្រួយបារម្ភណ៍ និងសំណើផ្សេងៗ។ |
| **១៣). នីតិវិធីករណី ដែលបានប្រទះឃើញអ្វីមួយ** | បើសិនជាអ្នកទទួលការបានប្រទះឃើញទីតាំងបុរាណ ទីតាំងប្រវត្តិសាស្ត្រ សំណល់ និង ឧបករណ៍ផ្សេងៗ រួមទាំង ទីតាំងកប់សព និង/ឬ ផ្នូរ កំឡុងពេលកាយដី ឬ សាងសង់ អ្នកទទួលការត្រូវ៖<br>• បញ្ឈប់សកម្មភាពសាងសង់ក្នុងតំបន់ទាំងនោះ<br>• គូសព្រំប្រទល់ទីតាំង ឬ កន្លែងទាំងនោះ<br>• ការពារទីតាំងទាំងនោះ ដើម្បីកុំឲ្យមានការខូចខាត ឬ បាត់បង់របស់ដែលអាចចល័តទីបាន។ ក្នុងករណីរបស់បុរាណដែលអាចចល័តទីបាន ឬ សំណល់ដែលងាយរងគ្រោះ គួរតែចាត់ឲ្យមានអ្នកយាមពេលយប់ រហូតដល់ពេលដែលអាជ្ញាធរ មូលដ្ឋានដែលមានការទទួលខុសត្រូវ ឬ នាយកដ្ឋានវប្បធម៌ និងព័ត៌មានមកទទួលយក<br>• ជូនដំណឹងទៅទីប្រឹក្សាត្រួតពិនិត្យការសាងសង់ ដែលត្រូវផ្តល់ដំណឹងជាបន្តទៅ អាជ្ញាធរមូលដ្ឋាន ឬ ថ្នាក់ជាតិដែលមានការទទួលខុសត្រូវផ្នែកវប្បធម៌ (កំឡុងពេល២៤ម៉ោង ឬ ឆាប់ជាងនេះ)<br>• អាជ្ញាធរមូលដ្ឋាន ឬ ថ្នាក់ជាតិដែលពាក់ព័ន្ធ គួរតែទទួលខុសត្រូវក្នុងកិច្ចការពារ និងថែរក្សាទីតាំង មុនពេលសម្រេចចិត្តអំពីនីតិវិធីបន្ទាប់ដែលសមស្រប។ ចំណុចនេះ ទាមទារឲ្យមានការវាយតម្លៃបឋមមួយលើរបកគំហើញទាំងនោះ។ ភាពចាំបាច់ និងសារៈសំខាន់នៃរបកគំហើញទាំងនេះ គួរតែត្រូវបានប៉ាន់ប្រមាណ ស្របទៅតាមលក្ខណៈវិនិច្ឆ័យផ្សេងៗពាក់ព័ន្ធទៅនឹងបេតិកភ័ណ្ឌផ្នែកវប្បធម៌ ដូចជារបកគំហើញដែលមានតម្លៃផ្នែកសិល្បវិជ្ជា ប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ ឬការស្រាវជ្រាវ សង្គម និងសេដ្ឋកិច្ច។<br>• អាជ្ញាធរដែលមានការទទួលខុសត្រូវ គួរតែជាអ្នកធ្វើការសម្រេចចិត្តអំពីរបៀបចាត់ចែងលើរបកគំហើញ។ ការសម្រេចចិត្តទាំងនេះ រួមមាន ការផ្លាស់ប្តូររូបរាង (ដូចជា នៅពេលបានរកឃើញសំណល់វប្បធម៌ ឬ សារៈសំខាន់បុរាណវិទ្យាដែលមានអាចចល័តបាន) ការអភិរក្ស ថែរក្សា ជួសជុល និងការជួយស្រោចស្រង់។<br>• បើសិនជាទីតាំងវប្បធម៌ និង/ឬ វត្ថុបុរាណដែលមានតម្លៃខ្ពស់ ហើយអ្នកជំនាញអាជីពបានផ្តល់យោបល់ឲ្យមានការថែរក្សាទីតាំង ក៏ដូចជាការតម្រូវរបស់អាជ្ញាធរវត្ថុបុរាណ ម្ចាស់គម្រោងត្រូវរៀបចំឲ្យមានការផ្លាស់ប្តូរប្លង់ដែលចាំបាច់ ដើម្បីឆ្លើយតបទៅតាមសំណើទាំង |

| បញ្ហា/ហានិភ័យ | វិធានការកាត់បន្ថយ |
| --- | --- |
| | នោះ និងដើម្បីថែរក្សាទីតាំង។<br>• ការសម្រេចចិត្តពាក់ព័ន្ធនឹងការគ្រប់គ្រងរបកគំហើញ នឹងត្រូវធ្វើការប្រាស្រ័យទាក់ទងជាលាយលក្ខអក្សរដោយអាជ្ញាធរពាក់ព័ន្ធ។<br>• កិច្ចការសាងសង់អាចចាប់ផ្តើមបន្តឡើងវិញ បន្ទាប់ពីទទួលបានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋានដែលទទួលខុសត្រូវលើកិច្ចការគាំពារផ្នែកបេតិកភ័ណ្ឌ។ |

## ផ្នែកទី ២ – ក្រមប្រតិបត្តិផ្នែកបរិស្ថានសម្រាប់កម្មករ របស់អ្នកទទួលការ

នេះជាឧទាហរណ៍មួយសម្រាប់គម្រោងជាទូទៅ ប៉ុន្តែសម្រាប់គម្រោងជាក់លាក់ គឺមានតម្រូវការផ្សេងៗទៀត។ ឧទាហរណ៍ ពិធីសារលាងដៃ ការយល់ព្រមចូលរួមសិក្ខាសាលាអំពី STD។

| **គួរធ្វើ** | **មិនត្រូវធ្វើ** |
| --- | --- |
| • ប្រើប្រាស់បង្គន់អនាម័យដែលបានផ្តល់ឲ្យ – រាយការណ៍ពីភាពពកខ្វក់ ឬបរិក្ខាទាំងមូល<br>• សម្អាតទីកន្លែងការងាររបស់អ្នក កុំឲ្យមានសំរាម នៅពេលចុងបញ្ចប់នៃថ្ងៃនីមួយៗ – ប្រើធុងដាក់សំរាម ដែលបានផ្តល់ឲ្យ និងធានាថា មិនមានសំរាមបោះចោលពាសវាលពាសកាលឡើយ។<br>• រាយការណ៍ជាបន្ទាន់អំពីប្រេងដែលលិចនិងបញ្ឈប់កុំឲ្យវាហៀរទៀត។<br>• ជក់បារីនៅទីតាំងដែលបានអនុញ្ញាតតែប៉ុណ្ណោះ និងត្រូវទុកដាក់កន្ទុយបារីនិងឈើគូសដោយប្រុងប្រយ័ត្ន (ការបោះចោលផ្តេសផ្តាស់ គឺជាបទល្មើស)។ | • យកចេញ ឬ ធ្វើឲ្យខូចខាតដល់ការដាំដំណាំ ដោយគ្មានការពន្យល់ដោយផ្ទាល់<br>• ដុតភ្លើង<br>• លួច បង្ករបួសស្នាម ដាក់អន្ទាក់ ឲ្យចំណី/ធ្វើឲ្យសត្វដទៃមានគ្រោះថ្នាក់ – រួមមាន សត្វស្លាប កង្កែប ពស់ ។ល។<br>• ចូលទៅកាន់កន្លែងណាមួយដែលមានរបង ឬ មានស្លាក សញ្ញាហាមឃាត់។<br>• បើកបរដោយគ្មានការប្រុងប្រយ័ត្ន ឬ លើសល្បឿនកំណត់<br>• អនុញ្ញាតឲ្យសំណល់ សំរាម ប្រេង ឬ សម្ភារៈបរទេស ចូលទៅក្នុងអូ/ព្រែក។<br>• បោះសំរាម ឬ ទុកម្ហូបអាហារចោលកណ្តាលវាល<br>• កាត់ដើមឈើ ទោះជាមានមូលហេតុអីក៏ដោយ ក្រៅពីក្នុងតំបន់សាងសង់ដែលមានការអនុញ្ញាត។<br>• ទិញសត្វព្រៃសម្រាប់ធ្វើម្ហូប។ |

| | |
|---|---|
| ◆ កំណត់ការងារ និងកន្លែងទុកដាក់សម្ភារៈ ក្នុងតំបន់ក្បែរកន្លែងការងារ<br>◆ ប្រើប្រាស់ឧបករណ៍សុវត្ថិភាពទាំងអស់ និងអនុវត្តតាមនូវរាល់នីតិវិធីសុវត្ថិភាព។<br>◆ ទប់ស្កាត់ការចម្លងរោគ ឬ ការបំពុលតាមអូ និងប្រឡាយទឹក<br>◆ ធានាថាមានឧបករណ៍ពន្លត់អគ្គីភ័យអាចប្រើប្រាស់បានភ្លាមៗ នៅពេលកំពុងបំពេញ "ការងារដែលក្តៅៗ " ដូចជា ផ្សា ខាត់ កាត់ស្មៅ ។ល។<br>◆ រាយការណ៍អំពីគ្រោះថ្នាក់មកលើកម្មករ ឬ សត្វនានា។<br>◆ បើកឡាន/ធ្វើដំណើរតាមផ្លូវដែលបានកំណត់តែប៉ុណ្ណោះ។<br>◆ ការពារកុំឲ្យមានធូលី និងសំឡេងរំខានខ្លាំងពេក។ | ◆ ប្រើប្រាស់សម្ភារៈមានជាតិពុលដែលគ្មានការអនុញ្ញាត ដូចជាទឹកថ្នាំដែលធ្វើពីសំណរ និងរូបធាតុម្យ៉ាងដែលមិនឆេះ ។ល។<br>◆ បង្ករការរំខានដល់តម្លៃបុរាណវិទ្យា ឬ ប្រវត្តិសាស្រ្ត<br>◆ ប្រើកាំភ្លើង (លើកលែងតែបុគ្គលិកសន្តិសុខដែលទទួលបានសិទ្ធិ)<br>◆ ប្រើប្រាស់គ្រឿងស្រវឹងដោយកម្មករកំឡុងពេលធ្វើការ<br>◆ លាងឡាន ឬ ម៉ាស៊ីននៅតាមអូ/ព្រែក<br>◆ ធ្វើការថែទាំ (ផ្លាស់ប្តូរប្រេងរំអិល និងតម្រងប្រេង) របស់ ឡាន និងឧបករណ៍ ក្រៅពីតំបន់ដែលទទួលបានសិទ្ធិ។<br>◆ បោះចោលសំរាមនៅទីកន្លែងដែលគ្មានការអនុញ្ញាត<br>◆ ដាក់សត្វព្រៃក្នុងទ្រុង (ជាពិសេស សត្វស្លាប) នៅកន្លែងស្នាក់នៅ។<br>◆ ធ្វើការងារដោយគ្មានឧបករណ៍ការពារសុវត្ថិភាព (រួមមានស្បែកជើងកវែង និងមួកការពារ)<br>◆ បង្ករភាពសៅហ្មង និងរំខាននៅក្នុង ឬនៅក្បែរសហគមន៍។<br>◆ បោកគក់សំលៀកបំពាក់នៅតាមទន្លេ និងព្រែក/អូ<br>◆ បោះចោលសំរាម សំណល់សាងសង់ ឬ កំទិចកំទីផ្ទេសផ្តាស់។<br>◆ ធ្វើឲ្យកំពប់ជាតិពុលជាសក្តានុពល ដូចជា ផលិតផលប្រេង<br>◆ កាប់អូស<br>◆ ចាប់ត្រីដោយប្រើសារធាតុគីមី និងគ្រឿងផ្ទុះ<br>◆ ប្រើបង្គន់ក្រៅពីបរិក្ខាដែលបានកំណត់ និង<br>◆ ដុតសំណល់ និង/ឬ ស្ទួនដំណាំដែលបានសម្អាតហើយ។ |

## ឧបសម្ព័ន្ធ ៣៖ គោលការណ៍ណែនាំផែនការគ្រប់គ្រងបរិស្ថាន សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធទេសភាព និងទេសចរណ៍

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ផែនការគ្រប់គ្រងបរិស្ថាន សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍ របស់

ក្រុមហ៊ុន ……………………… (ខ្មែរ)

…………………………………….. (អង់គ្លេស)

រៀបចំដោយ៖ ............................

ខែ.......... ឆ្នាំ................

## តារាងមាតិកា


ទំព័រ

**ជំពូក ១. សេចក្តីផ្តើម**

១.១ ទិដ្ឋភាពរួមទូទៅ........................................................................................................1

១.២ គោលបំណង...............................................................................................................1

1.3 វិធីសាស្ត្រ ..................................................................................................................1

**ជំពូក ២. ការពិពណ៌នារបស់គម្រោង**

២.១ សាវតា និងបទពិសោធន៍របស់ក្រុមហ៊ុន .....................................................................1

២.២ ទីតាំងរបស់គម្រោង .....................................................................................................1

២.៣ ប្រភេទគម្រោង/វិសាលភាព និងពេលវេលានៃសកម្មភាពរបស់គម្រោង.................................1

២.៤ ផែនការសកម្មភាពការងារ .............................................................................................1

២.៥ កម្មវិធីសកម្មភាពការងាររបស់គម្រោង ..........................................................................1

**ជំពូក ៣. ផែនការគ្រប់គ្រងបរិស្ថាន**

៣.១ សង្ខេបអំពីផលប៉ះពាល់អវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ .....................................1

៣.២ កម្មវិធីបណ្តុះបណ្តាល .................................................................................................1

៣.៣ កម្មវិធីពិនិត្យតាមដានបរិស្ថាន ក្នុងដំណាក់កាលសាងសង់
ប្រតិបត្តិការ និងការបញ្ចប់គម្រោង ...................................................................................1

**ជំពូក ៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

**ជំពូក ១. សេចក្តីផ្តើម**

១.១ ទិដ្ឋភាពរួម៖ ពិពណ៌នាដោយសង្ខេបអំពីសាវតា និងមូលហេតុដែលត្រូវមានគម្រោង និង ស្ថានភាពទូទៅរបស់គម្រោង។

១.២ គោលបំណងនៃផែនការគ្រប់គ្រងបរិស្ថាន

១.៣ វិធីសាស្ត្រ៖ នៅចំណុចនេះ ពិពណ៌នាអំពីតម្រូវការព័ត៌មាន - ទិន្នន័យ វិធីសាស្ត្រប្រមូល និងវិភាគទិន្នន័យ។

**ជំពូក ២. ការពិព៌ណនារបស់គម្រោង**

នៅក្នុងជំពូកនេះ គម្រោងនឹងបកស្រាយលម្អិត ដូចដែលមានចែងនៅក្នុងរបាយការណ៍សិក្សាលទ្ធភាពគម្រោង ឬ ផែនការមេរបស់ក្រុមហ៊ុន ដោយផ្តោតលើព័ត៌មានដូចខាងក្រោម៖

២.១ សាវតា និងបទពិសោធន៍របស់ក្រុមហ៊ុន

២.២ ទីតាំងក្រុមហ៊ុន (គួរតែភ្ជាប់មកជាមួយនូវផែនទីរដ្ឋបាលនៃតំបន់ និងទីតាំងរបស់គម្រោង)

២.៣ ប្រភេទគម្រោង/វិសាលភាព និងពេលវេលារបស់សកម្មភាពគម្រោង (តំណាក់កាលមុនប្រតិបត្តិការរបស់គម្រោង កំឡុងពេលប្រតិបត្តិការរបស់គម្រោង និងពេលបញ្ចប់គម្រោង)

២.៤ ផែនការសកម្មភាពការងារ៖ ដូចជា (១) ប្រភព និងបរិមាណវត្ថុធាតុដើមដែលត្រូវប្រើ (២) តម្រូវការគ្រឿងម៉ាស៊ីន (៣) តម្រូវការកម្លាំងពលកម្មក្នុងស្រុក និងពីបរទេស (៤) បរិមាណនៃផលិតផលសម្រេច (៥) ចំណូលចំណាយ (៦) សង្វាក់ផលិតកម្ម (៧) ផែនការគ្រប់គ្រងសំណល់ ។ល។

២.៥ កម្មវិធីសកម្មភាពការងាររបស់គម្រោង

**ជំពូក ៣. ផែនការគ្រប់គ្រងបរិស្ថាន**

ក្នុងផ្នែកនេះ គម្រោងចាំបាច់ត្រូវមានមូលនិធិគ្រប់គ្រាន់សម្រាប់កិច្ចការពារបរិស្ថាន និងសម្រាប់បង្កើត ក្រុមមួយដែលមានអ្នកជំនាញមានសមត្ថភាព ឧបករណ៍ វិធាន និងកាលវិភាគត្រឹមត្រូវ សម្រាប់ការ ពិនិត្យតាមដានគុណភាពផ្នែកបរិស្ថាន ដោយមានកិច្ចសហការយ៉ាងជិតស្និតជាមួយក្រសួង/ស្ថាប័នពាក់ព័ន្ធ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានផ្នែកបរិស្ថានរបស់គម្រោង។

ផែនការគ្រប់គ្រងបរិស្ថាន រួមមាន៖

៣.១ សង្ខេបអំពីផលប៉ះពាល់អវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ

៣.២ កម្មវិធីបណ្តុះបណ្តាល

៣.៣ កម្មវិធីពិនិត្យតាមដានបរិស្ថាន ក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិការ និងការបញ្ចប់គម្រោង

គម្រោងនឹងបញ្ជាក់នូវចំណុចខាងក្រោម៖

- ស្ថាប័នទទួលខុសត្រូវលើការពិនិត្យតាមដានគម្រោង
- ការកំណត់ព្រំដែនដែលត្រូវពិនិត្យតាមដាន
- វិធានពិនិត្យតាមដាន
- គោលការណ៍ណែនាំ ឬ បទបញ្ញត្តិដែលត្រូវអនុវត្តសម្រាប់ការពិនិត្យតាមដាន
- កម្មវិធី និងរយៈពេលដែលត្រូវពិនិត្យតាមដាន
- ការវាយតម្លៃផ្ទាល់លើលទ្ធផលពីការពិនិត្យតាមដាន ដែលធ្វើដោយម្ចាស់គម្រោង
- ផ្តល់របាយការណ៍ប្រចាំត្រីមាសទៅក្រសួងបរិស្ថាន និងក្រសួង/ស្ថាប័នពាក់ព័ន្ធ។

## ជំពូក ៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ក្នុងសេចក្តីសន្និដ្ឋាន ម្ចាស់គម្រោង/ម្ចាស់ក្រុមហ៊ុន ចាំបាច់ត្រូវបង្ហាញការវិនិយោគ ដោយត្រូវបញ្ជាក់ពីវិធានការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ចីរភាពវិជ្ជមានផ្នែកបរិស្ថាន និងការកែលម្អជីវភាពរស់នៅរបស់សហគមន៍ពាក់ព័ន្ធ នៅពេលដែលមានការវិនិយោគក្នុងតំបន់របស់គម្រោង។

នៅក្នុងជំពូកនេះ ម្ចាស់គម្រោងត្រូវធានា និងទទួលខុសត្រូវលើផែនការគ្រប់គ្រងបរិស្ថាន និងអនុសាសន៍ពាក់ព័ន្ធនឹងគម្រោង។

## ឧបសម្ព័ន្ធ ៤៖ សង្ខេបនៃផលប៉ះពាល់ផ្នែកបរិស្ថាន និងវិធានការកាត់បន្ថយផលប៉ះពាល់

| ធនធានបរិស្ថាន ធម្មជាតិនិងធនធានសេដ្ឋកិច្ចសង្គម | ផលប៉ះពាល់អវិជ្ជមាន | កំណត់វិសាលភាពនៃផលប៉ះពាល់ | | | វិធានការកាត់បន្ថយ | កំណត់សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ធ្ងន់ធ្ងរ | | |
| **១. ផលប៉ះពាល់កំឡុងពេលដំណាក់កាលមុនប្រតិបត្តិការគម្រោង** | | | | | | |
| ក. ធនធានធម្មជាតិ និងបរិស្ថាន | | | | | | |
| - ធនធានរូបវន្ត | | | | | | |
| - ធនធានជីវសាស្ត្រ | | | | | | |
| ខ. ធនធានសេដ្ឋកិច្ចសង្គម | | | | | | |
| **១.២ ផលប៉ះពាល់កំឡុងពេលដំណាក់កាលសាងសង់របស់គម្រោង** | | | | | | |
| ក. ធនធានធម្មជាតិ និងបរិស្ថាន | | | | | | |
| - ធនធានរូបវន្ត | | | | | | |
| - ធនធានជីវសាស្ត្រ | | | | | | |
| ខ. ធនធានសេដ្ឋកិច្ចសង្គម | | | | | | |
| **២. ផលប៉ះពាល់កំឡុងពេលដំណាក់កាលប្រតិបត្តិការរបស់គម្រោង** | | | | | | |
| ក. ធនធានធម្មជាតិ និងបរិស្ថាន | | | | | | |
| - ធនធានរូបវន្ត | | | | | | |
| - ធនធានជីវសាស្ត្រ | | | | | | |
| ខ. ធនធានសេដ្ឋកិច្ចសង្គម | | | | | | |
| **៣. ផលប៉ះពាល់កំឡុងពេលដំណាក់កាលបញ្ចប់របស់គម្រោង** | | | | | | |
| ក. ធនធានធម្មជាតិ និងបរិស្ថាន | | | | | | |
| - ធនធានរូបវន្ត | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| - ធនធានជីវសាស្ត្រ | | | | | | |
| ខ. ធនធានសេដ្ឋកិច្ចសង្គម | | | | | | |

## ឧបសម្ព័ន្ធ ៥៖ គំរូក្របខ័ណ្ឌទំនួលខុសត្រូវនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន

គំរូក្របខ័ណ្ឌទំនួលខុសត្រូវនេះ កំណត់សកម្មភាពរបស់គម្រោង វិសាលភាព វិធីសាស្ត្រសិក្សាស្រាវជ្រាវ និងទម្រង់របាយការណ៍បឋម ឬ របាយការណ៍ពេញលេញនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម សម្រាប់ប្រើប្រាស់នៅក្រសួងបរិស្ថាន ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ និងអ្នកពាក់ព័ន្ធជាមួយគម្រោងផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍។ .

### ១. សេចក្តីផ្តើម

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាពិគ្រោះយោបល់នឹងពិពណ៌នានូវចំណុចសំខាន់មួយចំនួន ដូចខាងក្រោម៖

- ទស្សនៈវិស័យ និងគោលបំណងនៃការវិនិយោគ ក្នុងការចូលរួមដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈវិស័យហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍។
- កាតព្វកិច្ចផ្លូវច្បាប់ដែលតម្រូវឲ្យក្រុមហ៊ុនវិនិយោគធ្វើការរៀបចំក្របខ័ណ្ឌទំនួលខុសត្រូវលើការរៀបចំរបាយការណ៍បឋម ឬរបាយការណ៍ពេញលេញនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម។
- សារៈសំខាន់នៃក្របខ័ណ្ឌទំនួលខុសត្រូវសម្រាប់រៀបចំរបាយការណ៍នៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម សម្រាប់គម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍។

### ២. គោលបំណងរបស់ក្របខ័ណ្ឌទំនួលខុសត្រូវ៖

គោលបំណងសំខាន់របស់ក្របខ័ណ្ឌទំនួលខុសត្រូវ គឺ៖

- គឺជាផែនទីបង្ហាញផ្លូវមួយសម្រាប់រៀបចំរបាយការណ៍បឋម ឬពេញលេញនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម ប្រកបដោយគុណភាពខ្ពស់ និងភាពត្រឹមត្រូវ។
- កំណត់វិសាលភាព និងវិធីសាស្ត្រក្នុងការសិក្សាស្រាវជ្រាវអំពីធនធានបរិស្ថានដែលមានស្រាប់ ដូចជាធនធានរូបវន្ត ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម។
- កំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធ និងសាធារណៈជន ដើម្បីធ្វើការពិគ្រោះយោបល់
- កំណត់ទម្រង់របាយការណ៍ប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម សមាជិកក្នុងក្រុមសិក្សាស្រាវជ្រាវ និងកាលវិភាគនៃផែនការសិក្សា។

### ៣. ការពិពណ៌នារបស់គម្រោង

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាពិគ្រោះយោបល់នឹងបង្ហាញនូវចំណុចមួយចំនួន ដូចខាងក្រោម៖

- សារៈសំខាន់នៃវត្តមានរបស់គម្រោង
- ការវិភាគអំពីជម្រើសនានារបស់គម្រោង
- សាវតានិងបទពិសោធន៍របស់ក្រុមហ៊ុន ពាក់ព័ន្ធនឹងការអនុវត្តគម្រោង
- ប្រភពទុន និងប្រភេទគម្រោង (វិស័យសាធារណៈ ឬ វិស័យឯកជន ឬ ដៃគូអភិវឌ្ឍន៍)
- ឧបករណ៍ផ្នែកច្បាប់ពាក់ព័ន្ធនឹងគម្រោង
- ទីតាំងភូមិសាស្ត្រ៖ បង្ហាញទីតាំងភូមិសាស្ត្រ ព្រំប្រទល់ ទំហំដី និងទីតាំងរបស់គម្រោង ដែលជាប់ទាក់ទងនឹងតំបន់សំខាន់ៗ ដោយត្រូវភ្ជាប់ជាមួយនឹងផែនទីរដ្ឋបាល (Datum Coordinate System: UTM_WGS1984_48N) and Google Map។
- សង្ខេបសកម្មភាពរបស់គម្រោង (វដ្តគម្រោង និងរយៈពេល) រួមមាន៖
    - ➢ ផែនការបែងចែកដីសម្រាប់គម្រោង (ដីសម្រាប់សាងសង់ ហេដ្ឋារចនាសម្ព័ន្ធ តំបន់បៃតង និងចំណតឡាន ស្របទៅតាមផែនការមេ ។ល។) (មានភ្ជាប់មកជាមួយនូវទម្រង់ផែនការបែងចែងដីផែនការអគារ គំរូព្រាងផែនការស្ថាបត្យកម្ម ការប្រើប្រាស់ដីធ្លី គំរូព្រាង អគារ និងផែនការ ។ល។)
    - ➢ ផែនការអនុវត្តគម្រោង
    - ➢ បច្ចេកទេសសាងសង់
    - ➢ តម្រូវការគ្រឿងម៉ាស៊ីន ឧបករណ៍ សម្ភារៈ និងបរិក្ខាផ្សេងៗទៀត
    - ➢ តម្រូវការវត្ថុធាតុដើម (សម្ភារៈ និងឧបករណ៍សំណង់)
    - ➢ តម្រូវការធនធានមនុស្ស-កម្លាំងពលកម្ម និងចំនួនទេសចរ (តួនាទី សញ្ជាតិ និងប្រាក់ខែកំឡុងពេលសាងសង់ និងប្រតិបត្តិការ)
    - ➢ តម្រូវការប្រើប្រាស់ថាមពល
        - ▪ អគ្គីសនីរដ្ឋ ឬ ឯកជន (ការប្រើប្រាស់ថាមពល)
        - ▪ ម៉ាស៊ីនភ្លើង (ទំហំកម្លាំងថាមពល)
        - ▪ ប្រព័ន្ធពន្លឺព្រះអាទិត្យ
    - ➢ តម្រូវការទឹក (ប្រភព និងបរិមាណ)
    - ➢ ផែនការគ្រប់គ្រងសំណល់រឹង-ទន់៖

- សំណល់រឹង៖ ត្រូវកំណត់អត្តសញ្ញាណប្រភព និងប្រភេទសំណល់ដែលបានបង្កើតឡើង ដោយសកម្មភាពរបស់គម្រោង និងពិពណ៌នាអំពីទីតាំង ការទុកដាក់ និងការគ្រប់គ្រងសំណល់។
- សំណល់ទឹក៖ ទីតាំងរោងចក្រចម្រោះទឹក បច្ចេកទេស មុខងារ ដំណើរការនៃរោងចក្រចម្រោះទឹក ទំហំ សមត្ថភាព និងទីតាំងស្តុកសំណល់ទឹកចុងក្រោយ
- ភក់៖ ការគ្រប់គ្រងភក់ដែលចេញពីរោងចក្រចម្រោះសំណល់ទឹក
- សំណល់ពីឧស្ម័ន៖ ការគ្រប់គ្រងឧស្ម័នចេញពីម៉ាស៊ីនភ្លើង ឬ ម៉ាស៊ីន ផ្សេងៗទៀត
- សំណល់ដែលមានគ្រោះថ្នាក់៖ (កំបោរ ថ្នាំលាប ។ល។)

➢ ការបង្កើតប្រព័ន្ធប្រមូលទឹកភ្លៀងនៅក្នុងតំបន់របស់គម្រោង

➢ ការគ្រប់គ្រងសុខភាព និងសុវត្ថិភាពបុគ្គលិក/កម្មករ ទេសចរ និងប្រជាជន

➢ ការគ្រប់គ្រងហានិភ័យ (គ្រោះមហន្តរាយធម្មជាតិ ប្រព័ន្ធការពារភ្លើងឆេះ ការដាក់ស្លាក សញ្ញាគ្រោះថ្នាក់ ការផ្តល់សញ្ញាប្រមានអំពីមហន្តរាយ ជណ្តើរឡើងចុះក្នុងគ្រាអាសន្ន ការបណ្តុះបណ្តាលអំពីការសង្គ្រោះ ការជម្លៀសមនុស្ស គិលានដ្ឋាន និងមេធាវី សម្រាប់ដោះស្រាយករណីមានហានិភ័យកើតឡើង)។

➢ រយៈពេលនៃសកម្មភាពរបស់គម្រោង

## ៤. វិសាលភាព និងវិធីសាស្ត្រនៃការសិក្សា

ពាក់ព័ន្ធនឹងការកំណត់វិសាលភាព និងវិធីសាស្ត្រក្នុងការសិក្សាលើរបាយការណ៍បឋម ឬរបាយការណ៍ពេញលេញអំពីការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម ឬ អំពីរបាយការណ៍ប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ ត្រូវប៉ាន់ប្រមាណធនធានបរិស្ថានដែលមានស្រាប់ក្នុងតំបន់គម្រោង និងនៅជុំវិញការដ្ឋានគម្រោង ដូចជា ធនធានជារូបវន្ត ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម។

ក្នុងការប្រមូលទិន្នន័យ ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវពឹងផ្អែកលើ៖

ទិន្នន័យទី ២៖ ជាទិន្នន័យដែលត្រូវប្រមូលនិងទាញយកពីឯកសារបច្ចេកទេសសំខាន់ៗរបស់គម្រោង រួមមានរបាយការណ៍បច្ចេកទេសរបស់ក្រុមហ៊ុន ផែនការមេ និងឯកសារពាក់ព័ន្ធ។

ទិន្នន័យទី១៖ ជាទិន្នន័យដែលត្រូវប្រមូល តាមរយៈការអង្កេតនៅក្នុង និងជុំវិញតំបន់របស់គម្រោង ដោយផ្តោតលើធនធានរូបវន្ត ជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម និងការប្រើប្រាស់វិធី សាស្ត្រលម្អិតបែបវិទ្យាសាស្ត្រ។

## ៤.១ ធនធានបរិស្ថានដែលមានស្រាប់

- ធនធានរូបវន្ត៖
  - ❖ **ដី៖**

➢ ភូគព្ភសាស្ត្រ៖ កំណត់វិធីសាស្ត្រ និងការប្រើប្រាស់ទិន្នន័យដែលមានស្រាប់

➢ ឋានលេខា៖ សិក្សាអំពីកម្ពស់ និងចំណោត់ថ្នាក់នៃទីជម្រាល ដោយត្រូវភ្ជាប់ផែនទីជាមួយធនធាន និងកំណត់វិធីសាស្ត្រ និងឧបករណ៍ – សម្ភារៈអង្កេត

➢ ការចាត់ថ្នាក់ដី និងជីវជាតិដី៖ សិក្សាអំពីប្រភេទដី កម្រិតជីវជាតិដី និងភាពសមស្រប របស់ដី (ទាប មធ្យម ខ្ពស់)

➢ គុណភាព និងកំហាប់ដី៖ កំណត់ចំនួនសំណាកដោយផ្អែកលើប្រភេទនិងទំហំរបស់ដី ក្នុងតំបន់របស់គម្រោង និងបញ្ជាក់អំពីទីតាំង (កូអ័រដោណេ)។ ព្រំដែនដែលត្រូវវិភាគ រួមមាន៖

- ▪ ជាតុផ្សំគីមីនៃដី៖ នីត្រូហ្សែន (N), ហ្វូសហ្វ័រ (P), ប៉ូតាស្យូម (K), កាល់ស្យូម (Ca), ម៉ាញេស្យូម (Mg), សូដ្យូម (Na), សមាសជាតុសេរីរាង្គ រេត្យូ C/N, ហ្វូសហ្វ័រសរុប ហ្វូសហ្វ័រដែលរលាយ cation-exchange capacity (CEC), អាស៊ីត ឬ បាស (pH) នីត្រូហ្សែន (N), electrode conductivity, ។ល។
  - ▪ ជាតុផ្សំដីជារូបវន្ត Soil physical properties៖ សំណើម ល្បាប់ឥដ្ឋ alluvial clays (%), ល្បាប់ទន់ (%), ល្បាប់រឹង (%), ខ្សាច់ទន់ (%), និងខ្សាច់រឹង(%).
  - ▪ បញ្ជាក់ច្បាស់អំពីវិធីសាស្ត្រជ្រើសរើសសំណាក រួមមាន ស្តង់ដាប្រៀបធៀបថ្នាក់ជាតិ។ ក្នុងករណីដែលស្តង់ដាជាតិមិនសមស្រប គឺត្រូវប្រើ ស្តង់ដាប្រៀបធៀបថ្នាក់អន្តរជាតិ។

➢ ធនធានរ៉ែ និងទិន្នន័យដែលមានស្រាប់ (បើសិនជាមាន)។

➢ យន្តការដី ដែលអាចធន់នឹងអគារខ្ពស់ៗ។

- ○ **បរិយាកាស៖** កំណត់ទិន្នន័យអាកាសធាតុ/កម្តៅ របបទឹកភ្លៀង សំណើម និងទិសដៅនិងល្បឿនខ្យល់ ដោយប្រើទិន្នន័យក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ របស់ ក្រសួងធនធានទឹក និងឧត្តុនិយម ឬ នាយកដ្ឋានធនធានទឹក និងឧត្តុនិយម និងទិន្នន័យពាក់ព័ន្ធនឹងទឹកជំនន់ និងគ្រោះមហន្តរាយធម្មជាតិ ដែលបានកើតឡើងក្នុង និងជុំវិញតំបន់របស់គម្រោង។ *សូមកត់សម្គាល់ថា:*

*ករណីដែលមិនមានទិន្នន័យបរិយាកាសសម្រាប់ខេត្តដែលមានគម្រោង គឺអាចប្រើទិន្នន័យរបស់ខេត្ត ដែលនៅក្បែរនោះបាន។*

- **គុណភាពខ្យល់៖** ធ្វើការវិភាគយ៉ាងហោចណាស់ លើ ២ សំណាកខ្យល់ (ដែលមួយយកនៅទីតាំងគម្រោង និងមួយទៀតយកពីទីតាំងដែនជម្រកដែលមានប្រជាពលរដ្ឋរស់នៅ) ទីតាំងភូមិសាស្ត្រ ឬ ទិសដៅខ្យល់ (សម្រាប់របាយការណ៍បឋម នៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម យ៉ាងហោចណាស់ ត្រូវសិក្សាឲ្យបាន ០១ សំណាក និងសម្រាប់របាយការណ៍ពេញលេញនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម គួរតែត្រូវបានសិក្សា) ដោយត្រូវ កំណត់យ៉ាងហោចណាស់ ០៨ សមាសធាតុ ដូចជា CO, $NO_2$, $SO_2$, TSP, $O_3$, Pb, PM10, និង PM2.5.

តារាង ១៖ ប៉ារ៉ាម៉ែត្រ និងស្តង់ដាសម្រាប់ការគ្រប់គ្រងគុណភាពខ្យល់

| ល.រ | សមាសធាតុ | រង្វាស់ | ស្តង់ដារបស់ MOE | រយៈពេល |
|---|---|---|---|---|
| ១ | កាបោនម៉ូណូអុកស៊ីត (CO) | $mg/m^3$ | ២០ | ៨ ម៉ោង |
| ២ | កាបោនឌីអុកស៊ីត ($NO_2$) | $mg/m^3$ | 0.១ | ២៤ ម៉ោង |
| ៣ | សុលហ្វ័រឌីអុកស៊ីត ($SO_2$) | $mg/m^3$ | 0.៣ | ២៤ ម៉ោង |
| ៤ | អូហ្សូន ($O_3$) | $mg/m^3$ | 0.២ | ១ ម៉ោង |
| ៥ | សំណរ (Pb) | $mg/m^3$ | 0.00៥ | ២៤ ម៉ោង |
| ៦ | Total Suspended Particles (TSP) | $mg/m^3$ | 0.៣៣ | ២៤ ម៉ោង |
| ៧ | Particulate Matter (PM10) | $mg/m^3$ | 0.0៥ | ២៤ ម៉ោង |
| ៨ | Particulate Matter (PM2.5) | $mg/m^3$ | 0.0២៥ | ២៤ ម៉ោង |

*កំណត់សម្គាល់៖ វិធានវិភាគផ្អែកលើវិធីសាស្ត្រអនុវត្តជាក់ស្តែង។*

- **ការវិភាគគុណភាពខ្យល់៖** ម្ចាស់គម្រោងនិងក្រុមហ៊ុនប្រឹក្សាយោបល់ អាចស្នើសុំការវិភាគនៅមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន។

  ក្នុងករណីដែលម្ចាស់គម្រោងនិងក្រុមហ៊ុនប្រឹក្សាយោបល់ ប្រើមន្ទីរពិសោធន៍ឯកជន ឬបរិក្ខាផ្សេងៗទៀត មន្ទីរពិសោធន៍ ឬ បរិក្ខាទាំងនោះ ត្រូវតែមានការទទួលស្គាល់ដោយក្រសួងបរិស្ថាន។

- **ស្តង់ដាប្រៀបធៀបៈ** លទ្ធផលនៃការពិនិត្យ ដែលម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវប្រៀបធៀបនឹងកម្រិតកំណត់ស្តង់ដាគុណភាពខ្យល់ក្នុងតារាងទី១ ខាងលើ។

❖ **សំឡេង និងរំញ័រៈ**

- ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវវាស់កម្រិតសំឡេង និងរំញ័រយ៉ាងតិច ០២ សំណាក ដោយ០១សំណាកយកនៅទីតាំងគម្រោង និង០១សំណាកទៀតយកនៅតំបន់ទីប្រជុំជន ឬតំបន់សាធារណៈ (សាលារៀន មន្ទីរពេទ្យ វត្តអារាម ទីសក្ការៈបូជា) ដើម្បីទទួលបានទិន្នន័យគោល សម្រាប់ផ្ទៀងផ្ទាត់នៅពេលអនាគត
- ការវាស់កម្រិតសំឡេង និងរំញ័រៈ ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់អាចសុំធ្វើការវិភាគនៅមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន។ ក្នុងករណីម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ ប្រើប្រាស់មន្ទីរពិសោធន៍ឯកជន ឬឧបករណ៍ផ្សេងៗទៀត ត្រូវមានការទទួលស្គាល់ជាផ្លូវការពីក្រសួងបរិស្ថាន
- រយៈពេលវាស់កម្រិតសំឡេង និងរំញ័រៈ ២៤ម៉ោង ដោយធ្វើការកត់ត្រាគម្លាតទិន្នន័យ ០១ម៉ោងម្តង
- ស្តង់ដាប្រៀបធៀបៈ លទ្ធផលនៃការវាស់កម្រិតសំឡេង ម្ចាស់គម្រោងនិងក្រុមហ៊ុន ប្រឹក្សាយោបល់ត្រូវប្រៀបធៀបនឹងស្តង់ដាកម្រិតសំឡេង ដូចមានចែងនៅក្នុងតារាងទី២ ខាងក្រោម។

តារាងទី២ៈ ប៉ារ៉ាម៉ែត្រ និងស្តង់ដាសម្រាប់កម្រិតសំឡេង

| **ល.រ** | **ទីតាំង** | **អំឡុងពេល** | | |
|---|---|---|---|---|
| | | **ពីម៉ោង ៦ព្រឹក ដល់ម៉ោង ១៨ល្ងាច** | **ពីម៉ោង ១៨ល្ងាច ដល់ម៉ោង ២២យប់** | **ពីម៉ោង ២២យប់ ដល់ម៉ោង ៦ព្រឹក** |
| ១ | តំបន់ស្ងាត់ស្ងៀម<br>- មន្ទីរពេទ្យ<br>- បណ្ណាល័យ<br>- សាលារៀន<br>- មត្តេយ្យសាលា | ៤៥ dBA | ៤០ dBA | ៣៥ dBA |

| ល.រ | ទីតាំង | អំឡុងពេល | | |
|---|---|---|---|---|
| | | ពីម៉ោង ៦ព្រឹក ដល់ម៉ោង ១៨ល្ងាច | ពីម៉ោង ១៨ល្ងាច ដល់ម៉ោង ២២យប់ | ពីម៉ោង ២២យប់ ដល់ម៉ោង ៦ព្រឹក |
| ២ | តំបន់ដែនជម្រក<br>- សណ្ឋាគារ ទីកន្លែងរដ្ឋបាល<br>- ភូមិគ្រឹះ ផ្ទះល្វែង | ៦០ dBA | ៥០ dBA | ៤៥ dBA |
| ៣ | តំបន់ពាណិជ្ជកម្ម សេវាកម្ម និងចំរុះ | ៧០ dBA | ៦៥ dBA | ៥០ dBA |
| ៤ | ឧស្សាហកម្មធន់ស្រាល លាយចំរុះនៅក្នុងតំបន់ដែនជម្រក | ៧៥ dBA | ៧០ dBA | ៥០ dBA |

*<u>កំណត់សម្គាល់</u>៖ វិធីសាស្ត្រវិភាគផ្អែកលើវិធីសាស្ត្រជាក់ស្តែង*

- ចំពោះស្តង់ដារំញ័រ ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវកំណត់ម៉ោងចាប់ពី ៦ព្រឹក ដល់ ១៨ល្ងាច និងពីម៉ោង ១៨ល្ងាច ដល់ម៉ោង ៦ព្រឹក ហើយលទ្ធផលនៃការវាស់កម្រិតរំញ័រត្រូវប្រៀបធៀបនឹងស្តង់ដាកម្រិតសំឡេង ដូចមានចែងនៅក្នុងតារាងទី៣ ខាងក្រោម។

តារាងទី៣៖ ប៉ារ៉ាម៉ែត្រ និងស្តង់ដាសម្រាប់វាស់កម្រិតរំញ័រ

| ល.រ | រយៈពេល | ស្តង់ដារំញ័រ គិតជា (dBA) |
|---|---|---|
| ១ | ពីម៉ោង ០៦ព្រឹក ទៅម៉ោង០៦ ល្ងាច | ៦៥ |
| ២ | ពីម៉ោង ០៦ល្ងាច ទៅម៉ោង០៦ព្រឹក | ៦០ |

- **ជលវិទ្យា៖** សិក្សាអំពីប្រភពចុងក្រោយនៃផ្លូវទឹក លំហូរ អូ ការបញ្ចេញទឹកចោល ឈ្មោះ/រូបរាង និងចំងាយ/មុខងារ/ទំហំនៃប្រព័ន្ធផ្លូវទឹក (ប្រភពទឹកសាធារណៈ) ដែលមានទីតាំងនៅក្នុង និងក្បែរទីតាំងគម្រោង។ ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ គួរតែកំណត់ចំងាយពីទីកន្លែងដែលត្រូវសិក្សាទៅប្រព័ន្ធផ្លូវទឹក (ផ្លូវទឹកលើដី និងផ្លូវទឹកផ្នែកខាងក្រោមនៃទីតាំងគម្រោង) យ៉ាងហោចណាស់ ០១ គីឡូម៉ែត្រ។ (កំណត់សម្គាល់៖ សម្រាប់គម្រោងដែលមានទីតាំងនៅក្បែរប្រភពទឹកសាធារណៈ)។
- **គុណភាពទឹកលើដី**
  - ការកំណត់ចំនួនសំណាក និងទីតាំងសំណាក គឺផ្អែកលើស្ថានភាពទីតាំងភូមិសាស្ត្រ ជាក់ស្តែង និងប្រព័ន្ធផ្លូវទឹកធម្មជាតិ ដែលអាចនឹងទទួលរងផលប៉ះពាល់អវិជ្ជមានពីគម្រោង។ យ៉ាង

ហោចណាស់ ត្រូវយកសំណាកចំនួន ០២ ដែល ០១សំណាកយកចេញពីប្រភពធម្មជាតិដែលមានទីតាំងនៅក្បែរទីតាំងគម្រោង និង ០១សំណាកទៀតត្រូវយកចេញពីចំណុចបញ្ចេញចោលសំណល់ទឹកពីរោងចក្រចម្រោះចុងក្រោយរបស់គម្រោង។

- បញ្ជាក់អំពីវិធីសាស្ត្រយកសំណាកទឹកលើដីសម្រាប់វិភាគលើគុណភាពទឹក និងប៉ារ៉ាម៉ែត្រដែលត្រូវវិភាគ រួមមាន ការកំណត់ស្តង់ដាគុណភាពទឹក។
- ប៉ារ៉ាម៉ែត្រ និងស្តង់ដា

តារាង ទី ៤៖ ប៉ារ៉ាម៉ែត្រ និងស្តង់ដាវាស់វែងគុណភាពផ្ទៃទឹកខាងលើ

| ល.រ | ប៉ារ៉ាម៉ែត្រ | ឯកតារង្វាស់ | ទឹកទន្លេ | បឹង និងអាង | សមុទ្រ |
|---|---|---|---|---|---|
| ១ | អាស៊ីត ឬ បាស pH | - | ៦.៥-៨.៥ | ៦.៥-៨.៥ | ៧.០-៨.៣ |
| ២ | Total Dissolved Solid (TDS) | mg/l | <១០០០ | <១០០០ | <១០០០ |
| ៣ | Total Suspended Solid (TSS) | mg/l | ២៥-១០០ | ១-១៥ | <២០ |
| ៤ | អុកស៊ីហ្សែនរលាយ (DO) | mg/l | ៧.៥-២.០ | ៧.៥-២.០ | ៧.៥-២.០ |
| ៥ | Biochemical Oxygen Demand ($BOD_5$) | mg/l | ១-១០ | <៣០ | <៣០ |
| ៦ | Chemical Oxygen Demand (COD) | mg/l | <៥០ | ១-៨ | ២-៨ |
| ៧ | ប្រេង និងខ្លាញ់ | mg/l | <៥.០ | <៥.០ | ០ |
| ៨ | សាប៊ូ | mg/l | <៥.០ | <៥.០ | ០ |
| ៩ | ស៊ុលហ្វាត ($SO_4$) | mg/l | <៣០០ | <៣០០ | <៣០០ |
| ១០ | តូតាល់ នីត្រូហ្សែន (TN) | mg/l | ០.១-០.៦ | ០.១-០.៦ | ០.២-១.០ |
| ១១ | តូតាល់ ហ្វូស្វ័រ (TP) | mg/l | ០.០០៥-០.០៥ | ០.០០៥-០.០៥ | ០.០២-០.០៩ |
| ១២ | សំណរ (Pb) | mg/l | <០.០១ | <០.០១ | <០.០១ |
| ១៣ | អាសេនិក (AS) | mg/l | <០.០១ | <០.០១ | <០.០១ |
| ១៤ | Cadmium (Cd) | mg/l | <០.០០១ | <០.០០១ | <០.០០១ |
| ១៥ | ដែក (Fe) | mg/l | <១ | <១ | <១ |
| ១៦ | បារត (Hg) | mg/l | <០.០០០៥ | <០.០០០៥ | <០.០០០៥ |
| ១៧ | Total Coliform | MPN/១០០ml | < ៥០០០ | < ១០០០ | < ១០០០ |

*កំណត់សម្គាល់៖ - ចំនួនប៉ារ៉ាម៉ែត្រ អាចតម្រូវឲ្យមានការវិភាគបន្ថែម បើសិនជាចាំបាច់ (ដូចជា ដែកធ្ងន់ ។ល។)*

*- វិធីសាស្ត្រវិភាគផ្អែកលើវិធីសាស្ត្រដាក់ស្តែង*

តារាងទី ៥៖ ប៉ារ៉ាម៉ែត្រ និងស្តង់ដា សម្រាប់វាស់វែងការបញ្ចេញសំណល់ទឹកពីអគារពាណិជ្ជកម្ម អគារស្នាក់នៅ ទីក្រុងធំៗ និងរីហ្សត ឬ កន្លែងកំសាន្តនានា៖

| ល.រ | ប៉ារ៉ាម៉ែត្រ | រង្វាស់ | ស្តង់ដាកំណត់ | |
|---|---|---|---|---|
| | | | កម្រិតជាតិពុលដែលអនុញ្ញាតឲ្យបញ្ចេញចោលតាមប្រព័ន្ធលូ | កម្រិតជាតិពុលដែលអនុញ្ញាតឲ្យបញ្ចេញចោលតាមប្រភពទឹក សាធារណៈ |
| ១ | អាស៊ីត ឬ បាស់ pH | - | ៥-៩ | ៦-៨ |
| ២ | Total Suspended Solid (TSS) | mg/l | <១៥០ | <៨០ |
| ៣ | ប្រេង និងខ្លាញ់ | mg/l | <២០ | <៥ |
| ៤ | Biochemical Oxygen Demand ($BOD_5$) (5 day at 20 $^0$C) | mg/l | <៨០ | <៣០ |
| ៥ | Chemical Oxygen Demand (COD) ($Cr_2O_7^{2-}$) | mg/l | <១២០ | <៥០ |
| ៦ | សាប៊ូ –LAS | mg/l | <១៥ | <៧ |
| ៧ | តូតាល់ នីត្រូហ្សែន (TN) | mg-N/l | <១០ | <៦ |
| ៨ | តូតាល់ ហ្វូសហ្វ័រ (TP) | mg-P/l | <១ | <0.៥ |
| ៩ | Ammonia ($NH_3$) | mg/l | <៨ | <៥ |
| ១០ | Coliform | MPN/100 ml | - | ៥00-២៥00 |

*កំណត់សម្គាល់៖ - ចំនួនប៉ារ៉ាម៉ែត្រ អាចតម្រូវឲ្យមានការវិភាគបន្ថែម បើសិនជាចាំបាច់ (ដូចជា ដែកធូន់ ។ល។)*

*- វិធីសាស្ត្រវិភាគផ្អែកលើវិធីសាស្ត្រដាក់ស្តែង*

❖ **គុណភាពទឹកក្រោមដី**

➢ ការពិពណ៌នាដោយសង្ខេបអំពីប្រភពទឹកក្រោមដី នៅក្នុង និងក្បែរតំបន់គម្រោង។

➢ កំណត់ចំនួនសំណាក និងទីតាំងសំណាក ផ្អែកលើស្ថានភាពភូមិសាស្ត្រជាក់ស្តែង និងប្រព័ន្ធផ្លូវទឹក ដែលអាចទទួលរងផលប៉ះពាល់អវិជ្ជមានពីគម្រោង។

➢ បញ្ជាក់អំពីវិធីសាស្ត្រសម្រាប់យកសំណាកទឹកក្រោមដី សម្រាប់ធ្វើការវិភាគគុណភាពទឹក និងប៉ារ៉ាម៉ែត្រសម្រាប់វិភាគ រួមមាន ការកំណត់ស្តង់ដាគុណភាពទឹក។

➢ ប៉ារ៉ាម៉ែត្រ និងស្តង់ដា

- ការពិនិត្យតាមដានគុណភាពទឹកក្រោមដី៖ ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់អាចស្នើសុំការវិភាគនៅមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន។ ក្នុងករណីដែលម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ ប្រើមន្ទីរពិសោធន៍ឯកជន ឬ បរិក្ខាផ្សេងៗទៀត គឺត្រូវតែមានការទទួលស្គាល់ជាផ្លូវការដោយក្រសួង បរិស្ថាន។
- ស្តង់ដាប្រៀបធៀប៖ ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវប្រៀបធៀប លទ្ធផលពីការវិភាគ ជាមួយនឹងកម្រិតស្តង់ដាគុណភាពទឹកដែលបានកំណត់ ក្នុងតារាងទី ៦ ខាងក្រោម៖

តារាងទី ៦៖ ប៉ារ៉ាម៉ែត្រ និងស្តង់ដាសម្រាប់វាស់វែងគុណភាពទឹកក្រោមដី៖

| ល.រ | ប៉ារ៉ាម៉ែត្រ | រង្វាស់ | ស្តង់ដា |
|---|---|---|---|
| ១ | អាស៊ីត និងបាស pH | - | ៦.៥-៨.៥ |
| ២ | Turbidity | NTU | ៥ |
| ៣ | Electrode Conductivity (EC) | NTU | ៥00-១៥00 |
| ៤ | Total Dissolved Solid (TDS) | mg/l | ៨00 |
| ៥ | Total Hardness (as CaCO3) | mg/l | ៣00 |
| ៦ | ក្លរីដ (Cl) | mg/l | ២៥0 |
| ៧ | ភ្លរីដ (F) | mg/l | ១.៥ |
| ៨ | នីត្រាត ($NO_3$) | mg/l | ៥0 |
| ៩ | សុលហ្វាត ($SO_4$) | mg/l | ២៥0 |
| ១0 | ដែក (Fe) | mg/l | 0.៣ |

| | | | |
|---|---|---|---|
| ១១ | អាសេនិក (As) | mg/l | 0.0៥ |
| ១២ | បារត (Hg) | mg/l | 0.00១ |
| ១៣ | ក្រូមៀម Chromium (Cr) | mg/l | 0.0៥ |
| ១៤ | ម៉ង់ហ្គាណែស (Mn) | mg/l | 0.១ |
| ១៥ | អាលុយមីញ៉ូម (Al) | mg/l | 0.២ |
| ១៦ | បង់ហ្សែន ($C_6H_6$) | mg/l | 0.0១ |
| ១៧ | ឌីក្លរ៉ូមីតាន ($CH_2Cl_2$) | mg/l | - |
| ១៨ | កាដមៀម Cadmium (Cd) | mg/l | 0.00៣ |
| ១៩ | Total Coliform | MPN/100ml | 0 |
| ២០ | អ៊ី-កូលី | MPN/100ml | 0 |

*<u>កំណត់សម្គាល់៖</u> - ចំនួនប៉ារ៉ាម៉ែត្រ អាចតម្រូវឲ្យមានការវិភាគបន្ថែម បើសិនជាចាំបាច់ (ដូចជា ដែកធូន់ ។ល។)*

*សម្រាប់ប៉ារ៉ាម៉ែត្រ បង់ហ្សែន និងឌីក្លរ៉ូមីតាន មិនតម្រូវឲ្យមានការវិភាគណាមួយឡើយ បើសិនជាពួកគេមិនអាចត្រូវបានវិភាគដោយមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន។*

*- វិធីសាស្ត្រវិភាគផ្អែកលើវិធីសាស្ត្រជាក់ស្តែង*

❖ **ការគូសផែនទី៖** ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់នឹងត្រូវធ្វើផែនទីកំណត់ ទីតាំងរបស់គ្រប់សំណាកទាំងអស់នៃគុណភាពដី គុណភាពខ្យល់ សំឡេង និង រំញ័រ ទឹកលើដី និងទឹកក្រោមដី។

**●ធនធានជីវសាស្ត្រ**

➢ **ធនធានព្រៃឈើ៖** ការពិពណ៌នាខ្លីអំពីស្ថានភាពព្រៃឈើក្នុងតំបន់គម្រោង ដោយភ្ជាប់មកជាមួយនឹងផែនទីគម្របព្រៃឈើឆ្នាំ ២០០២ ឆ្នាំ ២០០៦ និងឆ្នាំ ២០១០ ឬ ផែនទីគម្របព្រៃឈើដែលមានបច្ចុប្បន្នភាពចុងក្រោយបំផុតផ្លូវការរបស់រដ្ឋបាលព្រៃឈើ ព្រមទាំងគោលបំណង វិសាលភាព និងវិធីសាស្ត្រនៃការអង្កេតធនធានព្រៃឈើ។

*<u>កំណត់សម្គាល់៖</u> ក្នុងករណីដែលព្រៃឈើក្នុងតំបន់គម្រោងត្រូវបានកាប់អស់ហើយ ការអង្កេតលើព្រៃឈើអភិរក្ស និងព្រៃឈើការពារ ឬ ព្រៃឈើតាមបណ្តោយអាងស្តុកទឹក និងប្រភពទឹកធម្មជាតិនានា ដែលនៅក្នុង ឬ នៅក្បែរទីតាំងគម្រោង នឹងត្រូវបានសិក្សា សម្រាប់ជាសំណាក*

*តំណាង (មានចំងាយ ១ គីឡូម៉ែត្រ)។*

- **គោលបំណងនៃការអង្កេត៖** ដើម្បីដឹងពីវត្តមាន/អវត្តមាននៃពពួក ប្រភេទ ដង់ស៊ីតេ ទំហំដើមឈើ ការប៉ាន់ប្រមាណពីបរិមាណកាបោន (ផ្អែកលើគោលការណ៍ណែនាំថ្នាក់ជាតិ ឬឧបករណ៍ច្បាប់ ឬ ឯកសារយោងនានា ដែលស្ថាប័នជាតិ ឬ អង្គការ/កម្មវិធី/ដៃគូអភិវឌ្ឍន៍ធ្លាប់អនុវត្តកន្លងមក) ភាពងាយរងគ្រោះ ការពិពណ៌នាអំពីតួនាទីរបស់ធនធានព្រៃឈើ (ការវិភាគអំពីតួនាទី និងស្ថានភាពព្រៃ និងប្រព័ន្ធអេកូឡូស៊ី)។
- **វិធីសាស្ត្រ និងឧបករណ៍សម្រាប់ការអង្កេត ៖** ការប៉ាន់ប្រមាណព្រៃឈើ ឬការធ្វើបញ្ជីសារពើភ័ណ្ឌព្រៃឈើ ដោយគណនាសំណាកមួយតំបន់ ស្របទៅតាមបច្ចេកទេសបញ្ជីសារពើភ័ណ្ឌជាតិ និងមានភ្ជាប់មកជាមួយនូវផែនទីនៃទីតាំងតំបន់សំណាកនោះ ឬ វិធីសាស្ត្របែបវិទ្យាសាស្ត្រផ្សេងទៀត អាស្រ័យលើស្ថានភាពជាក់ស្តែងរបស់ព្រៃឈើ។ ជាងនេះទៅទៀតចាំបាច់ត្រូវធ្វើការសម្ភាសជាមួយជនបង្គោល និងអ្នកពាក់ព័ន្ធ។
- **វិធីសាស្ត្រវិភាគទិន្នន័យ៖** វិធីសាស្ត្រវិភាគទិន្នន័យ រួមមាន កម្មវិធី SPSS, MS. Excel ឬកម្មវិធីវិភាគផ្សេងៗទៀត គួរតែមានមានបញ្ជាក់ឲ្យបានច្បាស់លាស់។

*<u>កំណត់សម្គាល់៖</u> សម្រាប់គម្រោងដែលមានទីតាំងក្នុងទីប្រជុំជន គឺមិនចាំបាច់ធ្វើការ សិក្សាពីធនធានព្រៃឈើទេ។*

- **ធនធានសត្វព្រៃ និងជីវចម្រុះ ៖** គោលបំណងនៃការសិក្សា ដែនកំណត់ (ការសិក្សាត្រូវធ្វើឡើងក្នុងតំបន់គម្រោង និងតំបន់ជុំវិញ ដែលមានចំងាយចន្លោះ ០១-០២ គីឡូម៉ែត្រ) និងវិធីសាស្ត្រសម្រាប់សិក្សាអំពីសត្វព្រៃ និងធនធានជីវៈចម្រុះ និងឧបករណ៍ជំនួយ។
  - **គោលបំណងនៃការសិក្សា៖** ដើម្បីដឹងអំពីវត្តមាន/អវត្តមាននៃច្រករបៀង ប្រភពស្បៀង ការពនេចរណ៍ និងដែនជម្រករបស់សត្វព្រៃ។
  - វិធីសាស្ត្រ និងឧបករណ៍នៃការសិក្សា៖ ១). ការអង្កេតផ្ទាល់ ឧទាហរណ៍ ក្នុងន័យត្រង់ (ចំនួនចំងាយ ទីតាំង និងវិធីសាស្ត្រអង្កេត) វិធីសាស្ត្រអង្កេតតាមចំណុច និង ២). ការសម្ភាសជាមួយជនបង្គោល (កំណត់ជនបង្គោល អាយុ ភេទ ។ល។) ដោយភ្ជាប់មកជាមួយនូវកូអ័រដោណេ និងផែនទីនៃកន្លែងអង្កេត។

    *<u>កំណត់សម្គាល់៖</u> គួរតែមានការញែកគ្នាឲ្យច្បាស់រវាងវិធីសាស្ត្រសិក្សាអំពីថនិកសត្វ សត្វស្លាប ពពួកសត្វល្មូន ដោយត្រូវលម្អិតវាតាមប្រភេទនីមួយៗ។*
  - *វិធីសាស្ត្រវិភាគទិន្នន័យ៖ បញ្ជាក់ពីវិធីសាស្ត្រវិធីទិន្នន័យ ដូចជា SPSS,MS. Excel ឬកម្មវិធីវិភាគទិន្នន័យផ្សេងៗទៀត។*

*<u>កំណត់សម្គាល់</u>៖ សម្រាប់គម្រោងក្នុងទីប្រជុំជន មិនចាំបាច់សិក្សាអំពីធនធានសត្វព្រៃទេ។*

- **ធនធានមច្ឆាជាតិ និងជីវចម្រុះក្នុងទឹក៖** គោលបំណងគឺធ្វើការសិក្សានៅក្នុងតំបន់របស់គម្រោង និងនៅជុំវិញ ក្នុងរង្វង់ចំងាយចន្លោះពី ០១-០២ គីឡូម៉ែត្រ និងវិធីសាស្រ្តសិក្សាអំពីមច្ឆាជាតិ និងធនធានជីវចម្រុះនៅក្នុងទឹក។
  - គោលបំណងនៃការសិក្សា៖ ដើម្បីស្វែងយល់អំពីវត្តមានការពនេចរណ៍ ប្រភពស្បៀង និងភាពងាយរងគ្រោះ។
  - **វិធីសាស្រ្ត៖** ១). ការអង្កេតដោយផ្ទាល់ដោយប្រើសំណាញ់ មុង ឬ ផ្លែសន្ទូច និង ២). ការសម្ភាសជាមួយជនបង្គោល (កំណត់ជនបង្គោល ក្រុមអាយុ ភេទ ។ល។) ដោយភ្ជាប់មកជាមួយនូវកូអរដោណេ និងផែនទីនៃកន្លែងអង្កេត។
- វិធីសាស្រ្តវិភាគទិន្នន័យ៖ បញ្ជាក់ពីវិធីសាស្រ្តវិភាគទិន្នន័យ ដូចជា SPSS,MS. Excel ឬកម្មវិធីវិភាគទិន្នន័យផ្សេងៗទៀត។
- **តំបន់ការពារធម្មជាតិ៖** ក្នុងករណីដែលទីតាំងគម្រោងស្ថិតនៅជាប់ ឬ ក្បែរតំបន់អភិរក្ស ឬ តំបន់ការពារធម្មជាតិ ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវបញ្ជាក់ថា គម្រោងវិនិយោគមានទីតាំងនៅក្បែរតំបន់ការពារធម្មជាតិ ដោយត្រូវភ្ជាប់មកជាមួយនូវផែនទីនៃតំបន់ការពារធម្មជាតិទាំងនោះ។

*<u>កំណត់សម្គាល់</u>៖ សម្រាប់គម្រោងក្នុងទីប្រជុំជន មិនចាំបាច់ធ្វើការសិក្សានេះទេ។*

- **ធនធានសេដ្ឋកិច្ចសង្គម**

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវកំណត់វិសាលភាព និងវិធីសាស្រ្តការអង្កេតលើធនធានសេដ្ឋកិច្ចសង្គម កំណត់ចំងាយពីចំណុចកណ្តាលរបស់គម្រោង ក្នុងរង្វង់ចន្លោះពី ០.៥-៥ គីឡូម៉ែត្រ ដោយផ្អែកលើ (១). ការតាំងទីលំនៅ (២). ទីតាំងភូមិសាស្រ្ត និង (៣). ទិសដៅខ្យល់។ ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវប្រើវិធីសាស្រ្តសម្ភាសន៍ដោយចៃដន្យ និងប្រើរូបមន្ត Taro Yamane ឬ រូបមន្តសិក្សាស្រាវជ្រាវបែបវិទ្យាសាស្រ្តផ្សេងទៀតដែលសមស្រប សម្រាប់កំណត់សំណាកប្រជាពលរដ្ឋដែលត្រូវសម្ភាសន៍ ដោយប្រើបញ្ជីសំណួរ។ សំណាកដែលត្រូវសម្ភាសន៍ នឹងត្រូវមានចន្លោះពី ៥-១០% គឺអាស្រ័យលើស្ថានភាពភូមិសាស្រ្តជាក់លាក់។ វិធីសាស្រ្តលម្អិតសម្រាប់ជ្រើសរើសសំណាកនឹងត្រូវបញ្ជាក់ច្បាស់លាស់ដោយមានបង្ហាញអំពីប្រភពនិងឯកសារយោងច្បាស់លាស់។

ក្នុងការសិក្សាអំពីធនធានសេដ្ឋកិច្ចសង្គម ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវសិក្សាអំពី៖

- ប្រជាសាស្រ្ត

- ការតាំងទីលំនៅ
- ការប្រើប្រាស់ដីធ្លី និងការចុះបញ្ជីដីធ្លី (មានភ្ជាប់ឯកសារពាក់ព័ន្ធ)
- សកម្មភាពសេដ្ឋកិច្ច និងមុខរបរ (ប្រាក់ចំណូល ចំណាយ និងអត្រានៃភាពក្រីក្រ)
- ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- ការប្រើប្រាស់ថាមពល (ប្រភពថាមពល ការប្រើប្រាស់ចង្ក្រាន ។ល។)
- ការប្រើប្រាស់ទឹក
- សុខមាលភាពសាធារណៈ (សុខភាព អនាម័យ បង្គន់អនាម័យ ។ល។)
- ការអប់រំ
- ទីតាំងទេសចរណ៍
- ទេសភាព
- វប្បធម៌ (បេតិកភ័ណ្ឌវប្បធម៌ ទីតាំងសក្ការៈបូជា ទីតាំងបូជា ព្រៃកប់សព ព្រៃឈើសហគមន៍ នេសាទសហគមន៍ ប្រពៃណី ទំនៀមទំលាប់ និងអ្នកកាន់សាសនា)
- ការគ្រប់គ្រងជាតិពុលបរិស្ថាន (សំណល់រឹងនិងទន់ សំណល់ដែលមានគ្រោះថ្នាក់ ផ្សែង និង សំឡេងដែលចេញមកពីសកម្មភាពរបស់មនុស្ស នៅក្នុង និងនៅជុំវិញតំបន់របស់គម្រោង)
- ការអង្កេតចរាចរណ៍តាមផ្លូវថ្នល់
- ការអង្កេតអំពីគ្រឿងផ្ទុះដែលមិនទាន់ផ្ទុះ
- ការដោះស្រាយបញ្ហាដីធ្លី និងយន្តការសាងសង់ (សម្រាប់ផ្លូវថ្នល់ ខ្សែរបញ្ជូនចរន្ត អគ្គីសនី ទីតាំងទេសចរណ៍ ។ល។)។

### ៤.២ ការចូលរួមជាសាធារណៈ

ផែនការសម្រាប់ការចូលរួមជាសាធារណៈមានបីដំណាក់កាល ដូចខាងក្រោម៖

### ១. ដំណាក់កាលផ្សព្វផ្សាយក្នុងតំបន់គម្រោង

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវផ្តល់ព័ត៌មានអំពីគម្រោង វិសាលភាពរបស់គម្រោង និងទំហំនៃផលប៉ះពាល់ដែលគម្រោងនឹងមានមកលើអ្នកពាក់ព័ន្ធទាំងអស់ ទាំងនៅក្នុងតំបន់ និងជុំវិញតំបន់គម្រោង ព្រមទាំងផ្តល់លទ្ធភាពឲ្យអាជ្ញាធរមូលដ្ឋាន អ្នកពាក់ព័ន្ធ និងប្រជាជនរងគ្រោះអាចទទួលបាននូវព័ត៌មានសំខាន់ៗរបស់គម្រោង។

**សមាសភាពអ្នកចូលរួម៖** មន្ទីរបរិស្ថាន មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីររ៉ែ និងថាមពល មន្ទីរជំនាញពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋានថ្នាក់ស្រុក/ខណ្ឌ ឃុំ/សង្កាត់ ភូមិ សហគមន៍ អង្គការសង្គមស៊ីវិល និងប្រជាជនរងគ្រោះ ឬ អាជ្ញាធរមីន និងគ្រឿងផ្ទុះ (ករណីដែលគម្រោងស្ថិតក្នុងទីតាំងមានសង្គ្រាមកាលពីអតីតកាល)។

**ទីកន្លែង៖** ការជួបជុំនេះអាចធ្វើនៅទីតាំងគម្រោង ឬ កន្លែងសាធារណៈ (វត្តអារាម ឬ សាលារៀន) ឬ កន្លែងប្រជុំផ្សេងៗទៀត។

**រយៈពេលនៃការផ្សព្វផ្សាយ៖** យ៉ាងហោចណាស់ ០១ ថ្ងៃ។

### ២. ដំណាក់កាលសម្ភាសន៍ជាមួយអាជ្ញាធរមូលដ្ឋាន នាយកដ្ឋានពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធ

### ក. ការសម្ភាសជាមួយអាជ្ញាធរមូលដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធ

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវសម្ភាសន៍អាជ្ញាធរមូលដ្ឋាន មន្ទីរពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធផ្សេងៗ ដាច់ពីគ្នា ដើម្បីទទួលយោបល់ និងអនុសាសន៍លើគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍។

**សមាសភាពអ្នកចូលរួម៖** រដ្ឋបាលរាជធានី/ខេត្ត មន្ទីរបរិស្ថាន មន្ទីរដែនដី នគរូបនីយកម្ម និងសំណង់ មន្ទីរទេសចរណ៍ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរធនធានទឹក និងឧតុនិយម មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ នាយកដ្ឋានផែនការ មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរសុខាភិបាល និងអាជ្ញាធរមីន និងគ្រឿងផ្ទុះ (ករណីដែលគម្រោងស្ថិតក្នុងទីតាំងដែលមានគ្រាប់មីន និងគ្រឿងមិនទាន់ផ្ទុះ)។

**ទីកន្លែង៖** ការសម្ភាសអាចធ្វើបាននៅក្នុងទីតាំងរបស់គម្រោង ឬ នៅទីសាធារណៈ (វត្តអារាម ឬ សាលារៀន) ឬ កន្លែងប្រជុំផ្សេងៗ។

**រយៈពេលសម្ភាសន៍៖** យ៉ាងហោចណាស់ ០១ សប្តាហ៍។

**២. ការសម្ភាសជាមួយអាជ្ញាធរមូលដ្ឋាន សហគមន៍រងគ្រោះ និងអ្នកពាក់ព័ន្ធផ្សេងៗ**

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់នឹងត្រូវធ្វើការប្រជុំជាក្រុម ឬ ការប្រជុំដាច់ដោយឡែកជាមួយអ្នកពាក់ព័ន្ធ ដើម្បីទទួលបានយោបល់ និងអនុសាសន៍អំពីគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍។

**សមាសភាពអ្នកចូលរួម៖** អាជ្ញាធរឃុំ/សង្កាត់ និងភូមិ តំណាងសហគមន៍ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋដែលរងគ្រោះ។

**ទីកន្លែង៖** ការសម្ភាសអាចធ្វើបាននៅក្នុងទីតាំងរបស់គម្រោង ឬ នៅទីសាធារណៈ (វត្តអារាម ឬ សាលារៀន) ឬ កន្លែងប្រជុំផ្សេងៗ។

**រយៈពេលសម្ភាសន៍៖** យ៉ាងហោចណាស់ ០៤ សប្តាហ៍។

**៣. ដំណាក់កាលសិក្ខាសាលាពិគ្រោះយោបល់**

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវរៀបចំសិក្ខាសាលាពិគ្រោះយោបល់សាធារណៈមួយ ដើម្បីបង្ហាញលទ្ធផលពីការសិក្សាលើការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម និងលទ្ធផលពីការសម្ភាសជាមួយអ្នកពាក់ព័ន្ធខាងលើ។

**សមាសភាពអ្នកចូលរួម៖** ក្រសួងបរិស្ថាន (នាយកដ្ឋានប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន) រដ្ឋបាលរាជធានី/ខេត្ត មន្ទីរបរិស្ថាន មន្ទីររ៉ែ និងថាមពល មន្ទីរដែនដី នគរូបនីយកម្ម និងសំណង់ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរធនធានទឹក និងឧតុនិយម មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរកិច្ចការនារី មន្ទីរទេសចរណ៍ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអាជ្ញាធរមីន

និងគ្រឿងផ្ទុះ (ករណីដែលគម្រោងស្ថិតក្នុងទីតាំងដែលមានគ្រាប់មីន និងគ្រឿងមិនទាន់ផ្ទុះ) សហគមន៍ និងប្រជាពលរដ្ឋដែលរងគ្រោះ។

**ទីកន្លែង៖** ការសម្ភាសអាចធ្វើបាននៅក្នុងទីតាំងរបស់គម្រោង ឬ នៅទីសាធារណៈ (វត្តអារាម ឬ សាលារៀន) ឬ កន្លែងប្រជុំផ្សេងៗ។

**រយៈពេលសម្ភាសន៍៖** យ៉ាងហោចណាស់ ០១ ថ្ងៃ។

លទ្ធផលពីការពិគ្រោះយោបល់នឹងត្រូវបានបូកសរុប និងបង្ហាញពីភាគរយនៃអ្នកដែលគាំទ្រ និងអ្នកដែលមិនគាំទ្រ។
*កំណត់សម្គាល់៖ ការធ្វើរបាយការណ៍សម្រាប់ការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម មិនចាំបាច់តម្រូវឲ្យមានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ទេ លើកលែងតែ គម្រោងនោះវាអាចបង្កគ្រោះថ្នាក់ដល់បរិស្ថាន និងសង្គម ជាពិសេស។*

## ៤.៣ ការកំណត់អត្តសញ្ញាណផលប៉ះពាល់ជាសក្តានុពលផ្នែកបរិស្ថាន និងវិធានការកាត់បន្ថយ

### ៤.៣.១ ផលប៉ះពាល់ផ្នែកបរិស្ថាន និងវិធានការកាត់បន្ថយ

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវបញ្ជាក់ឲ្យច្បាស់អំពីវិសាលភាព និងវិធីសាស្ត្រ សម្រាប់កំណត់ផលប៉ះពាល់ជាសក្តានុពលផ្នែកបរិស្ថាន និងសង្គម នៅដំណាក់កាលមុនពេលប្រតិបត្តិការ (ដំណាក់កាលរៀបចំគម្រោង និងដំណាក់កាលសាងសង់) ដំណាក់កាលប្រតិបត្តិការ និងដំណាក់កាលបញ្ចប់ ដោយត្រូវប្រើវិធានមួយចំនួន ដូចខាងក្រោម៖

- តារាងម៉ាទ្រិក ដែលត្រូវបង្ហាញពីទំនាក់ទំនងរវាងសកម្មភាពគម្រោង និងផលប៉ះពាល់របស់វាដែលមានមកលើធនធានបរិស្ថាន ដើម្បីកំណត់ផលប៉ះពាល់ជាសក្តានុពល (បាទ/ចាស់ ឬ ទេ)
- ប្រព័ន្ធព័ត៌មានទីតាំងភូមិសាស្ត្រ (GIS) ដោយប្រើឧបករណ៍ Tool Overlay ដើម្បីកំណត់ទីតាំងដែលគម្រោងអាចនឹងធ្វើឲ្យមានផលប៉ះពាល់លើបរិស្ថាន។
- តារាងត្រួតពិនិត្យសម្រាប់ផលប៉ះពាល់លើធនធានបរិស្ថាន (តិចតួច មធ្យម ធ្ងន់ធ្ងរ)។

សម្រាប់សំណើគម្រោង ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវធ្វើការប៉ាន់ប្រមាណមួយ ដែលផ្តោតលើដំណាក់កាលមុនប្រតិបត្តិការ ដំណាក់កាលប្រតិបត្តិការ និងដំណាក់កាលបញ្ចប់របស់គម្រោង។ សម្រាប់គម្រោង

ដែលកំពុងបន្ត ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវធ្វើការប៉ាន់ប្រមាណមួយ ដែលផ្តោតលើដំណាក់កាលសាងសង់ និង/ឬ ដំណាក់កាលប្រតិបត្តិការ និងដំណាក់កាលបញ្ចប់។

- **ដំណាក់កាលមុនប្រតិបត្តិការ៖** ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវចែកដំណាក់កាលនេះជាពីរដំណាក់ រួមមាន ដំណាក់កាលរៀបចំគម្រោង និងដំណាក់កាលសាងសង់ ដោយត្រូវកំណត់និយមន័យនៃផលប៉ះពាល់ផ្នែកបរិស្ថានលើធនធានជារូបវន្ត ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម ព្រមទាំងវិធានការកាត់បន្ថយ។ ដំណាក់កាលរៀបចំគម្រោង សំដៅដល់ការរៀបចំផែនការស្វែងរកដំណោះស្រាយជម្លោះដីធ្លី រហូតដល់ការកំណត់ព្រំដែន ហើយដំណាក់កាលសាងសង់ សំដៅដល់ការសម្អាតដី ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធក្នុងទីតាំងគម្រោង។ល។
- **ដំណាក់កាលប្រតិបត្តិការ៖** ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវកំណត់អត្តសញ្ញាណផលប៉ះពាល់ផ្នែកបរិស្ថានលើធនធានជារូបវន្ត ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម និងវិធានការកាត់បន្ថយ។ ដំណាក់កាលនេះ សំដៅដល់ការចាប់ផ្តើមសកម្មភាពសាងសង់ និងប្រតិបត្តិការរបស់គម្រោង។
- **ដំណាក់កាលបញ្ចប់គម្រោង៖**បន្ទាប់ពីបានបញ្ចប់សកម្មភាពរបស់គម្រោង ម្ចាស់គម្រោង ត្រូវផ្ទេរគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍ទៅឲ្យរាជរដ្ឋាភិបាល (សម្រាប់គម្រោងជួលដីពីរាជរដ្ឋាភិបាល) ហើយសម្រាប់គម្រោងលើដីដែលជាសម្បត្តិឯកជនរបស់រដ្ឋ ម្ចាស់គម្រោងត្រូវបន្តអនុវត្តកិច្ចព្រមព្រៀងជួលពីរដ្ឋាភិបាល។ ហេតុដូច្នេះ មុនពេលផ្ទេរដី ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវកំណត់ ផលប៉ះពាល់ផ្នែកបរិស្ថានលើធនធានជារូបវន្ត ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម ព្រមទាំងវិធានការកាត់បន្ថយ និងវិធានការស្តារឡើងវិញ។

## ៤.៣.២ ផលប៉ះពាល់សរុបផ្នែកបរិស្ថានសម្រាប់របាយការណ៍ពេញលេញនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវធ្វើការប៉ាន់ប្រមាណផលប៉ះពាល់សរុប ដែលបណ្តាលមកពីសកម្មភាពរួមគ្នារវាងគម្រោងជាច្រើន ឬ សកម្មភាពផ្សេងៗ ដោយផ្តោតលើធនធានជារូបវន្ត ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម (ភ្ជាប់មកជាមួយផែនទីនៃទីតាំងគម្រោង ឬ សកម្មភាព)។

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវបញ្ជាក់ឲ្យបានច្បាស់ពីទំហំ និងវិធីសាស្ត្រ ដើម្បីកំណត់ផលប៉ះពាល់ជាសក្តានុពលផ្នែកបរិស្ថាន និងសង្គមសរុប តាមរយៈការប្រើប្រាស់ប្រព័ន្ធព័ត៌មានទីតាំងភូមិសាស្ត្រ (GIS)

ឧបករណ៍ Tool Overlay ក្នុងការកំណត់ទីតាំងដែលគម្រោងនឹងបណ្តាលឲ្យមានផលប៉ះពាល់ផ្នែកបរិស្ថាន។ *(សូមភ្ជាប់នូវផែនទីទីតាំងគម្រោង ឬសកម្មភាពផ្សេងៗ)*។

## ៤.៤ ផែនការគ្រប់គ្រងបរិស្ថាន

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវពិពណ៌នាផែនការគ្រប់គ្រងបរិស្ថាន ដោយផ្តោតលើផែនការសំខាន់ៗ សម្រាប់ពិនិត្យតាមដានបរិស្ថាន និងបង្កើតតារាងកម្មវិធីពិនិត្យតាមដានបរិស្ថាន កំឡុងពេលដំណាក់កាលសាងសង់ ប្រតិបត្តិការ និងដំណាក់កាលបញ្ចប់គម្រោង ដែលក្រុមហ៊ុនត្រូវរៀបចំ៖

១. សេចក្តីផ្តើម

២. មុខងារត្រួតពិនិត្យ និងគណនេយ្យភាព

ក). ស្ថាប័នត្រួតត្រាថ្នាក់ជាតិ

ខ). ស្ថាប័នត្រួតត្រាថ្នាក់ក្រោមជាតិ

គ). ស្ថាប័នទទួលខុសត្រូវ

៣. សង្ខេបផលប៉ះពាល់ និងវិធានការកាត់បន្ថយ ដែលឆ្លុះទៅរកការកសាងផែនការគ្រប់គ្រងបរិស្ថាន

៤. កម្មវិធីបណ្តុះបណ្តាល

៥. កម្មវិធីពិនិត្យតាមដាន

ក). កំណត់អត្តសញ្ញាណធនធានបរិស្ថាន ទីតាំង ប៉ារ៉ាម៉ែត្រ និងឧបករណ៍ សម្ភារះពិនិត្យតាមដាន។

ខ). ស្ថាប័នត្រួតត្រា អ្នកទទួលខុសតករូវ និងថវិកាសម្រាប់ការពិនិត្យតាមដាន

គ). កត់ត្រា និងវិភាគទិន្នន័យ និងប្រៀបធៀបទិន្នន័យទាំងនោះជាមួយនឹងទិន្នន័យមូលដ្ឋាន និងស្តង់ដាបច្ចេកទេសអនុវត្ត។

៦. ផែនការថវិកាសម្រាប់កម្មវិធីពិនិត្យតាមដាន

៧. របាយការណ៍ពិនិត្យតាមដាន

៨. មូលនិធិសង្គមនិងបរិស្ថាន៖ មូលនិធិនេះស្របទៅតាមអនុក្រឹត្យលេខ ២៣៨ អនក្រ បក ចុះកាលបរិច្ឆេទ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ស្តីពី ការបង្កើតមូលនិធិសង្គមនិងបរិស្ថាន និងប្រកាសរួម រវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៤.៥. ការវិភាគតម្លៃសេដ្ឋកិច្ចនិងការខូចខាតផ្នែកបរិស្ថាន សម្រាប់របាយការណ៍ពេញលេញ នៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់នឹងត្រូវបញ្ជាក់ឲ្យច្បាស់អំពីវិសាលភាព និងវិធីសាស្ត្រ រូបមន្ត គោលបំណង និងសូចនាករនៃការវិភាគផ្នែកសេដ្ឋកិច្ចនិងសង្គម ដោយផ្តោតលើការវិភាគផ្នែកហិរញ្ញវត្ថុ សេដ្ឋកិច្ច និងការខូចខាតផ្នែកបរិស្ថាន ដោយមានបញ្ជាក់អំពីឯកសារយោង និងប្រភពច្បាស់លាស់។

១. ការវិភាគផ្នែកហិរញ្ញវត្ថុ៖ ផ្អែកលើការសិក្សាអំពីការខាតបង់ប្រាក់ចំណេញរបស់ម្ចាស់ គម្រោង។

២. ការវិភាគផ្នែកសេដ្ឋកិច្ច៖ ផ្អែកលើប្រាក់ចំណេញរបស់ម្ចាស់គម្រោង ដែលបានបង់ទៅឲ្យរដ្ឋ

៣. ការវិភាគអំពីការខូចខាតផ្នែកបរិស្ថាន៖ ការវិភាគពីតម្លៃដោយផ្ទាល់ និងប្រយោលលើ៖

- ក.) ធនធានជារូបវន្ត៖ ឋានលេខាដី ជាតិពុលក្នុងខ្យល់ ការរំខានដោយសំឡេង និងរំញ័រ គុណភាពទឹកលើដី និងទឹកក្រោមដី ការថយគុណភាពដី ។ល។
- ខ). ធនធានជីវសាស្ត្រ៖ តម្លៃព្រៃឈើនៅសល់ សេវាកម្មប្រព័ន្ធអេកូឡូស៊ី ផលិតផលនិងអនុផលព្រៃឈើ ធនធានសត្វព្រៃ ធនធានក្នុងទឹក តម្លៃទេសចរណ៍បែបធម្មជាតិ តម្លៃបរិស្ថាន ។ល។
- គ). ធនធានសេដ្ឋកិច្ចសង្គម៖ ការងារ ប្រាក់ចំណូល ទទួលបានអនុផលព្រៃឈើ ។ល។

## ៥. ការកំណត់ទម្រង់របាយការណ៍បឋម ឬ របាយការណ៍ពេញលេញនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់នឹងត្រូវរៀបចំរបាយការណ៍បឋម ឬ របាយការណ៍ពេញលេញនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម ស្របតាមប្រកាសរបស់ក្រសួងបរិស្ថាន ស្តីពីគោលការណ៍ណែនាំទូទៅសម្រាប់ការធ្វើរបាយការណ៍បឋម ឬ របាយការណ៍ពេញលេញនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម ហើយត្រូវពិពណ៌នាដោយសង្ខេប អំពីចំណុចដែលត្រូវសិក្សា នៅក្នុងផ្នែកនីមួយៗនៃរបាយការណ៍។

### មាតិកានៃរបាយការណ៍បឋម ឬ របាយការណ៍ពេញលេញ នៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែក បរិស្ថាន និងសង្គម

| មាតិកានៃរបាយការណ៍ពេញលេញនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម | មាតិកានៃរបាយការណ៍បឋមនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម |
|---|---|

| | |
|---|---|
| – បញ្ជីតារាង<br>– បញ្ជីរូបភាព<br>– បញ្ជីក្រាហ្វិក<br>– បញ្ជីផែនទី<br>– បញ្ជីអក្សរកាត់<br>– សង្ខេបប្រតិបត្តិ<br>ជំពូក ១៖ សេចក្តីផ្តើម<br>ជំពូក ២៖ វិសាលភាព និងវិធីសាស្រ្តសិក្សា<br>ជំពូក ៣៖ ក្របខ័ណ្ឌច្បាប់<br>ជំពូក ៤៖ សេចក្តីពិពណ៌នាអំពីគម្រោង<br>ជំពូក ៥៖ សេចក្តីពិពណ៌នាអំពីធនធានបរិស្ថាន ដែលមានស្រាប់<br>ជំពូក ៦៖ ការចូលរួមជាសាធារណៈ<br>ជំពូក ៧៖ ផលប៉ះពាល់ផ្នែកបរិស្ថាន និងវិធានការកាត់បន្ថយ<br>ជំពូក ៨៖ ផែនការគ្រប់គ្រងបរិស្ថាន<br>ជំពូក ៩៖ ការវិភាគតម្លៃសេដ្ឋកិច្ច និងបរិស្ថាន<br>ជំពូក ១០៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍<br>– ឯកសារយោង<br>– ឧបសម្ព័ន្ធ | – បញ្ជីតារាង<br>– បញ្ជីរូបភាព<br>– បញ្ជីក្រាហ្វិក<br>– បញ្ជីផែនទី<br>– បញ្ជីអក្សរកាត់<br>– សង្ខេបប្រតិបត្តិ<br>ជំពូក ១៖ សេចក្តីផ្តើម រួមទាំង វិសាលភាព និងវិធីសាស្រ្តសិក្សា<br>ជំពូក ២៖ ក្របខ័ណ្ឌច្បាប់<br>ជំពូក ៣៖ សេចក្តីពិពណ៌នាអំពីគម្រោង<br>ជំពូក ៤៖ សេចក្តីពិពណ៌នាអំពីធនធានបរិស្ថាន ដែលមានស្រាប់<br>ជំពូក ៥៖ ការចូលរួមជាសាធារណៈ<br>ជំពូក ៦៖ ផលប៉ះពាល់ផ្នែកបរិស្ថាន និងវិធានការកាត់បន្ថយ<br>ជំពូក ៧៖ ផែនការគ្រប់គ្រងបរិស្ថាន<br>ជំពូក ៨៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍<br>– ឯកសារយោង<br>– ឧបសម្ព័ន្ធ |

## ៦. សមាសភាគនៃក្រុមការងារសិក្សា

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវបង្ហាញឈ្មោះប្រធានក្រុមសិក្សា អ្នកជំនាញ និងជំនួយការសម្រាប់ការសិក្សា និងស្រាវជ្រាវរបស់គម្រោងនានា ហើយអ្នកទាំងនោះនឹងត្រូវចុះក្នុងបញ្ជីក្រុមហ៊ុនប្រឹក្សាយោបល់។ បើសិនជាម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់សហការជាមួយដៃគូពិគ្រោះយោបល់ឯកជន ឬអ្នកជំនាញ ដែលមិនមាននៅក្នុងបញ្ជី ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវជូនដំណឹងដល់ក្រសួងបរិស្ថាន ក្នុងរយៈពេល ០១ ខែមុន។

## ៧. កាលវិភាគការងារ/សកម្មភាពការងារសិក្សា

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវកំណត់រយៈពេល ចាប់ពីការសិក្សាដំបូង រហូតដល់ការដាក់របាយការណ៍ទៅក្រសួងបរិស្ថាន ដើម្បីពិនិត្យ និងផ្តល់យោបល់។

## ៨. ឧបសម្ព័ន្ធ

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវភ្ជាប់មកជាមួយនូវឯកសារផ្លូវច្បាប់ ដែលពាក់ព័ន្ធនឹងគម្រោង ដូចជា អនុក្រឹត្យ ស្តីពីការផ្តល់ចំណាត់ថ្នាក់ឡើងវិញលើដី កិច្ចសន្យាជួលដី ប័ណ្ណចុះបញ្ជីក្រុមហ៊ុនប្រឹក្សាយោបល់នៅក្រសួងបរិស្ថាន លិខិតអនុញ្ញាតពីម្ចាស់គម្រោង ឲ្យក្រុមហ៊ុនប្រឹក្សាពិគ្រោះយោបល់ធ្វើការសិក្សា និងរៀបចំរបាយការណ៍ EIA ឧបករណ៍ផ្លូវច្បាប់នានា របស់ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ។ល។

# ឧបសម្ព័ន្ធ ៦៖ បញ្ជីអ្នកពាក់ព័ន្ធក្នុងការពិគ្រោះយោបល់ក្នុង ESMF

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បញ្ជីវត្តមាន

កិច្ចប្រជុំ: National Consultation Workshop on "Sustainable Landscape and Ecotourism Project Formulation", December 21, 2018, Himawari Hotel, Phnom Penh

ថ្ងៃទី.......... ខែ.............. ២០១៨

| ល.រ<br>No | ឈ្មោះ<br>Name | ភេទ<br>sex | មុខងារ<br>Position | ក្រសួង/ស្ថាប័ន<br>Ministry/institute |
|---|---|---|---|---|
| 1. | [illegible] | ស្រី | [illegible] | [illegible] |
| 2. | [illegible] | ប | [illegible] | M.E |
| 3. | [illegible] | ប | [illegible] | [illegible] |
| 4. | [illegible] | ប | [illegible] | [illegible] |
| 5. | [illegible] | ប | [illegible] | MOE |
| 6. | Leng Bunlong | M | Env spec | WB |
| 7. | [illegible] | ប | [illegible] | MOE |
| 8. | [illegible] | ប | [illegible] | MoE |
| 9. | [illegible] | [illegible] | [illegible] | MoE |
| 10 | [illegible] | ប | PM | PIU-MoE |

| | | | | |
|---|---|---|---|---|
| 1. | San Sikd | M | Facilitator | Cambodia Bird guide Association |
| 2 | Rath Virak | M | Under-Secretary of State | M.E |
| 3 | [illegible] | [illegible] | [illegible] | MOE/[illegible] |
| 4 | [illegible] | [illegible] | [illegible] | [illegible] |
| 5 | Maria Dumpert | F | Consultant | WBG |

| | | | | |
|---|---|---|---|---|
| 6 | Kim Nheng | M | DDG | MoE |
| 7 | [illegible] | M | MoE | |
| 8 | Tea Savora | M | Interpreter | BTI |
| 9 | Neak Sannarong | M | Vice director | MoE |
| 10 | [illegible] | F | [illegible] | UNIDO |

| ល.រ No | ឈ្មោះ Name | ភេទ sex | តួនាទី Position | ក្រសួង/ស្ថាប័ន/ក្រុមហ៊ុន Ministry/institute/company |
|---|---|---|---|---|
| 1. | CHHEN RÉMY | M | STUDENT | UNIVERSITY ITT |
| 2. | [illegible] | ប | [illegible] | [illegible] |
| 3. | [illegible] | [illegible] | Deputy | TVM |
| 4. | [illegible] | [illegible] | [illegible] | WEA |
| 5. | [illegible] | ប | [illegible] | Mlup Baitong |
| 6. | [illegible] | ស្រី | [illegible] | GDLC - MoE |
| 7. | [illegible] | ស | [illegible] | MOGI EIA |
| 8. | [illegible] | ប | [illegible] | [illegible] |
| 9. | [illegible] | ប | [illegible] | [illegible] / MEPA MoE |
| 10 | CHHAY RIDOR | F | National Expert | UNIDO |
| 11 | [illegible] | M | VP | CATA |
| 12 | [illegible] | ស្រី | [illegible] | [illegible] |
| 13 | [illegible] | ប | [illegible] | SBD/GSSD |
| 14 | [illegible] | ស្រី | | MOE |

| ល.រ No | ឈ្មោះ Name | ភេទ sex | តួនាទី Position | ក្រសួង/ស្ថាប័ន/ក្រុមហ៊ុន Ministry/institute/company |
|---|---|---|---|---|
| 1 | [illegible] | ប | [illegible] | MoE |
| 2 | [illegible] | ប | មន្ត្រី | MoT |
| 3. | [illegible] | ប | [illegible] | MOE |
| 4. | [illegible] | ប | [illegible] | MoE |
| 5. | [illegible] | ស | [illegible] | Birdlife |
| 6. | [illegible] | ស | [illegible] | MoE |
| 7. | [illegible] | ប | [illegible] | GDLC-MoE |
| 8. | [illegible] | ប | [illegible] | MoE |
| 9. | [illegible] | ស | [illegible] | MoE |
| 10. | [illegible] | ប | [illegible] | MoE |
| 11 | [illegible] | ប្រុស | [illegible] | MoE |
| 12. | [illegible] | ស | [illegible] | MRD |
| 13. | [illegible] | ប | [illegible] | CFDD/FiA |
| 14. | [illegible] | — | [illegible] | MoE |

| | | | | |
|---|---|---|---|---|
| 1 | [illegible] | ស | មន្ត្រី | MEF |
| 2 | [illegible] | ប្រុស | [illegible] | MOWRAM |
| 3 | [illegible] | ស | | RECOFTC |
| 4 | [illegible] | ប | មន្ត្រី | MOE |
| 5 | [illegible] | ស | [illegible] | MOE |
| 6 | [illegible] | ស | [illegible] | MOE |
| 7 | [illegible] | ប | [illegible] | MOE |
| 8 | [illegible] | ស | | MOE |

## ឧបសម្ព័ន្ធ ៧. បញ្ជីគម្រោងអវិជ្ជមាន

បញ្ជីគម្រោងអវិជ្ជមាន ឬ បញ្ជីគម្រោងដែលខ្វះលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានន័យថា ជាអនុគម្រោង ឬ សកម្មភាពវិនិយោគ ដែលត្រូវបានហាមឃាត់ពីការទទួលបានហិរញ្ញប្បទានពីធនាគារពិភពលោក ហើយគម្រោងប្រភេទនេះនឹងត្រូវបញ្ចូលទៅក្នុងសៀវភៅណែនាំអនុវត្ត ឬ ប្រតិបត្តិការ។ ភ្នាក់អនុវត្តន៍ និងធនាគារពិភពលោកនឹងពិចារណាលើព័ត៌មានទាំងនេះ នៅពេលពិនិត្យអនុគម្រោង ដើម្បីផ្ទៀងផ្ទាត់លក្ខណៈសម្បត្តិសមស្របវិសាលភាព និង កម្រិតនៃវិធានការគាំពារ បើសិនជាមាន។

បញ្ជីគម្រោងអវិជ្ជមាន ឬ គម្រោងដែលខ្វះលក្ខណៈសម្បត្តិ មានចំណុចមួយចំនួន មិនត្រឹមតែដូចខាងក្រោមទេ៖

- សកម្មភាពដែលមានផលប៉ះពាល់លើបរិស្ថានធ្ងន់ធ្ងរ និងដែលមិនអាចផ្លាស់ប្តូរបាន នៅក្នុង ប្រករបៀង PA និងដែលមិនងាយកាត់បន្ថយបាន
- សកម្មភាពដែលប៉ះពាល់អវិជ្ជមានលើតំបន់ការពារធម្មជាតិដែលទទួលស្គាល់ដោយរដ្ឋាភិបាល ថ្នាក់ជាតិ ថ្នាក់ខេត្ត ឬ រាជធានី (ឧទាហរណ៍ តំបន់ទ្រនាប់)
- ការរានដី ដូចជា ការបង្ហូរទឹកចេញពីដីសើម ឬការចាក់បំពេញដែនទឹក ដើម្បីបង្កើតបានជាដី
- ការជួល ឬ ការទិញដីដែលមានកម្មសិទ្ធិមិនច្បាស់លាស់
- សកម្មភាពពាក់ព័ន្ធនឹងការផលិតឈើ
- សកម្មភាពពាក់ព័ន្ធនឹងការបរបាញ់សត្វសម្រាប់គោលបំណងពាណិជ្ជកម្ម
- ពាណិជ្ជកម្មសត្វព្រៃ និងផលិតផលសត្វព្រៃដែលត្រូវបានហាមឃាត់ដោយសន្ធិសញ្ញា CITES
- ការបញ្ចេញអង្គធាតុដែលមានការផ្លាស់ប្តូរហ្សេនេទិក ចូលទៅក្នុងបរិស្ថានធម្មជាតិ
- សកម្មភាពពាក់ព័ន្ធនឹងការសម្អាត ឬ សាងសង់អគារនៅចំកណ្តាលតំបន់អភិរក្ស និងការអភិវឌ្ឍប្រកបដោយចីរភាព ឬ ក្នុងតំបន់សហគមន៍ គឺទាមទារឲ្យមានការអនុម័តពីរដ្ឋាភិបាល។ ការអភិវឌ្ឍទាំងឡាយក្នុងតំបន់ទាំងនេះ ឬ ក្នុងតំបន់ជិតគ្នា គឺតម្រូវឲ្យធ្វើការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម។
- សកម្មភាពដែលញាំងឲ្យមានការទន្ទ្រានកាប់កាប់ដីដោយខុសច្បាប់ ឬ ដោយគ្មានការធានាពីការអនុវត្តច្បាប់ និងការពង្រឹងសមត្ថភាពលើការគ្រប់គ្រងតំបន់ការពារ។

តំបន់គ្រប់គ្រងទាំងបួន គឺ៖

- តំបន់សំខាន់ Core zone៖ តំបន់ដែលមានតម្លៃខាងអភិរក្សក្នុងកម្រិតខ្ពស់ ដែលមានពពួកសត្វនិងរុក្ខជាតិដែលកំពុងទទួលការគម្រាមគំហែង និងជិតផុតពូជ និងប្រព័ន្ធអេកូឡូស៊ីដែលងាយរងគ្រោះ។

ការចូលទៅកាន់តំបន់សំខាន់ គឺត្រូវបានហាមឃាត់ លើកលែងតែតំបន់អភិរក្សធម្មជាតិ និងមន្ត្រីរដ្ឋបាលផ្នែកអភិរក្ស និងអ្នកសិក្សាស្រាវជ្រាវ។ NCPA អាចផ្តល់ការអនុញ្ញាតចេញចូលឲ្យមន្ត្រី និងអ្នកសិក្សាស្រាវជ្រាវ ដោយមានការអនុញ្ញាតជាមុនពីក្រសួងបរិស្ថាន។ (មន្ត្រីផ្នែកការពារ និងសន្តិសុខថ្នាក់ជាតិ គឺមានសិទ្ធិផ្ទាល់ខ្លួនក្នុងការចេញចូលតំបន់សំខាន់)។ ការប្រើប្រាស់ធនធានធម្មជាតិពីតំបន់សំខាន់ត្រូវបានហាមឃាត់។ កសិកម្មពនេចរ (ជួនការត្រូវបានគេហៅថា កសិកម្មកាប់-ដុត) ត្រូវបានហាមឃាត់។

- តំបន់អភិរក្ស៖ តំបន់ដែលមានតម្លៃខាងអភិរក្សក្នុងកម្រិតខ្ពស់ ដែលមានធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ីតំបន់ជម្រាល និងទេសភាពធម្មជាតិដែលមានទីតាំងនៅក្បែរតំបន់សំខាន់។ ការផ្តល់សិទ្ធិចេញចូលទៅក្នុងតំបន់សំខាន់ អាចធ្វើទៅបាន លុះត្រាតែមានការអនុញ្ញាតពីផ្នែករដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ជាមុនសិន។ (មន្ត្រីផ្នែកការពារ និងសន្តិសុខថ្នាក់ជាតិ គឺមានសិទ្ធិផ្ទាល់ខ្លួនក្នុងការចេញចូល)។ ការប្រើប្រាស់ខ្នាតតូចរបស់សហគមន៍លើអនុផលព្រៃឈើ (NTFPs) សម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជនមូលដ្ឋាន អាចត្រូវបានអនុញ្ញាត ដោយមានការត្រួតពិនិត្យយ៉ាងហ្មត់ចត់ បើសិនជាការប្រើប្រាស់ទាំងនោះនឹងមិនប៉ះពាល់ធ្ងន់ធ្ងរដល់ជីវចម្រុះ។ ក្រៅពីនេះ ការប្រើប្រាស់ធនធានធម្មជាតិពីតំបន់នេះ គឺត្រូវបានហាមឃាត់។ កសិកម្មពនេចរក៏ត្រូវបានហាមឃាត់ដែរ។ ព័ត៌មានលម្អិតមាននៅក្នុងច្បាប់ ស្តីពីការការពារធនធានធម្មជាតិ ដែលមាននៅលើគេហទំព័ររបស់ក្រសួងបរិស្ថាន។